ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សង្ខេប

# ស្តីពី

# សមិទ្ធផលសំខាន់ៗមួយចំនួន

# របស់

# រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

# ឆ្នាំ២០១២-២០១៦

ទីស្តីការគណៈរដ្ឋមន្ត្រី

ខែមេសា ឆ្នាំ២០១៧

# មាតិកា

របាយការណ៍សង្ខេប ស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២-២០១៦ ១

បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

១-សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ២

ក-លទ្ធផលនៃការបង្ក្រាបបទល្មើស ការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ២

ខ-ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ២

គ-កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ២

ឃ-មណ្ឌលបន្សាបគ្រឿងញៀន ៣

ង-ការងារអន្តោប្រវេសន៍ ៣

ច-គ្រោះថ្នាក់ចរាចរណ៍ ៣

២-បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ និងចីរភាពបរិស្ថាន ៣

ក-ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ៣

ខ-ភាពជាដៃគូអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ៤

គ-អត្រាប្តូរប្រាក់មានស្ថេរភាព ៥

៣-ភាពជាដៃគូក្នុងការអភិវឌ្ឍ ៥

✡ ការចូលរួមពីសហគមន៍ជាតិ និងអន្តរជាតិ ៥

៤-សមាហរណកម្មកម្ពុជា ការតែស៊ីជម្រៅទៅក្នុងតំបន់ និងពិភពលោក ៦

៤.១- ការងារព្រំដែន ៧

៤.២-ច្រកទ្វារអន្តរជាតិ (ស្ថិតនៅផ្ទៃក្នុងព្រះរាជាណាចក្រកម្ពុជា) ៩

៤.៣-ច្រកទ្វារព្រំដែនអន្តរជាតិ(ស្ថិតនៅតាមព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសជិតខាង) ៩

អភិបាលកិច្ចល្អ

១-ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ១០

ក-លទ្ធផលការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ ១០

ខ-លទ្ធផលការងាររបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ១១

**២-ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌** ១១
**ក-លទ្ធផលការងាររបស់ក្រសួងយុត្តិធម៌** ១១
**ខ-ការពង្រឹងនីតិរដ្ឋ** ១៤
**គ-សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី** ១៥
**ឃ-ប្រជុំអន្តរក្រសួងនៅទីស្ដីការគណៈរដ្ឋមន្ត្រី** ១៥
**៣-ការកែទម្រង់រដ្ឋបាលសាធារណៈ** ១៥
**ក-ការគ្រប់គ្រងក្របខណ្ឌមន្ត្រីរាជការស៊ីវិល** ១៥
**ខ-ការកែទម្រង់ប្រព័ន្ធបៀវត្ស** ១៦
**គ-ការរៀបចំដំឡើងប្រាក់បៀវត្ស**ជូនមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ និង ប្រាក់ឧបត្ថម្ភ ប្រចាំខែជូនសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់និងមន្ត្រីភូមិ ១៦
**ឃ-ការរៀបចំបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន** ១៧
**ង-ការដំឡើងសន្ទស្សន៍បៀវត្ស** ១៨
**ច.ការងារវិមជ្ឈការ និងវិសហមជ្ឈការ** ១៨
**ច.១-ការអភិវឌ្ឍថ្នាក់ក្រោមជាតិ** ១៨
**ច.២-ការងារប្រជាធិបតេយ្យនីយកម្ម** ១៩
**ច.៣-សង្គមស៊ីវិល** ១៩
**៤-ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ** ១៩

## I- ការលើកស្ទួយវិស័យកសិកម្ម

**១-ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម** ២១
**ក-ផលិតកម្មដំណាំស្រូវ** ២១
**ខ-ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម** ២២
**គ-ការនាំចេញផលិតផលកសិកម្ម** ២២
**ឃ-សហគមន៍កសិកម្ម** ២៣
**ង-ការជំរុញចលនាភូមិ១ ផលិតផល១** ២៤
**ច-ដំណាំកៅស៊ូ** ២៤
**២-ការចិញ្ចឹមសត្វ និងការងារវារីវប្បកម្ម** ២៥

ក-ការចិញ្ចឹមសត្វ ២៥
ខ-ការងារវារីវប្បកម្ម ២៥
៣-ការកែទម្រង់ដីធ្លី និងការបោសសំអាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ២៧
៣.១-ការកែទម្រង់ដីធ្លី ២៧
៣.១.១-លទ្ធផលការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី (អ.ជ.ដ) ២៧
៣.១.២-ការចុះបញ្ជីដីធ្លី ២៧
៣.១.៣-ការងារដោះស្រាយទំនាស់ដីធ្លីជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ២៨
៣.១.៤-ការបែងចែកដីក្នុងគោលដៅសម្បទានដីសង្គមកិច្ច និងប្រទានកម្ម ២៨
៣.១.៥-ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យសំណង់ ២៨
៣.១.៦-ទិន្នន័យអគារស្នាក់នៅរួម និងបុរី ២៩
៣.១.៧-ចំណូលពីសេវា ៣០
៣.២-ការបោសសំអាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ៣០
៤-ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ៣០
ក.កិច្ចគាំពារបរិស្ថាន ៣០
ខ-ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន ៣០
គ-ការងារអប់រំ និងព័ត៌មានបរិស្ថាន ៣១
ឃ-ការកែទម្រង់ព្រៃឈើ ៣២

## II- ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

១-ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ៣៣
១.១-ផ្លូវ និងការគ្រប់គ្រងយានយន្តតាមផ្លូវគោក ៣៣
១.២-ការងារដឹកជញ្ជូន និងអាជីវកម្មផ្លូវទឹក និងផ្លូវអាកាស ៣៤
ក-ការងារដឹកជញ្ជូន និងអាជីវកម្មតាមផ្លូវទឹក ៣៤
ខ-ការងារដឹកជញ្ជូន និងអាជីវកម្មតាមផ្លូវអាកាស ៣៤
✡ក្រុមហ៊ុនអាកាសចរណ៍ជាតិ និងអន្តរជាតិ ដែលមានច្បាប់អនុញ្ញាតហោះហើរចេញ ចូលព្រះរាជាណាចក្រកម្ពុជា ៣៥
១.៣-ការងារផ្លូវដែក ៣៦
២-ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ ៣៧
២.១-ការស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រ ៣៧
២.២-ការជួសជុល និងថែទាំសំណង់សិល្បការ ៣៨
២.៣-ការជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ ៣៨

២.៣.១-ការជួសជុល និងថែទាំទំនប់ ៣៨
២.៣.២-ការខារជីក និងស្តារប្រឡាយ ៣៨
២.៤-ការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក ៣៩
២.៥-ការគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ទឹកប្រៃ ៣៩
២.៦-ការអន្តរាគមន៍សង្គ្រោះស្រូវពេលមានគ្រោះរាំងស្ងួត ៤០
២.៧-ការសាងសង់ដំឡើងស្ថានីយបូមទឹក ៤០
២.៨-ការងារអភិវឌ្ឍន៍ជនបទ ៤១
៣-ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី ៤៥
៣.១-ប្រភពផលិតកម្មអគ្គិសនី ៤៥
៣.២-ខារីអគ្គិសនី និងថាមពលអគ្គិសនីដើរដោយធ្យូងថ្ម
ដែលបានស្ថាបនា និងដាក់ឲ្យដំណើរការ ៤៦
៣.៣-ការអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទ ៤៩
៣.៤-ការផ្គត់ផ្គង់អគ្គិសនីជនបទ ៥០
៣.៥-ការតភ្ជាប់ចរន្តអគ្គិសនីចូលបន្ទប់ស្នាក់នៅរបស់កម្មករ ៥១
៣.៦- វិស័យធនធានរ៉ែ ៥១
៤-ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ៥២
ក-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍ ៥២
ខ-ការងារវិសាលគមន៍ប្រេកង់សំវិទ្យុ ៥៣
គ-ការងារព័ត៌មាន ៥៤

## III- ការអភិវឌ្ឍវិស័យឯកជន និងការងារ

១-ការពង្រឹងវិស័យឯកជន និងជំរុញការវិនិយោគ និងធុរកិច្ច ៥៥
១.១-ការកៀរគរ និងតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយ
អាទិភាពអភិវឌ្ឍជាតិ ៥៥
១.២-គណៈកម្មាធិការវិនិយោគកម្ពុជា និងគណៈកម្មាធិការតំបន់សេដ្ឋកិច្ច
ពិសេសកម្ពុជា ៥៥
២-ការអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម ៥៦
៣-ការអភិវឌ្ឍទីផ្សារការងារ ៥៧
ក-ការបង្កើតការងារ ៥៧
ខ-ការបង្កើតការងារ និងវិស័យទេសចរណ៍ ៥៨
ខ.១-ចំនួនភ្ញៀវទេសចរអន្តរជាតិ និងចំណូលពីការទិញសំបុត្រ
ចូលទស្សនារមណីយដ្ឋានអង្គរ ៥៨

ខ.២-ចំនួនភ្ញៀវទេសចរចូលទស្សនាសារមន្ទីរ ៥៨
ខ.៣-លទ្ធផលការងារសំខាន់ៗរបស់អាជ្ញាធរជាតិអប្សរា ៥៩
ខ.៤-លទ្ធផលការងារសំខាន់ៗរបស់អាជ្ញាធរជាតិព្រះវិហារ ៦៣
ខ.៥-រមណីយដ្ឋានទេសចរណ៍ វប្បធម៌ ធម្មជាតិ និងកែច្នៃ ៦៣
ខ.៦-ការដាក់បញ្ចូលសម្បត្តិវប្បធម៌រូបី និងអរូបីរបស់ព្រះរាជាណាចក្រកម្ពុជាទៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក ៦៤
ខ.៧-ការអភិវឌ្ឍតំបន់សមុទ្រ ៦៤
ខ.៨-ស្ថិតិឧស្សាហកម្មទេសចរណ៍ ៦៥
ខ.៩-មគ្គុទ្ទេសក៍ទេសចរណ៍គិតត្រឹមឆ្នាំ២០១៦ ៦៥
ខ.១០-ការចាត់លំដាប់ថ្នាក់សណ្ឋាគារពីផ្កាយ៥ ដល់ផ្កាយ១ ៦៥
គ-កិច្ចការសាសនា ៦៦
៤-ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ ៦៧
៤.១- ការអភិវឌ្ឍវិស័យធនាគារ ៦៧
៤.២-ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ៦៨
៤.២.១-ចំណូល ចំណាយថវិកាជាតិ ៦៨
៤.២-២-ការកៀរគរចំណូល ៦៩
៤.២-៣-ការកៀរគរឥណទានពីដៃគូអភិវឌ្ឍន៍ និងប្រទេសជាមិត្ត ៦៩

IV- ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស

១-ការពង្រឹង និងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស ៦៩
ក-ការសិក្សាចំណេះដឹងទូទៅ ៧០
ខ-គ្រឹះស្ថានសិក្សាឯកជនភាសាខ្មែរ និងបរទេស ៧២
គ-ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ៧៣
ឃ-ការងារយុវជន និងកីឡា ៧៦
២-ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ ៧៨
ក-មូលដ្ឋានសុខាភិបាលសាធារណៈ ៧៨
ខ-ចំនួនមន្ត្រីសុខាភិបាល ៧៩
គ-ឱសថស្ថាន ឱសថស្ថានរង និងគ្រឹះស្ថានអាជីវកម្មឱសថឯកជន ៧៩
ឃ-សេវាសុខាភិបាលឯកជន ៨០

ខ-លទ្ធផលការទារគ្រប់គ្រងគ្រោះមហន្តរាយ (២០១៤-២០១៦) ៨៤
៣-ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ៨៤
៣.១-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៨៤
៣.២-វិស័យសោធន (ប្រព័ន្ធគាំពារសង្គម) ៨៦
៣.៣-ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម ៨៦
៤-ការអនុវត្តគោលនយោបាយជាតិប្រជាជន និងសមភាពយេនឌ័រ ៨៧
៤.១-ការអនុវត្តគោលនយោបាយជាតិប្រជាជន ៨៧
៤.២-សមភាពយេនឌ័រ ៨៨
❖❖❖ សមិទ្ធផលសំខាន់ៗដែលសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងការសម្ពោធដាក់ឲ្យប្រើប្រាស់ (២០១២-២០១៦) ៩១

# គំនូរបំព្រួញស្តីពី " យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ "
# របស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា (២០១៣-២០១៨)



# របាយការណ៍សង្ខេប
# ស្តីពីសមិទ្ធផលសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាល
# នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២-២០១៦

| | |
|---|---|
| ផ្ទៃដីសរុប ៖ គ.ម² : | ១៨១ ០៣៥គ.ម² |
| ចំនួនរាជធានី: | ១ |
| ចំនួនខេត្ត : | ២៤ |
| ចំនួនស្រុក : | ១៥៩ |
| ចំនួនខណ្ឌ : | ១២ |
| ចំនួនក្រុង : | ២៦ |
| ចំនួនឃុំ : | ១ ៤០៩ |
| ចំនួនសង្កាត់ : | ២៣៧ |
| ចំនួនភូមិ : | ១៤ ៣៦៤ |
| ប្រជាជនសរុប៖ ការធ្វើចំណោលឆ្នាំ២០១៧ | ១៥ ៨៤៨ ៤៩៥ |
| ដង់ស៊ីតេប្រជាជន (ក្នុង ១គ.ម²) : | ៨៧,៥៤ |
| ប្រជាជនអាយុ ០-១៤ ( % នៃប្រជាជនសរុប)២០១៧ : | ២៨,៦៧% |
| ប្រជាជនអាយុ ១៥-៦៤ ( % នៃប្រជាជនសរុប)២០១៧ : | ៦៦,៤៨% |
| ប្រជាជនអាយុ ៦៥ឆ្នាំឡើងទៅ ( % នៃប្រជាជនសរុប)២០១៧ : | ៤,៨៥% |
| អត្រាកំណើនប្រចាំឆ្នាំ : | ១,៥៤ |
| អត្រាបង្កើតកូនសរុប (ក្នុងស្ត្រីម្នាក់) (កំណើតរស់) : | ២,៧ |
| ចំនួនគ្រួសារ : | ៣ ៣០៧ ៧២២ |

◆បន្ទាប់ពីការអនុវត្តនយោបាយ ឈ្នះ ឈ្នះ របស់រាជរដ្ឋាភិបាល ដឹកនាំដោយ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចាប់តាំងពីចុងឆ្នាំ១៩៩៨មក ព្រះរាជាណាចក្រកម្ពុជា បានបញ្ចប់នូវការបែកបាក់ផ្ទៃក្នុង ជម្លោះប្រដាប់អាវុធ សង្គ្រាមវិនាសកម្មទុក្ខសោកវេទនារបស់ប្រជាជនរាប់ទសវត្សកន្លងមក ហើយបាននាំមកនូវសុខ**សន្តិភាព**ឯកភាពជាតិ និងឯកភាពទឹកដីដ៏ពេញលេញរហូតមកដល់បច្ចុប្បន្ននេះ មានរយៈពេលជាង១៨ឆ្នាំ ហើយបង្កលក្ខណៈឲ្យ**មានការអភិវឌ្ឍលើគ្រប់វិស័យ និងការកាត់បន្ថយភាពក្រីក្រ**។

◆ចាប់តាំងពីឆ្នាំ១៩៩៩មក រាជរដ្ឋាភិបាលបានផ្តោតកិច្ចខិតខំប្រឹងប្រែងក្នុងការពន្លឿនការអភិវឌ្ឍវិស័យឯកជនផ្អែកលើគោលការណ៍ទីផ្សារ និងបានទទួលលទ្ធផលល្អគួរឲ្យកត់សម្គាល់។ ក្នុងរយៈពេលពីរទសវត្សកន្លងមកនេះ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចនូវកំណើនសេដ្ឋកិច្ចគួរជាទីមោទនៈ គឺក្នុងរង្វង់ ៧,៧% ដែលគាំទ្រមួយផ្នែកធំក្នុងវិស័យឧស្សាហកម្មកាត់ដេរ អចលនទ្រព្យ សំណង់ ដឹកជញ្ជូន និងគមនាគមន៍ ពាណិជ្ជកម្មក្នុងស្រុក និងទេសចរណ៍។ រាជរដ្ឋាភិបាលបាន

វិនិយោគជាច្រើនលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលធ្វើឲ្យវិនិយោគផ្ទាល់ពីបរទេសកើនឡើងគួរឲ្យកត់សម្គាល់។ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចតាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុ និងសារពើពន្ធប្រកបដោយភាពប្រុងប្រយ័ត្នគួបផ្សំនឹងកំណែទម្រង់វិស័យហិរញ្ញវត្ថុ បានរួមចំណែកក្នុងការសម្រេចបាននូវសមិទ្ធផលសេដ្ឋកិច្ចទាំងនេះ។

តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីឆ្នាំ១៩៩៣មក ព្រះរាជាណាចក្រកម្ពុជាអនុវត្តតាមបែបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស លើកកម្ពស់សិទ្ធិសេរីភាព ជំនឿសាសនារបស់ប្រជាពលរដ្ឋ និងអនុវត្តសេដ្ឋកិច្ចទីផ្សារ។

## បរិស្ថានគ្រប់ដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

### ១-សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

#### ក-លទ្ធផលនៃការបង្ក្រាបបទល្មើស ការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| បទល្មើសឧក្រិដ្ឋ(លើក) | ៨៣៨ | ៧៩០ | ៧១៦ | ៧៥១ | ៥២៩ |
| បទល្មើសមជ្ឈិម(លើក) | ១ ៨៥១ | ១ ៩២៦ | ២ ០៩៨ | ១ ៩៥៨ | ១ ៤៨៣ |
| កិច្ចប្រតិបត្តិការប្រឆាំងបទល្មើសព្រហ្មទណ្ឌ(ករណី) | ១ ៨២៤ | ១ ៩១១ | ២ ១០៨ | ២ ១៣៦ | ១ ៦៥១ |
| ការបង្ក្រាបក្មេងទំនើង(ករណី) | ៥៥៧ | ២៩៦ | ៣៨៨ | ៤១៥ | ៥៦៨ |
| ការបង្ក្រាបការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ(ករណី) | ១៣៥ | ៩៣ | ៩៤ | ៩៤ | ៤៩ |

#### ខ-ការផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

ចាប់ពីឆ្នាំ២០១២ដល់ ឆ្នាំ២០១៦នេះ ក្រសួងមហាផ្ទៃបានបោះពុម្ពអត្តសញ្ញាណបណ្ណគំរូថ្មីទាំង៣ជំហានបាន **៩ ១០៩ ៤៩៦សន្លឹក** និងបានផ្តល់ជូនស្នងការនគរបាលរាជធានី ខេត្ត ដើម្បីចែកជូនប្រជាពលរដ្ឋបាន **៩ ០៧៧ ៨៩៩សន្លឹក** លើផែនការ **១០ ៩៤៤ ១០១សន្លឹក**។

#### គ-កិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន

| **បរិយាយ** | **២០១២** | **២០១៣** | **២០១៤** | **២០១៥** | **២០១៦** |
|---|---|---|---|---|---|
| ការបង្ក្រាបបទល្មើសគ្រឿងញៀន (ករណី) | ៨១៨ | ៨៨៩ | ១ ៣៣៩ | ៣ ០៦១ | ៣ ៤០៦ |
| ចាប់បានជនសង្ស័យ(នាក់) | ១ ៧៨៨ | ១ ៨៣០ | ៣ ១៣៨ | ៧ ០០៨ | ៨ ០៩៧ |

ចាប់ពីឆ្នាំ២០១២ដល់ ឆ្នាំ២០១៦នេះ ការបង្ក្រាបបទល្មើសគ្រឿងញៀនបាន **៩ ៥១៣ ករណី** ចាប់ជនសង្ស័យ **២១ ៨៦១នាក់** និងរឹបអូសបានគ្រឿងញៀនមួយចំនួនមានជាអាទិ៍ ហេរ៉ូអ៊ីន **៧គ.ក្រ**

និង ៣៩ ៦២៣ក្រ មេតំហ្វេតាមីន ៦៤គ.ក្រ និង ៧៩ ៥២៨ក្រ មេតំហ្វេតាមីនម្សៅទឹកកក ១៥៨គ.ក្រ និង៦៧ ៦៦៨ក្រ អ៊ិចស្តាស៊ី ៣គ.ក្រ ៩៥៥ ក្រ និង១ ៣១៨គ្រាប់ កេតាមីន ២ ៨៦៨ក្រ កូកាអ៊ីន ២២គ.ក្រ និង៥៤ ៩៣៨ក្រ។ល។

**ឃ-មណ្ឌលបន្សាបគ្រឿងញៀន**

គិតមកដល់ឆ្នាំ២០១៦ មណ្ឌលបន្សាបគ្រឿងញៀនមាន **១០** ក្នុងនោះមណ្ឌលរដ្ឋមាន **០៧** និង មណ្ឌលឯកជនមាន **០៣** ព្រមទាំងព្យាបាលអ្នកញៀនថ្នាំសរុបចំនួន **២១ ២៩៦** នាក់។

**ង-ការងារអន្តោប្រវេសន៍**

ចាប់ពីខែមេសា ឆ្នាំ២០១៤ដល់ដំណាច់ឆ្នាំ២០១៦នេះ កម្លាំងមានសមត្ថកិច្ចបានធ្វើការ បណ្តេញជនបរទេសដែលរស់នៅព្រះរាជាណាចក្រកម្ពុជាខុសច្បាប់ស្តីពីអន្តោប្រវេសន៍ បានចំនួន ១៨ ២៣០នាក់ស្មើនឹង ៧៩សញ្ជាតិ ក្នុងនោះ មានជាអាទិ៍ ជនជាតិវៀតណាម ចិន នីហ្សេរីយ៉ា ....។

**ច-គ្រោះថ្នាក់ចរាចរណ៍**

| ល.រ | បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|---|
| ១ | គ្រោះថ្នាក់ចរាចរណ៍កើតឡើង (លើក) | ៤ ៣០៥ | ៤ ៣២២ | ៤ ៨២០ | ៤ ៥៩៥ | ៣ ៣៣៨ |
| ២ | ស្លាប់ (នាក់) | ១ ៨៩៤ | ១ ៩៥០ | ២ ១៩៥ | ២ ២៦៤ | ១ ៥៧៦ |
| ៣ | របួសស្រាល (នាក់) | ៣ ០៧៩ | ៨ ១០៩ | ៣ ៣៤៣ | ៣ ១៩៦ | ២ ២៤៤ |
| ៤ | របួសធ្ងន់(នាក់) | ៤ ៣៨៨ | ៥ ៩៧១ | ៤ ៥៨០ | ៤ ៤៣៨ | ៣ ៥១៧ |
| ៥ | អត្រាស្លាប់ក្នុងយាន ១០ ០០០គ្រឿង | ៨,៧០ | ៧,៩០ | ៧,៨០ | ៧,៨០ | ៤,២០ |
| ៦ | អត្រាស្លាប់ក្នុងប្រជាជន ១០០ ០០០នាក់ | ១៣,១០ | ១៣,០០ | ១៤,៤០ | ១៤,៤០ | ១០,០៨ |

## ២-បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ និងចីរភាពបរិស្ថាន

### ក-ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច (២០១២-គិតត្រឹម៩ខែ ២០១៦)

**កំណើនសេដ្ឋកិច្ច**

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ប៉ាន់ស្មាន |
|---|---|---|---|---|---|
| កំណើនសេដ្ឋកិច្ច (%) | ៧,៣ | ៧,៤ | ៧,១ | ៧ | ៧ |
| ផលិតផលក្នុងស្រុកសរុប(ផសស) សម្រាប់មនុស្សម្នាក់ (ដុល្លារ) | ៩៧៣ | ១ ០៤២ | ១ ១៣៨ | ១ ២១៥ | ១ ៣០៧ |
| អត្រានៃការកាត់បន្ថយភាពក្រីក្រ(%) | ១៨,៩ | ១៦ | ១៣,៥ | | |
| អត្រាអតិផរណា(%) | ២,៩ | ៣ | ៣,៩ | ១,២ | ៣,១ |

## ខ-ភាពជាដៃគូអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

ចាប់ពីឆ្នាំ២០១២ដល់ ឆ្នាំ២០១៦នេះ គណៈកម្មការមូលបត្រកម្ពុជា បានផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈចំនួន៤ ហើយមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនទាំង៤ ត្រូវបានដាក់ឲ្យជួញដូរជាផ្លូវការនៅក្នុងក្រុមហ៊ុនមូលបត្រកម្ពុជា និងក្រុមហ៊ុនមួយចំនួនទៀត កំពុងស្ថិតក្នុងដំណើរការរៀបចំការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

| ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ | | | |
|---|---|---|---|
| **ល.រ** | **ឈ្មោះក្រុមហ៊ុន** | **អក្សរកាត់** | **កាលបរិច្ឆេទចុះបញ្ជី** |
| ១ | រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | PPWSA | ១៨ មេសា ២០១២ |
| ២ | ហ្រ្គេនធ្វីនអ៊ិនធឺណេលសិនណល | GTI | ១៦ មិថុនា ២០១៤ |
| ៣ | កំពង់ផែស្វយ័តក្រុងភ្នំពេញ | PPAP | ០៩ ធ្នូ ២០១៥ |
| ៤ | តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ | PPEZ | ៣០ ឧសភា ២០១៦ |

លើសពីនេះ ក្នុងនាមជាបញ្ញត្តិករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានសម្របសម្រួលជូនដៃគូ ជាពិសេសក្រុមហ៊ុនឯកជនលើវិស័យមួយចំនួនដូចខាងក្រោម ៖

✡ វិស័យធានារ៉ាប់រង និងសោធន បាន ៖

-ដាក់ចេញនូវប្រព័ន្ធស្វ័យវាយតម្លៃ (Self Assessment) ក្របខណ្ឌអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជា ដោយអនុលោមតាមគោលការណ៍គ្រឹះធានារ៉ាប់រងទាំង២៦ (២៦ICPs) របស់សមាគមបញ្ញត្តិករធានារ៉ាប់រងអន្តរជាតិ(IAIS)។

-អនុម័តលើការប្រើប្រាស់បណ្ណធានារ៉ាប់រង តារាងអត្រាបុព្វលាភ និងតារាងទូទាត់សំណងសម្រាប់ការធានារ៉ាប់រងឆ្លងកាត់ព្រំដែនវៀតណាម និងអនុម័តលើការធ្វើវិសោធនកម្មចំណុចមួយចំនួននៃវិធានទូទៅ ស្តីពីអត្រាបុព្វលាភធានារ៉ាប់រងអគ្គិភ័យរបស់សមាគមធានារ៉ាប់រងកម្ពុជា និងបានអនុម័តលើផលិតផលធានារ៉ាប់រងថ្មីៗរបស់ក្រុមហ៊ុនធានារ៉ាប់រងនានា ព្រមទាំងបានបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តឹងរបស់អ្នកប្រើប្រាស់សេវាធានារ៉ាប់រង។

-ផ្តល់អាជ្ញាបណ្ណជូនក្រុមហ៊ុនធានារ៉ាប់រងទូទៅចំនួន១ ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន៥ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចនិងប្រតិបត្តិករធានារ៉ាប់រងចំនួន៩ ជើងសារធានារ៉ាប់រងចំនួន៨ ភ្នាក់ងារធានារ៉ាប់រងចំនួន១១ និងក្រុមហ៊ុនវាយតម្លៃធានារ៉ាប់រងចំនួន២។

✡ វិស័យទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ

-ប្រកាសស្តីពីការបង្កើតក្រុមការងារធ្វើសមាហរណកម្មស្ថាប័នបញ្ញត្តិករហិរញ្ញវត្ថុនៅកម្ពុជា

-បានចុះពិធីសារនៃគម្រោងអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅកម្ពុជាក្រោមហិរញ្ញប្បទានឥតសំណងរបស់សាធារណរដ្ឋកូរ៉េ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)

-បានចុះកិច្ចព្រមព្រៀងអន្តររដ្ឋាភិបាល ស្តីពីការអនុវត្តការងារអនុលោមភាពពន្ធចំពោះគណនីក្រៅប្រទេសរបស់សហរដ្ឋអាមេរិក(FATCA) រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា តំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋាភិបាលនៃសហរដ្ឋអាមេរិក។

✡ វិស័យអចលនទ្រព្យ និងបញ្ចាំ

ក្រោមគំនិតផ្តួចផ្តើម និងគាំទ្រក្នុងនាមជាបញ្ញត្តិករ សមាគមដែលតំណាងឲ្យវិស័យអចលនវត្ថុ និងបញ្ចាំចំនួន៣ស្ថាប័ន ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់មាន ១-សមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៨ និងបានធ្វើសមាហរណកម្មនៅក្នុងតំបន់ជាសមាជិកពេញសិទ្ធិទី៨ នៃសមាគមអ្នកវាយតម្លៃអាស៊ាននៅឆ្នាំ២០០៩ ២-សមាគមអ្នកទទួលបញ្ចាំ និងអ្នកទទួលប្រាតិភោគដោយអនុប្បទាន (ស.ប.អ) ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១២ និង ៣-សមាគមអ្នកអភិវឌ្ឍន៍លំនៅស្ថានកម្ពុជា ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៥។

**គ-អត្រាប្តូរប្រាក់មានស្ថេរភាព**

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ ប៉ាន់ស្មាន |
|---|---|---|---|---|---|
| អត្រាប្តូរប្រាក់រៀល/ដុល្លារអាមេរិក | ៤ ០៣៤ | ៤ ០២៥ | ៤ ០៣៩ | ៤ ០៦២ | ៤ ០៥០ |

ប្រភព៖ ២០១២ ដល់ ២០១៥ ធនាគារជាតិនៃកម្ពុជា ២០១៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ៣-ភាពជាដៃគូក្នុងការអភិវឌ្ឍ

### ✡ ការចូលរួមពីសហគមន៍ជាតិ និងអន្តរជាតិ

-សប្បុរសជនក្នុង និងក្រៅប្រទេស ដែលបានចូលរួមថវិកា និងសម្ភារៈក្នុងការកសាងអភិវឌ្ឍន៍មូលដ្ឋានលើគ្រប់វិស័យទាំងផ្នែកអាណាចក្រ និងពុទ្ធចក្រ កសាងរចនាសម្ព័ន្ធនានា ដូចជា ផ្លូវ ស្ពាន ប្រព័ន្ធលូទឹក ប្រព័ន្ធទឹកស្អាត ធារាសាស្ត្រទំនប់ប្រឡាយ មន្ទីរពេទ្យ មណ្ឌលសុខភាព កសាងអន្តេវាសិកដ្ឋាន អគារសិក្សា សាលារៀនគ្រប់កម្រិត មណ្ឌលកុមារកំព្រា វត្តអារាម ព្រះវិហារ កុដិ សាលាបាលី សាលាឆាន់ វិហារឥស្លាម សារ៉ាវ ។ល។

| បរិយាយ | ប្រាក់ដុល្លារអាមេរិក | ប្រាក់រៀល | ប្រាក់បាត |
|---|---|---|---|
| ២០១២ | ១៩ ៤៦៨ ០៣១ | ៥៦៦ ៦៩៥ ០០០ | ១២០ ០០០ |
| ២០១៣ | ១២ ៣៧៥ ៩០៨ | | |
| ២០១៤ | ១៤ ៦២៨ ៧១១ | ៩ ៥០០ ០០០ | |
| ២០១៥ | ១៧ ០៦៣ ៧០៧ | ៥២៧ ៧៩៦ ០០០ | |
| ២០១៦ | ១០ ១៣៩ ៦១៥ | ១ ១១០ ០០០ ០០០ | |

-ដើម្បីសម្តែងការដឹងគុណចំពោះសប្បុរសជនក្នុង និងក្រៅប្រទេស ដែលចេញដោយ ៖

ឯកតា : គិតជាគ្រឿង

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ព្រះរាជក្រឹត្យ | | | | | |
| ព្រះរាជាណាចក្រកម្ពុជា | ៨ ៣១០ | ៨ ៤២០ | ៨ ២៥១ | ៤ ៥១៩ | ២ ៦៨០ |
| ព្រះមហាក្សត្រីយានី | ១៤៧ | ៣៩៩ | ៣៦៩ | ២២៦ | ៨៨ |
| ការពារជាតិ | ២ ៩២០ | ១ ៣១៤ | ២ ៣៥៣ | ២ ៧៨៧ | ៥១ |
| សហមេត្រី | ១៤១ | ៩២ | ១៥៦ | ១៨៨ | ១៦៥ |
| សុវត្ថារា | ៤២៨ | ៦៤០ | ៥៩៩ | ៥២៣ | ៦២៣ |
| មុនីសារាភ័ណ្ឌ | ៩១៣ | ១ ១៦៤ | ៩១៨ | ៧៣៨ | ៦៥១ |
| ជាតូបការ | ២៤៣ | ៣១២ | ២៨៩ | ២៣៩ | ២៨៦ |
| សេនាជ័យសិទ្ធិ | ១៧៤ | ២៩០ | ៣៣១ | ២៣១ | ១៨៨ |
| ឯករាជជាតិ | ០ | ០ | ៣ | ០ | ០ |
| ឧកញ៉ា | ឆ្នាំ២០១២ រហូតដល់ឆ្នាំ២០១៥ ចំនួន ៣០៥នាក់ | | | | |
| អនុក្រឹត្យ | | | | | |
| សហមេត្រី | ២៦១ | ២១៤ | ២៥២ | ៣៣៤ | ១៦៤ |
| សុវត្ថារា | ២ ៦៧២ | ១ ៩០៩ | ២ ៧៨០ | ១ ៧១៩ | ១ ៩៩៦ |
| មុនីសារាភ័ណ្ឌ | ៣ ១៤៥ | ២ ៧៦៣ | ៣ ០៩៩ | ២ ១៦៨ | ២ ៨៨៤ |
| ស្ថាបនាជាតិ | ២ ៣៣០ | ២ ៤៣៩ | ១ ៩៦៨ | ២ ០៩៦ | ២ ៣៩៧ |
| ការងារ | ២៧ ៨៧០ | ២៣ ៤២០ | ២២ ៥៨៧ | ២៣ ៥៩៣ | ២២ ៩៦៣ |
| ស្ត្រីវឌ្ឍនា | ៦ | ១៦ | ៤ | ០ | ០ |
| ខេមរាកីឡាឫទ្ធិ | ០ | ០ | ១ | ០ | ០ |

## ៤-សមាហរណកម្មកម្ពុជា កាន់តែស៊ីជម្រៅនៅក្នុងតំបន់ និងពិភពលោក

រាជរដ្ឋាភិបាលកម្ពុជា បានបន្តអនុវត្តដោយជោគជ័យនូវសមាហរណកម្មកម្ពុជាចូលក្នុងសហគមន៍អន្តរជាតិ ទាំងក្នុងក្របខណ្ឌអនុតំបន់ តំបន់ និងពិភពលោក។ រហូតមកដល់បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជា មានទំនាក់ទំនងការទូតជាមួយប្រទេសជាមិត្តចំនួន ១៧១ប្រទេស។ ស្ថានទូតបរទេសនៅរាជធានីភ្នំពេញសរុបទាំងអស់មានចំនួន ៣០។ ប្រទេសចំនួន ៨៧ បានតែងតាំងឯកអគ្គរាជទូត/រដ្ឋទូតប្រចាំកម្ពុជា ប៉ុន្តែមាននិវេសនដ្ឋាននៅក្រៅប្រទេស។ ស្ថានឯកអគ្គរាជទូត និងស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាប្រចាំនៅបរទេស សរុបមានចំនួន ២៥ ។

ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាប្រចាំបរទេស មានចំនួន៣ (ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការ UNESCO ប្រទេសបារាំង និងប្រទេសស្វីស ស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការសហប្រជាជាតិ នៅសហរដ្ឋអាមេរិក) និងស្ថានកុងស៊ុលកម្ពុជានៅបរទេស មានចំនួន ១៥ ក្នុងនោះស្ថានកុងសុលកិត្តិយសចំនួន៧។

កម្ពុជាចូលជាសមាជិកអាស៊ាននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ នៅទីក្រុងហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ សមាជិកអាស៊ានទាំង១០ រួមមាន ថៃ សិង្ហបុរី ហ្វីលីពីន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី(៨/៨/១៩៦៧) ប្រ៊ុយណេ (៧/១/១៩៨៤) វៀតណាម (២៨/៧/១៩៩៥) មីយ៉ាន់ម៉ា ឡាវ (២៧/៧/១៩៩៧) និងកម្ពុជា(៣០/៤/១៩៩៩)។

កម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកWTO នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៤ នៅប្រទេសម៉ិចសិក ។

កម្ពុជាចូលជាសមាជិកអង្គការអន្តរជាតិ គយ និងរដ្ឋាករ នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០០១ នៅទីក្រុងប្រ៊ុសសែល នៃប្រទេសបែលហ្ស៊ិក។

កម្ពុជាចូលជាសមាជិកអង្គការអន្តរជាតិអាកាសចរណ៍ស៊ីវិលនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៥៦ នៅទីក្រុងស៊ីកាហ្គោ នៃសហរដ្ឋអាមេរិក។

កម្ពុជាចូលជាសមាជិកអង្គការទេសចរណ៍ពិភពលោកនៅឆ្នាំ១៩៧៥ នៅ ទីក្រុងហ្សឺណែវ នៃប្រទេសស្វីស។

### ៤.១- ការងារព្រំដែន

<table>
<tr><td colspan="4">សរុបសមិទ្ធផល<br>ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៦</td><td>ស្ថានភាពសូចនាករ<br>បច្ចុប្បន្ន</td><td>គោលដៅសូចនាករ<br>ចុងក្រោយ</td></tr>
<tr><td colspan="6">ក.ការងារចរចា និងបោះបង្គោលខណ្ឌសីមាព្រំដែនគោកជាមួយ<br>សាធារណរដ្ឋសង្គមនិយមវៀតណាម</td></tr>
<tr><td colspan="2">បោះបង្គោល</td><td colspan="2">បោះបង្គោល<br>បំពេញបន្ថែម<br>បណ្ដោះអាសន្ន</td><td rowspan="3">-បន្តចរចារកដំណោះស្រាយលើបណ្ដាចំណុចដែលនៅរាំងស្ទះ<br>-បន្តបោះបង្គោលព្រំដែនធំ បង្គោលព្រំដែនបំពេញបន្ថែម និងបង្គោលតម្រុយព្រំដែននៅលើដីជាក់ស្ដែង</td><td rowspan="3">-មានបង្គោលព្រំដែននៅលើដីជាក់ស្ដែងច្បាស់លាស់<br>-មានខ្សែព្រំដែនពិតប្រាកដទាំងនៅលើផែនទី និងនៅលើដី<br>-កសាងបានព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ<br>-កាត់បន្ថយជម្លោះនៅតាមព្រំដែន<br>-ប្រែក្លាយខ្សែបន្ទាត់ព្រំដែនបច្ចុប្បន្នទៅជាព្រំដែនអន្តរជាតិទទួលស្គាល់ដោយភាគីទាំងពីរ<br>-បញ្ចប់បានការរំលោភបំពានពីប្រទេសជិតខាង។</td></tr>
<tr><td>ទីតាំង</td><td>បង្គោលលើដីជាក់ស្ដែង</td><td>ទីតាំង</td><td>លើដី</td></tr>
<tr><td>៣២</td><td>៣៥</td><td>៦៤៣</td><td>៨៨៣</td></tr>
<tr><td colspan="6">ខ.ការងារចរចា និងបោះបង្គោលព្រំដែនគោកជាមួយសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ</td></tr>
</table>

<table>
<tr><td colspan="2">បានប្រជុំចរចា និងចុះត្រួតពិនិត្យវាស់វែងលើដីជាក់ស្តែងជាច្រើនដង ប៉ុន្តែនៅមិនទាន់ឯកភាពគ្នាទទួលបានលទ្ធផលនៅឡើយ។</td><td>កំពុងបន្តចរចារកដំណោះស្រាយនៅតំបន់ដែលនៅសេសសល់</td><td>-មានបង្គោលព្រំដែននៅលើដីជាក់ស្តែងច្បាស់លាស់<br>-មានខ្សែព្រំដែនពិតប្រាកដទាំងនៅលើផែនទី និងនៅលើដី<br>-កសាងបានព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ<br>-កាត់បន្ថយជម្លោះនៅតាមព្រំដែន<br>-ប្រែក្លាយខ្សែបន្ទាត់ព្រំដែនបច្ចុប្បន្នទៅជាព្រំដែនអន្តរជាតិទទួលស្គាល់ដោយភាគីទាំងពីរ<br>-បញ្ចប់បានការរំលោភបំពានពីប្រទេសជិតខាង។</td></tr>
<tr><td colspan="4">គ.ការចរចារ និងរុករកបង្គោលព្រំដែនចាស់ជាមួយព្រះរាជាណា-ចក្រថៃឡង់ដ៍</td></tr>
<tr><td>ទីតាំងបង្គោល</td><td>បង្គោលលើដីជាក់ស្តែង</td><td rowspan="3">កំពុងបន្តរុករកបង្គោលព្រំដែនដែលនៅសល់</td><td rowspan="3">-រកឲ្យឃើញបង្គោលចាស់ទាំងអស់ឡើងវិញ<br>-ជួសជុល និងកែលម្អបង្គោលទាំងនោះក្នុងករណីបាក់បែកខូចខាត<br>-មានខ្សែព្រំដែនពិតប្រាកដទាំងនៅលើដី និងនៅលើផែនទី<br>-កសាងបានព្រំដែនសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ<br>-កាត់បន្ថយជម្លោះនៅតាមព្រំដែន<br>-បញ្ចប់បានការរំលោភបំពានពីប្រទេសជិតខាង<br>-នឹងបន្ថែមបង្គោលព្រំដែនមួយចំនួនទៀតក្នុងករណីចាំបាច់ដើម្បីងាយស្រួលគ្រប់គ្រងខ្សែព្រំដែន និងងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការមើលឃើញបង្គោលព្រំដែនដោយភ្នែកទទេ។</td></tr>
<tr><td>រុករកឃើញបង្គោលបានចំនួន១៧ទីតាំង ក្នុងនោះ ៖<br>-ឯកភាពចំនួន ០៧ទីតាំង និង<br>-មិនឯកភាពចំនួន ១០ទីតាំង</td><td>រុករកឃើញបង្គោលបានចំនួន១៨ បង្គោល ក្នុងនោះ ៖<br>-ឯកភាពចំនួន ០៧ទីតាំង និង<br>-មិនឯកភាពចំនួន ១១ទីតាំង</td></tr>
<tr><td colspan="2">ភាគីទាំងពីរបាន ៖<br>-ធ្វើកំណត់ហេតុបង្គោលដែលបានរកឃើញទាំង១៨បង្គោលបានរួចរាល់<br>-បញ្ចប់ការវាស់វែងកំណត់ទីតាំងច្រកទ្វារព្រំដែនអន្តរជាតិចំនួន ០៣ គឺ<br>១-ច្រកទ្វារអន្តរជាតិអានសេះ-ចុងអានម៉ា ខេត្តព្រះវិហារ-ឧប៊ុនរ៉ាត់ធានី<br>២-ច្រកទ្វារអន្តរជាតិភ្នំដី-បានខៅឌីន ខេត្តបាត់ដំបង-ស្រះកែវ<br>៣-ច្រកទ្វារអន្តរជាតិថ្មដា-បានថាសេន ខេត្តពោធិ៍សាត់-ត្រាត។</td></tr>
</table>

## ៤.២-ច្រកទ្វារអន្តរជាតិ (ស្ថិតនៅផ្ទៃក្នុងព្រះរាជាណាចក្រកម្ពុជា)

១-អាកាសយានដ្ឋានអន្តរជាតិមាន៣ គឺ ៖ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ អាកាសយានដ្ឋានអន្តរជាតិសៀមរាប និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ។

២-កំពង់ផែអន្តរជាតិមាន០២ គឺ ៖ កំពង់ផែស្វយ័តក្រុងព្រះសីហនុ និងកំពង់ផែស្វយ័តភ្នំពេញ។

៣-កំពង់ផែសមុទ្រ មាន ៖ កំពង់ផែទំនប់រលក ស្ទឹងហាវ ប៉ាក់ខ្លង កែវផុស ស្រែអំបិល កំពង់ផែសមុទ្រទីរួមខេត្តកំពត និងកំពង់ផែកែប។

## ៤.៣-ច្រកទ្វារព្រំដែនអន្តរជាតិ (ស្ថិតនៅតាមព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសជិតខាង)

| ល.រ | ឈ្មោះច្រកទ្វារព្រំដែនអន្តរជាតិ | ខេត្ត |
|---|---|---|
| ១ | ចាំយាម | កោះកុង |
| ២ | ប៉ោយប៉ែត | បន្ទាយមានជ័យ |
| ៣ | ដូង | បាត់ដំបង |
| ៤ | ព្រំ | ប៉ៃលិន |
| ៥ | អូរស្មាច់ | ឧត្តរមានជ័យ |
| ៦ | ជាំ | |
| ៧ | ត្រពាំងក្រៀល | ស្ទឹងត្រែង |
| ៨ | អូរយ៉ាដាវ | រតនគិរី |
| ៩ | ត្រពាំងស្រែ | ក្រចេះ |
| ១០ | ត្រពាំងផ្លុង | ត្បូងឃ្មុំ |
| ១១ | បាវិត | ស្វាយរៀង |
| ១២ | សំរោង | |
| ១៣ | ព្រៃវល្លិ៍ | |
| ១៤ | ក្អមសំណ | កណ្តាល |
| ១៥ | បន្ទាយចក្រី | ព្រៃវែង |
| ១៦ | កោះរកា | |
| ១៧ | ភ្នំដិន | តាកែវ |
| ១៨ | ព្រែកចាក | កំពត |

# អភិបាលកិច្ចល្អ

## ១-ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

### ក-លទ្ធផលការងាររបស់អង្គភាពប្រឆាំងអំពើពុករលួយ

អនុវត្តតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ដែលបានចូលជាធរមានកាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១ ការងារប្រឆាំងអំពើពុករលួយរយៈពេល៥ឆ្នាំ (២០១២-២០១៦) កន្លងមកនេះ អង្គភាពប្រឆាំងអំពើពុករលួយ បានផ្សព្វផ្សាយនៅស្ទើរគ្រប់ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំរដ្ឋ ឯកជន រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នានា នៅទូទាំងប្រទេស។

ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលបានពង្រឹងការអនុវត្តជាប់ជាប្រចាំនូវការអប់រំ បង្ការ ទប់ស្កាត់អំពើពុករលួយ។ ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ចូលទៅក្នុងកម្មវិធីសិក្សាគ្រប់កម្រិត ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ ហើយបានបោះពុម្ពឯកសារសៀវភៅអប់រំសម្រាប់គាំទ្រការសិក្សា និងការបង្រៀនដល់សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ សម្រាប់អប់រំ ផ្សព្វផ្សាយនៅគ្រប់គ្រឹះស្ថានសិក្សា សាលារៀនរដ្ឋ និងឯកជន។

ក្រសួង ស្ថាប័ននានា បង្កើតក្របខណ្ឌច្បាប់សម្រាប់អនុវត្តការងាររបស់ខ្លួនប្រកបដោយតម្លាភាព និងប្រសិទ្ធភាពដែលរួមមាន ការព្រាងអនុក្រឹត្យ ការធ្វើប្រកាសអន្តរក្រសួង និងសេចក្តីសម្រេចនានា ក្នុងគោលបំណងកាត់បន្ថយ និងលុបបំបាត់នូវភាពចន្លោះប្រហោងដែលនាំឲ្យមានការប្រព្រឹត្តអំពើពុករលួយ ក្នុងនោះរួមមាន ប្រកាសរួមស្តីពីការអនុវត្តសេវាសាធារណៈនៅតាមក្រសួង ស្ថាប័ននានា ចំនួន៣៣ ប្រកាសរួមស្តីពីការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន២២ ប្រកាស និងលិខិតបទដ្ឋាន ស្តីពីការដាក់ចេញការត្រួតពិនិត្យការអនុវត្ត និងការកែសម្រួលប្រាក់រង្វាន់លើកទឹកចិត្ត ដើម្បីពង្រឹងប្រសិទ្ធភាពការអនុវត្តសាធារណៈ។

ការចុះអនុស្សរណៈនៃការយោគយល់គ្នា(MOU) ស្តីពីការប្រឆាំងអំពើពុករលួយរវាងអង្គភាពប្រឆាំងអំពើពុករលួយជាមួយនឹងបណ្តាក្រុមហ៊ុនវិនិយោគឯកជនចំនួនជាង២០០ក្រុមហ៊ុន ក្នុងនោះមានក្រុមហ៊ុនចិន និងក្រុមហ៊ុនធំៗ ដូចជា COCACOLA របស់សហរដ្ឋអាមេរិក និងក្រុមហ៊ុន TATA របស់ឥណ្ឌា ដោយមិនរាប់ទាំងអង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល និងគ្រឹះស្ថានសាធារណៈមួយចំនួនទៀតផង គឺដើម្បីលើកទឹកចិត្ត និងការពារផលប្រយោជន៍ក្រុមហ៊ុន និងសហគ្រាសទាំងនោះឲ្យជៀសផុតពីការគាបសង្កត់ទាមទារប្រាក់ ឬការសូកប៉ាន់ប្រាក់ទៅអាជ្ញាធរមានសមត្ថកិច្ចដោយខុសច្បាប់។

ការប្រកាសទ្រព្យសម្បត្តិ និងបំណុលត្រូវបានអនុវត្តជាប់ជាប្រចាំ ការងារនេះបានធ្វើឲ្យមន្ត្រីរាជការមានទម្លាប់ជាប្រចាំ និងជួយបានយ៉ាងមានប្រសិទ្ធភាពដល់ការទប់ស្កាត់ ក៏ដូចជាការស៊ើបអង្កេតបទល្មើសពុករលួយ។ មន្ត្រីជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល បានមកប្រកាសគ្រប់ចំនួន ១០០% ដែលបានឆ្លុះបញ្ចាំងអំពីការបំពេញតួនាទី ភារកិច្ចរបស់ខ្លួន ដោយការទទួលខុសត្រូវខ្ពស់។

ការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងអំពើពុករលួយ UNCAC កម្ពុជា ក្នុងនាមជាសមាជិករបស់ UNCAC SEA-PAC ADB/OECD IACA និងអង្គការអន្តរជាតិដទៃទៀត អង្គភាពប្រឆាំងអំពើពុករលួយ បានអនុវត្តកាតព្វកិច្ចរបស់ខ្លួនចូលរួមក្នុងកិច្ចប្រជុំសន្និសីទ សិក្ខាសាលា ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់ជាតិ អន្តរជាតិ។

អង្គភាពប្រឆាំងអំពើពុករលួយ បានទៅពិនិត្យអំពើពុករលួយក្នុងនាមអង្គការសហប្រជាជាតិ នៅប្រទេសចំនួន៣ គឺប្រទេសម៉ាល់តា ប៉ារ៉ាឡាវ និងប្រទេសអារ៉ាប៊ីសាអ៊ូឌីត ហើយកម្ពុជាខ្លួនឯងក៏បានដាក់ខ្លួនជូនអង្គការសហប្រជាជាតិ មកពិនិត្យអំពីស្ថានភាពអំពើពុករលួយនៅកម្ពុជាផងដែរ។

**ខ-លទ្ធផលការងាររបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច**

- ចាប់ពីឆ្នាំ២០១២-២០១៦ ក្រសួងបាន ៖

-ទទួលបណ្តឹងចំនួន ៣១៧បណ្តឹង (ថ្នាក់កណ្តាល ១៦៩បណ្តឹង និងមន្ទីររាជធានី ខេត្ត ១៤៨បណ្តឹង ក្នុងនោះ ដោះស្រាយបញ្ចប់ ៧៩បណ្តឹង ថ្នាក់កណ្តាល ១៦បណ្តឹង និងថ្នាក់មន្ទីររាជធានី ខេត្ត ៦៣បណ្តឹង)។

-ចុះធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅក្រសួង ស្ថាប័ន ១៦ រដ្ឋបាលសាលាខេត្ត ០៧ និងមន្ទីរ អង្គភាព ១ ៧៩២ ក្នុង ២៤រាជធានី ខេត្ត។

-ធ្វើសេចក្តីណែនាំ ១ ០០៥លិខិត ជូនដល់ក្រសួង ស្ថាប័ន ឲ្យជួយជំរុញកែលម្អនូវរាល់ចំណុចខ្វះខាតនៅតាមមន្ទីរ អង្គភាព ស្ថិតក្រោមឱវាទរបស់ខ្លួន។

-ទទួលលិខិតឆ្លើយតប ស្តីពីការកែលម្អចំណុចខ្វះខាតតាមការណែនាំរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ៥៥លិខិត ពីក្រសួង ស្ថាប័នចំនួន ១៥ និងបានទទួលរបាយការណ៍ស្តីពីលទ្ធផលអធិការកិច្ចរបស់អគ្គាធិការដ្ឋាន អធិការដ្ឋាន នាយកដ្ឋានអធិការកិច្ចតាមក្រសួង ស្ថាប័ន ២៥៥លើក។

-រៀបចំកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំ អគ្គាធិការដ្ឋាន អធិការដ្ឋាន និងនាយកដ្ឋាន អធិការកិច្ចនៃបណ្តាក្រសួង ស្ថាប័នចំនួន២៦ ស្តីពីការឆ្លុះបញ្ចាំងវឌ្ឍនភាពការងារអធិការកិច្ច និងការអនុវត្តតួនាទី និងបទពិសោធន៍ដើម្បីជាធាតុចូលនៃសេចក្តីព្រាងច្បាប់ស្តីពីអធិការកិច្ច។

ទន្ទឹមនេះ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានចុះផ្សព្វផ្សាយច្បាប់ចំនួន ១៨១លើក នៅរាជធានី ខេត្ត ដោយមានអ្នកចូលរួមស្តាប់ ១០២ ៣៤១នាក់ (ស្រី ២០ ៩៥៤ នាក់) និងទទួលបានសំណួរ ១០ ៨៥០សំណួរ ព្រមទាំងបានឆ្លើយជូនដល់ម្ចាស់សំណួរវិញ។

## ២-ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

**ក-លទ្ធផលការងាររបស់ក្រសួងយុត្តិធម៌ ៖**

| បរិយាយ | ចេញព្រឹត្តិបត្រថ្កោលទោស(ច្បាប់) | កម្រៃសេវាពីព្រឹត្តិបត្រថ្កោលទោស(រៀល) |
|---|---|---|
| ២០១២ | ៣១ ០៦៤ | ៥៦៤ ៩៩០ ០០០ |
| ២០១៣ | ៣១ ៤៣៤ | ១ ១១០ ៣៦០ ០០០ |
| ២០១៤ | ៣៦ ២១៧ | ១ ៤៧៩ ៥០០ ០០០ |
| ២០១៥ | ៣៧ ៦០៦ | ១ ៦២២ ៧១០ ០០០ |

| ២០១៦ | ៤៧ ២០១ | ២ ០៩២ ៤៦០ ០០០ |
|---|---|---|

### ចៅក្រម

| បរិយាយ | ចៅក្រមអាសនៈ (នាក់) | ចៅក្រមអយ្យការ (នាក់) |
|---|---|---|
| ២០១២ | ២៦៩ | ១៤៣ |
| ២០១៣ | ២៦៦ | ១៤៦ |
| ២០១៤ | ២៦៣ | ១៤៧ |
| ២០១៥ | ២៧៨ | ១៨៤ |
| ២០១៦ | ២៧៨ | ១៨៤ |

ចាប់ពីឆ្នាំ២០១២ ដល់ដំណាច់ឆ្នាំ២០១៦នេះ ចៅក្រមសរុបនៅទូទាំងប្រទេស ដែលបានបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យពីរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការមានចំនួន ១១០នាក់ (ស្រី ២៣នាក់) ក្នុងនោះ មានចៅក្រមអាសនៈ ៣២នាក់ (ស្រី ៧នាក់) ចៅក្រមអយ្យការ ២៣នាក់ (ស្រី ៤នាក់)។ ដោយឡែក ចៅក្រម ៥៥នាក់ (ស្រី ១២នាក់)ទៀត មិនទាន់ធ្វើការបែងចែក (កំពុងជាប់កម្មសិក្សា)។

### ក្រឡាបញ្ជី

| បរិយាយ | ឆ្នាំ ២០១២ | ឆ្នាំ ២០១៣-២០១៤ (ជំនាន់ទី៣ ៖ ២វគ្គ) | ឆ្នាំ ២០១៥-២០១៦ (ជំនាន់ទី៤ ៖ ១វគ្គ) |
|---|---|---|---|
| ក្រឡាបញ្ជីទទួលការបណ្តុះបណ្តាល | - | ១២៥ នាក់ (ស្រី ៣៥នាក់ ប្រុស ៩០នាក់) | ៩៣ នាក់ (ស្រី ១៣នាក់ ប្រុស ៨០នាក់) |

ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៦ ក្រឡាបញ្ជីសរុបនៅទូទាំងប្រទេស ដែលបានបញ្ចប់ការសិក្សាដោយជោគជ័យពីរាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ (ជំនាន់ទី៣ និងជំនាន់ទី៤) មានចំនួនសរុប ២១៨នាក់ (ស្រី ៤៨នាក់)។

### មេធាវី

| បរិយាយ | ២០១២ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ |
|---|---|---|---|---|
| មេធាវីទទួលការបណ្តុះបណ្តាល | - | ៥៩នាក់ (ប្រុស ៤២នាក់ ស្រី ១៧នាក់) | ៥៤នាក់ (ប្រុស ៣៨នាក់ ស្រី ១៦នាក់) | ៥៣នាក់ (ប្រុស ៣៩នាក់ ស្រី ១៤នាក់) |

ចាប់ពីឆ្នាំ២០១២ ដល់ដំណាច់ឆ្នាំ២០១៦នេះ មេធាវីសរុបនៅទូទាំងប្រទេសមានចំនួន ១ ២០៣នាក់ (ស្រី ២៣៩នាក់)។ ដោយឡែកនៅឆ្នាំ២០១៦នេះ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវីបានបណ្តុះបណ្តាលមេធាវីចំនួន ៥៣នាក់ (ស្រី ១៤នាក់)។

**អាជ្ញាសាលា**

| ជំនាន់១ | កាលបរិច្ឆេទបណ្តុះបណ្តាល | ចំនួនសិស្ស | ប្រុស | ស្រី |
|---|---|---|---|---|
| | កុម្ភៈ ២០១៣-ឧសភា ២០១៥ | ២៨នាក់ | ២៦នាក់ | ២នាក់ |

**សារការី**

| ជំនាន់១ | កាលបរិច្ឆេទបណ្តុះបណ្តាល | ចំនួនសិស្ស | ប្រុស | ស្រី |
|---|---|---|---|---|
| | កុម្ភៈ ២០១៣-សីហា ២០១៦ | ១៥នាក់ | ១០នាក់ | ៥នាក់ |

- ចាប់ពីឆ្នាំ២០១២ ដល់ដំណាច់ឆ្នាំ២០១៦នេះ រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ បានរៀបចំវគ្គបណ្តុះបណ្តាលបន្ត វិក្រឹត្យការ សុក្រឹត្យការ សិក្ខាសាលា និងបទបាឋកថា ជូនដល់សិស្ស និងសិក្ខាកាម ជាចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា និងសារការី ដែលកំពុងបំពេញការិយកម្មនៅតាមសាលាជម្រះគ្រប់ជាន់ថ្នាក់ នៃព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះ រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ ក៏បានធ្វើការបណ្តុះបណ្តាលវគ្គវិក្រឹត្យការដល់មន្ត្រីអតីតក្រឡាបញ្ជី ចំនួន ២៨រូប ដើម្បីទទួលបាននីតិសម្បទាជាក្រឡាបញ្ជីពេញសិទ្ធិកាលពីអំឡុងខែមករា ដល់ខែឧសភា ឆ្នាំ២០១៦ បណ្តុះបណ្តាលគ្រូបង្គោលផ្នែករដ្ឋប្បវេណីបានចំនួន ២៤រូប ក្រោមកិច្ចសហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និងបណ្តុះបណ្តាលចៅក្រមពាណិជ្ជកម្មបានចំនួន ២ជំនាន់ សរុបចំនួន ៣២រូបផងដែរ។

- **ការដោះស្រាយបណ្តឹង**

| **១-ការដោះស្រាយបណ្តឹងព្រហ្មទណ្ឌពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០១៦** | | | | | | |
|---|---|---|---|---|---|---|
| ស្ថិតិបណ្តឹងចូលមកក្រសួងយុត្តិធម៌ | | | | | | |
| **ឆ្នាំ** | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប |
| **សល់ពីមុន** | ៣៤ | ២០ | ២៧ | ៥២ | ១៤៦ | **២៧៩** |
| **ចូលថ្មី** | ២១០ | ២០៩ | ១៩២ | ១៥១ | ៩៤ | **៨៥៦** |
| **ចាត់ការរួច** | ២២៤ | ២០២ | ១៦៧ | ៥៧ | ៩៥ | **៧៤៥** |
| **កំពុងចាត់ការ** | ២០ | ២៧ | ៥២ | ១៤៦ | ១៤៥ | **៣៩០** |
| ស្ថិតិសំណុំរឿងព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី-ខេត្ត | | | | | | |
| **សល់ពីមុន** | ៤ ៩០៤ | ៦ ០៦២ | ៦ ៩៥៧ | ៧ ៣៣៧ | ៩ ១៧២ | ៣៤ ៤៣២ |
| **ចូលថ្មី** | ៦ ៧២៤ | ៨ ២៧៤ | ៥ ៩៥២ | ១១ ៤៤៦ | ១៥ ២៣៧ | ៤៧ ២៣៣ |

| | | | | | | |
|---|---|---|---|---|---|---|
| ចាត់ការរួច | ៥ ២៩២ | ៨ ០៧៩ | ៥ ០១២ | ១០ ១៧២ | ១២ ៥៨៨ | ៤១ ១៤៣ |
| កំពុងចាត់ការ | ៦ ៣៣៦ | ៦ ២៥៧ | ៧ ៤៩៣ | ៨ ៦១១ | ១១ ៨២១ | ៤០ ៥២២ |
| **២-ការដោះស្រាយបណ្ដឹងរដ្ឋប្បវេណីពីឆ្នាំ ២០១២ ដល់ឆ្នាំ ២០១៦** | | | | | | |
| ស្ថិតិបណ្ដឹងចូលមកក្រសួងយុត្តិធម៌ | | | | | | |
| **ឆ្នាំ** | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប |
| **សល់ពីមុន** | ៣៦ | ២៧ | ៣៤ | ៦៨ | ៣២ | **១៩៧** |
| **ចូលថ្មី** | ១៣៧ | ១៣១ | ១៧៧ | ១៨៣ | ២៥៨ | **៨៨៦** |
| **ចាត់ការរួច** | ១៤៦ | ១២៤ | ១៤៣ | ២១៩ | ២០៦ | **៨៣៨** |
| **កំពុងចាត់ការ** | ២៧ | ៣៤ | ៦៨ | ៣២ | ៨៤ | **២៤៥** |
| ស្ថិតិសំណុំរឿងរដ្ឋប្បវេណីរបស់សាលាដំបូងរាជធានី-ខេត្ត | | | | | | |
| **សល់ពីមុន** | ៦ ៧៣៦ | ៦ ៨៧៦ | ៦ ៤៨១ | ៧ ១៧៨ | ៩ ០០៤ | **៣៦ ២៧៥** |
| **ចូលថ្មី** | ៣ ៩២០ | ៤ ៤១៩ | ៥ ៨៥០ | ៥ ១២០ | ១៥ ២៣៧ | **៣៤ ៥៤៦** |
| **ចាត់ការរួច** | ៣ ៧៨០ | ៤ ៨១៤ | ៥ ១៥៣ | ៣ ២៩៤ | ១២ ៤២០ | **២៩ ៤៦១** |
| **កំពុងចាត់ការ** | ៦ ៨៧៦ | ៦ ៤៨១ | ៧ ១៧៨ | ៩ ០០៤ | ១១ ៨២១ | **៤១ ៣៦០** |

## ខ-ការពង្រឹងនីតិរដ្ឋ

✡ ព្រះរាជក្រមដែលប្រកាសឲ្យប្រើចាប់ពីឆ្នាំ២០១២-២០១៦

| **បរិយាយ** | **២០១២** | **២០១៣** | **២០១៤** | **២០១៥** | **២០១៦** | **សរុប** |
|---|---|---|---|---|---|---|
| ព្រះរាជក្រម (ច្បាប់) | **១៣** | **១៨** | **២៦** | **១៨** | **២១** | **៩៦** |

✡ ច្បាប់ដែលរាជរដ្ឋាភិបាលបានក្រាបបង្គំទូលថ្វាយស្នើសូមព្រះករុណា ព្រះមហាក្សត្រទ្រង់ព្រះរាជទានព្រះរាជក្រមប្រកាសឲ្យប្រើបន្ទាប់ពីស្ថាប័ននីតិប្បញ្ញត្តិ បានអនុម័តរួចចាប់ពីឆ្នាំ**១៩៩៣ ដល់ដំណាច់ឆ្នាំ២០១៦** សរុបមាន **៤៧៦ច្បាប់**។

✡ ទទួលសំណួរ ចម្លើយសភា ដែលទទួលបានពីសមាជិករដ្ឋសភា និងស្ថាប័នពាក់ព័ន្ធចាប់ពីឆ្នាំ២០១២-២០១៦

| **បរិយាយ** | **២០១២** | **២០១៣** | **២០១៤** | **២០១៥** | **២០១៦** | **សរុប** |
|---|---|---|---|---|---|---|
| សំណួរ ចម្លើយ (ករណី) | ៣៦ | ១១ | ៣៣ | ៦២ | ២៣ | ១៦៥ |

-រាជរដ្ឋាភិបាលបានចេញ ៖

| **បរិយាយ** | **២០១២** | **២០១៣** | **២០១៤** | **២០១៥** | **២០១៦** | **សរុប** |
|---|---|---|---|---|---|---|
| សេចក្ដីសម្រេច | ៤៩ | ៥៧ | ១៧២ | ១០៥ | ១៣៥ | ៥១៨ |
| ប្រកាស | ១៣៧ | ២៤ | ៤១ | ១១៧ | ៦៣ | ៣៨២ |

| | | | | | | |
|---|---|---|---|---|---|---|
| អនុក្រឹត្យតែងតាំង | ២ ៩៨២ | ១ ២០៦ | ១ ៧៤៨ | ១ ២៧៥ | ១ ២៥៧ | ៨ ៤៦៨ |
| អនុក្រឹត្យបង្កើត | ២៧៩ | ៥៩៤ | ៣៤៤ | ១៩៤ | ២៨៨ | ១ ៧០៣ |
| សារាចរ | ៣ | ៦ | ៧ | ៩ | ១២ | ៣៧ |
| សារាចរណែនាំ | ១២ | ១៣ | ៦ | ៩ | ៦ | ៤៦ |
| សេចក្ដីណែនាំ | ៣ | ៦ | ២ | ១ | ២ | ១៤ |

### គ-សម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប |
|---|---|---|---|---|---|---|
| លើក | ១០ | ១១ | ១១ | ១៤ | ៨ | **៥៤** |

### ឃ-ប្រជុំអន្តរក្រសួងនៅទីស្ដីការគណៈរដ្ឋមន្ត្រី

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប |
|---|---|---|---|---|---|---|
| លើក | ៨១ | ២៣ | ២៩ | ២៩ | ២៤ | **១៨៦** |

## ៣-ការកែទម្រង់រដ្ឋបាលសាធារណៈ

### ក-ការគ្រប់គ្រងក្របខណ្ឌមន្ត្រីរាជការស៊ីវិល

ចាប់ពីឆ្នាំ២០១២ដល់ ឆ្នាំ២០១៦នេះ ៖

| ឆ្នាំ | មន្ត្រីជាប់កិច្ចសន្យា | គ្រូបង្រៀនជាប់កិច្ចសន្យា | គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ | ផែនការក្របខណ្ឌ |
|---|---|---|---|---|
| ២០១២ | ១៩ ៨២២ | ១ ៨៥២ | ២ ៩០៥ | ៨ ៥៣៩ |
| ២០១៣ | ២០ ០៩៣ | ១ ៨៦៣ | ៣ ០៣៥ | ៨ ៨១០ |
| ២០១៤ | ២០ ០៩៤ | ១ ៧៣០ | ២ ៩៦៨ | ១០ ១០៤ |
| ២០១៥ | ២៣ ៤៨៨ | ២ ៧៩៩ | ៤ ៥៥៧ | ៥ ២៣៧ |
| ២០១៦ | ២០ ៣០១ | ៦ ១៧៦ | ២ ៤៧២ | ១៦ ៤៦០ |
| **សរុប** | **១០៣ ៧៩៨** | **១៤ ៤២០** | **១៥ ៩៣៧** | **៤៩ ១៥០** |

-ជ្រើសរើសមន្ត្រីរាជការស៊ីវិលចូលក្របខណ្ឌថ្មី ៤៩ ១៥០នាក់។

-មន្ត្រីជាប់កិច្ចសន្យា ១០៣ ៧៩៨នាក់។

-គ្រូបង្រៀនជាប់កិច្ចសន្យា ១៤ ៤២០នាក់។

-គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ ១៥ ៩៣៧នាក់។

-តែងតាំងមន្ត្រីរាជការស៊ីវិល ១០ ៨៨៨នាក់។

-ដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ ២៨ ១០០នាក់។

-ផ្តល់សលាកប័ត្រព័ត៌មានមន្ត្រីរាជការស៊ីវិលនិងបញ្ចូលទិន្នន័យមន្ត្រីក្របខ័ណ្ឌថ្មី ៣១ ៤៥២នាក់។
-រៀបចំព្រះរាជក្រឹត្យនិងអនុក្រឹត្យតាំងស៊ប់ក្នុងក្របខ័ណ្ឌ ៣១ ០២៣នាក់។
-រៀបចំព្រះរាជក្រឹត្យនិងអនុក្រឹត្យដំឡើងឋានន្តរសក្តិនិងថ្នាក់ ២៨០ ៨៩៧នាក់។

| បរិយាយ | ថ្នាក់ឧត្តមមន្ត្រី (នាក់) | ថ្នាក់វរមន្ត្រី (នាក់) | ថ្នាក់អនុមន្ត្រី (នាក់) |
|---|---|---|---|
| ២០១២ | ៥០៧ | ១ ៤៣៥ | ៣១ ១៧១ |
| ២០១៣ | ៥១៣ | ១ ៥៨៨ | ៣៣ ៦៧២ |
| ២០១៤ | ៧០៧ | ១ ៨៩៤ | ៣១ ៦០០ |
| ២០១៥ | ១ ២៤២ | ១៤ ៧៦៩ | ២៨ ៦៨២ |
| ២០១៦ | ១ ១៧៦ | ១៤ ៥៤៩ | ៣២ ០៨៤ |

មន្ត្រីរាជការស៊ីវិលទូទាំងប្រទេសក្នុងតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា មានចំនួនសរុប ២០១ ០១៨នាក់ (ស្ត្រី ៧៩ ៨៦៦នាក់ ស្មើនឹង ៤០%) ក្នុងនោះ មន្ត្រីរាជការនៅថ្នាក់ជាតិ មានចំនួន ៣៨ ៥៤៣នាក់ ស្មើនឹង ១៩% និងថ្នាក់ក្រោមជាតិចំនួន ១៦២ ៤៧៥នាក់ ស្មើនឹង ៨១%។

## ខ-ការកែទម្រង់ប្រព័ន្ធបៀវត្ស

រាជរដ្ឋាភិបាល បានដាក់ឲ្យអនុវត្តនូវព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ជាច្រើនក្នុងការធ្វើកំណែទម្រង់បៀវត្សជូនមន្ត្រីរាជការស៊ីវិល កងកម្លាំងប្រដាប់អាវុធ កងនគរបាល ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលក៏មានការធ្វើកំណែទម្រង់ប្រព័ន្ធបៀវត្ស និងប្រព័ន្ធរដ្ឋបាលសាធារណៈ ហើយប្រការដែលសំខាន់នោះ គឺការធានាបាននូវការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធធនាគារ បានទាន់ពេលវេលាក្នុងសប្តាហ៍ទី៤នៃខែនីមួយៗ។

**គ-ការរៀបចំដំឡើងប្រាក់បៀវត្ស** ជូនមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ និងប្រាក់ឧបត្ថម្ភ ប្រចាំខែជូនសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់និងមន្ត្រីភូមិ ៖

| បរិយាយ | បៀវត្សអប្បបរមាសម្រាប់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ និងប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ក្រុមប្រឹក្សាគ្រប់ប្រភេទ និងមន្ត្រីភូមិ (ជារៀល) | | | | |
|---|---|---|---|---|---|
| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| វិស័យរដ្ឋបាលការទូត និងបច្ចេកទេស | ១២៦ ០០០ | ៣៤៤ ០០០ | ៤២៤ ០០០ | ៥៥២ ៨០០ | ៧០០ ៥០០ |
| វិស័យអប់រំ | ១៨៩ ០០០ | ៤០២ ៨០០ | ៥៥០ ០០០ | ៦៥២ ៨០០ | ៨០០ ៥០០ |
| វិស័យសុខាភិបាល | ១៨៩ ០០០ | ៣៦០ ០០០ | ៥៥០ ០០០ | ៦៥២ ៨០០ | ៨០០ ៥០០ |
| នគរបាល | | ៣៧៩ ៩៣០ | ៤៦០ ៩៣០ | ៦២៨ ២៧០ | ៧៨៤ ៧៣០ |
| យោធិន | | ៣១៥ ៩៩០ | ៣៩៦ ៩៩០ | ៥៨២ ៤៣០ | ៧៣៣ ៧៣០ |

| | | | | | |
|---|---|---|---|---|---|
| ប្រធានក្រុមប្រឹក្សារាជធានីខេត្ត | ១ ០០០ ០០០ | ១ ០០០ ០០០ | ១ ០០០ ០០០ | ១ ០០០ ០០០ | ១ ០៩០ ០០០ |
| សមាជិកក្រុមប្រឹក្សារាជធានីខេត្ត | ៨០០ ០០០ | ៨០០ ០០០ | ៨០០ ០០០ | ៨០០ ០០០ | ៨៧០ ០០០ |
| ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ៧០០ ០០០ | ៧០០ ០០០ | ៧០០ ០០០ | ៧០០ ០០០ | ៨១០ ០០០ |
| សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ៥០០ ០០០ | ៥០០ ០០០ | ៥០០ ០០០ | ៥០០ ០០០ | ៦៥០ ០០០ |
| ប្រធានក្រុមប្រឹក្សាឃុំសង្កាត់ ចាប់ពីខែកក្កដា ឆ្នាំ២០១៥ | ១៥០ ០០០ | ១៥០ ០០០ | ៣០០ ០០០ | ៤០០ ០០០-៥៧០ ០០០ | ៧៥០ ០០០ |
| ជំទប់ទី១ និងទី២ ចៅសង្កាត់រងទី១ និងទី២ ចាប់ពីខែកក្កដា ឆ្នាំ២០១៥ | ១២០ ០០០ | ១២០ ០០០ | ២៤០ ០០០ | ៣៥០ ០០០-៤០០ ០០០ | ៥៥០ ០០០ |
| សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ចាប់ពីខែកក្កដា ឆ្នាំ២០១៥ | ១០០ ០០០ | ១០០ ០០០ | ២០០ ០០០ | ៣០០ ០០០-៣៥០ ០០០ | ៤៨០ ០០០ |
| មេភូមិ | ៦០ ០០០ | ៦០ ០០០ | ១២០ ០០០ | ១៦០ ០០០ | ២០០ ០០០ |
| អនុប្រធានភូមិ | ៥០ ០០០ | ៥០ ០០០ | ១០០ ០០០ | ១៤០ ០០០ | ១៦០ ០០០ |
| សមាជិកភូមិ | ៤០ ០០០ | ៤០ ០០០ | ៨០ ០០០ | ១២០ ០០០ | ១៤០ ០០០ |

## ឃ- ការរៀបចំបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ៖

| បរិយាយ | របបសន្តិសុខសង្គមអប្បបរមាប្រចាំខែ (ជារៀល) | |
|---|---|---|
| | ២០១៥ | ២០១៦ |
| អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន | ៣០០ ០០០ | ៣៦០ ០០០ |

-បានរៀបចំកាត់ពន្ធប្រាក់បៀវត្សប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលតាមតារាងទូទាត់បៀវត្សដោយស្វ័យប្រវត្តិ ចាប់ពីខែសីហា ឆ្នាំ២០១៤ ៖

| ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|
| ៤ ១៩១ ២៧២ ៦១០រៀល | ៥ ៦៣៦ ៥៥១ ៨០៣រៀល | ១២ ៧៤៧ ៩៨៨ ៨៧៥រៀល |

## ខ-ការដំឡើងសន្ទស្សន៍បៀវត្ស

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| សន្ទស្សន៍ | ១ ២៦០ | ១ ៥២០ | ១ ៥២០ | ១ ៥២០ | ១ ៧០០ |

## ច.ការងារវិមជ្ឈការ និងវិសហមជ្ឈការ

### ច.១-ការអភិវឌ្ឍថ្នាក់ក្រោមជាតិ

ចាប់ពីឆ្នាំ២០១២ដល់ឆ្នាំ២០១៦នេះ រាជរដ្ឋាភិបាល ៖

-បានគាំទ្រមូលនិធិឃុំ សង្កាត់សរុបចំនួន ១ ២០៣ ៨៨៧ ៨៩០ ០០០រៀល ស្មើនឹង ២៩៧ ២៥៦ ២៦៩ដុល្លារអាមេរិក ដែលក្នុងនោះឃុំ សង្កាត់នីមួយៗទទួលមូលនិធិនេះ ជាមធ្យមប្រមាណ ១៤៧ ៤៤៤ ៩៣៤រៀល ស្មើនឹង ៣៦ ៥០០ដុល្លារអាមេរិក/មួយឆ្នាំៗ សម្រាប់ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច គម្រោងអភិវឌ្ឍន៍សង្គម និងការផ្ដល់សេវាជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានភូមិ ឃុំរបស់ខ្លួន ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។

-បង្កើតមូលនិធិក្រុង ស្រុក ដែលរហូតមកដល់ឆ្នាំ២០១៦នេះ រាជរដ្ឋាភិបាលបានគាំទ្រមូលនិធិក្រុង ស្រុក មានចំនួនប្រមាណ ៣១៩ ២២៨ ០០០ ០០០រៀល ស្មើនឹង ៨១ ៨៥៣ ៣៣៣ ដុល្លារអាមេរិក។ ក្រុង ស្រុកនីមួយៗទទួលបានមូលនិធិជាមធ្យមចំនួនប្រមាណ ៤៣១ ៣៨៩ ១៨៩ រៀល ស្មើនឹង ១១០ ៦១២ដុល្លារអាមេរិក/មួយឆ្នាំៗ សម្រាប់ការអនុវត្តគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតមធ្យម គម្រោងអភិវឌ្ឍន៍សង្គម និងការផ្ដល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានក្រុង ស្រុករបស់ខ្លួនដើម្បីបំពេញបន្ថែមទៅនឹងគម្រោងមូលនិធិឃុំ សង្កាត់។

-ការិយាល័យច្រកចេញចូលតែមួយនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំនួន ៤៦ បានផ្ដល់សេវាសរុបចំនួន ១ ៦៥៧ ៧៧១សេវា បានទទួលចំណូលសរុបចំនួន ៤២ ០៤៥ ៦៧៤ ០០០រៀល ស្មើនឹង ១០ ៥១១ ៤១៨ដុល្លារអាមេរិក។

-នៅថ្នាក់រាជធានី ខេត្ត បានទទួលថវិកាវិភាជន៍សរុបចំនួនប្រមាណ ៣ ២៥៣ ៥៤០ ០០០ ០០០រៀល ស្មើនឹង ៨០៣ ៣៤៣ ២១០ដុល្លារអាមេរិក និងបានចំណាយទៅលើការផ្ដល់សេវាសាធារណៈ និងគម្រោងវិនិយោគនានារបស់រដ្ឋបាលរាជធានី ខេត្ត។

-រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងគោលបំណងធានានូវការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធភាព និងឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ និងធុរជន។

### ច.២-ការងារប្រជាធិបតេយ្យនីយកម្ម

គិតត្រឹមឆ្នាំ២០១៦នេះ គណបក្សនយោបាយសរុប **៦៨** បានចុះបញ្ជីនៅក្រសួងមហាផ្ទៃ **៤៤** គណបក្ស។

-ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៦ គិតចាប់ពីថ្ងៃទី១ ខែកញ្ញា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ លទ្ធផលផ្លូវការនៃការចុះឈ្មោះបោះឆ្នោតចំនួន **៧ ៨៦៥ ០៣៣ នាក់** ស្មើនឹង **៨១,៤៧%** នៃចំនួនប្រជាពលរដ្ឋដែលដល់អាយុបោះឆ្នោតសរុប **៩ ៦៦៤ ២១៦នាក់**។

### ច.៣- ការងារសង្គមស៊ីវិល

គិតត្រឹមឆ្នាំ២០១៦នេះ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ **៤ ៩២០** ក្នុងនោះ សមាគម **១ ៩៥៤** និងអង្គការមិនមែនរដ្ឋាភិបាល **២ ៩៦៦**។

## ៤-ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ

✡ លទ្ធផលការងាររបស់ក្រសួងការពារជាតិ ៖

-យោធិនចូលនិវត្តន៍ បាត់បង់សមត្ថភាពការងារ និងយោធិនប្រភេទ២ ដែលបានបើកប្រាក់ឧបត្ថម្ភគោលនយោបាយមួយលើកដំបូង និងផ្ទេរទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាគ្រប់គ្រងបន្តចំនួន ៩ ៥៣៨នាក់ (ក្នុងនោះ ឆ្នាំ២០១២ ចំនួន ៤ ៦៦២នាក់ ឆ្នាំ២០១៣ ចំនួន ៨៦៧នាក់ ឆ្នាំ២០១៤ ចំនួន ១ ៣៣៧នាក់ ឆ្នាំ២០១៥ ចំនួន ១ ៤៣៥នាក់ និងឆ្នាំ២០១៦ ចំនួន ១ ២៣៧នាក់)។

-កងយោធពលខេមរភូមិន្ទ ក៏មានភាគព្វកិច្ចនៅក្នុងការចូលរួមចំណែកកសាងបណ្តាញផ្លូវគមនាគមន៍ ស្ពាន លូ ប្រព័ន្ធធារាសាស្ត្រ ជួយសង្គ្រោះមហន្តរាយនានា (គ្រោះរាំងស្ងួត ព្យុះ ទឹកជំនន់ អគ្គិភ័យ គ្រោះថ្នាក់ចរាចរណ៍....) ជួយប្រជាពលរដ្ឋក្នុងការកសាង និងជួសជុលផ្ទះសម្បែង ផ្លូវ ស្ពាន បង្គន់អនាម័យ ដឹកស្រះទឹក អណ្តូងទឹក ពិនិត្យព្យាបាលជំងឺ ដឹកទឹកចែកជូនតំបន់ខ្វះទឹក ជួយការងារបង្កបង្កើនផល (ភ្ជួររាស់ ដកស្ទូង ច្រូតកាត់ បោកបែន ដាំដុះដំណាំនិងប្រមូលផល លើកភ្លឺស្រែ បូមទឹកដាក់ស្រែ....)និងបានឧបត្ថម្ភជូនបងប្អូនជួបការលំបាកខ្វះខាតជាថវិកា សម្ភារៈផ្សេងៗជាដើម ព្រមទាំងកសាងសំណង់អគារ បន្ទាយ ដំរំដម្រេកគ្រប់ប្រភេទ ផ្ទះគ្រួសារកងទ័ព ផ្ទះយោធិនពិការ ឧបត្ថម្ភដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត សប្បុរសជន បណ្តាប្រទេសជាមិត្ត ព្រមទាំងថវិការបស់រដ្ឋ និងបណ្តាស្ថាប័ន កងឯកភាពម្ចាស់ការសាងសង់ សរុបកសាងថ្មីបានចំនួន ២ ២៥៧ខ្នង ស្មើនឹង ១៨២ ៤៣៧,៤៣ម$^{2}$ និងជួសជុលបានចំនួន ២៨៩ខ្នង ស្មើនឹង ៣៧ ២៦៧,៧៥ម$^{2}$។

| ប្រភេទសំណង់ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប |
|---|---|---|---|---|---|---|
| ផ្លូវកៅស៊ូ | ៨ខ្សែ ៣៥ ៩២៧គ.ម | ១១ខ្សែ ៨០,២៧គ.ម | ១៦ខ្សែ ១០២,៧៦គ.ម | ៩ខ្សែ ៧៨,៩គ.ម | ៩ខ្សែ ៦២, ៤៨១គ.ម | ៥៣ខ្សែ ៣៦០,៣៣៨គ.ម |
| ផ្លូវក្រួសក្រហម | ៣៩ខ្សែ ២៦៩,៥៦គ.ម | ៣៦ខ្សែ ៤៣០,៩៧៤គ.ម | ៣៥ខ្សែ ៣៧៣,៩៩គ.ម | ៣២ខ្សែ ៤៧៣,៦២គ.ម | ២៤ខ្សែ ២០៣,៧៧គ.ម | ១៦២ខ្សែ ១ ៧៥១,៩១៤គ.ម |
| ផ្លូវបេតុង | ៣ខ្សែ ១,៩គ.ម | ៣ខ្សែ ៤,១៦៤គ.ម | ១ខ្សែ ០,៣៨គ.ម | ៤កន្លែង ១៦,០៥គ.ម | ១ខ្សែ ១,០៤គ.ម | ១២ខ្សែ ២៣,៥៣៤គ.ម |
| ស្ពានបេតុង | ៥៨កន្លែង ១ ៤៥០ម | ៥៦កន្លែង ១ ៥៨៧ម | ២២កន្លែង ៥៨៣ម | ២៨កន្លែង ៧៨៤ម | ២៨កន្លែង ១ ០១៣ម | ១៩២កន្លែង ៥ ៤១៧ម |
| ស្ពានបេឡេត៍ | | ២កន្លែង ១៩៨ម | ២កន្លែង ៥៥ម | ២កន្លែង ១៣៦ម | | ៦កន្លែង ៦ ៩៤៦ម |
| លូអ៊ុយ | ៦០៤ខ្នង ៣៤ | | | ៤កន្លែង ៥ ៨៩០ម | ១កន្លែង ១ ០៥៦ម | ៥កន្លែង ៦ ៩៤៦ម |
| លូជ្រុង | ៥៧កន្លែង | ៩០កន្លែង | ២៥កន្លែង | ៨៧កន្លែង | ៦៤កន្លែង | ៣២៣កន្លែង |
| លូមូល | ១ ២៨៨កន្លែង | ៤៦៨កន្លែង | ២២៨កន្លែង | ៤៨៧កន្លែង | ២៨១កន្លែង | ២ ៧៥២កន្លែង |

-ក្រសួងការពារជាតិមានមជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការស្ថិតនៅក្រោមការគ្រប់គ្រងចំនួន ០៣កន្លែង គឺមជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ៣១៧កោះស្លា ស្រុកឈូក ខេត្តកំពត មជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការសម្តេចតេជោហ៊ុនសែនគូលែន៣១៧ ខេត្តសៀមរាប និង មជ្ឈមណ្ឌលអភិវឌ្ឍន៍យោធិនពិការ៣១៧តេជោភ្នំឆត្រ ខេត្តបន្ទាយមានជ័យ។ គិតមកដល់បច្ចុប្បន្ននេះមានគ្រួសារជនពិការកំពុងរស់នៅសរុបចំនួន ១ ០៦៩គ្រួសារ ស្មើនឹងសមាជិក ៤ ០៧៦ នាក់ (ក្នុងនោះយោធិនពិការ ៦៨៦គ្រួសារ បញ្ជូនមកពីអគ្គស្នងការនគរបាលជាតិ ពិការ ៤០គ្រួសារ និងពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពិការ ៣៤៣គ្រួសារ)។

-បានទទួលអ្នកញៀនគ្រឿងញៀនមកធ្វើការអប់រំ និងបន្សាបសារធាតុញៀនចំនួន ៣ ០៧២ នាក់ ក្នុងនោះជាសះស្បើយត្រឡប់ទៅលំនៅស្ថានវិញចំនួន ១ ៥៨៣នាក់។

-ការចូលរួមបេសកកម្មរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិ ព្រះរាជាណាចក្រកម្ពុជា បានបញ្ជូនកងកម្លាំងជាបន្តបន្ទាប់ទៅបំពេញបេសកកម្មនៅសាធារណរដ្ឋអារ៉ាប់ស៊ីរី សាធារណរដ្ឋស៊ូដង់ខាងត្បូង សាធារណរដ្ឋស៊ូដង់ សាធារណរដ្ឋម៉ាលី សាធារណរដ្ឋសាយប្រឹស សាធារណរដ្ឋអាហ្វ្រិកកណ្តាល និងសាធារណរដ្ឋលីបង់ សរុបបានចំនួន ៣ ១៧៧នាក់ (ស្រី ១៤៧នាក់)។ នៅឆ្នាំ២០១៦នេះ កម្ពុជាត្រូវបានអង្គការសហប្រជាជាតិវាយតម្លៃ ជាប្រទេសជាប់លំដាប់ថ្នាក់លេខ ៣៥ ក្នុងចំណោម ១២១ប្រទេស និងលំដាប់ថ្នាក់លេខ៣ ក្នុងចំណោម៨ប្រទេស នៅក្នុងសហគមន៍អាស៊ាន ដែលបានបរិច្ចាគកងកម្លាំងទៅចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។

✡លទ្ធផលការងាររបស់អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ បានធ្វើការសាងសង់សំណង់ប៉ុស្តិ៍នគរបាលរដ្ឋបាល (១១ម x ៧ម) ចំនួន ១២១ខ្នង មានដូចខាងក្រោម ៖

-ឆ្នាំ២០១៣ បាន ២៤ខ្នង ក្នុងនោះខេត្តបាត់ដំបង ៦ខ្នង ព្រៃវែង ៥ខ្នង កណ្តាល ៨ខ្នង កែប ១ខ្នង កំពង់ស្ពឺ ២ខ្នង និងខេត្តព្រះសីហនុ ២ខ្នង។

-ឆ្នាំ២០១៤ បាន ៣៣ខ្នង ក្នុងនោះរាជធានីភ្នំពេញ ៤ខ្នង ខេត្តកណ្តាល ៤ខ្នង កំពង់ចាម ២ខ្នង តាកែវ ១ខ្នង ស្វាយរៀង ២ខ្នង ព្រៃវែង ១២ខ្នង ត្បូងឃ្មុំ ៣ខ្នង បាត់ដំបង ៤ខ្នង និងខេត្តបន្ទាយមានជ័យ ១ខ្នង។

-ឆ្នាំ២០១៥ បាន ៣២ខ្នង ក្នុងនោះខេត្តព្រះសីហនុ ២ខ្នង ឧត្តរមានជ័យ ២ខ្នង ព្រៃវែង ៥ខ្នង កំពង់ស្ពឺ ២ខ្នង ពោធិ៍សាត់ ១ខ្នង កំពត ២ខ្នង ស្ទឹងត្រែង ៣ខ្នង រតនគិរី ៣ខ្នង មណ្ឌលគិរី ៣ខ្នង ក្រចេះ ៣ខ្នង កំពង់ឆ្នាំង ២ខ្នង កណ្តាល ១ខ្នង បាត់ដំបង ១ខ្នង និងខេត្តបន្ទាយមានជ័យ ២ខ្នង។

-ឆ្នាំ២០១៦ បាន ៣២ខ្នង ក្នុងនោះខេត្តព្រះសីហនុ ២ខ្នង ឧត្តរមានជ័យ ២ខ្នង ព្រៃវែង ៥ខ្នង កំពង់ស្ពឺ ២ខ្នង ពោធិ៍សាត់ ១ខ្នង កំពត ២ខ្នង ស្ទឹងត្រែង ៣ខ្នង រតនគិរី ៣ខ្នង មណ្ឌលគិរី ៣ខ្នង ក្រចេះ ៣ខ្នង កំពង់ឆ្នាំង ២ខ្នង កណ្តាល ១ខ្នង បាត់ដំបង ១ខ្នង និងខេត្តបន្ទាយមានជ័យ ២ខ្នង។

## I-ការលើកស្ទួយវិស័យកសិកម្ម

### ១-ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម

#### ក-ផលិតកម្មដំណាំស្រូវ

ផ្ទៃដីដាំដុះដំណាំស្រូវសម្រេចបានលើផ្ទៃដី ៣លានហិកតានៅឆ្នាំ២០១២ និងបានកើនដល់ ៣,០៩លានហិកតានៅឆ្នាំ២០១៦។ ផលិតកម្មស្រូវបានកើនឡើងពី ៩,២៩លានតោន នៅឆ្នាំ២០១២ ដល់ ៩,៨២លានតោននៅឆ្នាំ២០១៦នេះ (កើនប្រហែល៥,៦%)។ ទិន្នផលស្រូវជាមធ្យមទាំងប្រាំង និងវស្សា បានកើនពី ៣,១១៧តោន/ហិកតា ដល់ ៣,១៨៩តោន/ហិកតា ពីឆ្នាំ២០១២ដល់ឆ្នាំ២០១៦ (កើនប្រមាណជាង ២,២៤%)។

| ឆ្នាំ | បរិយាយ | | | | |
|---|---|---|---|---|---|
| | ផ្ទៃដីដំណាំស្រូវ (លានហិកតា) | | | ទិន្នផល (តោន/ហិកតា) | បរិមាណផល (លានតោន) |
| | ផែនការ | ដាំដុះ | ប្រមូលផល | | |
| ២០១២ | ២,៧៣ | ៣ | ២,៩៨ | ៣,១១៧ | ៩,២៩ |
| ២០១៣ | ២,៧៨ | ៣,០៥ | ២,៩៦ | ៣,១៦៣ | ៩,៣៩ |
| ២០១៤ | ២,៨២ | ៣,០៥ | ៣,០៣ | ៣,០៧៩ | ៩,៣២ |
| ២០១៥ | ២,៩៨ | ២,០៥ | ៣,០២ | ៣,០៨៥ | ៩,៣៣ |
| ២០១៦ | ២,៩១ | ៣,០៩ | ៣,០៨ | ៣,១៨៩ | ៩,៨២ |

គិតត្រឹមឆ្នាំ២០១៦នេះ ផ្ទៃដីប្រមូលផលមាន ៣,០៨លានហិកតា (ស្រូវវស្សាមាន ២,៥៩លានហិកតា និងស្រូវរដូវប្រាំងមាន ០,៤៩លានហិកតា) បរិមាណផលសរុបទទួលបាន ៩,៨២លានតោន

ក្នុងនោះ ស្រូវរដូវវស្សាមាន ៧,៦២លានតោន និងស្រូវរដូវប្រាំងមាន ២,២លានតោន អតិរេកស្រូវមាន ៤,៩៩លានតោន គិតជាអង្ករស្មើនឹង ៣,២លានតោន។

គួរកត់សម្គាល់ថា បច្ចុប្បន្ននេះ ផលិតកម្មដំណាំស្រូវមានការរីកចម្រើនឡើងជាលំដាប់ គឺអាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងក្លាពីរាជរដ្ឋាភិបាលកម្ពុជា ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍នានា អង្គការជាតិនិងអន្តរជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ និងការចូលរួមយ៉ាងសកម្មពីប្រជាកសិករ។

**ខ-ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម**

-ដំណាំរួមផ្សំ ពោត ដំឡូងមី ដំឡូងជ្វា បន្លែ សណ្តែកបាយ កើនឡើងពី ៧៣២ពាន់ហិកតានៅឆ្នាំ២០១២ ដល់ជិត ៩២៦ពាន់ហិកតានៅឆ្នាំ២០១៦។ សន្ទុះនេះបានហក់ឡើងខ្ពស់នៅឆ្នាំ២០១៦ ដែលមានកំណើន ជិត ៩% ធៀបនឹងឆ្នាំ២០១៥ ។

-ដំណាំឧស្សាហកម្មបានធ្លាក់ចុះ ២៦% នៅឆ្នាំ២០១៦ ធៀបនឹងឆ្នាំ២០១៥ ហើយបរិមាណផលបានថយចុះពី ១,៧៦លានតោននៅឆ្នាំ២០១២ មកត្រឹម ០,៨៨លានតោន នៅឆ្នាំ២០១៦។

| បរិយាយ | ផលិតកម្មដំណាំរួមផ្សំ | | ផលិតកម្មដំណាំឧស្សាហកម្ម | |
|---|---|---|---|---|
| | ផ្ទៃដីដាំដុះ (ពាន់ហ.ត) | បរិមាណផល (ពាន់តោន) | ផ្ទៃដីដាំដុះ (ពាន់ហ.ត) | បរិមាណផល (ពាន់តោន) |
| ២០១២ | ៧៣១,៩៥ | ៩ ០៩៩,៤៧ | ១៨០,៩២ | ១ ៧៦០,៣៣ |
| ២០១៣ | ៧៧៥,៣២ | ៩ ៤៣១,៥៣ | ១៦៥,៧២ | ១ ១០៥,២១ |
| ២០១៤ | ៧៧៥,៨២ | ១៣ ០២២,៩៦ | ១៧៧,៧៧ | ១ ៧០៤,៣០ |
| ២០១៥ | ៨៤៩,០៥ | ១៥ ២៩១,៥០ | ១៣៥,០៨ | ៨៥៧,២៦ |
| ២០១៦ | ៩២៥,៧២ | ១៥ ៩០៥,៩២ | ៩៩,៣៤ | ៨៦៧,៥៧ |

**គ-ការនាំចេញផលិតផលកសិកម្ម**

ការនាំចេញផលិតផលកសិកម្មសរុប (៩៨មុខទំនិញកសិផល) មាននិន្នាការកើនឡើងជាលំដាប់ ហើយមានសន្ទុះខ្លាំងក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ដែលនៅឆ្នាំ២០១២ ការនាំចេញផលិតផលកសិកម្មសម្រេចបាន ៦៨០,៤៦ពាន់តោន ហើយកើនដល់ ៣,៦៦លានតោននៅឆ្នាំ២០១៣ ដល់ ៤,១៦លានតោននៅឆ្នាំ២០១៥ និងដល់ ៤,៧លានតោននៅឆ្នាំ២០១៦។ សន្ទុះបានកើនជាង៥ដងនៅឆ្នាំ២០១៣ធៀបនឹងឆ្នាំ២០១២ តែក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះ កំណើនជាមធ្យមប្រចាំឆ្នាំមានជាង១៣%ប៉ុណ្ណោះ។ ដោយឡែក ការនាំចេញផលិតផលកសិកម្មសំខាន់ៗដូចជា ចំណិតដំឡូងមី ដំឡូងមីស្រស់ ម្សៅដំឡូងមី ពោតក្រហម ម្រេច ផ្លែស្វាយស្រស់ និងដូងប្រេងឆៅ មានការកើនឡើងជារៀងរាល់ឆ្នាំតាំងពីឆ្នាំ២០១២ ពិសេសដំឡូងមី ម្រេច និងផ្លែស្វាយស្រស់។ ចំពោះការនាំចេញផលិតផលគ្រាប់ស្វាយចន្ទី សណ្តែកសៀង មានការប្រែប្រួលជារៀងរាល់ឆ្នាំ និងបានធ្លាក់ចុះនៅឆ្នាំ២០១៦។

| ការនាំចេញផ្លូវការនៃផលិតផលកសិកម្មសំខាន់ៗ (គិតជាពាន់តោន) | | | | | |
|---|---|---|---|---|---|
| ផលិតផល | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| អង្ករ | ២០៥,៧១ | ៣៧៨,៨៥ | ៣៨៧,០៦ | ៥៣៨,៣៩ | ៥៤២,១៤ |
| ចំណិតដំឡូងមី | ១២៦,២៣ | ១ ២៦៩,៦៥ | ១ ៤១៩,១៤ | ២ ២៦៦,២៦ | ២ ៨៨៨,៩៣ |
| គ្រាប់ស្វាយចន្ទី | ១២,០៤ | ៨១,២១ | ២៧០,៦៩ | ១០៣,២៥ | ៨៧,៨៥ |
| ពោតក្រហម | ៣២,៨១ | ១៨៤,៧៥ | ១០៦,៦៨ | ៥៦,៤២ | ៧០,៤៨ |
| សណ្ដែកសៀង | ៨,៥១ | ៦៣,៣៦ | ១២៨,៩៤ | ៧១,២៥ | ៣៨,៧០ |
| ម្រេច | ០,១៣ | ០,៧ | ១,១៦ | ០,៦៧ | ១,០៥ |
| ផ្លែស្វាយស្រស់ | | ០,៦ | ០,០៣ | ៩,១២ | ២២,១១ |
| ដូងប្រេងឆៅ | ២១,២០ | ១៩,៨២ | ១២,២១ | ១៧,៣៨ | ១៨,៣៩ |

## ឃ-សហគមន៍កសិកម្ម

ការចងក្រងបង្កើត និងចុះបញ្ជីសហគមន៍កសិកម្ម បានចាប់ផ្ដើមពីឆ្នាំ២០០៣ រហូតដល់ឆ្នាំ២០១៦ មានសហគមន៍ចំនួន ៨៥៧សហគមន៍ មានសមាជិកចំនួន ៨៧ ៩៨៦**នាក់ (ស្រី ៥៣ ១៣៦នាក់ ស្មើនឹង ៦០%)** ដែលមានតម្លៃភាគហ៊ុន **២៤ ៤១២ ០៧៥ ៦៥០រៀល** ដើមទុនសរុប **៣៩ ៣៧៤ ២៥៨ ០៥៨រៀល** ។

ដោយឡែក គិតពីឆ្នាំ២០១២-២០១៦ សហគមន៍កសិកម្មសរុបមានចំនួន ៥៧៩ ត្រូវបានចងក្រងនិងចុះបញ្ជីដែលមានសមាជិកសរុបចំនួន ៥៥ ៤៥៣នាក់ ឬគ្រួសារ ក្នុងនោះ នារីមានចំនួន ៣៤ ០៤០នាក់ តម្លៃភាគហ៊ុន ១៥ ២៥៧ ២៤០ ០០០រៀល និងដើមទុនសរុបចំនួន ២២ ៥៥១ ២៦០ ៣៤០រៀល។

| សហគមន៍កសិកម្មបានបង្កើតក្នុងឆ្នាំ២០១២ ដល់ឆ្នាំ២០១៦ | | | | | |
|---|---|---|---|---|---|
| ឆ្នាំ | ចំនួនសហគមន៍ | សមាជិក (នាក់) | | តម្លៃភាគហ៊ុន (លានរៀល) | ដើមទុន (លានរៀល) |
| | | សរុប | សមាជិកនារី | | |
| ២០១២ | ១៤១ | ១៨ ៦៦៩ | ១១ ៨៣៧ | ៣ ១៨៣,៥២ | ៥ ៦៦០,៧៩ |
| ២០១៣ | ២៤៥ | ២៩ ៣៦៧ | ១៨ ៦៤១ | ៧ ៩៩៤,៩២ | ១២ ២៥០,៩២ |
| ២០១៤ | ៣៣៩ | ៣៩ ៩៩៦ | ២៤ ៩៥១ | ១១ ៧៣៦,១៨ | ១៧ ៨០៨,២៩ |
| ២០១៥ | ៤៧២ | ៤៥ ៥៩៣ | ២៨ ២៩៨ | ១៣ ០៣១,៣៥ | ១៩ ២៦៧,៩៧ |
| ២០១៦ | ៥៧៩ | ៥៥ ៤៥៣ | ៣៤ ០៤០ | ១៥ ២៧៥,២៤ | ២២ ៥៥១,២៦ |

✡ **ការងារស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា** ៖ រាជរដ្ឋាភិបាលបានបញ្ចេញពូជដំណាំចំនួន៧ពូជ បានបញ្ចេញពូជស្រូវចំនួន៦ពូជ (ខា១៤ ខា១៥ ខា១៦ ផ្ការំដួលប្រាំង ដំណើបស្បែមង្គល និង ស្នាច់០២) និងពូជពោតដំណើបចំនួន១ពូជ (ស៊ីអ៊ឹម១) សម្រាប់កសិករប្រើប្រាស់។

## ខ-ការជំរុញចលនាភូមិ១ ផលិតផល១

-រៀបចំគោលនយោបាយជាតិ ស្តីពីការជំរុញចលនាភូមិ១ផលិតផល១ ដែលត្រូវបានរាជរដ្ឋាភិបាលអនុម័តកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦

-សហការជាមួយនឹងគណៈកម្មាធិការជំរុញចលនាភូមិ១ផលិតផល១ រាជធានី ខេត្ត ទាំង ២៥ អគ្គលេខាធិការដ្ឋានភូមិ១ផលិតផល១ បានជ្រើសរើសខេត្តគោលដៅសាកល្បងចំនួន៧ ក្នុងឆ្នាំ២០១៧ ដើម្បីពង្រឹងនិងពង្រីកការងារជំរុញចលនាភូមិ១ផលិតផល១ ក្នុងនោះ មានខេត្តស្វាយរៀង កំពង់ចាម ក្រចេះ កំពត តាកែវ សៀមរាប និងខេត្តឧត្តរមានជ័យ។

-សហការជាមួយនឹងបណ្តាប្រទេសមួយចំនួន ដូចជាប្រទេសចិន ម៉ាឡេស៊ី វៀតណាម និងប្រទេសថៃ ដើម្បីដឹកនាំផលិតករកម្ពុជាទៅចូលរួមក្នុងការតាំងពិព័រណ៍ផលិតផលនៃបណ្តាប្រទេសទាំងនោះ។

## ច-ដំណាំកៅស៊ូ

ផ្ទៃដីកៅស៊ូកម្ពុជាសរុបបានកើនពី ២៨០,៤ពាន់ហិកតានៅឆ្នាំ២០១២ ដល់ ៤៣២,៧ពាន់ហិកតានៅឆ្នាំ២០១៦នេះ (កើនប្រមាណ ៥៤,៣%)។ ផ្ទៃដីកៅស៊ូទាំងនេះត្រូវបានបែងចែកជា ២ផ្នែកគឺ ៖ ផ្ទៃដីកៅស៊ូកសិឧស្សាហកម្ម (ផ្ទៃដីរបស់អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) សរុបមានចំនួន ២៧៨ ២៧១ហិកតា ស្មើនឹង ៦៤,២៩% និងកៅស៊ូគ្រួសារមាន ១៥៤ ៤៥៤ហិកតា ស្មើនឹង ៣៥,៧១% នៃផ្ទៃដីកៅស៊ូសរុបក្នុងឆ្នាំ២០១៦។ ផលិតផលកៅស៊ូកម្ពុជាសរុបបានកើនពី ៦៤,៥ពាន់តោននៅឆ្នាំ២០១២ ដល់ ១៤៥,២ពាន់តោននៅឆ្នាំ២០១៦ (កើនប្រមាណជាង ២,២ដង)។ ផ្ទៃដីដាំកៅស៊ូគ្រួសារបានកើនឡើងពី ១០៧,៦៩ពាន់ហិកតានៅឆ្នាំ២០១២ ដល់ ១៥៤,៤៥ពាន់ហិកតានៅឆ្នាំ២០១៦ (កើនប្រមាណ ៤៣,៤២% ពីចន្លោះឆ្នាំ២០១២ដល់ឆ្នាំ២០១៦។ ចំពោះផលិតកម្មដំណាំកៅស៊ូកសិឧស្សាហកម្មក៏មានការរីកចម្រើនគួរឲ្យកត់សម្គាល់ផងដែរ ពោលគឺបានកើនពី ១៧២,៦៥ពាន់ហិកតានៅឆ្នាំ២០១២ ដល់ ២៧៨,២៧ពាន់ហិកតានៅឆ្នាំ២០១៦ (កើនប្រមាណ៦១% ពីចន្លោះឆ្នាំ២០១២ ដល់ឆ្នាំ២០១៦)។

| ផលិតកម្មដំណាំកៅស៊ូ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ផ្ទៃដីដាំកៅស៊ូសរុប(ពាន់ហិកតា) | ២៨០,៤ | ៣២៨,៨ | ៣៥៧,៨ | ៣៨៩ | ៤៣២,៧ |
| ផ្ទៃដីចៀរជ័រ (ពាន់ហិកតា) | ៥៥,៤ | ៧៨,៥ | ៩០,៥ | ១១១,២ | ១២៧ |
| ផលិតផលកៅស៊ូ (ពាន់តោន) | ៦៤,៥ | ៨៥,៣ | ៩៧,១ | ១២៦,៩ | ១៤៥,២ |

-តាមការប៉ាន់ស្មានរបស់អគ្គនាយកដ្ឋានកៅស៊ូ ការនាំចេញកៅស៊ូឆ្នាំ២០១៦ អាចសម្រេចបានចំនួន ១៤៥,១ពាន់តោន ស្មើនឹងទឹកប្រាក់ជាង ១៨៧លានដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០១៥ មាន ១២៨,០៤ពាន់តោន កើនឡើងចំនួន ១៧ ០៥៣តោន ស្មើនឹង ១១,៧៥% តែចំណូលកើន

ឡើងតិចតួច ដោយសារស្ថានភាពថ្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិបន្តធ្លាក់ចុះយ៉ាងខ្លាំងនៅបីត្រីមាសដើមឆ្នាំ២០១៦ និងកើនឡើងបន្តិចនៅចុងឆ្នាំ។

-កៅស៊ូនាំចេញគិតជាមធ្យមតម្លៃ ១ ២៩០ដុល្លារអាមេរិក/តោន បើធៀបនឹងឆ្នាំ២០១៤ ដែលតម្លៃមធ្យម ១ ៥៣៩ដុល្លារអាមេរិក/តោន គឺថយចុះ ២៤៩ដុល្លារអាមេរិក/តោន ស្មើនឹង ១៩,៣០%។ ប៉ុន្តែបើធៀបនឹងឆ្នាំ២០១៥ ដែលមានតម្លៃមធ្យម ១ ២០៣ដុល្លារអាមេរិក/តោន ឃើញថាមានការកើនឡើងបន្តិច គឺ ៨៧ដុល្លារអាមេរិក/តោន ស្មើនឹង ០៧,២៣%។

## ២-ការចិញ្ចឹមសត្វ និងវារីវប្បកម្ម

### ក-ការចិញ្ចឹមសត្វ

| ប្រភេទសត្វ(ពាន់ក្បាល) | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| សត្វគោ | ៣ ៣៨១ | ៣ ៤៣១ | ៣ ០៦០ | ២ ៩១៧ | ២ ៩២០ |
| សត្វក្របី | ៦៥៧ | ៦១៩ | ៥៤២ | ៥០៦ | ៥២៤ |
| សត្វជ្រូក | ២ ៤៦៥ | ២ ៤៣៧ | ២ ៧៣៦ | ២ ៧៧៦ | ២ ៩៧១ |
| សត្វស្លាប | ២៧ ៣២៣ | ២៧ ៣១៦ | ៣១ ៥៨៤ | ៣៤ ៥១៩ | ៣៥ ៧៣៤ |

ការចិញ្ចឹមគោមានការប្រែប្រួលថយចុះប្រមាណពី៣,៣៨លានក្បាលនាឆ្នាំ២០១២ មកត្រឹមតែ២,៩២លានក្បាលនាឆ្នាំ២០១៦។ រីឯក្របីក៏មានការប្រែប្រួលថយចុះប្រមាណពី៦៥៧ពាន់ក្បាលនាឆ្នាំ២០១២ មកត្រឹមតែ៥២៤ពាន់ក្បាលនាឆ្នាំ២០១៦។ ការថយចុះចំពោះផលិតកម្មចិញ្ចឹមសត្វគោក្របីនេះ គឺជាការថយចុះគោ ក្របីអូសទាញ បណ្ដាលមកពីកសិករកាន់តែច្រើនឡើងៗបោះបង់ការភ្ជួររាស់ដោយគោ ក្របី មកប្រើប្រាស់សេវាគ្រឿងយន្តកសិកម្មជាង៩២% នៃផ្ទៃដីដាំដុះដំណាំស្រូវ។

ការចិញ្ចឹមសត្វស្លាប (ពិសេសមាន់ ទា) មានការកើនឡើងយ៉ាងខ្លាំងរហូតដល់ ៣០% បើប្រៀបធៀបពីឆ្នាំ២០១២និងឆ្នាំ២០១៦។

ដោយមានការអភិវឌ្ឍវិស័យចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វ ក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់ តាមរយៈការអប់រំណែនាំ ផ្សព្វផ្សាយការអនុវត្តល្អប្រសើរលើការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិ បាននិងកំពុងអនុវត្តយ៉ាងសកម្មផុសផុល ដែលមកទល់ឆ្នាំ២០១៥ ឡជីវឧស្ម័នសរុបចំនួនជាង ២៥ពាន់ឡត្រូវបានសាងសង់ឡើង។

### ខ-ការវារីវប្បកម្ម

✡ ការអភិវឌ្ឍសហគមន៍នេសាទ ៖

រហូតមកដល់បច្ចុប្បន្ននេះ ក្រសួងបានបង្កើតសហគមន៍នេសាទសរុបចំនួន ៥១៦ សហគមន៍នៅតាមបណ្ដាខេត្តនានា ដោយមានសមាជិកចូលរួមសរុប ១៤៧ ៥១៨គ្រួសារ ស្មើនឹង ៣៣២ ១៦៨នាក់ ដែលមានទីតាំងក្នុងដែននេសាទទឹកសាបចំនួន ៤៧៥សហគមន៍ និងតំបន់

ឆ្នេរសមុទ្រចំនួន ៤១សហគមន៍ នៅក្នុងដែននេសាទសហគមន៍ រហូតមកដល់បច្ចុប្បន្ននេះ បានបង្កើតតំបន់អភិរក្សបានចំនួន ៤៨៤កន្លែង ដោយមានការបោះបង្គោលព្រំប្រទល់កន្លែងអភិរក្សបានចំនួន ៤ ៩៨៨ដើម និងស្លាកសញ្ញាកន្លែងអភិរក្សបានចំនួន ២៤២ស្លាក សម្រាប់សម្គាល់ទីតាំងកន្លែងអភិរក្សនៃកន្លែងនេសាទសហគមន៍នីមួយៗ ដែលត្រូវការពារ និងគ្រប់គ្រង។

✡ ការងារអភិរក្សជលផល ៖

ក្រោយការរំសាយឡូត៍នេសាទឆ្នាំ២០១២មក មានកន្លែងអភិរក្សដែលបានបង្កើតថ្មីចំនួន ៥០កន្លែង ដែលមានទំហំសរុប ៩៧ ៥៨៣ហិកតា។ បើគិតរួមទាំងកន្លែងអភិរក្សជលផលនៅតាមដែនសហគមន៍នេសាទ និងកន្លែងអភិរក្សសម្រាប់ប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ និងកន្លែងអភិរក្សនៅតាមតំបន់ឆ្នេរ គឺមានរហូតដល់ ៥១៦កន្លែង។ ចាប់ពីឆ្នាំ២០១៣មក យើងបានសាងសង់បង្គោលកំណត់ព្រំប្រទល់កន្លែងអភិរក្សជលផល កម្ពស់៨ម៉ែត្របានចំនួន ១៣៤បង្គោល និងកម្ពស់១២ម៉ែត្របានចំនួន ៥៩បង្គោល ស្នាក់ការល្បាតបណ្តែតទឹកចំនួន ១៧ខ្នង ស្នាក់ការបេតុងចំនួន៨ខ្នង និងស្នាក់ការធំ(សាឡាង)ចំនួន០២។សកម្មភាពអភិរក្សជលផលផ្សេងៗទៀត រួមមាន ៖ អភិរក្សផ្កាថ្ម ស្មៅសមុទ្រចំនួន ៤ ០៥០ហិកតា នៅតាមតំបន់ឆ្នេរ ដាំព្រៃលិចទឹកនិងព្រៃកោងកាងបានចំនួន ២ ២៧០ហិកតា បោះបង្គោលកំណត់ព្រំប្រទល់ព្រៃកោងកាងបានចំនួន ១០៩បង្គោល រៀបចំអន្លង់ត្រីមេពូជ បានចំនួន ៩៧កន្លែងនៅតំបន់មេគង្គលើក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។

| ស្ថានភាពការបង្ក្រាបបទល្មើសជលផល | | | | | |
|---|---|---|---|---|---|
| **បរិយាយ** | **២០១២** | **២០១៣** | **២០១៤** | **២០១៥** | **២០១៦** |
| ពិន័យអន្តរការណ៍(ករណី) | ២០៦ | ២២៥ | ៤០៨ | ៤១៨ | ៣៨៥ |
| បញ្ជូនទៅតុលាការ(ករណី) | ១៦៣ | ៩៦ | ១១៨ | ១៨១ | ១៦៩ |
| បំផ្លាញវត្ថុតាង(ករណី) | ៤ ៩៣៨ | ៣ ៥០៥ | ៣ ១៦០ | ៣ ៣៧៥ | ៣ ០៩៦ |
| សរុប | ៥ ៣០៧ | ៣ ៨២៦ | ៣ ៦៨៦ | ៣ ៩៧៤ | ៣ ៦៥០ |
| ទោសជាប់ពន្ធនាគារ(នាក់) | ១៤២ | ១៣៣ | ១៥២ | ៨៥ | ១០១ |

| ស្ថានភាពការអភិវឌ្ឍវារីវប្បកម្ម | | | | | |
|---|---|---|---|---|---|
| **បរិយាយ** | **២០១២** | **២០១៣** | **២០១៤** | **២០១៥** | **២០១៦** |
| ផលវារីវប្បកម្ម(តោន) | ៧៤ ០០០ | ៩០ ០០០ | ១២០ ០៥៥ | ១៤៣ ១៤១ | ១៧២ ៥០០ |
| ក្រពើចិញ្ចឹម (ក្បាល) | ២៥០ ០០០ | ៣២០ ០០០ | ២១៥ ៥០០ | ២៩៨ ៦៦៩ | ៣០៧ ០០០ |
| កូនត្រីពូជ(ពាន់ក្បាល) | ១៤០ ០០០ | ១៥០ ០០០ | ១២០ ០០០ | ១៨០ ៥០០ | ១៩៤ ០០០ |

-វឌ្ឍនភាពផ្នែកផលផល សម្រេចបាន ៖

| ផលនេសាទទឹកសាប សមុទ្រ និងវារីវប្បកម្ម (តោន) | | | | | |
|---|---|---|---|---|---|
| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| ផលនេសាទទឹកសាប | ៥០៩ ០០០ | ៥២៨ ០០០ | ៥០៥ ០០៥ | ៤៨៧ ៩០៥ | ៥០៩ ៣៥០ |
| ផលនេសាទសមុទ្រ | ៩៩ ០០០ | ១១០ ០០០ | ១២០ ២៥០ | ១២០ ៥០០ | ១២០ ៦០០ |
| ផលវារីវប្បកម្ម | ៧៤ ០០០ | ៩០ ០០០ | ១២០ ០៥៥ | ១៤៣ ១៤១ | ១៧២ ៥០០ |
| សរុប | ៦៨២ ០០០ | ៧២៨ ០០០ | ៧៤៥ ៣១០ | ៧៥១ ៥៤៦ | ៨០២ ៤៥០ |

## ៣-ការកែទម្រង់ដីធ្លី និងការបោសសំអាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

### ៣.១-ការកែទម្រង់ដីធ្លី

#### ៣.១.១-លទ្ធផលការងាររបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(អ.ជ.ដ)

| បរិយាយ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|
| ទទួលបណ្តឹង | ១០១ | ៨២ | ៨៥ | ៨៦ |
| ដោះស្រាយរួច | ៤២ | ៤២ | ២២ | ៣៨ |
| កំពុងបន្តដោះស្រាយបណ្តឹងចាស់ និងថ្មី | ១៤៥ | ១៥១ | ១៥០ | ១៣៨ |

#### ៣.១.២-ការចុះបញ្ជីដីធ្លី

| បរិយាយ | ការចុះបញ្ជីដី លក្ខណៈជាប្រព័ន្ធ | ការចុះបញ្ជីដី លក្ខណៈដាច់ដោយដុំ | ការចុះបញ្ជីដីសហគមន៍ ជនជាតិដើមភាគតិច | សរុបតាមឆ្នាំ |
|---|---|---|---|---|
| ២០១២ | ២២០ ៩៧០ | ២ ៣១១ | ១០១ (៣សហគមន៍) | ២២២ ៩៨២ |
| ២០១៣ | ៥០៧ ២៤៣ | ២ ១៥១ | ១៨២ (៥សហគមន៍) | ៥០៩ ៥៧៦ |
| ២០១៤ | ៥៣៦ ៩១១ | ១ ២៧៦ | ០ | ៥៣៨ ១៨៧ |
| ២០១៥ | ៣០៧ ១៦៨ | ១ ៦៩៦ | ១១៦ (៣សហគមន៍) | ៣០៩ ០៣០ |
| ២០១៦ | ៣១៣ ២៩១ | ២ ៦១៤ | ៦០ (៣សហគមន៍) | ៣១៥ ៩៦៥ |
| សរុប | ១ ៨៨៥ ១៨៣ | ១០ ០៤៨ | ៤៥៩ (១៤សហគមន៍) | ១ ៨៩៥ ៦៩០ |

លទ្ធផលសរុបនៃការចុះបញ្ជីដីធ្លី គិតចាប់ពីពេលចាប់ផ្តើមមកដល់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦នេះ សម្រេចចែកបណ្ណដល់ដៃប្រជាពលរដ្ឋបានចំនួន ៤ ៤៥១ ៨១៧បណ្ណ(ស្មើនឹង ៦៣,៦% នៃក្បាលដីប៉ាន់ស្មាន ៧លានក្បាលដី)។ ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចសម្រេចបាន ១៤សហគមន៍ ស្មើនឹង ៤៥៩បណ្ណ ទំហំ ១២ ៣៥៧,៧៩ហិកតា ស្មើនឹង ១ ៤៧៨គ្រួសារ។

### ៣.១.៣-ការដោះស្រាយទំនាស់ដីធ្លីជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ការដោះស្រាយចប់នីតិវិធីដោយយន្តការគណៈកម្មាធិការសុរិយោដី និងក្រុមដោះស្រាយវិវាទ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៖

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប |
|---|---|---|---|---|---|---|
| ករណីទទួលបាន | ១០៥ | ៥០៧ | ៤០០ | ៦៨៥ | ៤៣៣ | ២ ១៣០ |
| ដោះស្រាយបញ្ចប់ | ១៦៣ | ២២០ | ៣៣០ | ៣៧៦ | ២៧៩ | ១ ៣៦៨ |
| ច្រានចោល | ៧៨ | ៨៥ | ២៤៨ | ១៩២ | ១៣២ | ៧៣៥ |
| ដកបណ្តឹង | ៧១ | ៥៤ | ៦២ | ៦៩ | ៨០ | ៣៣៦ |

លទ្ធផលសរុបនៃការដោះស្រាយគិតចាប់ពីពេលចាប់ផ្តើមមកដល់ត្រឹមថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០១៦នេះ ទទួលបណ្តឹង ៧ ៦៧៦ករណី ក្នុងនោះ ដោះស្រាយបញ្ចប់ ៣ ៦១៤ករណី ច្រានចោល ២ ៥៧៥ករណី និងដកបណ្តឹង ៨១៨ករណី។

### ៣.១.៤-ការបែងចែកដីក្នុងគោលដៅសម្បទានដីសង្គមកិច្ច និងប្រទានកម្ម

-សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ សម្រេចបានប្រមាណ ១ ៣២៤គ្រួសារ។

-សម្បទានដីសង្គមកិច្ចជូនយោធិន និងគ្រួសារ ដែលកំពុងឈរជើងការពារតំបន់ព្រំដែនទិសខាងលិច និងខាងជើង សម្រេចបានប្រមាណ ៦ ១០៦គ្រួសារ។

-សម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅតាមគ្រប់រូបភាព សម្រេចបានប្រមាណ ៧ ៦៤៤គ្រួសារ។

-គម្រោងបែងចែកដីសម្បទានសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ច ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការជាតិ អន្តរជាតិ សម្រេចបានប្រមាណជិត ២ ៦៨១គ្រួសារ។

-រាជរដ្ឋាភិបាល បានចេញបទបញ្ជាលេខ ០១បប ស្តីពីវិធានការពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ០៧ ខែឧសភា ឆ្នាំ២០១២ ជាអាទិ៍ ផ្អាកជាបណ្តោះអាសន្ន នូវការផ្តល់ដីសម្បទានសេដ្ឋកិច្ច និងការដាក់ចេញនូវវិធានការមួយចំនួនដើម្បីផ្តល់ផលប្រយោជន៍ពិតប្រាកដជូនដល់ប្រទេសជាតិ និងប្រជាជនប្រកបដោយចីរភាព។

### ៣.១.៥-ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យសំណង់

| បរិយាយ | ចំនួនគម្រោង | ផ្ទៃក្រឡាសំណង់ (ម$^2$) | តម្លៃប៉ាន់ស្មាន (ដុល្លារអាមេរិក) | ប្រៀបធៀបទុនវិនិយោគ (%) |
|---|---|---|---|---|
| ២០១២ | ១ ៦៩៤ | ៦ ៥២៨ ៤៥២ | ២ ១០៩ ៦០៧ ២៤២ | |
| ២០១៣ | ១ ៦៤១ | ៧ ៥៩៦ ១៥១ | ២ ៧៧៣ ១២៦ ៥៥៩ | + ៣១,៤៥% |

| | | | | |
|---|---|---|---|---|
| ២០១៤ | ១ ៩៦០ | ៦ ៨៦០ ១៤៨ | ២ ៥០៧ ១៩៤ ៨៣០ | -៩,៥៨% |
| ២០១៥ | ២ ៣០៥ | ៧ ៦៨៦ ១១២ | ៣ ៣៣៨ ១០៧ ២១៨ | +៣៣,១៤% |
| ២០១៦ | ២ ៦៣៥ | ១២ ១៥៨ ២៦៨ | ៥ ៥៧៩ ៧០៩ ៩៨៩ | +៦៧,១៥% |

សម្គាល់ ៖ ទុនវិនិយោគប្រចាំឆ្នាំ២០១៦ គឺមិនបានបញ្ចូលទុនវិនិយោគអគារពហុមុខងារ ១៣៣ជាន់ទេ។

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានផ្តល់លិខិតអនុញ្ញាតសាងសង់ និងការគ្រប់គ្រងការដ្ឋានសំណង់ គឺបានបែងចែកតាមឋានានុក្រមដូចតទៅ៖ក/-សំណង់មានទំហំផ្ទៃក្រឡាកម្រាលក្រោម ៥០០ម² ត្រូវស្ថិតក្រោមសមត្ថកិច្ចរដ្ឋបាលស្រុក ខណ្ឌ សម្រាប់លំនៅស្ថាន ខ/-សំណង់មានទំហំក្រឡា កម្រាលចាប់ពី ៥០០ម² ដល់ ៣០០០ម² ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត និង គ/-សំណង់មានទំហំផ្ទៃក្រឡាកម្រាលលើសពី ៣ ០០០ម² ត្រូវស្ថិតក្រោមសមត្ថកិច្ចថ្នាក់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

❖❖❖ គិតមកដល់ឆ្នាំ២០១៦នេះ **សហគ្រាស និងក្រុមហ៊ុនសាងសង់** និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ទាំងក្នុងស្រុក និងបរទេស ៖

| បរិយាយ | សហគ្រាសក្រុមហ៊ុន | ចំនួនក្រុមហ៊ុន | ប្រភេទ៣ | ប្រភេទ២ | ប្រភេទ១ | សរុបរួម |
|---|---|---|---|---|---|---|
| ២០១២ | ក្រុមហ៊ុនសាងសង់ | ១៨៨ | ១៤១ | ២៥ | ២២ | ១៩៣ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ៥ | ៤ | ០ | ១ | |
| ២០១៣ | ក្រុមហ៊ុនសាងសង់ | ២០៨ | ១៤១ | ៤១ | ២៦ | ២១២ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ៤ | ២ | ០ | ២ | |
| ២០១៤ | ក្រុមហ៊ុនសាងសង់ | ២៤៨ | ១៦៩ | ៣៩ | ៤០ | ២៦២ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ១៤ | ៩ | ១ | ៤ | |
| ២០១៥ | ក្រុមហ៊ុនសាងសង់ | ២៧៨ | ២១៥ | ២២ | ៤១ | ២៨៧ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ៩ | ៦ | ១ | ២ | |
| ២០១៦ | ក្រុមហ៊ុនសាងសង់ | ៣៥០ | ២៦៧ | ៣៥ | ៤៨ | ៣៦៩ |
| | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ១៩ | ១២ | ១ | ៦ | |

### ៣.១.៦-និន្នន័យអគារស្នាក់នៅរួម និងបុរី

| ចំនួនគម្រោង | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប |
|---|---|---|---|---|---|---|
| អគារស្នាក់នៅរួម | ១៧ | ២៦ | ៣៣ | ៤៨ | ៧៣ | ១៩៧ |
| បុរីលំនៅស្ថាន និងលំនៅស្ថានមានលក្ខណៈបុរី | | ៧៤ | ១៧ | ៣១ | ១៧ | ១៣៩ |

## ៣.១.៧-ចំណូលពីសេវា

ឯកសារ ៖ (រៀល)

| ចំណូល | សេវាសុរិយោដី | សេវាសំណង់ | ការជួលទីតាំងរោងចក្រ | ការផ្ទេរអេលចនវត្ថុ |
|---|---|---|---|---|
| ២០១២ | ៤ ៣៦១ ៧៤៣ ៥០០ | ៧២៧ ៣៩២ ១០០ | ២៧១ ២៨០ ០០០ | ១០៦ ៨១០ ៩៨៨ ២៣៦ |
| ២០១៣ | ១៥ ៣៤៥ ៩៨៦ ៥២២ | ៤ ៨៦២ ៩៣៦ ៣០៤ | ២៦៥ ៥៩៦ ១១០ | ១៤៨ ៦៩៥ ៧២៨ ១៣៦ |
| ២០១៤ | ២៥ ៩៨៤ ៨១០ ៦៧៥ | ៨ ២៥៨ ៦៤៦ ៨០០ | ២៦៥ ៦៧០ ៧៣០ | ២៣៧ ២១០ ៤៥៥ ៩៣៥ |
| ២០១៥ | ៣២ ៤០៩ ៦៦០ ៧៨៩ | ៨ ៣៣១ ២៥៩ ៨០០ | ២៦៩ ៦០៤ ៥៥៥ | ៣២០ ៧៣៤ ២៥២ ៤៤៨ |
| ២០១៦ | ៣២ ២១៣ ៦០៩ ០៩៣ | ១១ ៦៨៧ ៤១២ ៦០០ | ២៧២ ២៣៤ ០៦០ | ២៤២ ៨១៦ ៦៥៣ ៨៦៧ |
| សរុប | ១១០ ៣១៥ ៨១០ ៥៧៩ | ៣៣ ៨៦៧ ៦៥០ ៦០៤ | ១ ៣៤៤ ៣៨៥ ៤៥៥ | ៨៣៨ ២៦៨ ០៧៨ ៦២២ |

## ៣.២-ការបោសសំអាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| មីនប្រឆាំងមនុស្ស(គ្រាប់) | ២៦ ៧៦៨ | ១៩ ៥៥០ | ២១ ៥៥៤ | ១៦ ៤៧២ | ១៣ ០៤៩ |
| មីនប្រឆាំងរថក្រោះ (គ្រាប់) | ៩១០ | ៥៣១ | ៤៣៨ | ៣៦០ | ៣៥៧ |
| សំណល់ជាតិផ្ទុះ (គ្រាប់) | ១០២ ៩៤៦ | ១១៨ ៧៥០ | ១០៩ ៨៤៣ | ៦៥ ៩១៣ | ៤៦ ៣៧៦ |
| ផ្ទៃដីសម្រេចបាន (ម$^{២}$) | ១៣២ ៩០១ ៥៣៩ | ៧៥ ៧៧៧ ៤៥៩ | ១៨០ ៧៦៥ ៥៣៦ | ១៨៥ ៣០៤ ៩៨០ | ១៣២ ២៨៤ ១១៦ |
| ជនរងគ្រោះដោយសារមីន (នាក់) | ១៨៥ (ស្លាប់៤៣ របួស ១៤២) | ១១១ (ស្លាប់២២ របួស៨៩) | ១៥៤ (ស្លាប់២១ របួស១៣៣) | ១១១ (ស្លាប់១៨ របួស៩៣) | ៨៣ (ស្លាប់២៥ របួស៥៨) |

# ៤-ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

## ក.កិច្ចគាំពារបរិស្ថាន

-បានផ្ទេរមុខងារ និងវិភាជន៍ថវិកា ទៅឱ្យរដ្ឋបាលក្រុងគោលដៅទាំង២៦ សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ នៅតាមទីប្រជុំជនទូទាំងព្រះរាជាណាចក្រកម្ពុជា។

-បានពង្រឹងប្រសិទ្ធភាពការតាមដាន និងត្រួតពិនិត្យគុណភាពបរិស្ថាន (ទឹក ដី និងខ្យល់) ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃពីស្ថានភាពបំពុលបរិស្ថាន និងដាក់ចេញនូវវិធានបង្ការជាមុនក្នុងគោលដៅធានាសុវត្ថិភាព សុខភាពសាធារណៈ និងគុណភាពបរិស្ថាន។

-បានតម្រូវឱ្យរាល់គម្រោងអភិវឌ្ឍន៍ទាំងឯកជន និងសាធារណៈរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងពន្លឿនការពិនិត្យផ្តល់យោបល់លើរបាយការណ៍ ដែលដាក់ស្នើដោយម្ចាស់គម្រោង។

## ខ.ការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍មូលដ្ឋាន

-បានអនុវត្តបទបញ្ជាលេខ០១បប ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាល ក្នុងការចុះវាស់វែង ធ្វៀលដីក្នុងតំបន់ការពារធម្មជាតិទាំង ២៣កន្លែង ជូនប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ទាំងនោះ

-បានត្រួតពិនិត្យវាយតម្លៃគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច ដោយបាននិរាករណ៍គម្រោងវិនិយោគអភិវឌ្ឍន៍ចំនួន២៧ បានកាត់បន្ថយរយៈពេលជួលពី ៩៩ឆ្នាំ ឬ ៧០ឆ្នាំ មកនៅត្រឹម ៥០ឆ្នាំ

-បានផ្ទេរគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចដំណាំកសិឧស្សាហកម្ម ចំនួន ៧៣ កន្លែង ទៅឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីគ្រប់គ្រងបន្ត ចំណែកតំបន់ព្រៃការពារ តំបន់អភិរក្សព្រៃឈើ និងព្រៃផ្តល់ផលចំនួន ១៨កន្លែង ត្រូវបានផ្ទេរមកក្រសួងបរិស្ថានគ្រប់គ្រងវិញ

-បានបង្កើនផ្ទៃដីតំបន់ការពារធម្មជាតិបន្ថែមលើតំបន់ដែលមានស្រាប់ទាំង ៤៥កន្លែង ដោយបានបង្កើតរបៀងអភិរក្សជីវចម្រុះ ដែលក្នុងនោះផ្ទៃដីសរុបនឹងកើនដល់ប្រមាណជាង៧,៣លានហិកតា

-បានកំណត់ព្រំ និងបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិចំនួន ១ ៧០៤បង្គោល និងបានរៀបចំផែនការ និងកំណត់តំបន់គ្រប់គ្រងបានចំនួន ០៤តំបន់

-បានបញ្ចូលមន្ត្រីជាប់កិច្ចសន្យាជាឧទ្យានុរក្សចំនួន ៩៥៧នាក់ ជាមន្ត្រីក្របខណ្ឌសាធារណៈ សម្រាប់ឆ្នាំ២០១៦ និងបានជ្រើសរើសមន្ត្រីឧទ្យានុរក្ស ចំនួន ៣០០នាក់បន្ថែមទៀតក្នុងឆ្នាំ២០១៧

-បានបង្ក្រាប ទប់ស្កាត់ និងបញ្ឈប់ទាំងស្រុងនូវបទល្មើសព្រៃឈើទ្រង់ទ្រាយធំក្នុងតំបន់ការពារធម្មជាតិ ដោយគណៈកម្មការជាតិដើម្បីទប់ស្កាត់បទល្មើសព្រៃឈើ និងបានរឹបអូសឈើចំនួន ៧០ ៩៨៣ ម៣

-បានបង្កើតសហគមន៍តំបន់ការពារធម្មជាតិ សរុបចំនួន ១៣៣សហគមន៍ ដែលមានប្រជាពលរដ្ឋសរុបចំនួន ៣២ ០២៨គ្រួសារ រស់នៅក្នុងភូមិ ២៤៣ភូមិ លើផ្ទៃដី ១៩៣ពាន់ហិកតា និងបានលើកកម្ពស់ជីវភាពសហគមន៍ តាមរយៈការបង្កើតជម្រើសមុខរបរថ្មីក្នុងវិស័យកសិកម្ម និងចិញ្ចឹមសត្វ ការកែច្នៃផលនិងអនុផលព្រៃឈើ ជំនួសឱ្យការពឹងអាស្រ័យទាំងស្រុងលើធនធានធម្មជាតិ

-បានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិជាប្រចាំ ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តគម្រោង ក៏ដូចជាការកាត់បន្ថយបញ្ហាទំនាស់ដីធ្លី។ ជាក់ស្តែង ការចុះបញ្ជីដីរដ្ឋ សម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិចំនួន០៦ ត្រូវបានបញ្ចប់ និងគម្រោង០៩ទៀត កំពុងដំណើរការ។

## គ-ការងារអប់រំ និងព័ត៌មានបរិស្ថាន

-បានអនុវត្តការងារអប់រំបរិស្ថានក្នុងប្រព័ន្ធ ដោយបានបញ្ចូលការអប់រំបរិស្ថានទៅក្នុងកម្មវិធីគ្រប់ភូមិសិក្សា ជំរុញការអនុវត្ត « កម្មវិធីសាលាមេត្រីបរិស្ថាន » កសាងសមត្ថភាពគ្រូនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា បណ្តុះបណ្តាលក្រុមអ្នកនិពន្ធសៀវភៅសិក្សាគោល និងបញ្ជ្រាបការអប់រំបរិស្ថាន ដើម្បីការអភិវឌ្ឍដោយចីរភាពទៅក្នុងកម្មវិធីបង្រៀនរបស់វិទ្យាស្ថានជាតិអប់រំ

-បានអនុវត្តការងារអប់រំបរិស្ថានក្រៅប្រព័ន្ធ ដោយបានរៀបចំយុទ្ធនាការបរិស្ថាន ពង្រឹង និងពង្រីកការផ្សព្វផ្សាយព័ត៌មានបរិស្ថានតាមគ្រប់មធ្យោបាយ និងគ្រប់រូបភាព ដូចជា វិទ្យុ ទូរទស្សន៍ បណ្តាញទំនាក់ទំនងសង្គម គេហទំព័រ www.moe.gov.kh យូធូប បណ្ណាល័យអេឡិចត្រូនិក។ល។

-បានធ្វើប្រតិភូកម្មមុខងារអប់រំ និងផ្សព្វផ្សាយព័ត៌មានបរិស្ថានទៅឱ្យរដ្ឋបាលរាជធានី ខេត្តទាំង២៥

-បានធ្វើបច្ចុប្បន្នភាពផែនទីតំបន់ការពារធម្មជាតិទូទាំងប្រទេសដែលក្នុងនោះ បានបញ្ចូលផែនទីតំបន់ការពារធនធានធម្មជាតិថ្មីចំនួន៨តំបន់ និងរៀបចំឡើងវិញនូវផែនទីតំបន់ការពារធម្មជាតិចំនួន១៣តំបន់ ដែលបានផ្ទេរពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកសាងផែនទីរបៀងអភិរក្សជីវចម្រុះ ។

### ឃ-ការកែទម្រង់ព្រៃឈើ

| លទ្ធផលសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងវិស័យព្រៃឈើ | | | | | |
|---|---|---|---|---|---|
| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| ចំណូលពីព្រៃឈើ(លានរៀល) | ៣៩ ៧៣៥ | ៧៧ ៤៤១ | ៧០ ០៦៣ | ៣២ ២៦៣ | ២៣ ៦៥០ |
| ការដាំដើមឈើ (ហ.ត) | ១៦ ៧៦៥ | ១៧ ៩៣២ | ៥ ៨៨៣ | ៤ ៦៨០ | ២ ៥០៨ |
| ការនាំចូលឈើ(ម៣) | ១ ០០០ | ៥០០ | ១ ៣០០ | ១ ៥៧៤ | ១ ៤២៩ |
| ការនាំចេញឈើ(ម៣) | ១៦ ១៩៣ | ៣៩ ៧៤៣ | ៧៥ ២៩២ | ២១ ៦៥៥ | ១៥ ៨៦៨ |
| ការបង្ក្រាបបទល្មើសព្រៃឈើ (ករណី) | ១ ០៩៩ | ១ ៥២៣ | ២ ៤០០ | ២ ១៨៩ | ១ ៤៩០ |
| សហគមន៍ព្រៃឈើ | | | | | |
| សហគមន៍ព្រៃឈើ បានអនុម័ត | ២៩១ | ៣៤៥ | ៣៦៤ | ៤០៤ | ៤០៤ |
| សហគមន៍ព្រៃឈើសរុប | ៤៥៥ | ៤៥៧ | ៤៨៥ | ៤៩៩ | ៥៨០ |

- រាជរដ្ឋាភិបាលបានធ្វើការកែទម្រង់ធំមួយទៀតក្នុងវិស័យព្រៃឈើ ដោយបានសម្រេចផ្ទេរផ្ទៃដីព្រៃការពារចំនួន ១៣កន្លែង ស្មើនឹង ១ ៦៨៤ ៧៥៥ហិកតា និងផ្ទៃដីព្រៃដែលរដ្ឋបាលព្រៃឈើកំពុងដំណើរការរៀបចំដាក់ជាព្រៃការពារ៥កន្លែងទៀតមានទំហំ ៩៥១ ៣២៥ហិកតា ដែលនាំឱ្យផ្ទៃដីដែលត្រូវផ្ទេរសមត្ថកិច្ចនេះមានទំហំសរុប ២ ៦៣៦ ០៨០ហិកតា ផ្ទេរការគ្រប់គ្រងពីរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនក្រសួងបរិស្ថានគ្រប់គ្រងបន្ត ហើយក្រសួងបរិស្ថានបានផ្ទេរត្រឡប់មកវិញនូវដីសម្បទានសេដ្ឋកិច្ចក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទគ្រប់គ្រងវិញ។
- រាជរដ្ឋាភិបាលបានចេញសេចក្តីសម្រេចលេខ០៩ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចេញប្រកាសលេខ ៦៥២ប្រក.កសក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីការផ្ទេរធនធាន និងក្របខណ្ឌមន្ត្រីរាជការស៊ីវិល នៃខណ្ឌ ផ្នែក សង្កាត់ រដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។

## II- ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

### ១-ការបន្តស្ថារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍

ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន មកទល់នឹងដំណាច់ឆ្នាំ ២០១៦ នេះ ៖

#### ១.១-ផ្លូវ និងការគ្រប់គ្រងយានយន្តតាមផ្លូវគោក

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ផ្លូវជាតិ និងផ្លូវខេត្ត (ឯកតា ៖ គិតជា គ.ម) | | | | | |
| ផ្លូវជាតិ១ខ្ទង់(៩ខ្សែ) | ២ ២៦៣ | ២ ២៤៣ | ២ ២៤៣ | ២ ២៤៣ | ២ ២៥៣ |
| ផ្លូវជាតិ២ខ្ទង់ | ៣ ៣៦០ | ៣ ៣៧៨ | ៨ ៦៦៤ | ៨ ៦៦៤ | ៥ ០០៧ |
| ផ្លូវខេត្ត៣ខ្ទង់ និង៤ខ្ទង់ | ៦ ៦៤១ | ៦ ៦១៧ | ៤ ៤០៧ | ៤ ៥៩៤ | ៨ ១១៤ |
| **សរុបផ្លូវជាតិ និងផ្លូវខេត្ត** | **១២ ២៥៧** | **១២ ២៣៩** | **១៥ ៣១៥** | **១៥ ៥០២** | **១៥ ៣៧៦** |
| ផ្លូវជាតិដែលបានស្តារ ដោយក្រាលកៅស៊ូ និងបេតុង ផ្លូវ១ខ្ទង់ និង២ខ្ទង់ | ៤ ៣៦៧ | ៤ ៤០៨ | ៥ ៥១៣ | ៥ ៧៧៤ | ៥ ២៦២ |
| ផ្លូវដែលបានស្តារដោយក្រាលកៅស៊ូនិងបេតុងផ្លូវ ១ខ្ទង់ ២ខ្ទង់ ៣ខ្ទង់ និង៤ខ្ទង់ | ៥ ៤៧៤ | ៥ ៦១៩ | ៥ ៩៥៩ | ៦ ៥២១ | ៦ ៩០១ |
| ការងារចុះបញ្ជីយានយន្ត (គ្រឿង) | | | | | |
| រថយន្តគ្រប់ប្រភេទ | ៣៧ ៦៥៨ | ៣៧ ១៦៦ | ៤១ ០៦៩ | ៥៦ ៤២៦ | ៥៣ ៣៤៩ |
| ម៉ូតូ | ២៣៣ ៤៩៧ | ២៤៤ ៩៧១ | ៣០៣ ១៨០ | ៣៤២ ០៧៦ | ៤០៦ ២៤៨ |
| **សរុប** | **២៧១ ១៥៥** | **២៨២ ១៣៧** | **៣៤៤ ២៤៩** | **៣៩៨ ៥០២** | **៤៥៩ ៥៩៧** |

| ការចុះបញ្ជីចំនួនយានយន្តពីឆ្នាំ១៩៩០-ឆ្នាំ នីមួយៗ (គ្រឿង) | | | |
|---|---|---|---|
| | រថយន្ត | ម៉ូតូ | សរុប |
| ១៩៩០-២០១២ | | | ២ ១៧៤ ៩៣៥ |
| ១៩៩០-២០១៣ | | | ២ ៤៥៧ ១០៨ |
| ១៩៩០-២០១៤ | ៤៥១ ២៦៧ | ២ ០៧៣ ១៥៣ | ២ ៥២៤ ៤២៥ |
| ១៩៩០-២០១៥ | ៤៨៤ ១១០ | ២ ៧២៦ ១១៣ | ៣ ២១០ ២២៣ |
| ១៩៩០-២០១៦ | ៥៣៧ ៤៥៩ | ៣ ១៣២ ៣៦១ | ៣ ៦៦៩ ៨២០ |

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ការប្រឡងយកបណ្ណបើកបរ (គ្រឿង) | | | | | |
| រថយន្តគ្រប់ប្រភេទ | ៦២ ៧១៩ | ៦១ ៩៧៥ | ៦១ ១៣៨ | ៩២ ៥២០ | ១២៩ ០៣១ |
| ម៉ូតូ | ៨ ៦៤៥ | ៣ ៧២៦ | ៤ ២១២ | ៥ ០៦៧ | ៤ ៧៣៥ |
| **សរុប** | **៧១ ៣៦៤** | **៦៥ ៧០១** | **៦៥ ៣៥០** | **៩៧ ៥៨៧** | **១៣៣ ៧៦៦** |

| ស្ថានភាពគ្រោះថ្នាក់ចរាចរណ៍ (ផ្លូវគោក) | | | | | |
|---|---|---|---|---|---|
| ចំនួនគ្រោះថ្នាក់(លើក) | ៤ ៣០៥ | ៤ ៣៥៣ | ៤ ៨២៦ | ៤ ៥៩៥ | ៣ ៣៣៨ |
| ស្លាប់ (នាក់) | ១ ៨៩៤ | ១ ៩៥០ | ២ ១៩៥ | ២ ២៦៤ | ១ ៥៧៦ |
| របួសស្រាល(នាក់) | ៣ ០៧៩ | ៨ ១០៩ | ៣ ៣៤៣ | ៣ ១៩៦ | ២ ២៤៤ |
| របួសធ្ងន់(នាក់) | ៤ ៣៨៨ | ៥ ៦៧១ | ៤ ៥៨០ | ៤ ៤៣៨ | ៣ ៥១៧ |
| អត្រាស្លាប់ក្នុងយានយន្ត ១០០០០គ្រឿង (នាក់) | ៨,៧០ | ៧,៩០ | ៧,៨០ | ៧,៨០ | ៤,២០ |
| អត្រាស្លាប់ក្នុងប្រជាជន ១០០០០០នាក់ | ១៣,១០ | ១៣,០០ | ១៤,៤០ | ១៤,៤០ | ១០,០៨ |

## ១.២-ការដឹកជញ្ជូន និងអាជីវកម្មតាមផ្លូវទឹក និងផ្លូវអាកាស

### ក-ការដឹកជញ្ជូន និងអាជីវកម្មតាមផ្លូវទឹក

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ✡ការងារអាជីវកម្ម និងហិរញ្ញវត្ថុនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ | | | | | |
| ទំនិញឆ្លងកាត់ផែ (ពាន់តោន) | ២ ៦៥៩ | ៣ ០១២ | ៣ ៤២៣ | ៣ ៧៦៣ | ៣ ៩៣០ |
| នាវាឆ្លងកាត់ (គ្រឿង) | ៩៤១ | ៩៨៨ | ១ ១០៣ | ១ ២៩២ | ១ ៣០០ |
| កុងតែន័រឆ្លងកាត់ (ពាន់TEU) | ២៥៥ ៣៧៨ | ២៨៦ ៤៥០ | ៣៣៣ ៩០៤ | ៣៩១ ៨១៩ | ៣៩៩ ១៩២ |
| ចំណូលអាជីវកម្ម ( ពាន់ដុល្លារអាមេរិក) | ៣៥ ៤៥៧ | ៣៩ ០៥០ | ៤៤ ៦២៣ | ៥២ ១៣៥ | ៥៣ ៩០២ |
| ✡ការងារអាជីវកម្ម និងហិរញ្ញវត្ថុនៅកំពង់ផែស្វយ័តភ្នំពេញ | | | | | |
| ទំនិញឆ្លងកាត់ផែ (ពាន់តោន) | ១ ៥៣៤ | ១ ៤០៤ | ១ ៦២៧ | ១ ៨៦២ | ២ ៤៣៤ |
| នាវាឆ្លងកាត់ (គ្រឿង) | ១ ៤៨១ | ១ ៤៤៥ | ១ ៤៦២ | ១ ៥៤១ | ១ ៦៥៥ |
| កុងតែន័រឆ្លងកាត់ (ពាន់TEU) | ៩៥ ៣៣៣ | ១១០ ៥០០ | ១៣៣ ៦៦៦ | ១៤៤ ៨១៣ | ១៥០ ០០០ |
| ចំណូលអាជីវកម្ម ( ពាន់ដុល្លារអាមេរិក) | ១០ ៥២៧ | ១១ ១០៩ | ១៣ ៦៩៨ | ១៥ ៧៣០ | ១៦ ៩៥៣ |

### ខ-ការដឹកជញ្ជូន និងអាជីវកម្មតាមផ្លូវអាកាស

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ការហោះហើរ ចុះចត ក្នុងប្រទេស អន្តរជាតិ និងការហោះហើរឆ្លងកាត់ (ជើង) | | | | | |
| ក្នុងប្រទេស | ៣ ៧៣៦ | ៥ ២៩៥ | ៦ ៩៥៤ | ៨ ៧៥៥ | ៨ ១២២ |
| អន្តរជាតិ | ១៩ ០០០ | ២៣ ៤១២ | ២៥ ២៣៣ | ២៦ ២៥១ | ២៨ ៣១៧ |
| ឆ្លងកាត់ | ៣៣ ០២៥ | ៤០ ២៥៨ | ៤១ ១៦០ | ៤៦ ៩៤០ | ៥៥ ០៧៩ |

| | | | | | |
|---|---|---|---|---|---|
| ដឹកភ្ញៀវក្នុងប្រទេស និងក្រៅប្រទេស (នាក់) | | | | | |
| ក្នុងប្រទេស | ១៧២ ២២៣ | ២១៤ ៤១៨ | ២៩៨ ៩០៤ | ៤៣៦ ១៦៧ | ៤២៣ ៤៧៨ |
| ក្រៅប្រទេស | ៣ ៩៩៧ ៣៣១ | ៤ ៦០៦ ២៨១ | ៥ ១៦៨ ៦៨៧ | ៥ ៦០៦ ៣១៧ | ៦ ២០១ ៣៣៨ |
| ដឹកអីវ៉ាន់ក្នុងប្រទេស និងក្រៅប្រទេស (គ.ក្រ) | | | | | |
| ក្នុងប្រទេស | ១ ៥១៤ ០៤៧ | ១ ៩០៣ ២៨១ | ២ ៧៥២ ៦៧៧ | ៣ ៦៧៩ ០៤៨ | ៧ ៣៦៦ ៦៥៨ |
| ក្រៅប្រទេស | ៥១ ៩៤៦ ៩២៨ | ៥៨ ៣០១ ៣៥៧ | ៦២ ៩២៥ ៤០១ | ៦៦ ១៧៨ ៧៥៨ | ៧២ ៥១៧ ៥៤០ |
| ដឹកទំនិញ ក្នុងប្រទេស និងក្រៅប្រទេស (គ.ក្រ) | | | | | |
| ក្នុងប្រទេស | ៥០៨ | ៦ ២៤៣ | ១៨៣ ២២២ | ២៥២ ១៤៧ | ១៥៣ ០៥០ |
| ក្រៅប្រទេស | ២៧ ៨១០ ៨៩៩ | ៣១ ៦១២ ០៦២ | ៣២ ៦៦៥ ៧៨៧ | ៣៦ ៨៩៧ ៨៤៥ | ៤៦ ៣០៨ ៧៤៤ |
| ដឹកកញ្ចប់ប្រៃសណីយ៍ក្រៅប្រទេស (គ.ក្រ) | | | | | |
| កញ្ចប់ប្រៃ-សណីយ៍ | ៦៧៩ ១៦៣ | ៧២០ ២៣១ | ៨២៦ ២៩៩ | ៨៥២ ៧៧៦ | ៨៦៦ ៩០៣ |
| ចំណូលបង់ចូលថវិការដ្ឋ (ដុល្លារអាមេរិក) | | | | | |
| **ចំណូល** | ១៦ ២៤៧ ០៨០ | ១៥ ៩៤២ ៦២៨ | ១៩ ៩៥៦ ៤៤៧ | ២៦ ៩៧០ ៧០០ | ៣២ ៩០៩ ៣៥០ |

-នៅក្នុងឆ្នាំ២០១៦នេះ ការដឹកជញ្ជូនភ្ញៀវក្នុង និងក្រៅប្រទេសបាន ៦ ៦២៤ ៨១៦នាក់ កើនឡើង ១០% បើធៀបនឹងឆ្នាំ២០១៥ ដឹកជញ្ជូនអីវ៉ាន់តាមផ្លូវអាកាសទាំងក្នុងប្រទេស និងក្រៅប្រទេសបានចំនួន ៧៩ ៨៨៤ ១៩៨គ.ក្រ កើនឡើង ៩% បើធៀបនឹងឆ្នាំ២០១៥ ដឹកជញ្ជូនទំនិញទាំងក្នុងប្រទេស និងក្រៅប្រទេសបានចំនួន ៤៦ ៤៦១ ៧៩៤គ.ក្រ កើនឡើង ២៥% បើធៀបនឹងឆ្នាំ២០១៥ ដឹកជញ្ជូនកញ្ចប់ប្រៃសណីយ៍ក្នុង និងក្រៅប្រទេសបានចំនួន ៨៦៦ ៩០៣គ.ក្រ កើនឡើង ២% បើធៀបនឹងឆ្នាំ២០១៥។ ចំណូលបង់ចូលថវិការដ្ឋបាន ៣២ ៩០៩ ៣៥០ដុល្លារអាមេរិក។

**☼ក្រុមហ៊ុនអាកាសចរណ៍ជាតិ និងអន្តរជាតិ ដែលមានច្បាប់អនុញ្ញាតហោះហើរចេញ ចូលព្រះរាជាណាចក្រកម្ពុជា**

| **ល.រ** | **ឈ្មោះក្រុមហ៊ុន** | **ថ្ងៃខែឆ្នាំ អនុញ្ញាតឲ្យហោះហើរ** |
|---|---|---|
| ១ | ក្រុមហ៊ុនអាកាសចរណ៍ Vietnam Airlines | ០១ កញ្ញា ១៩៧៩ |
| ២ | ក្រុមហ៊ុនអាកាសចរណ៍ Lao Airlines | ០១ មករា ១៩៨២ |
| ៣ | ក្រុមហ៊ុនអាកាសចរណ៍ Bangkok Airways | ២៥ តុលា ១៩៩០ |
| ៤ | ក្រុមហ៊ុនអាកាសចរណ៍ Malaysia Airlines | ១៧ មីនា ១៩៩២ |
| ៥ | ក្រុមហ៊ុនអាកាសចរណ៍ Thai Airways | ០១ តុលា ១៩៩២ |
| ៦ | ក្រុមហ៊ុនអាកាសចរណ៍ Silk Air | ០១ ធ្នូ ១៩៩២ |
| ៧ | ក្រុមហ៊ុនអាកាសចរណ៍ Dragon Air | ០១ កុម្ភៈ ១៩៩៣ |
| ៨ | ក្រុមហ៊ុនអាកាសចរណ៍ China Southern Airlines | ០១ កុម្ភៈ ១៩៩៩ |
| ៩ | ក្រុមហ៊ុនអាកាសចរណ៍ Eva Air | ០១ មករា ២០០១ |

| | | |
|---|---|---|
| ១០ | ក្រុមហ៊ុនអាកាសចរណ៍ China Eastern  Airlines | ០១ មករា ២០០៤ |
| ១១ | ក្រុមហ៊ុនអាកាសចរណ៍ Asiana Airlines | ០១ មេសា ២០០៥ |
| ១២ | ក្រុមហ៊ុនអាកាសចរណ៍ Thai Air Asia | ៣០ តុលា ២០០៥ |
| ១៣ | ក្រុមហ៊ុនអាកាសចរណ៍ Air Asia Berhad | ០១ វិច្ឆិកា ២០០៥ |
| ១៤ | ក្រុមហ៊ុនអាកាសចរណ៍ Korean Air | ០១ វិច្ឆិកា ២០០៦ |
| ១៥ | ក្រុមហ៊ុនអាកាសចរណ៍ China Airlines | ០១ វិច្ឆិកា ២០០៦ |
| ១៦ | ក្រុមហ៊ុនអាកាសចរណ៍ Jetstar Asia Airways | ០១ ធ្នូ ២០០៨ |
| ១៧ | ក្រុមហ៊ុនអាកាសចរណ៍ Cambodia Angkor Air | ២៧ កក្កដា ២០០៩ |
| ១៨ | ក្រុមហ៊ុនអាកាសចរណ៍ Skywing Asia Airlines | ១៣ កុម្ភៈ ២០១១ |
| ១៩ | ក្រុមហ៊ុនអាកាសចរណ៍ Cebu Pacific | ២៧ មីនា ២០១២ |
| ២០ | ក្រុមហ៊ុនអាកាសចរណ៍ Xiaman Airlines | ០១ មីនា ២០១៤ |
| ២១ | ក្រុមហ៊ុនអាកាសចរណ៍ Vietjet Air | ០១ មីនា ២០១៤ |
| ២២ | ក្រុមហ៊ុនអាកាសចរណ៍ Air Pusan | ៣០ មីនា ២០១៤ |
| ២៣ | ក្រុមហ៊ុនអាកាសចរណ៍ Cathay Pacific Airways | ០១ កញ្ញា ២០១៤ |
| ២៤ | ក្រុមហ៊ុនអាកាសចរណ៍ Shadong Airlines | ២៦ តុលា ២០១៤ |
| ២៥ | ក្រុមហ៊ុនអាកាសចរណ៍ Qatar Airways | ៣០ តុលា ២០១៤ |
| ២៦ | ក្រុមហ៊ុនអាកាសចរណ៍ Basskar Air | ០១ វិច្ឆិកា ២០១៤ |
| ២៧ | ក្រុមហ៊ុនអាកាសចរណ៍ Spring Airlines | ២៩ មីនា ២០១៥ |
| ២៨ | ក្រុមហ៊ុនអាកាសចរណ៍ Hong Kong Express | ០១ តុលា ២០១៥ |
| ២៩ | ក្រុមហ៊ុនអាកាសចរណ៍ Beijing Capital Airlines | ២៦ ធ្នូ ២០១៥ |
| ៣០ | ក្រុមហ៊ុនអាកាសចរណ៍ Hong Kong Airlines | ១៥ មករា ២០១៦ |
| ៣១ | ក្រុមហ៊ុនអាកាសចរណ៍ Turkish Airlines | ២៧ មីនា ២០១៦ |
| ៣២ | ក្រុមហ៊ុនអាកាសចរណ៍ Eastra Jet | ២៨ មីនា ២០១៦ |
| ៣៣ | ក្រុមហ៊ុនអាកាសចរណ៍ Emirates Airlines | ១១ សីហា ២០១៦ |
| ៣៤ | ក្រុមហ៊ុនអាកាសចរណ៍ All Nippon Airways | ០១ កញ្ញា ២០១៦ |
| ៣៥ | ក្រុមហ៊ុនអាកាសចរណ៍ Thai Smile | ០១ តុលា ២០១៦ |
| ៣៦ | ក្រុមហ៊ុនអាកាសចរណ៍ Air Seoul | ០៨ តុលា ២០១៦ |
| ៣៧ | ក្រុមហ៊ុនអាកាសចរណ៍ Tianjing Airlines | ១៩ ធ្នូ ២០១៦ |

### ១.៣-ការងារផ្លូវដែក

១.៣.១-ផ្លូវដែកទិសខាងជើង

-អនុវត្តគម្រោងស្តារជួសជុលកំណាត់ផ្លូវដែកប្រវែង ៦,៥គ.ម នៅប៉ោយប៉ែត ព្រំប្រទល់កម្ពុជា-ថៃ ដើម្បីតភ្ជាប់ផ្លូវដែករវាងប្រទេសទាំងពីរ។

-អនុវត្តគម្រោងស្តារជួសជុលកំណាត់ផ្លូវដែកទិសខាងជើងពីគ.ម ៣២៨+៥០០-គ.ម ៣៣៨+៥០០ សម្រេចបាន ២១,៨០%។

-បន្តជួសជុលផ្លូវ ស្ពានពី គ.ម ៣១០+០០០ - គ.ម ៣២៨+០០០ បានរៀបចំដោះមីន អាវុធជាតិផ្ទុះរួចហើយកំពុងអនុវត្តដោយនាយកដ្ឋានផ្លូវដែក (Force Account)។

-ការងារដោះដែករ៉ែ និងការងារសាងសង់ឡើងវិញ (គ.ម ៣០០+០០០-គ.ម ៣១០+០០០) សម្រេចបាន៥៣%។

-ការងារសាងសង់ផ្លូវដែក (គ.ម ៣២៨+០០០ - គ.ម ៣៣៨+០០០ : ពីមង្គលបុរី-សេរីសោភ័ណ) សម្រេចបាន ២២,៤៨%។

-ការងារសាងសង់ថ្មីបន្ត (គ.ម ៣៧៨+៥០០-គ.ម ៣៨៥+០៥០ : នៅក្រុងប៉ោយប៉ែត) និងផ្លូវវេថភ្លើងជៀសក្នុងស្ថានីយ៍ប៉ោយប៉ែត បានចាប់ផ្តើមការសាងសង់សម្រេចបាន ៤៥,៨៦%។

-ការងារជួសជុលផ្លូវដែក (គ.ម ៣១០+០០០-គ.ម៣២៨+៥០០)សម្រេចបាន ១១,២៦%។

-ការងារជួសជុលពង្រឹងផ្លូវដែក (គ.ម ៣៣៨+៥០០ - គ.ម ៣៧៨+៥០០) សម្រេចបាន ២១,៧៥% ។

-ការងារជួសជុលពង្រឹងស្ពាន (គ.ម ៣២៨+៥០០ - គ.ម ៣៧៨+៥០០) សម្រេចបាន ១៤%។

-ការងារជួសជុលផ្លូវដែក (គ.ម២៧៣+២៥០-គ.ម៣០០+០០០)សម្រេចបាន ១២,០៨% ។

-បំពាក់ប្រព័ន្ធសុវត្ថិភាពផ្លូវឆ្លងកាត់ផ្លូវដែកពាយ័ព្យ(គ.ម៣៨៤+៥៦៥-គ.ម ៣៨៤+៩២១) សម្រេចបាន៥%។

១.៣.២-ផ្លូវដែកទិសខាងត្បូង

-អនុវត្តគម្រោងដំឡើងឧបករណ៍ប្រពន្ធ័សុវត្ថិភាព ផ្លូវឆ្លងកាត់ផ្លូវដែក Level Crossing ពី គ.ម ៩+៤០០-គ.ម ៤៥+០០០ អនុវត្តដោយក្រុម Taing Cheng Oing សម្រេចបាន ១០០%។

-អនុវត្តគម្រោងជួសជុលកែសម្រួលការសាងសង់ពង្រឹងស្ពានទិសខាងត្បូងនៅគ.ម២៣, គ.ម៦៦,គ.ម១៦២,គ.ម១៦៨,គ.ម២១២ អនុវត្តដោយក្រុមហ៊ុន Sinohydro សម្រេចបាន ១០០%។

-ការងារជួសជុលពង្រឹងទៅលើការខូចខាតនៃខ្សែផ្លូវដែកបានស្តាររួចពីគ.ម៩+៤០០-គ.ម ២៦៦+០០០(ទិសខាងត្បូង) បានជ្រើសរើសអ្នកម៉ៅការជួសជុលឈ្មោះក្រុមហ៊ុន Italian-Thai Development សម្រេចបាន ៦២,០៧%។

## ២-ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ

### ២.១-ការស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រ

| បរិយាយ | ដំណាំ (ហ.ត) | លទ្ធភាពស្រោចស្រព (ហ.ត) | | |
|---|---|---|---|---|
| | | ស្រូវវស្សា | ស្រូវប្រាំង | សរុប |
| ២០១២ | ១ ០៥១ | ៩៤ ២៦១ | ៣៣ ០៥៧ | ១២៧ ៣១៨ |
| ២០១៣ | ២ ៥៥៦ | ៣៩ ៨៦៩ | ២២ ៩៥៧ | ៦២ ៨២៦ |
| ២០១៤ | ១ ២២៨ | ៨០ ២៤៥ | ៤១ ០១៣ | ១២១ ២៥៨ |

| | | | | |
|---|---|---|---|---|
| ២០១៥ | ១ ៥៥៨ | ៦២ ២៨៩ | ១៩ ១៦៦ | ៨១ ៤៥៥ |
| ២០១៦ | ៦១២ | ៤០ ៨៥០ | ១៤ ៣៦៣ | ៥៥ ២១៣ |
| **សរុប** | **៧ ០០៥** | **៣១៧ ៥១៤** | **១៣០ ៥៥៦** | **៤៤៨ ០៧០** |

## ២.២-ការជួសជុល និងថែទាំសំណង់សិល្បការ

| ឆ្នាំ | ទ្វារទឹក (កន្លែង) | លូទឹក (កន្លែង) | ស្អាក់ទឹក(កន្លែង) | បង្ហៀរ (កន្លែង) |
|---|---|---|---|---|
| ២០១២ | ២០ | ២០ | ២ | |
| ២០១៣ | ២១ | ៤១ | ១៣ | ១ |
| ២០១៤ | ៤១ | ១០៥ | ៣០ | ៥ |
| ២០១៥ | ២០ | ៧៣ | ៤ | ២ |
| ២០១៦ | ៣៣ | ៧ | | ៦ |
| **សរុប** | ១៣៥ | ២៤៦ | ៤៩ | ២០ |

## ២.៣-ការជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ

### ២.៣.១-ការជួសជុល និងថែទាំទំនប់

| ឆ្នាំ | ចំនួនកន្លែង | ប្រវែង (ម) | សាច់ដី (ម³) | ពលករ(នាក់) | សំបកបាវ |
|---|---|---|---|---|---|
| ២០១២ | ៥០ | ២៩ ៨៤៨ | ៨៨ ០៨៩ | ៤៨៧ | |
| ២០១៣ | ២៧ | ១៧ ៧៥៤ | ៧៥ ៥៥៧ | ១០៨ | ៥៤ ៨០០ |
| ២០១៤ | ៧១ | ២៤ ៤៣៣ | ២៤១ ២៤២ | ៩២៣ | ២៣ ២០០ |
| ២០១៥ | ២៩ | ២៣ ៤១៨ | ៧៨ ៩៦៨ | | |
| ២០១៦ | ១៨ | ២១ ១៩៩ | ២៩ ២៩២ | ១២៣ | |
| **សរុប** | ១៩៥ | ១១៦ ៦៥២ | ៥១៣ ១៤៨ | ១ ៦៤១ | ៧៨ ០០០ |

### ២.៣.២-ការខារជីក និងស្តារប្រឡាយ

| ឆ្នាំ | ចំនួនខ្សែ | ប្រវែង (ម) | សាច់ដី (ម³) | ពលករ (នាក់) |
|---|---|---|---|---|
| ២០១២ | ៨៤ | ១៣២ ៩៧០ | ៣២៤ ៩៩១ | ១ ២៩៧ |
| ២០១៣ | ៨៨ | ១៣១ ១០៦ | ១៧៩ ៧៧២ | ៧៦ |
| ២០១៤ | ៧៩ | ១១៩ ៣៧៥ | ១២៤ ៩៦៤ | ២ ០៥២ |
| ២០១៥ | ៤៨ | ១០៤ ៣៣២ | ១៥១ ៤១២ | |
| ២០១៦ | ៤៤ | ១១១ ៦៥៧ | ២៣ ៧៧៥ | |
| **សរុប** | ៣៤៣ | ៥៩៩ ៤៤០ | ៨០៤ ៩១៤ | ៣ ៤២៥ |

## ២.៤-ការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក

| បរិយាយ | ចំនួនសហគមន៍ | ផ្ទៃដីដំណាំស្រូវ (ហ.ត) | | | ចំនួនគ្រួសារ |
|---|---|---|---|---|---|
| | | ស្រូវវស្សា | ស្រូវប្រាំង | សរុប | |
| ២០១២ | ១៧ | ៦២៧ | | ៦២៧ | ៤៤៦ |
| ២០១៣ | ៦ | ២ ៦៦៨ | ៤ ២៤៧ | ៦ ៩១៥ | ៤ ៥២០ |
| ២០១៤ | ១៨ | ១៦ ៤០០ | ៥ ៤២៦ | ២១ ៨២៦ | ៩ ២៦៩ |
| ២០១៥ | ៩ | ៦ ៨៦៧ | ៦២៩ | ៧ ៤៩៦ | ៤០៧ |
| ២០១៦ | ១៩ | ១៨ ៣៤៧ | ៤ ៧០៧ | ២៣ ០៥៤ | ៥ ៨៣៩ |
| **សរុប** | **៦៩** | **៤៤ ៩០៩** | **១៥ ០០៩** | **៥៩ ៩១៨** | **២០ ៤៨១** |

## ២.៥-ការគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់ទឹកប្រៃ

✡ការទប់ស្កាត់ទឹកជំនន់ ៖ បានធ្វើការជួសជុលទំនប់ការពារទប់ស្កាត់ទឹកជំនន់ បានចំនួន ១៥គម្រោង ដែលមានលទ្ធភាពការពារផ្ទៃដីសរុប ២ ៤៥១ហ.ត ក្នុងនោះ លំនៅស្ថានប្រជាពលរដ្ឋបានទំហំ ៥២៦ហ.ត ការពារផ្ទៃដីស្រូវ ១ ៩២៥ហ.ត និងការពារច្រាំងទន្លេនៅក្រុងកំពង់ចាម ប្រវែង ៣៩០ម ។

| ឆ្នាំ | ចំនួនគម្រោង | លទ្ធភាពការពារ(ហ.ត) | | |
|---|---|---|---|---|
| | | លំនៅស្ថាន | ស្រូវ | សរុប |
| ២០១២ | ១ | | | |
| ២០១៣ | ៤ | | ១ ៩២៥ | ១ ៩២៥ |
| ២០១៤ | ៣ | ១៥០ | | ១៥០ |
| ២០១៥ | ៤ | ១០០ | | ១០០ |
| ២០១៦ | ៣ | ២៧៦ | | ២៧៦ |
| **សរុប** | **១៥** | **៥២៦** | **១ ៩២៥** | **២ ៤៥១** |

✡ការទប់ស្កាត់ទឹកប្រៃ ៖ បានធ្វើការជួសជុល និងថែទាំជាប្រចាំទំនប់ការពារទប់ស្កាត់ទឹកប្រៃ បានចំនួន ៣២គម្រោង ហើយការពារទប់ស្កាត់ទឹកប្រៃ កុំឲ្យប៉ះពាល់ផ្ទៃដីសរុប ២ ៤៧៦ហ.ត ក្នុងនោះស្រូវ ២ ៤៥១ហ.ត ដំណាំ ២៥ហ.ត ។

| ឆ្នាំ | ចំនួនគម្រោង | លទ្ធភាពការពារ(ហ.ត) | | |
|---|---|---|---|---|
| | | ស្រូវ | ដំណាំ | សរុប |
| ២០១២ | ៥ | ១ ០៥០ | | ១ ០៥០ |
| ២០១៣ | ១ | ៤៨៦ | | ៤៨៦ |

| | | | | |
|---|---|---|---|---|
| ២០១៤ | ១ | | | |
| ២០១៥ | ១២ | ៧៥០ | ១៥ | ៧៦៥ |
| ២០១៦ | ១៣ | ១៦៥ | ១០ | ១៧៥ |
| **សរុប** | **៣២** | **២ ៤៥១** | **២៥** | **២ ៤៧៦** |

## ២.៦-ការអន្តរាគមន៍សង្គ្រោះស្រូវពេលមានគ្រោះរាំងស្ងួត

| ឆ្នាំ | ការប្រើប្រាស់ប្រេង (លីត្រ) | | ផ្ទៃដីស្រូវសង្គ្រោះ (ហ.ត) | | |
|---|---|---|---|---|---|
| | ប្រេងម៉ាស៊ូត | ប្រេងរំអិល | ស្រូវប្រាំង | ស្រូវវស្សា | សរុប |
| ២០១២ | ៩៤៥ ០០០ | ៩ ៣៣០ | ៤៥ ៣៨៥ | ២៤ ៣២៦ | ៦៩ ៧១១ |
| ២០១៣ | ៧៣៩ ០០០ | ៦ ៩៧០ | ២៥ ៣៩៧ | ៣៣ ៨៧៥ | ៥៩ ២៧២ |
| ២០១៤ | ៦៩៤ ៨០០ | ៧ ៦៧០ | ២៣ ៥២៦ | ៣០ ៦២៣ | ៥៤ ១៤៩ |
| ២០១៥ | ៧៦៨ ០០០ | ៧ ៦៨០ | ២២ ១៦៤ | ៣៧ ៨៥១ | ៦០ ០១៥ |
| ២០១៦ | ១ ៣១៦ ០០០ | ១៣ ១៤០ | ៦៣ ៥៨៦ | ២៩ ៣២១ | ៦២ ៩០៧ |
| **សរុប** | **៤ ៤៦២ ៨០០** | **៤៤ ៧៩០** | | | |

ក្រៅពីការងារអន្តរាគមន៍សង្គ្រោះស្រូវដោយម៉ាស៊ីនបូមទឹក ក៏មានការសង្គ្រោះស្រូវដោយប្រព័ន្ធធារាសាស្ត្រ(បង្ហូរ) ។

| បរិយាយ | លទ្ធផលបង្ហូរសង្គ្រោះ (ហ.ត) | | |
|---|---|---|---|
| | ស្រូវប្រាំង | ស្រូវវស្សា | សរុប |
| ២០១២ | ៦ ០២៣ | ១១ ៨៨០ | ១៧ ៩០៣ |
| ២០១៣ | ៦ ៨២៦ | ១ ០៨១ | ៧ ៩០៧ |
| ២០១៤ | ៣ ៧៦៩ | ២ ៨៣៥ | ៦ ៦០៤ |
| ២០១៥ | ២ ៧៨២ | ៣ ២៨៧ | ៦ ០៦៩ |
| ២០១៦ | ៣៨១ | ៦៨១ | ១ ០៦២ |

**២.៧-ការសាងសង់ដំឡើងស្ថានីយបូមទឹក** បាន ១កន្លែង ជួសជុលស្ថានីយបូមទឹក ២៤កន្លែង និងជួសជុលម៉ាស៊ីនបូមទឹកចំនួន ១៧៧គ្រឿង ។

| ឆ្នាំ | សាងសង់ស្ថានីយ(កន្លែង) | ជួសជុលស្ថានីយ(កន្លែង) | ជួសជុលម៉ាស៊ីន(កន្លែង) |
|---|---|---|---|
| ២០១២ | | ៥ | |
| ២០១៣ | | | ១១៣ |
| ២០១៤ | ១ | ៧ | ៣២ |

| | | | |
|---|---|---|---|
| ២០១៥ | | ៩ | ១១ |
| ២០១៦ | | ៣ | ២១ |
| **សរុប** | **១** | **២៤** | **១៧៧** |

❖❖❖ជាក់ស្តែងនៅឆ្នាំ២០១២-២០១៦ ក្រសួងសម្រេចបាន ៖

-ពង្រីកលទ្ធភាពស្រោចស្រពលើផ្ទៃដីដំណាំស្រូវសរុប ៤៤៨ ០៧០ហ.ត ក្នុងនោះរួមមាន ស្រូវវស្សា ៣១៧ ៥៩៦ហ.ត និងស្រូវរដូវប្រាំង ១៣០ ៥៥៦ហ.ត ។

-សរុបមកវិញបើគិតចាប់ពីឆ្នាំ១៩៩០ មកដល់ឆ្នាំ២០១៦ **ពង្រីកលទ្ធភាពស្រោចស្រព** លើផ្ទៃដីដំណាំស្រូវសរុប ១ ៧៤៣ ៥៩៦ហ.ត ក្នុងនោះរួមមាន ស្រូវរដូវវស្សា ១ ២៣៣ ៥១៩ហ.ត និងស្រូវរដូវប្រាំង ៥១០ ០៧៧ហ.ត **ស្មើនឹង ៥៦,២៨% បើប្រៀបធៀបទៅនឹងផ្ទៃដីបង្កបង្កើនផលស្រូវក្នុងឆ្នាំ២០១៦** ដែលមានសរុប ៣ ០៩៧ ៦៤៧ហ.ត ក្នុងនោះស្រូវវស្សា ២ ៥៩៩ ៥៨៦ហ.ត និងស្រូវប្រាំង៤៩៨ ០៦១ហ.ត (តួលេខរបស់ក្រសួងកសិកម្ម)។

-ពង្រីកស្រោចស្រពដំណាំរួមផ្សំបាន ៧ ០០៥ហ.ត។ បើគិតចាប់ពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០១៦ ពង្រីកលទ្ធផលស្រោចស្រពដំណាំរួមផ្សំសរុប ១២ ៤៥០ហ.ត។

-ចងក្រងជាសហគមន៍កសិករប្រើប្រាស់ទឹកបានចំនួន ៦៩សហគមន៍។ បើគិតចាប់ពីឆ្នាំ១៩៩០មក ដល់ឆ្នាំ២០១៦ មានចំនួន ៤៨០សហគមន៍។

-មានលទ្ធភាពការពារលំនៅស្ថាន និងដំណាំស្រូវជូនប្រជាពលរដ្ឋកុំឲ្យទឹកជំនន់លិចលង់បាន ២ ៤៥១ហ.ត។ បើគិតចាប់ពីឆ្នាំ១៩៩០ មកដល់ឆ្នាំ២០១៦ ការពារពីទឹកជំនន់បានផ្ទៃដីសរុប ១៣៩ ១៥៦ហ.ត។

-មានលទ្ធភាពការពារទប់ស្កាត់ទឹកប្រៃកុំឲ្យហូរចូលលើផ្ទៃដីស្រូវ និងដំណាំរួមផ្សំ ២ ៤៧៦ហ.ត។

-បានព្យាករណ៍ និងជូនដំណឹងស្ថានភាពអាកាសធាតុ និងជលសាស្ត្រ ជូនប្រជាពលរដ្ឋផងដែរ។

## ២.៨-ការងារអភិវឌ្ឍន៍ជនបទ

លទ្ធផលការងារសំខាន់ៗរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ៖

| ២.៧.១-ការងារផ្លូវជនបទ | | | | | |
|---|---|---|---|---|---|
| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| ផ្លូវជនបទថែទាំខួប និងប្រចាំ | ២ ០៤៩,៤៨ គ.ម | ១ ៧៩៨,៦៣ គ.ម | ១ ១១៤,៥៧ គ.ម | ១ ០៥៥,២៤ គ.ម | ១ ៧១២,៣៧ គ.ម |
| ផ្លូវជនបទបានកែលម្អជា | ១៦គ.ម | ៦៣,៣០គ.ម | ៤,៥៥គ.ម | ៤៨,៧គ.ម | ១៨៥,៣១គ.ម |

| | | | | | |
|---|---|---|---|---|---|
| កម្រាល DBST និង Beton | | | | | |
| ផ្លូវដែលបានចុះបញ្ជីសារពើភ័ណ្ឌ | | | ១២ ៣១៧ខ្សែ ៣៤ ៥៩៦,៥៣គ.ម | ១២ ៣៩៧ខ្សែ ៤១ ៦៥៧,៩៨គ.ម | ១៤ ៨៦៣ខ្សែ ៤៣ ៥៩៥គ.ម |
| ចំនួនខ្សែនិងប្រវែងផ្លូវជួសជុលថ្មីដំពូក ២១ | ៣៥៦,១២ គ.ម | ៨៣៥,៣៣ គ.ម | ៥២៩,៨ គ.ម | ១ ៥៥៦,៧៥ គ.ម | ៣៤៦,៤៩ គ.ម |
| ផ្លូវជនបទបានជួសជុលបន្ទាន់ក្រោយទឹកជំនន់ | | | | | ៨៨ខ្សែ ២៤៩,៤២គ.ម |
| លូមូល លូជ្រុង ស្ពានដែលបានស្ថាបនាថ្មី | ៥៧២ កន្លែង | ១ ៣៨៧កន្លែង | ៣៤១ កន្លែង | ៦០២ កន្លែង | ៣៥១ កន្លែង |
| ស្ពាន | ៨៤៩ ម | ១ ៣៧៦ ម | ១៣៧ ម | ១៤១ ម | ៥៨៦ ម |
| ផ្សារជនបទ | | | | ២ផ្សារ (៣៨៦តូប) | |
| សាលារៀន | | ៨អគារ (៤០បន្ទប់) | | | |
| ២.៧.២-ការងារផ្គត់ផ្គង់ទឹកជនបទ | | | | | |
| អណ្តូងស្នប់និងអណ្តូងលូ សាងសង់ថ្មីគ្រប់ប្រភេទ | ១ ២១០ អណ្តូង | ៥៤៣ អណ្តូង | ១ ៦៤៣ អណ្តូង | ១ ២៤៤ អណ្តូង | ៤៨២ អណ្តូង |
| ជួសជុលអណ្តូងគ្រប់ប្រភេទ | ៣ ៣៧៤ អណ្តូង | ១ ២៤៧ អណ្តូង | ៣ ១៣៥ អណ្តូង | ៣ ០០៣ អណ្តូង | ៩៨៨ អណ្តូង |
| ស្រះសហគមន៍ដែលបានស្តារ/សាងសង់ថ្មី | ៣២ ស្រះ | ២៣ ស្រះ | ៨៥ ស្រះ | ៦៥ ស្រះ | ៤១ ស្រះ |
| អាងត្រងទឹកភ្លៀង (អាងបេតុង) | ៤០ | ៦៩ | ៣៥ | ៤៦ | ៣៤ |
| ប្រព័ន្ធចែកចាយទឹកតាមទុយោ | ៣ ប្រព័ន្ធ | ១ ប្រព័ន្ធ | ២៤ ប្រព័ន្ធ | ២៨ ប្រព័ន្ធ | ១ ប្រព័ន្ធ |
| ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ដែលបានស្តារ និងជួសជុល | ២៣ ប្រព័ន្ធ | ១៦ ប្រព័ន្ធ | ២០ ប្រព័ន្ធ | ១០ ប្រព័ន្ធ | ១១ ប្រព័ន្ធ |
| ធុងចម្រោះដែលបានសាងសង់ (ធុងចម្រោះ) | ១ ៣១៤ | ២៤២ | ៦២៩ | ២៣៣ | ១០៥ |

| | | | | | |
|---|---|---|---|---|---|
| ប្រជាពលរដ្ឋទទួលបានទឹកស្អាតជនបទ | ៤២% | ៤៤,២% | ៤៦,៧% | ៥០% | ៥៣% |
| ២.៧.៣-ការថែទាំសុខភាពជនបទ | | | | | |
| បង្គន់អនាម័យជនបទដែលបានសាងសង់(បង្គន់) | ៦ ១៤៩ | ១២ ៧០៦ | ៥១ ៦៤២ | ៣៧ ៦៨៧ | ៤ ៧២៤ |
| ប្រជាពលរដ្ឋដែលយល់ដឹងពីបញ្ហាអនាម័យ(នាក់) | ៤១ ៧៩៦ | ៣៨ ៦៧២ | ៤៣ ៧៥៤ | ១៥ ៨១៤ | ១៦ ៧២១ |
| ប្រជាពលរដ្ឋដែលទទួលបានសេវាអនាម័យជនបទ | ២៩% | ៤០,៩០% | ៤៦,២០% | ៥២,៩០% | ៥៥% |
| ២.៧.៤-ការអភិវឌ្ឍសហគមន៍ | | | | | |
| គណៈកម្មាធិការអភិវឌ្ឍន៍ភូមិបានបណ្តុះបណ្តាល | ៤ ៧២៧ ភូមិ | ៦ ១៦០ ភូមិ | ៧ ៩១០ ភូមិ | ៧ ៧៧៤ ភូមិ | ៣ ៣៦០ ភូមិ |
| ភូមិដែលធ្វើការអភិវឌ្ឍចម្រុះ | ៧ ភូមិ | ៦ ភូមិ | ៧ ភូមិ | ៥ ភូមិ | ៦ ភូមិ |
| គ្រូបង្គោលដែលបានបញ្ជ្រាបការយល់ដឹងពីការត្រៀមបង្ការនិងកាត់បន្ថយគ្រោះមហន្តរាយ | ៣៥នាក់ | ៣៥នាក់ | | | |
| ប្រជាពលរដ្ឋដែលបានបញ្ជ្រាបការយល់ដឹងពីការត្រៀមបង្ការនិងកាត់បន្ថយគ្រោះមហន្តរាយ | | | ១០៥នាក់ | ៤២០នាក់ | ៤៩០នាក់ |
| ពាងដីកំប៉ុស្តិ៍ដែលផ្តល់ជូនប្រជា-ពលរដ្ឋ (គ្រួសារ) | ១៦០ | ២០០ | ២២០ | ២០០ | ២៨០ |

| | | | | | |
|---|---|---|---|---|---|
| ប្រជាពលរដ្ឋដែលទទួលការបណ្តុះបណ្តាលជំនាញមូលដ្ឋាននៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទខេត្តតាកែវ និងកំពង់ស្ពឺ | ២៨៧នាក់ | ១ ២០៥នាក់ | ១១ ០៦៧នាក់ | ១ ២៨០នាក់ | ១ ២៥៧នាក់ |
| អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជី | ៣៣ សហគមន៍ | ១៩ សហគមន៍ | ៥ សហគមន៍ | ១៥ សហគមន៍ | ៤ សហគមន៍ |
| ប្រជាពលរដ្ឋដែលបានបណ្តុះបណ្តាលបច្ចេក-ទេសឡជីវឧស្ម័ន និងបង្កើតមុខរបរអាជីវកម្មខ្នាតតូច | ១១០ នាក់ | ៧៥ នាក់ | ៦៥ នាក់ | ៥០ នាក់ | ៨០ នាក់ |
| ប្រជាពលរដ្ឋទទួលបានប្រឹក្សាការងារទីផ្សារនិងផ្តល់គំនិតអាជីវកម្មខ្នាតតូច | ១៨៨ នាក់ | ២២៦ នាក់ | ៣២៥ នាក់ | ៩០ នាក់ | ២៩៨ នាក់ |
| ប្រជាពលរដ្ឋ/សហគមន៍ទទួលសេវាឥណទានជនបទ(នាក់) | ៨ ៥៦១ | ៦ ៩២៥ | ៥ ៩២៣ | ៥ ៤៣៨ | ៥ ៧២៩ |
| ២.៧.៥-ការរៀបចំផែនការ និងហិរញ្ញវត្ថុ (ការបណ្តុះបណ្តាលធនធានមនុស្ស) | | | | | |
| មន្ត្រីដែលបានបណ្តុះបណ្តាលជំនាញផែនការ | ២៤០នាក់ | ២២០នាក់ | ២៥០នាក់ | ២១០នាក់ | ២២០នាក់ |
| មន្ត្រីដែលបានទទួលការបណ្តុះបណ្តាលជំនាញកុំព្យូទ័រ | ៦០នាក់ | ៦០នាក់ | ៥០នាក់ | ៦០នាក់ | ៧០នាក់ |
| អង្គការក្រៅរដ្ឋា-ភិបាលដែលបាន | ៣៩អង្គការ | ៤០អង្គការ | ៤២អង្គការ | ៤៤អង្គការ | ៤៨អង្គការ |

| | | | | | |
|---|---|---|---|---|---|
| សហការជាមួយក្រសួង | | | | | |
| មន្ត្រីទទួលការបណ្តុះបណ្តាលសមត្ថភាពថវិកាកម្មវិធី | ២៥០នាក់ | ២៥០នាក់ | ៣០០នាក់ | ៣០០នាក់ | ៣០០នាក់ |
| មន្ត្រីទទួលបានការបណ្តុះបណ្តាលលទ្ធកម្មនិងបញ្ជីសារពើភណ្ឌ | ១២០នាក់ | ១២០នាក់ | ១២២នាក់ | ១២៥នាក់ | ១៣០នាក់ |

## ៣- ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី

មកទល់ពេលនេះ ការផលិតថាមពលអគ្គិសនីពីប្រភពក្នុងស្រុកត្រូវបានចូលរួមអភិវឌ្ឍន៍ដោយក្រុមហ៊ុនឯកជនចំនួន ០៩ក្រុមហ៊ុន មានអានុភាពសរុប ១ ៨៣៣,១មេហ្គាវ៉ាត់ ស្មើនឹងទុនវិនិយោគសរុបចំនួន ៣ ០៩៦,២២លានដុល្លារអាមេរិក។

ក្នុងអំឡុងពេលពីឆ្នាំ២០១៤ មកទល់ឆ្នាំ២០១៦នេះ មានក្រុមហ៊ុនឯកជនចំនួន ០៦ក្រុមហ៊ុន ដែលបានចូលរួមធ្វើការវិនិយោគអភិវឌ្ឍន៍គម្រោងបញ្ជូនអគ្គិសនី និងការចែកចាយអគ្គិសនីមានសេវាករឯកជនក្នុងស្រុកចំនួន ៣៤០នាក់ កំពុងចូលរួមយ៉ាងសកម្មក្នុងការវិនិយោគអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយ និងផ្តល់សេវាផ្គត់ផ្គង់អគ្គិសនីឲ្យតំបន់ជនបទ។ ជាលទ្ធផលរួម ចំពោះប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនីលាតសន្ធឹងពីខេត្តព្រះសីហនុកាត់តាមរាជធានីភ្នំពេញ ទៅដល់ខេត្តកំពង់ចាមភាគខាងកើត និងទៅដល់ខេត្តសៀមរាបនៅភាគខាងជើងឆៀងខាងលិច ព្រមទាំងភ្ជាប់ពីខេត្តពោធិ៍សាត់ទៅខេត្តកោះកុង។ គម្រោងពង្រីកខ្សែបណ្តាញជាតិដែលបានអនុម័ត និងកំពុងសាងសង់មានចំនួន ១០គម្រោង មានប្រវែង ១ ២១១គ.ម និងអនុស្ថានីយ៍ចំនួន ១០កន្លែងដែលគ្របដណ្តប់ខេត្តចំនួន៧ទៀត គឺខេត្តក្រចេះ ស្ទឹងត្រែង ព្រៃវែង ស្វាយរៀង ព្រះវិហារ ប៉ៃលិន និងខេត្តកំពង់ធំ នឹងត្រូវបញ្ចប់ការសាងសង់នៅឆ្នាំ២០១៨ ដោយផ្នែកឯកជន។

### ៣.១- ប្រភពផលិតកម្មអគ្គិសនី

នៅឆ្នាំ២០១៦ បរិមាណប្រភពថាមពលអគ្គិសនីដែលបានផលិត និងនាំចូលទូទាំងប្រទេសមានចំនួន ៧ ១៧៥,០៥លានគីឡូវ៉ាត់ម៉ោង បើប្រៀបធៀបនឹងឆ្នាំ២០១៥ ដែលមានត្រឹមតែ ៥ ៩៨៩,៥៦លានគីឡូវ៉ាត់ម៉ោង គឺមានការកើនឡើង ១៩,៧៩%។ សេចក្តីត្រូវការអតិបរមានៅទូទាំងប្រទេសក្នុងប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនីមានប្រមាណ ១ ១០០មេហ្គាវ៉ាត់ ដែលនៅរដូវវស្សាតម្រូវការប្រមាណក្រោម ១ ០០០មេហ្គាវ៉ាត់ ក្នុងនោះតំបន់រាជធានីភ្នំពេញ កំពង់ចាម ប្រមាណ

៧២០មេហ្គាវ៉ាត់ បណ្តាខេត្តភាគខាងត្បូងប្រមាណ ១១០មេហ្គាវ៉ាត់ និងភាគខាងលិច ១៤០មេហ្គាវ៉ាត់។ នៅរដូវវស្សាបានបន្ថយជាអតិបរមានូវការផលិតថាមពលចេញពីប្រភពដែលប្រើប្រេងឥន្ធនៈ ហើយជំនួសមកវិញដោយវារីអគ្គិសនី និងបានកាត់បន្ថយជាអតិបរមានូវការនាំចូលថាមពលតាមរយៈបណ្តាញតង់ស្យុងខ្ពស់ពីបណ្តាប្រទេសជិតខាង គឺការនាំចូលពីប្រទេសថៃបានកាត់បន្ថយរហូតដល់សូន្យមេហ្គាវ៉ាត់ និងពីប្រទេសវៀតណាមកាត់បន្ថយជាអតិបរមាមកនៅត្រឹម ៥០មេហ្គាវ៉ាត់។

## ៣.២- វារីអគ្គិសនី និងរោងចក្រថាមពលអគ្គិសនីដើរដោយធ្យូងថ្ម ដែលបានស្ថាបនា និងដាក់ឲ្យដំណើរការ

១-វារីអគ្គិសនីគិរីរម្យ១ (វារីអគ្គិសនីដំបូងគេបង្អស់នៅប្រទេសកម្ពុជា) ដែលមានអានុភាព ១២មេហ្គាវ៉ាត់ មានទីតាំងនៅខេត្តកំពង់ស្ពឺ និងខេត្តកោះកុង បានដាក់ឲ្យដំណើរការអាជីវកម្មនៅខែកក្កដា ឆ្នាំ២០០៣ ក្នុងរយៈពេលសម្បទាន៣០ឆ្នាំ ដែលបានស្តារ និងសាងសង់ដោយក្រុមហ៊ុន CETIC International Hydropower Development Co.,Ltd។

២-វារីអគ្គិសនីកំចាយដែលមានអានុភាព ១៩៤,១មេហ្គាវ៉ាត់ មានទីតាំងនៅខេត្តកំពត បានដាក់ឲ្យដំណើរការអាជីវកម្មនៅខែសីហា ឆ្នាំ២០១២ ក្នុងរយៈពេលសម្បទាន៤០ឆ្នាំ ដោយធ្វើការវិនិយោគ និងសាងសង់ដោយក្រុមហ៊ុន Sinohydro Kamchay Hydroelectric Project Co.,Ltd។

៣-វារីអគ្គិសនីគិរីរម្យ៣ ដែលមានអានុភាព ១៨មេហ្គាវ៉ាត់ មានទីតាំងនៅខេត្តកោះកុង បានដាក់ឲ្យដំណើរការអាជីវកម្មនៅខែកញ្ញា ឆ្នាំ២០១២ ក្នុងរយៈពេលសម្បទាន ៣០ឆ្នាំ ដោយធ្វើការវិនិយោគ និងសាងសង់ដោយក្រុមហ៊ុន CETIC International Hydropower Development Co.,Ltd។

៤-វារីអគ្គិសនីស្ទឹងអាតៃ ដែលមានអានុភាព ១២០មេហ្គាវ៉ាត់ មានទីតាំងនៅខេត្តពោធិ៍សាត់ បានដាក់ឲ្យដំណើរការអាជីវកម្មនៅខែកញ្ញា ឆ្នាំ២០១៣ ក្នុងរយៈពេលសម្បទាន ៣០ឆ្នាំ ដោយធ្វើការវិនិយោគ និងសាងសង់ដោយក្រុមហ៊ុន C.H.D Cambodia Hydropower Development Co.,Ltd។

៥-វារីអគ្គិសនីឫស្សីជ្រុំក្រោម ដែលមានអានុភាព ៣៣៨មេហ្គាវ៉ាត់ មានទីតាំងនៅខេត្តកោះកុង បានដាក់ឲ្យដំណើរការអាជីវកម្មនៅខែកក្កដា ឆ្នាំ២០១៤ ក្នុងរយៈពេលសម្បទាន ៣០ឆ្នាំ ដោយធ្វើការវិនិយោគ និងសាងសង់ដោយក្រុមហ៊ុន China Huadian Lower Stung Russey Chrum Hydro-Electric Project។

៦-វារីអគ្គិសនីស្ទឹងតាតៃ ដែលមានអានុភាព ២៤៦មេហ្គាវ៉ាត់ មានទីតាំងនៅខេត្តកោះកុង បានដាក់ឲ្យដំណើរការអាជីវកម្មនៅខែធ្នូ ឆ្នាំ២០១៦ ក្នុងរយៈពេលសម្បទាន ៣៧ឆ្នាំ ដោយធ្វើការវិនិយោគ និងសាងសង់ដោយក្រុមហ៊ុន Cambodia Tatay Hydropower។

៧-រោងចក្រអគ្គិសនីដុតធ្យូងថ្ម ដែលមានអានុភាព ១០០មេហ្គាវ៉ាត់ មានទីតាំងនៅខេត្តព្រះសីហនុ បានដាក់ឲ្យដំណើរការអាជីវកម្មនៅឆ្នាំ២០១៣ សាងសង់ដោយក្រុមហ៊ុន Cambodia Energy Limited។

៨-រោងចក្រអគ្គិសនីដុតធ្យូងថ្ម ដែលមានអានុភាព ៤០៥មេហ្គាវ៉ាត់ មានទីតាំងនៅខេត្តព្រះសីហនុ បានដាក់ឲ្យដំណើរការអាជីវកម្មនៅឆ្នាំ២០១៤ (១៣៥MW) ២០១៥(១៣៥MW) និង ២០១៧ (១៣៥MW) សាងសង់ដោយក្រុមហ៊ុន C.I.I.D.G ERDOS HONGJUN ELECTRIC POWER CO.,LTD។

៩-រោងចក្រអគ្គិសនីដុតធ្យូងថ្ម ដែលមានអានុភាព ១០មេហ្គាវ៉ាត់ មានទីតាំងនៅខេត្តកណ្តាល បានដាក់ឲ្យដំណើរការអាជីវកម្មនៅឆ្នាំ២០០៨ សាងសង់ដោយក្រុមហ៊ុនសុវណ្ណភូមិ។

១០-គម្រោងវារីអគ្គិសនីសេសានក្រោម២ (គម្រោងធំជាងគេបង្អស់នៅប្រទេសកម្ពុជា) ដែលមានអានុភាព ៤០០មេហ្គាវ៉ាត់ មានទីតាំងនៅខេត្តស្ទឹងត្រែង នឹងដាក់ឲ្យដំណើរការអាជីវកម្មនៅចុងឆ្នាំ២០១៧នេះ ដោយធ្វើការវិនិយោគ និងសាងសង់ដោយក្រុមហ៊ុន Hydro Power Sesan 2 Co.,Ltd ។

| ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនរង និងប្រព័ន្ធចែកចាយអគ្គិសនី | | | | | |
|---|---|---|---|---|---|
| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| បណ្តាញតង់ស្យុងមធ្យម (គ.ម) | ៧ ៣០៩ | ១១ ៧០១ | ១៧ ៤៥៦ | ២០ ៩០៧ | ២៨ ៨៩១ |
| ត្រង់ស្វូម៉ាទ័រ(គ្រឿង) | ៩ ៧៤៣ | ១១ ០០៣ | ៨ ៥៥៩ | ១០ ៧០៣ | ១២ ៦៧៨ |
| បណ្តាញតង់ស្យុងទាប (គ.ម) | ៤ ៩៣៣ | ៦ ៦៤២ | ១៧ ៤៥២ | ១៩ ៥៨៨ | ២៦ ៦០៥ |
| បរិក្ខារតភ្ជាប់ចរន្ត (ចំនួនតភ្ជាប់) | ៩០០ ៩៨២ | ១ ១២៥ ៦៧៩ | ១ ៣៥០ ០០០ | ១ ៧៥៩ ៧៩៧ | ២ ១៥៩ ៣២៤ |

✡ តារាងទិន្នន័យនៃប្រភពអគ្គិសនីដែលផ្គត់ផ្គង់តម្រូវការអគ្គិសនីនៅកម្ពុជា ២០១២-២០១៣

| ប្រភពអគ្គិសនី | ២០១២ | | | ២០១៣ | | |
|---|---|---|---|---|---|---|
| | MW | លានkWh | % | MW | លានkWh | % |
| **១-ប្រភពអគ្គិសនីក្នុងស្រុក** | | | | | | |
| ប្រភពដុតធ្យូងថ្ម | ១៣ | ៣៧,៤២ | ១,០៦ | ១១០ | ១៦៨,០៥ | ៤,១៥ |
| ប្រភពវារីអគ្គិសនី | ២២៥,៤៣ | ៥១៧,៣៧ | ១៤,៦៧ | ៣៤៤,១០ | ១ ០១៥,៥៤ | ២៥,០៧ |
| ប្រភពដុតប្រេង | ១៩៣,១០ | ៧៤៤,២៧ | ១៤,៦៧ | ២៧៥,៨៩ | ៤៨៧,២៥ | ១២,០៣ |
| ប្រភពថាមពលកកើតឡើងវិញ | ២២,៥០ | ១១,៧៥ | ២១,១០ | ១៤,៥៧ | ៦,០៤ | ០,១៥ |
| ប្រភពផ្ទាល់របស់ឧស្សាហកម្ម និងអ្នកចែកចាយ | ៧៧,៥២ | ១១២,២៩ | ៣,១៨ | ៤៩,៤៣ | ៩២,១៣ | ២,២៧ |
| **សរុបប្រភពអគ្គិ-សនីក្នុងស្រុក** | ៥៣១,៥៥ | ១ ៤២៣,១០ | ៤០,៣៤ | ៧៩៣,៩៩ | ១ ៧៦៩,០១ | ៤៣,៦៧ |

| | | | | | | |
|---|---|---|---|---|---|---|
| **២-ប្រភពអគ្គិសនីនាំចូល** | | | | | | |
| ប្រភពនាំចូលពីថៃ | ៩៥,៥០ | ៥៣៥,០៨ | ១៥,១៧ | ៩៥,៥០ | ៥៧៩,៦០ | ១៤,៣១ |
| ប្រភពនាំចូលពីវៀតណាម | ១៩៦,២៥ | ១ ៥៦០,២៣ | ៤៤,២៣ | ១៩៦,២៥ | ១ ៦៩១,៣១ | ៤១,៧៥ |
| ប្រភពនាំចូលពីឡាវ | ២ | ៩,០១ | ០,២៦ | ២ | ១០,៧៣ | ០,២៦ |
| **សរុបប្រភពនាំចូលអគ្គិសនី** | ២៩៣,៧៥ | ២ ១០៤,៣២ | ៥៩,៦៦ | ២៩៣,៧៥ | ២ ២៨១,៦៤ | ៥៦,៣៣ |
| **៣-សរុបប្រភពអគ្គិសនីទាំងអស់** | ៨២៥,៣០ | ៦៧៩,០៤ | ១០០ | ១ ០៨៧,៧៤ | ៤ ០៥០,៦៥ | ១០០ |

✡ តារាងទិន្នន័យនៃប្រភពអគ្គិសនីដែលផ្គត់ផ្គង់តម្រូវការអគ្គិសនីនៅកម្ពុជា២០១៤-២០១៥

| ប្រភពអគ្គិសនី | ២០១៤ | | | ២០១៥ | | |
|---|---|---|---|---|---|---|
| | MW | លានkWh | % | MW | លានkWh | % |
| **១-ប្រភពអគ្គិសនីក្នុងស្រុក** | | | | | | |
| ប្រភពដុតធ្យូងថ្ម | ១១០ | ៨៤០,៣៣ | ១៧,៨៣ | ៣៦៨ | ២ ២១០,១៤ | ៣៦,៩០ |
| ប្រភពវារីអគ្គិសនី | ៦៨២,១០ | ១ ៨២៩,៧៨ | ៣៨,៨២ | ៩២៧ | ១ ៩៨៨,៣៨ | ៣៣,២០ |
| ប្រភពដុតប្រេង | ១៧៦,៩៨ | ១៥៩,៩០ | ៣,៣៩ | ២១៨ | ១១៧,៦៩ | ១,៩៦ |
| ប្រភពថាមពលកកើតឡើងវិញ | ១៦,៥៧ | ២,៩០ | ០,០៦ | ១៦,៦៧ | ៣៨,០៤ | ០,៦៤ |
| ប្រភពផ្ទាល់របស់ឧស្សាហកម្ម និងអ្នកចែកចាយ | ៣៩,៥៤ | ៨៥,៩២ | ១,៨៣ | ៣៩,៥៤ | ៩៤ | ១,៥៧ |
| **សរុបប្រភពអគ្គិសនីក្នុងស្រុក** | ១ ០២៥,១៩ | ២ ៩១៨,៨៣ | ៦១,៩៣ | ១ ៥៦៩,១១ | ៤ ៤៤៨,២៥ | ៧៤,២៧ |
| **២-ប្រភពអគ្គិសនីនាំចូល** | | | | | | |
| ប្រភពនាំចូលពីថៃ | ១៣៥,៥០ | ៥២៤,២០ | ១១,១២ | ១៣៥,៥០ | ២៤៣,៥០ | ៤,០៧ |
| ប្រភពនាំចូលពីវៀតណាម | ១៩៦,២៥ | ១ ២៥៦,២៣ | ២៦,៦៥ | ២៧៧ | ១ ២៨០,០៦ | ២១,៣៧ |
| ប្រភពនាំចូលពីឡាវ | ២ | ១៣,៧៧ | ០,២៩ | ៤ | ១៧,៣៧ | ០,២៩ |
| **សរុបប្រភពនាំចូលអគ្គិសនី** | ៣៣៣,៧៥ | ១ ៧៩៤,២០ | ៣៨,០៧ | ៤១៦,៥០ | ១ ៥៤១,៣១ | ២៥,៧៣ |
| **៣-សរុបប្រភពអគ្គិសនីទាំងអស់** | ១ ៣៥៨,៩៤ | ៤ ៧១៣,០៣ | ១០០ | ១ ៩៨៥,៦១ | ៥ ៩៨៩,៥៦ | ១០០ |

✡ តារាងទិន្នន័យនៃប្រភពអគ្គិសនីដែលផ្គត់ផ្គង់តម្រូវការអគ្គិសនីនៅកម្ពុជា២០១៦

| ប្រភពអគ្គិសនី | ២០១៦ | | |
|---|---|---|---|
| | MW | លានkWh | % |
| **១-ប្រភពអគ្គិសនីក្នុងស្រុក** | | | |
| ប្រភពដុតធ្យូងថ្ម | ៣៦៨ | ២ ៥៥១,១៧ | ៣៥,៥៦ |
| ប្រភពវារីអគ្គិសនី | ៩២៧ | ២ ៦១៩,១១ | ៣៦,៥០ |
| ប្រភពដុតប្រេង | ២១៨ | ៣៦២,១៣ | ៥,០៥ |
| ប្រភពថាមពលកកើតឡើងវិញ | ៣៩,២៧ | ៤៣,៣៥ | ០,៦០ |
| ប្រភពផ្ទាល់របស់ឧស្សាហកម្ម និងអ្នកចែកចាយ | ៣៩,៧៩ | ១៦,៤៤ | ០,២៣ |
| **សរុបប្រភពអគ្គិសនីក្នុងស្រុក** | ១ ៥៩២,០៦ | ៥ ៥៩២,២០ | ៧៧,៩៤ |
| **២-ប្រភពអគ្គិសនីនាំចូល** | | | |
| ប្រភពនាំចូលពីថៃ | ១៣៥,៥០ | ៣៤,១៩ | ៤,៨២ |
| ប្រភពនាំចូលពីវៀតណាម | ២៧៧ | ១ ២០១,៧៨ | ១៦,៧៥ |
| ប្រភពនាំចូលពីឡាវ | ៤ | ៣៤,៨៨ | ០,៤៩ |
| **សរុបប្រភពនាំចូលអគ្គិសនី** | ៤១៦,៥០ | ១ ៥៨២,៨៥ | ២២,០៦ |
| **៣-សរុបប្រភពអគ្គិសនីទាំងអស់** | ២ ០០៨,៥៦ | ៧ ១៧៥,០៥ | ១០០ |

### ៣.៣- ការអភិវឌ្ឍអគ្គិសនីតាមប្រព័ន្ធ និងតាមប្រភេទនីយកម្មជនបទ

នៅចុងឆ្នាំ២០១៦ ការអភិវឌ្ឍប្រព័ន្ធបណ្តាញជាតិតង់ស្យុងខ្ពស់របស់កម្ពុជា ក្រៅពីបានតភ្ជាប់ជាមួយប្រព័ន្ធបណ្តាញតង់ស្យុងខ្ពស់ប្រទេសវៀតណាម និងប្រព័ន្ធបណ្តាញតង់ស្យុងខ្ពស់ប្រទេសថៃ និងភ្ជាប់ជាមួយប្រភពវារីអគ្គិសនីនៅតំបន់កំពង់ស្ពឺ កោះកុង និងពោធិ៍សាត់ ប្រភពវារីអគ្គិសនីនៅតំបន់ជួរភ្នំគិរីរម្យ និងជួរភ្នំកំចាយ ព្រមទាំងភ្ជាប់ជាមួយប្រភពអគ្គិសនីផលិតដោយធ្យូងថ្មនៅខេត្តព្រះសីហនុ។ ការផ្គត់ផ្គង់អគ្គិសនីរបស់ប្រព័ន្ធបណ្តាញជាតិនេះក៏បានគ្របដណ្តប់ផ្ទាល់លើរាជធានីខេត្ត ចំនួន១៤ គឺ រាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ តាកែវ កំពត កែប ព្រះសីហនុ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប កំពង់ចាម និងខេត្តកោះកុងរួចហើយ និងបានបញ្ជូនប្រភពអគ្គិសនីតាមរយៈបណ្តាញបញ្ជូនរងទៅជួយខេត្ត៤ទៀត គឺខេត្តត្បូងឃ្មុំ ព្រៃវែង កំពង់ធំ និងខេត្តប៉ៃលិន។ ការអភិវឌ្ឍប្រព័ន្ធបណ្តាញជាតិតង់ស្យុងខ្ពស់ជាបន្តបន្ទាប់ខាងលើនេះបានបើកឱកាស និងលទ្ធភាពឲ្យក្រសួងរ៉ែ និងថាមពល បន្តជំរុញការអភិវឌ្ឍប្រភពអគ្គិសនីផ្សេងៗទៀតជាច្រើនគម្រោង ទាំងប្រភពអគ្គិសនីនាំចូល និងទាំងស្ថានីយផលិតអគ្គិសនីក្នុងស្រុកតាមបច្ចេកទេសផ្សេងៗ។ គម្រោងប្រភពអគ្គិសនីដែលបានសាងសង់រួច និងដាក់ឲ្យដំណើរការបញ្ចូលថាមពលក្នុងប្រព័ន្ធបណ្តាញជាតិជាបន្តបន្ទាប់មានចំនួន១៤គម្រោង គឺ ១-ការនាំចូលថាមពលពីប្រទេសវៀតណាម ១៧០មេហ្គាវ៉ាត់ ២-ការនាំចូលអគ្គសនីពីប្រទេសថៃ ១២១មេហ្គាវ៉ាត់ ៣-ការនាំចូលអគ្គិសនីពីប្រទេស

ឡាវ ០៥មេហ្គាវ៉ាត់ ៤-វារីអគ្គិសនីគិរីរម្យ១ អានុភាព ១២មេហ្គាវ៉ាត់ ៥-វារីអគ្គិសនីកំចាយអានុភាព ១៩៤,១មេហ្គាវ៉ាត់ នៅខេត្តកំពត ៦-វារីអគ្គិសនីគិរីរម្យ៣ អានុភាព ១៨មេហ្គាវ៉ាត់ នៅខេត្តកំពង់ស្ពឺ ៧-វារីអគ្គិសនីស្ទឹងអាតៃ អានុភាព ១២០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់ ៨-វារីអគ្គិសនីស្ទឹងតាតៃ អានុភាព ២៤៦មេហ្គាវ៉ាត់ នៅខេត្តកោះកុង ៩-វារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម អានុភាព ៣៣៨មេហ្គាវ៉ាត់ នៅខេត្តកោះកុង ១០-រោងចក្រអគ្គិសនីដុតកាកអំពៅនៅតំបន់ឱរ៉ាល់ ខេត្តកំពង់ស្ពឺ អានុភាព ២០មេហ្គាវ៉ាត់ ១១-រោងចក្រអគ្គិសនីដុតកាកអំពៅនៅខេត្តក្រចេះ អានុភាព ២០មេហ្គាវ៉ាត់ ១២-រោងចក្រអគ្គិសនីដុតធ្យូងថ្មទី១ ជំហានទី១ អានុភាព ១០០មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ ១៣-រោងចក្រអគ្គិសនីដុតធ្យូងថ្មទី១ ជំហានទី២ អានុភាព ២ x ១៣៥មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ និង ១៤-រោងចក្រអគ្គិសនីដុតធ្យូងថ្មទី២ ជំហានទី១ អានុភាព ១៣៥មេហ្គាវ៉ាត់ នៅខេត្តព្រះសីហនុ បានដាក់ឲ្យដំណើរការសាកល្បងចុងឆ្នាំ២០១៦។ ក្រៅពីនេះក៏មានវារីអគ្គិសនីសេសានក្រោម២ អានុភាព ៤០០មេហ្គាវ៉ាត់ នៅខេត្តស្ទឹងត្រែង គ្រោងដាក់ដំណើរការចុងឆ្នាំ២០១៧នេះ។

### ៣.៤- ការផ្គត់ផ្គង់អគ្គិសនីជនបទ

ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ និងបង្កើតសុខដុមនីយភាព នៃការរស់នៅរបស់ប្រជាជន នៅតំបន់ជនបទរហូតដល់ចុងឆ្នាំ២០១៦ អាជ្ញាបណ្ណដែលបានចេញឲ្យសម្រាប់ធ្វើការផ្គត់ផ្គង់អគ្គិសនីមាន ៣៤២អាជ្ញាបណ្ណរួចហើយ ដែលក្នុងនោះព្រំដែននៃតំបន់ចែកចាយគ្របដណ្ដប់លើភូមិ ១៣ ៨០៣ភូមិ ត្រូវជា ៩៧,៤២% នៃចំនួនភូមិសរុប ១៤ ៣៦៤ នៅទូទាំងប្រទេសកម្ពុជា។ ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីដែលបានធ្វើការអភិវឌ្ឍន៍រួចមាន ៖ ខ្សែបណ្ដាញតង់ស្យុងមធ្យម ២៨ ៨៩២គ.ម ត្រង់ស្វូម៉ាទ័រចែកចាយចំនួន ១២ ៦០៥គ្រឿង ខ្សែបណ្ដាញចែកចាយតង់ស្យុងទាប ២៦ ៦៧៩គ.ម និងបរិក្ខារភ្ជាប់ចរន្តសរុប ២ ១៥៩ ៣២៤ ទីតាំងប្រើប្រាស់អគ្គិសនី ដែលនៅក្នុងនោះមានទីតាំងប្រើប្រាស់ ដែលជាប្រភេទគេហដ្ឋាន ១ ៩១០ ០០០ខ្នងផ្ទះ ត្រូវជា ៥៨,២៣% ធៀបនឹងចំនួនផ្ទះសរុបប្រមាណ ៣ ២៨០ ០០០ខ្នងផ្ទះ តាមស្ថិតិនៅឆ្នាំ២០១៦នេះ។ ហេដ្ឋារចនាសម្ព័ន្ធដែលបានសាងសង់ហើយទាំងនេះបានផ្ដល់លទ្ធភាពឲ្យព្រះរាជាណាចក្រកម្ពុជាអាចធ្វើការផ្គត់ផ្គង់អគ្គិសនីឱ្យភូមិ ១០ ៥៨៩ភូមិ ត្រូវជា ៧៤,៧៤% នៃចំនួនភូមិសរុបរបស់ព្រះរាជាណាចក្រកម្ពុជារួចហើយ។

ដើម្បីកាត់បន្ថយថ្លៃលក់អគ្គិសនីនៅតំបន់ជនបទនានា ដែលបាននិងកំពុងផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែលតូចៗ ដែលមានថ្លៃអគ្គិសនីខ្ពស់ជាង ២ ០០០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង រាជរដ្ឋាភិបាលបានដាក់ចុះនូវយុទ្ធសាស្ត្រឲ្យធ្វើការអភិវឌ្ឍន៍បណ្ដាញអគ្គិសនី ដើម្បីរុញប្រភពអគ្គិសនីដែលមានថ្លៃអគ្គិសនីទាបជាង ជាពិសេសប្រភពអគ្គិសនីពីបណ្ដាញជាតិទៅជំនួសការផលិតអគ្គិសនីពីម៉ាស៊ីនដៀសែលទាំងនោះ។ អនុវត្តតាមយុទ្ធសាស្ត្រនេះ រហូតមកដល់ចុងឆ្នាំ២០១៦ ក្នុងចំណោមដែនអាជ្ញាបណ្ណដែលបានគ្របដណ្ដប់លើភូមិ ១៣ ៨០៣ភូមិ គឺមាន ភូមិ ១០ ៧៣៦ភូមិ ត្រូវជា ៧៥,៧៧% នៃចំនួនភូមិសរុបទូទាំងប្រទេស បានទទួលប្រភពអគ្គិសនីពីបណ្ដាញជាតិរួចហើយ

ក្រៅពីនោះ ក៏មានតំបន់អាជ្ញាបណ្ណ ២ ៥៣៣ភូមិ ត្រូវជា ១៧,៨៨% នៃចំនួនភូមិសរុបទូទាំងប្រទេស ក៏បានទទួលការផ្គត់ផ្គង់តាមរយៈការនាំចូលប្រភពអគ្គិសនីពីប្រទេសជិតខាង តាមបណ្ដាញតង់ស្យុងមធ្យម។ នៅចុងឆ្នាំ២០១៦នេះ ការផ្គត់ផ្គង់អគ្គិសនីដែលនៅពឹងផ្អែកលើការផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែលតូចៗ នៅសល់តែតំបន់ដែនអាជ្ញាបណ្ណ ៥៣៤ភូមិ ត្រូវជា ៣,៧៦% នៃចំនួនភូមិសរុបប៉ុណ្ណោះ។

ប្រជាពលរដ្ឋដែលប្រើប្រាស់អគ្គិសនីពីបណ្ដាញជាតិដែលមានបរិមាណមិនលើសពី៥០គីឡូវ៉ាត់ម៉ោងក្នុងមួយខែ គឺមានតម្លៃតែ ៦១០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង ចាប់ពីខែមេសា ឆ្នាំ២០១៧តទៅ។ ចំពោះការប្រើប្រាស់ទូទៅរបស់ប្រជាពលរដ្ឋ តម្លៃអគ្គិសនីនឹងបញ្ចុះមកត្រឹម ៧៣០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោងសម្រាប់តំបន់ផ្គត់ផ្គង់អគ្គិសនីដោយអគ្គិសនីកម្ពុជា និង ៧៥០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោងសម្រាប់តំបន់ផ្គត់ផ្គង់អគ្គិសនីដោយឯកជននៅឆ្នាំ២០២០។ សម្រាប់អ្នកប្រើប្រាស់អគ្គិសនីមិនលើសពី១០គីឡូវ៉ាត់ម៉ោងក្នុងមួយខែ និងសហគមន៍កសិករដែលប្រើប្រាស់សម្រាប់បូមទឹកបង្កបង្កើនផលនៅពេលយប់ គឺមានតម្លៃតែ ៤៨០រៀលក្នុងមួយគីឡូវ៉ាត់។

បន្ថែមពីលើនេះ ដើម្បីជួយជំរុញឲ្យមានសមធម៌ក្នុងការទទួលសេវាកម្មអគ្គិសនី ដោយជួយឲ្យប្រជាជននៅជនបទទទួលបានអគ្គិសនីប្រើប្រាស់តាមថ្លៃមួយដែលអាចជាវបាន។ រួមចំណែកកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទរបស់អគ្គិសនីកម្ពុជាបានផ្ដល់ថវិកា២២លានដុល្លារអាមេរិក ដើម្បីជួយជំរុញការពង្រីកបណ្ដាញផ្គត់ផ្គង់អគ្គិសនីនៅជនបទដាច់ស្រយាល ជួយឲ្យគ្រួសារក្រីក្រនៅជនបទអាចមានលទ្ធភាពភ្ជាប់ចរន្តអគ្គិសនី និងជួយឲ្យគ្រួសារជនបទដាច់ស្រយាលពីបណ្ដាញផ្គត់ផ្គង់ អាចមានចរន្តអគ្គិសនីប្រើប្រាស់ពីប្រព័ន្ធពន្លឺព្រះអាទិត្យ ដែលមានសមិទ្ធផលសំខាន់ៗដូចជា ៖ ១-ផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រជនបទ ៤ ៣៩៩គ្រួសារ ២-ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ៤២ ០៤០ប្រព័ន្ធ ៣-ឧបត្ថម្ភទុនសម្រាប់ពង្រីក និងកែលំអការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទប្រវែង ៦ ២៩៦គ.ម។

### ៣.៥- ការតភ្ជាប់ចរន្តអគ្គិសនីចូលបន្ទប់ស្នាក់នៅរបស់កម្មករ

-គិតមកដល់ដំណាច់ឆ្នាំ២០១៦នេះ ការតភ្ជាប់ចរន្តអគ្គិសនីចូលបន្ទប់ស្នាក់នៅរបស់កម្មករសម្រេចបាន **២៥០ ១៣៤** បន្ទប់។

### ៣.៦- វិស័យធនធានរ៉ែ

ក្រសួងរ៉ែ និងថាមពល បានប្រមូលចំណូលពីវិស័យធនធានរ៉ែ គិតចាប់ពីឆ្នាំ២០១២ ដល់ចុងឆ្នាំ២០១៦ សរុប ៨,៥៩៣ពាន់លានរៀល និង ៣១,២លានដុល្លារអាមេរិក។ បន្ថែមពីចំណូលដែលបានរៀបរាប់ខាងលើ ក្រសួងក៏បានប្រមូលកាតព្វកិច្ចហិរញ្ញវត្ថុ ថវិកាមូលនិធិអភិវឌ្ឍន៍មូលដ្ឋានបាន ចំនួន ៦៦៣ពាន់ដុល្លារអាមេរិក ហើយមកទល់ពេលនេះក្រសួងបានសម្រេចផ្គត់ផ្គង់ថវិកា សម្រាប់អភិវឌ្ឍន៍មូលដ្ឋានដែលរងផលប៉ះពាល់ផ្ទាល់ពីអាជីវកម្មរ៉ែក្នុងខេត្តកំពង់ស្ពឺ និងខេត្តកណ្ដាលបានចំនួន ១៦៦,៥៥ពាន់ដុល្លារអាមេរិក។

គិតចាប់ពីឆ្នាំ២០១២មកដល់ចុងឆ្នាំ២០១៦នេះ ក្រសួងបានបញ្ចប់អាជ្ញាបណ្ណពាក់ព័ន្ធនឹងវិស័យរ៉ែចំនួន ៣៤០អាជ្ញាបណ្ណ ក្នុងនោះមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មរ៉ែចំនួន ១អាជ្ញាបណ្ណរ៉ែសំណង់ចំនួន ២៤៧ និងអាជ្ញាបណ្ណស្វែងរុករកចំនួន ៩២អាជ្ញាបណ្ណ។ ក្រសួងបានចាត់វិធានការតាមផ្លូវច្បាប់ចំពោះក្រុមហ៊ុនចំនួន០៣ ដោយដាក់បណ្តឹងទៅតុលាការ ដើម្បីអនុវត្តការផាកពិន័យ និងផ្តន្ទាទោសជនល្មើសឲ្យទទួលខុសត្រូវតាមផ្លូវច្បាប់ជាធរមាន។ ក្នុងអំឡុងពេលនេះ ក្រសួងបានចេញអាជ្ញាបណ្ណពាក់ព័ន្ធវិស័យធនធានរ៉ែសរុបចំនួន ២៨៦អាជ្ញាបណ្ណ ដែលក្នុងនោះមានអាជ្ញាបណ្ណរ៉ែសំណង់ចំនួន ២៧៤ អាជ្ញាបណ្ណស្វែងរុករកចំនួន ០៦ អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែចំនួន ០៦។

តាមរយៈការអនុវត្តកម្មវិធីការងារអធិការកិច្ចលើវិស័យរ៉ែ និងយន្តការទទួលបណ្តឹងបានធ្វើឲ្យក្រសួងអាចកាត់បន្ថយនូវសកម្មភាពអាជីវកម្មរ៉ែអនាធិបតេយ្យបានយ៉ាងច្រើន ជាពិសេសពាក់ព័ន្ធទៅនឹងការលុបបំបាត់អាជីវកម្មបូមខ្សាច់អនាធិបតេយ្យតាមដងទន្លេមេគង្គបានទាំងស្រុង។

ក្រុមការងារអធិការកិច្ចក៏បានសហការជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធក្នុងការអប់រំ និងលើកកម្ពស់ការទទួលខុសត្រូវក្នុងការចូលរួមកាត់បន្ថយផលប៉ះពាល់បរិស្ថាន ក្នុងការដឹកជញ្ជូនផលិតផលរ៉ែ ជាពិសេសការដឹកជញ្ជូនអាចម៍ដីនិងខ្សាច់។ គិតមកដល់ពេលនេះក្រុមការងារបានអប់រំ និងចាត់វិធានការចំពោះអ្នកបើកបរ និងក្រុមហ៊ុនដឹកជញ្ជូនចំនួន ៣៥១ករណី និងដាក់ពិន័យចំនួន ២៦៧ករណី។

ក្រសួងរ៉ែ និងថាមពល បានចាប់ផ្តើមរៀបចំគ្រប់គ្រងវិស័យដោនស្ទ្រីម (downstream) ហើយបានប្រមូលចំណូលសេវាសាធារណៈពីវិស័យនេះចាប់តាំងពីចុងឆ្នាំ២០១៥មកទល់បច្ចុប្បន្ន។ ចំពោះវិស័យអាប់ស្ទ្រីម (upstream) ក្រុមហ៊ុនដែលបានចុះកិច្ចព្រមព្រៀងប្រេងកាតជាមួយនឹងរាជរដ្ឋាភិបាល បានបន្តបង់កាតព្វកិច្ចហិរញ្ញវត្ថុស្របតាមកិច្ចព្រមព្រៀងតាមកាលកំណត់ដែលគិតចាប់ពីឆ្នាំ២០១៤មកដល់ដំណាច់ឆ្នាំ២០១៦នេះ ចំណូលពីវិស័យប្រេងកាតបានចំនួនជាង ៤១ ៦៤៨,០៩លានរៀល ក្នុងនោះក្រសួងបានប្រមូលបំណុលប្រាក់រង្វាន់ចុះហត្ថលេខាកិច្ចព្រមព្រៀងប្រេងកាតរបស់ក្រុមហ៊ុន RPL បានចំនួន ១០លានដុល្លារអាមេរិក។

## ៤-ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍

### ក-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍

-គិតមកដល់ឆ្នាំ២០១៦នេះ អត្រាអ្នកប្រើប្រាស់ទូរស័ព្ទចល័ត និងអចល័តនៅទូទាំងប្រទេសឡើងដល់ចំនួន ១៩ ៦៨០ ៥០៤នាក់ ស្មើនឹង ១២៥,៩៤% ក្នុងចំណោមប្រជាពលរដ្ឋ ១០០នាក់ ក្នុងនោះ ទូរស័ព្ទចល័ត មានចំនួន ១៩ ៤៥០ ៥៤២នាក់ ស្មើនឹង ១២៤,៤៧% ក្នុងចំណោមប្រជាពលរដ្ឋ ១០០នាក់ និងទូរស័ព្ទអចល័ត ២២៩ ៩៦២គ្រឿង ស្មើនឹងអត្រា ១,៤៥% ក្នុងចំណោមប្រជាពលរដ្ឋ ១០០នាក់។ អត្រាអ្នកប្រើប្រាស់អ៊ិនធឺណែតចល័ត និងអចល័តនៅទូទាំងប្រទេសកើនឡើងដល់ចំនួន ៧ ៥៧៥ ៥២២នាក់ ស្មើនឹងអត្រា ៤៨,៤៨% ក្នុងចំណោមប្រជាពលរដ្ឋ ១០០នាក់។

-គិតមកដល់ឆ្នាំ២០១៦នេះ ចំនួនប្រតិបត្តិករទូរគមនាគមន៍កំពុងធ្វើអាជីវកម្មទូរស័ព្ទចល័តមាន ០៦ (Viettel, Smart Axiata, CamGSM, XinWei, South East Asia Telecom(Sea Tel), Cadcomms) ទូរស័ព្ទអចល័តមាន ០៨ (Cadcomms,Cam GSM, Camintel, Smart Axiata, South East Asia Telecom(Sea Tel), Telecom Cambodia(T.C), Viettel, XinWei) អ៊ិនធើណែតមាន ៣៣ (Angkor Data Communication Group Co.,Ltd(MekongNet0, Anco Cable TV Internet, ATA Telecom, BDKTEL(Y5Net), CAMBO Technology, Camintel, Cambodia Broadband Technologies, Chuan Wai (Cabodia), CIDC info Technology, City Link, COGETEL(Online), DTV Star(Digi), EMAXX Telecom(kingtel), EZECOM, G-TELL(Mega), HT Network, King Technology (OpenNet), Maximum Business Information Technology, Neocom ISP Limited, NTT Communication Technology, Neocom ISP Limited NTT Communications, PPTCV, S.I Group(SINET), Saturn Holding Group, South East Asia Telecom(SEATel), SingMeng Telemedia (Cambodia), Telco Tech, Telecom Cambodia(T.C), Viettel(Cambodia)(Metfone), Wicam Corporation, World City(Camko),Xin Wei(Cambodia)Telecom(Cootel) ប្រព័ន្ធ 3G មាន ០៦ មាត់ច្រកអន្តរជាតិមាន ០៣សេវា VoIP មាន ១៩ និង VSAT មាន ០៦។

-ការអភិវឌ្ឍទូរគមនាគមន៍ជនបទ ដោយប្រើប្រាស់ប្រាក់កម្ចី និងការវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធកាប្លិ៍អុបទិក មានប្រវែងសរុប ២៩ ៨០០គ.ម. គិតជាទឹកប្រាក់វិនិយោគមានប្រមាណ ៦៤៣លានដុល្លារអាមេរិក ក្នុងនោះ ទី១ ក្រុមហ៊ុនទូរគមន៍កម្ពុជា(TC) ប្រវែង ១ ៩៣៧គ.ម ទី២ ក្រុមហ៊ុន CFOCN ប្រវែង ១៣ ០៣១គ.ម និងទី៣ ក្រុមហ៊ុន VIETTEL ប្រវែង ១៧ ២០០គ.ម។ រចនាសម្ព័ន្ធឆ្អឹងខ្នងរបស់ក្រុមហ៊ុនទាំងនេះ ត្រូវបានតភ្ជាប់ទៅសាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងព្រះរាជាណាចក្រថៃឡង់ដ៍។

**ខ-ការងារទិសាលគមន៍ប្រេកង់សំចិន្ទ** មានដូចខាងក្រោម ៖

| | |
|---|---|
| -វិទ្យុអាម៉ាទ័រ(Amateur Radio) | ចំនួន ១៧គ្រឿង |
| -វិទ្យុទាក់ទង(RadioCom) | ចំនួន ១ ២២៥គ្រឿង |
| -វិទ្យុផ្សាយសម្លេងFM | ចំនួន ៩១គ្រឿង |
| -វិទ្យុផ្សាយសម្លេងAM | ចំនួន ៥គ្រឿង |
| -ទូរទស្សន៍ TV(VHF) | ចំនួន ១០គ្រឿង |
| -ទូរទស្សន៍ TV(UHF) | ចំនួន ១៤០គ្រឿង |
| -ទូរទស្សន៍ TV(UHF DVB-T) | ចំនួន ៨៤គ្រឿង |
| -វិទ្យុម៉ៃក្រូវ៉េវ Microwave | ចំនួន ២ ២៨៨គ្រឿង |

- វិទ្យុ Base Telephone ចំនួន ២៧គ្រឿង
- វិទ្យុ Base BWA ចំនួន ២៦គ្រឿង
- វិទ្យុ Mobile Satellite ចំនួន ២គ្រឿង
- Meteorology( Radar ) ចំនួន ១គ្រឿង

**សរុប ចំនួន ៣ ៨៧៦គ្រឿង**

ក្រសួងបានផ្តល់អាជ្ញាបណ្ណសេវាបញ្ជើធាប់រហ័សអន្តរជាតិដល់ក្រុមហ៊ុនចំនួន ២៦ និងភ្នាក់ងារប្រៃសណីយ៍ចំនួន៥។ លទ្ធផលហិរញ្ញវត្ថុ គិតជាដុល្លារអាមេរិក ៖

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ចំណូល | ៤ ០៥៤ ៧២៧ | ៤ ៥៦៣ ០៩៣ | ៥ ១៩៨ ៥០៧ | ៥ ៤៥៧ ៤៩៧ | ៩ ០៩៥ ០០៩ |

| តារាងប្រៀបធៀបលទ្ធផលប្រមូលចំណូលសរុប | | |
|---|---|---|
| បរិយាយ | ប្រាក់រៀល | ប្រាក់ដុល្លារអាមេរិក |
| ២០១២ | ១៩ ៤៥៣ ៥៣០ ៦៣៣ | ១៦ ៧០០ ២៣៤ |
| ២០១៣ | ៧ ៤៦២ ៤៨៦ ៩៤៨ | ២០ ១០៤ ៧១៩ |
| ២០១៤ | ១ ៥៣១ ៤៩០ ៤២៤ | ២៣ ៩០៤ ១៨៤ |
| ២០១៥ | ២៧៣ ១៧០ ១០០ | ២៨ ៤៨១ ៤៧៩ |
| ២០១៦ | ១៥១ ៥១៥ ៥២០ | ៣១ ១២០ ៨៦៧ |

## គ-ការខារព័ត៌មាន

### -ស្ថានីយទូរទស្សន៍

| ឆ្នាំ | ២០១២ | | ២០១៣ | | ២០១៤ | | ២០១៥ | | ២០១៦ | |
|---|---|---|---|---|---|---|---|---|---|---|
| ទីកន្លែង | ភ្នំពេញ | ខេត្ត | ភ្នំពេញ | ខេត្ត | ភ្នំពេញ | ខេត្ត | ភ្នំពេញ | ខេត្ត | ភ្នំពេញ | ខេត្ត |
| ប្រព័ន្ធផ្សព្វផ្សាយរដ្ឋ | | | | | | | | | | |
| ស្ថានីយទូរទស្សន៍រដ្ឋ( ទទក ) | ១ | ៧ | ១ | ៧ | ១ | ៥ | ១ | ៥ | ១ | ៥ |
| ស្ថានីយវិទ្យុរដ្ឋ | ៣ | ១៧ | ៣ | ១៧ | ៣ | ១៧ | ៣ | ១៧ | ៤ | ២០ |
| ទីភ្នាក់ងារសារព័ត៌មានរដ្ឋ | ១ | | ១ | | ១ | | ១ | | ១ | |
| ប្រព័ន្ធផ្សព្វផ្សាយឯកជន | | | | | | | | | | |
| ស្ថានីយទូរទស្សន៍ឯកជន | ១២ | ៩ | ១២ | ១០ | ១៣ | ៧ | ១៤ | ៧ | ២១ | ៨ |
| ស្ថានីយទូរទស្សន៍ខ្សែកាប | ១១ | ១៣៨ | ១២ | ១៤៣ | ១៣ | ១៤៣ | ២៦ | ១៤៣ | ២៨ | ១៥០ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ស្ថានីយវិទ្យុឯកជន | ៥១ | ៦៦ | ៥១ | ៦៨ | ៥៣ | ៦៤ | ៧៥ | ៦៤ | ៧៧ | ១៧០ |
| សារព័ត៌មានបោះពុម្ព (កាសែត ព្រឹត្តិប័ត្រ ទស្សនាវដ្តី) និងសារព័ត៌មានអេឡិចត្រូនិច | ៥៧៤ | | ៥៧៤ | | ៥៨០ | | ៨៧៨ | | ៩១៥ | |
| រោងពុម្ព | ១០០ | | ១០០ | | ១០៣ | | ១១៧ | | ១១៨ | |

## III-ការអភិវឌ្ឍវិស័យឯកជន និងការងារ

### ១-ការពង្រឹងវិស័យឯកជន និងជំរុញការវិនិយោគ និងធុរកិច្ច

#### ១.១-ការរៀបគេរ និងតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការជាមួយអាទិភាពអភិវឌ្ឍជាតិ

-ក្នុងអំឡុង៥ឆ្នាំចុងក្រោយ ហិរញ្ញប្បទានសហប្រតិបត្តិការជាមធ្យមមានទំហំ ១,៤ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ។ វិស័យសង្គមកិច្ច ជាវិស័យដែលទទួលបានហិរញ្ញប្បទានសហប្រតិ-បត្តិការ ច្រើនជាងគេប្រមាណ ២,៣ពាន់លានដុល្លារអាមេរិក ស្មើនឹង ៣៤%នៃហិរញ្ញប្បទានសរុប។ ហិរញ្ញប្បទានសហប្រតិបត្តិការគាំទ្រវិស័យហេដ្ឋារចនាសម្ព័ន្ធមានទំហំ ២,២ពាន់លានដុល្លារអាមេរិក (៣១%) វិស័យសេដ្ឋកិច្ចមានទំហំ ១,៥ពាន់លានដុល្លារអាមេរិក (២២%) និងអន្តរវិស័យមានទំហំ ៨៩៩លានដុល្លារអាមេរិក (១៣%)។

-ចាប់ពីឆ្នាំ២០១២-២០១៦ វិស័យដែលទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការច្រើនជាងគេ គឺវិស័យហេដ្ឋារចនាសម្ព័ន្ធ ដែលមានទំហំហិរញ្ញប្បទានសរុបប្រមាណ ១,៦ពាន់លានដុល្លារអាមេរិក ស្មើនឹង២៣%។ ហិរញ្ញប្បទានសម្រាប់វិស័យសុខាភិបាលមានទំហំ៩៤១លានដុល្លារអាមេរិក(១៤%) វិស័យកសិកម្មមានទំហំ ៩២៨លានដុល្លារអាមេរិក (១៣%) វិស័យអប់រំមានទំហំ ៧៩៧ លានដុល្លារអាមេរិក (១១%) និងវិស័យអភិវឌ្ឍន៍សហគមន៍ និងសុខុមាលភាពសង្គមមានទំហំ ៥៤២លានដុល្លារអាមេរិក (៧%)។

#### ១.២-គណៈកម្មាធិការវិនិយោគកម្ពុជា និងគណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

ការពង្រឹងវិស័យឯកជន និងជំរុញការវិនិយោគ និងធុរកិច្ច ៖

-ចាប់ពីឆ្នាំ២០១២-២០១៦លំហូរវិនិយោគផ្ទាល់ពីបរទេសមានចំនួន ៧ពាន់លានដុល្លារអាមេរិក ពោលគឺជាងប្រមាណ ១ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។ ការវិនិយោគមានសក្តានុពលបង្កើតការងារថ្មីជាមធ្យមប្រមាណ ១៩៥ ១៩៨នាក់ក្នុងមួយឆ្នាំ។ គណៈកម្មាធិការវិនិយោគកម្ពុជា បានសម្រេចអនុញ្ញាតឲ្យក្រុមហ៊ុនធ្វើការវិនិយោគលើគម្រោងថ្មី និងពង្រីកផលិតកម្មលើគម្រោងដែលមានស្រាប់ចាប់ពីឆ្នាំ២០១២ រហូតមកដល់ឆ្នាំ២០១៦ សរុបចំនួន ៧១១គម្រោង ដែលមានដើមទុនចុះបញ្ជី

ប្រមាណ ២,៧ពាន់លានដុល្លារអាមេរិក និងទុនវិនិយោគប្រមាណ ១៥,៨ពាន់លានដុល្លារអាមេរិក ដែលក្នុងនោះវិស័យកសិកម្មមានចំនួន ៧០គម្រោង វិស័យទេសចរណ៍មានចំនួន ២៩គម្រោង និងវិស័យផ្សេងៗទៀតចំនួន ៦១២គម្រោង។

-រាជរដ្ឋាភិបាលបានឯកភាពឲ្យមានការបង្កើតតំបន់សេដ្ឋកិច្ចពិសេសចំនួន៤៤។ នៅតាមតំបន់សេដ្ឋកិច្ចពិសេសចំនួន ២១ ដែលបានដំណើរការ មានរោងចក្រចំនួន២៨៨ កំពុងមានសកម្មភាពផលិតដោយប្រើប្រាស់កម្លាំងពលកម្មចំនួន ៨០ ៣១០នាក់។ នៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលកំពុងដំណើរការទាំងនេះ មានការបណ្តាក់ទុនលើគម្រោងវិនិយោគតាមមុខសញ្ញាផលិតកម្មថ្មីក្រៅពីផ្នែកឧស្សាហកម្មកាត់ដេរ មានជាអាទិ៍ ការដំឡើងរថយន្ត ម៉ូតូ កង់ ការផលិតម៉ូទ័រខ្នាតតូច ឧបករណ៍អគ្គិសនី ក្តារបន្ទះ សក់សិប្បនិមិត្ត ធុងអនាម័យ និងការផលិតសម្ភារៈក្មេងលេង។

## ២-ការអភិវឌ្ឍវិស័យឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម

✡✡✡គិតត្រឹមដំណាច់ឆ្នាំ២០១៦នេះ រោងចក្រដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានចំនួនសរុប **១ ៥៧៩រោងចក្រ** ស្មើនឹង ១៧៤% នៃឆ្នាំ២០១២ ក្នុងនោះមានកំណើនខ្លាំងទៅតាមផ្នែកសំខាន់ៗមួយចំនួនដូចជា ផ្នែកអាហារ ភេសជ្ជៈ បារី មាន ១៣៥រោងចក្រ ស្មើនឹង ១៨២% ផ្នែកឧស្សាហកម្មតម្បាញ កាត់ដេរ ចាក់សម្លៀកបំពាក់ ចំនួន ១ ០៧៩រោងចក្រ ស្មើនឹង ១៦០% ផ្នែកផលិតកម្មពីក្រដាស និងក្រដាស ចំនួន ៤៣រោងចក្រ ស្មើនឹង ២៥៣% ផ្នែកផលិតកម្មរ៉ែមិនមែនលោហៈចំនួន ៣១រោងចក្រ ស្មើនឹង ២០៧% ផ្នែកឧស្សាហកម្មគីមី កៅស៊ូ និងប្លាស្ទិកចំនួន ១១០រោងចក្រ ស្មើនឹង ១៨៣% ផ្នែកឧស្សាហកម្មកែច្នៃលោហៈចំនួន ១១១រោងចក្រ ស្មើនឹង ២៤១% ផ្នែកគ្រឿងសង្ហារិម ចំនួន ៣៤រោងចក្រ ស្មើនឹង ២៨៣% និងឧស្សាហកម្មផ្សេងៗទៀតចំនួន ៣៦រោងចក្រ ស្មើនឹង ៤០០%។

✡✡✡គិតត្រឹមដំណាច់ឆ្នាំ២០១៦នេះ កម្លាំងពលកម្មបម្រើឲ្យផ្នែករោងចក្រឧស្សាហកម្ម សរុបចំនួន **៩២១ ៨៥៨នាក់** ស្មើនឹង ១៦៥% បើធៀបនឹងឆ្នាំ២០១២ ក្នុងនោះបម្រើផ្នែកឧស្សាហកម្មកាត់ដេរ និងស្បែកជើង ចំនួន ៧៩៨ ៨១៥នាក់ និងផ្នែកផ្សេងៗចំនួន ១២៣ ០៤៣នាក់។

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| រោងចក្រ | ៩០៧ | ១ ១០៨ | ១ ៣០១ | ១ ៤៥០ | ១ ៥៧៩ |
| កម្លាំងពលកម្ម | ៥៥៩ ៥៨៥ | ៦៨៦ ១៤៧ | ៧៧៨ ៨៧៨ | ៨៥៩ ៥៤៦ | ៩២១ ៨៥៨ |

✡✡✡ចំនួនមូលដ្ឋានសហគ្រាសឧស្សាហកម្មធុនតូច មធ្យម និងសិប្បកម្ម ដែលបានបង្កើតថ្មីនៅឆ្នាំ២០១៦ មានចំនួន ៣១០មូលដ្ឋាន ដែលធ្វើឲ្យចំនួនសរុបមូលដ្ឋានដែលបានចុះបញ្ជី នៅឆ្នាំ២០១៦ មានចំនួន **៣៩ ១៤១មូលដ្ឋាន**។

✡✡✡នៅឆ្នាំ២០១៦នេះ ចំនួនពលកម្មសរុបដែលបម្រើឲ្យសហគ្រាសធុនតូច មធ្យម និងសិប្បកម្ម ដែលបានចុះបញ្ជី មានចំនួន **១៩៧ ០៥៣នាក់**។ ទោះបីចំនួនមូលដ្ឋានផលិតកម្មមាន

ការប្រែប្រួល ដោយថយចុះនៅឆ្នាំ២០១៤ក៏ដោយ ក៏ចំនួនពលកម្មក្នុងរយៈពេល៥ឆ្នាំ (២០១២-២០១៦)មានការកើនឡើងជារៀងរាល់ឆ្នាំ។

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| សហគ្រាស | ៣៨ ៩៥៧ | ៣៩ ១៦៩ | ៣៨ ៤៥៩ | ៣៨ ៨៣១ | ៣៩ ១៤១ |
| ចំនួនពលករ | ១៨៥ ៦២៧ | ១៨៨ ៩១១ | ១៨៩ ២៦០ | ១៩៤ ០៥៣ | ១៩៧ ០៥៣ |

❖❖❖**ផលិតកម្មអំបិល** ជាមុខទំនិញយុទ្ធសាស្ត្រសម្រាប់បម្រើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដែលក្នុងនោះដីស្រែអំបិលមាន ៤ ៣៧៩ហិកតា នៅលើទឹកដីខេត្តកែប និងខេត្តកំពត ដោយអាចផលិតអំបិលបានចំនួនពី ១០០ ០០០តោន ទៅ ១៥០ ០០០តោន/មួយឆ្នាំ អាស្រ័យលើកត្តាអាកាសធាតុ។ បរិមាណនេះអាចប្រើប្រាស់ដល់សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋបានគ្រប់គ្រាន់ ហើយរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើទីផ្សារអំបិល និងការថែរក្សាដីស្រែអំបិល ព្រមទាំងការបញ្ចូលជាតិអ៊ីយ៉ូតទៅក្នុងផលិតផលអំបិល ដើម្បីលើកកម្ពស់សុខភាពប្រជាពលរដ្ឋ។

| អំបិល | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| បរិមាណ(តោន) | ៨៣ ១៤០ | ៥២ ៣៥៣ | ១៤៧ ៨១០ | ១៧៧ ៨១០ | ១៤៨ ៨៨០ |

❖❖❖**ការផលិតទឹកស្អាត**នៅទូទាំងប្រទេស ទាំងអង្គភាពរដ្ឋាករទឹកសាធារណៈរបស់រដ្ឋ និងអាជីវករ/ក្រុមហ៊ុនទឹកស្អាតឯកជន ក្នុងរយៈពេល៥ឆ្នាំ(២០១២-២០១៦) ផលិតបានចំនួន ៩៩៧ ៤១៣ ៣០៤ម៣។

| រដ្ឋាករទឹកស្វយ័ត រាជធានី ខេត្ត និងឯកជន (គិតជា ម៣) | | | | | |
|---|---|---|---|---|---|
| បរិយាយ | រដ្ឋាករទឹកស្វយ័ត រាជធានីភ្នំពេញ | រដ្ឋាករទឹកស្វយ័ត ខេត្តសៀមរាប | រដ្ឋាករទឹក សាធារណៈ | ក្រុមហ៊ុនទឹក ស្អាតឯកជន | អត្រា%នៃប្រជាជន ទទួលបានការ ផ្គត់ផ្គង់ទឹកស្អាត |
| ២០១២ | ១១៨ ៩១៩ ៦៥៨ | ៣ ៧៥៩ ៥៧៨ | ១៤ ២៧៥ ៦៦៤ | ១៦ ៣៤៤ ៣៤១ | ៦៨,៤៦ |
| ២០១៣ | ១៣៦ ០២០ ៥០៥ | ៣ ៩៤៧ ៤២៣ | ១៥ ៥២៩ ៣៤៧ | ២១ ០៣៤ ៧៦៦ | ៧៤,៨៥ |
| ២០១៤ | ១៤៩ ៥៥៧ ៥០៧ | ៤ ៣៤២ ១៦៤ | ១៧ ៦៥៣ ៨០៨ | ២៥ ៤៥០ ០៥០ | ៨១,២៨ |
| ២០១៥ | ១៦១ ៦២៣ ៦៣៧ | ៤ ៧៩៤ ៥១៣ | ១៩ ៩៥៦ ៦២៣ | ៣៤ ០២៧ ៤៤៨ | ៨៨,០១ |
| ២០១៦ | ១៧៩ ៦៣៩ ១៩១ | ៥ ៣៨៥ ៥៩៣ | ២៣ ២៣០ ១៦០ | ៤១ ៩២១ ៣២៨ | ៧៥,០៧ |
| **សរុប** | **៧៤៥ ៧៦០ ៤៩៨** | **២២ ២២៩ ២៧១** | **៩០ ៦៤៥ ៦០២** | **១៣៨ ៧៧៧ ៩៣៣** | |

## ៣-ការអភិវឌ្ឍទីផ្សារការងារ

### ក-ការបង្កើតការងារ

-ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៦ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរកការងារឲ្យប្រជាពលរដ្ឋធ្វើចំនួន ៤៧២ ៥១១នាក់ ដែលជាប្រជាពលរដ្ឋរស់នៅរាជធានីភ្នំពេញ ក្នុងនោះធ្វើការនៅក្នុងប្រទេស ចំនួន ៣១៣ ៩៩២នាក់ និងទៅធ្វើការនៅក្រៅប្រទេសចំនួន ១៥៨ ៥១៩នាក់ តាមរយៈក្រុមហ៊ុនចំនួន ៦៣ក្រុមហ៊ុន និងតាមប្រព័ន្ធអនុញ្ញាតមុខរបរ EPS នៅតាមបណ្តាប្រទេសដូចខាងក្រោម ៖

១-ប្រទេសថៃ ៖ តាមរយៈក្រុមហ៊ុនចំនួន ៥២ មានពលករសរុបចំនួន ១៤០ ៩០០នាក់ (ស្រី ៥៧ ០៥៤នាក់)។

២-ប្រទេសម៉ាឡេស៊ី ៖ តាមរយៈក្រុមហ៊ុនចំនួន ៤ មានពលករសរុបចំនួន ១ ៦៥២នាក់ (ស្រី ១ ០៤៩នាក់)។

៣-សាធារណរដ្ឋកូរ៉េ ៖ តាមរយៈគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស តាមប្រព័ន្ធអនុញ្ញាតមុខរបរ(EPS) ចំនួន ៥០ ៩៨៦នាក់ (ស្រី១០ ០៩៦នាក់)។

៤-ប្រទេសជប៉ុន៖ តាមរយៈក្រុមហ៊ុនចំនួន ៧ មានពលករសរុបចំនួន ៣ ៦៤០នាក់(ស្រី ២ ២៣២នាក់)។

## ខ-ការបង្កើតការងារ និងវិស័យទេសចរណ៍

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ទេសចរជាតិ (លាននាក់) | ៨,២៥ | ៨,៥២ | ៩ | ៩,៦៨ | ១០ |
| ទេសចរអន្តរជាតិ (លាននាក់) | ៣,៥៨ | ៤,២១ | ៤,៥០ | ៤,៧៨ | ៥,០១ |
| ទេសចរកម្ពុជាចេញទៅក្រៅប្រទេស (លាននាក់) | ០,៧៩ | ០,៨៧ | ០,៩៦ | ១,១៩ | ១,៤៣ |
| កម្លាំងពលកម្ម(ពាន់នាក់) | ៣៥០ | ៣៨០ | ៤២៥ | ៤៥៥ | ៦០០ |
| ចំណូលពីវិស័យទេសចរណ៍ (លានដុល្លារអាមេរិក) | ២ ២១០ | ២ ៥៤៧ | ២ ៧៣៦ | ៣ ០១២ | |
| ការស្នាក់នៅ (បន្ទប់) | ៤៦ ៤៤៦ | ៥១ ២២៣ | ៥១ ៩៨៥ | ៦៣ ២៧៩ | |

### ខ.១-ចំនួនភ្ញៀវទេសចរអន្តរជាតិ និងចំណូលពីការទិញសំបុត្រចូលទស្សនារមណីយដ្ឋានអង្គរ

| ឆ្នាំ | ចំនួនភ្ញៀវទេសចរអន្តរជាតិ(នាក់) | ចំណូលពីការទិញសំបុត្រ (ដុល្លារអាមេរិក) |
|---|---|---|
| ២០១២ | ១ ៨០៨ ៦២៣ | ៥១ ៣១៩ ១៨០ |
| ២០១៣ | ២ ០២១ ៧១៥ | ៥៧ ៦៨៧ ៦៨០ |
| ២០១៤ | ២ ០៥៩ ៧០២ | ៥៩ ៣៤២ ០០០ |
| ២០១៥ | ២ ១០០ ០១៨ | ៦០ ០៥៣ ៧០០ |
| ២០១៦ | ២ ១៩៧ ២៥៤ | ៦២ ៥៨២ ២០០ |
| សរុប | ១០ ១៨៧ ៣១២ | ២៣៩ ៦៦៥ ៥៨០ |

### ខ.២-ចំនួនភ្ញៀវទេសចរចូលទស្សនាសារមន្ទីរ

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ភ្ញៀវទេសចរអន្តរជាតិចូលមើលសារមន្ទីរ (គិតជានាក់) | | | | | |
| សារមន្ទីរជាតិភ្នំពេញ | ១០៧ ២១៣ | ១១១ ៧០៥ | ១៥៧ ២៨៧ | ១៧២ ៧៩៥ | ១៩៥ ០៥៤ |
| សារមន្ទីរទួលស្លែង | | | ១៨៨ ៩៧៨ | ៣៧៥ ៣៧៣ | ៣៨៩ ០៦៧ |

| | | | | | |
|---|---|---|---|---|---|
| មណ្ឌលវត្តភ្នំ | ៩១ ៦៩២ | ១៣៦ ០៥៥ | ១៥៣ ៩៨២ | ១១៤ ៣៦៧ | ១៥៧ ០៦៥ |
| មណ្ឌលជើងឯក | ១៨៥ ៩៨០ | ១៣៨ ៦០៣ | ១៦០ ៩៨២ | ២៣២ ៨៦៧ | ២៣២ ៩៧៧ |
| ចំណូលពីភ្ញៀវទេសចរចូលមើលសារមន្ទីរ (គិតជាដុល្លារអាមេរិក) | | | | | |
| សារមន្ទីរជាតិភ្នំពេញ | ៣១៧ ៦៤០ | ៥៥២ ៨៦៧ | ៧៧៤ ៨១៥ | ៨៥៨ ០៩០ | ៩៦៨ ១៣០ |
| សារមន្ទីរទួលស្លែង | | | ៤១០ ១៤៥ | ១ ០៨៦ ៣៧២ | ១ ១៣៥ ៩២៩ |

## ខ.៣-លទ្ធផលការងារសំខាន់ៗរបស់អាជ្ញាធរជាតិអប្សរា

អាជ្ញាធរជាតិអប្សរា បាន ៖

១-ការងារអភិរក្ស និងជួសជុលប្រាសាទ

១.១-ការដ្ឋានអន្តរជាតិ

-ស្ថាប័នសាលាបារាំងចុងបូព៌ា "EFEO" កំពុងបន្តជួសជុលប្រាសាទមេបុណ្យខាងលិច

-ស្ថាប័ន JASA ប្រទេសជប៉ុន សហការជាមួយអាជ្ញាធរជាតិអប្សរា និងអង្គការយូណេស្កូ កំពុងបន្តជួសជុលប្រាសាទបាយ័ន

-ស្ថាប័នស្រាវជ្រាវបុរាណវិទ្យាប្រទេសឥណ្ឌា ASI កំពុងបន្តជួសជុលប្រាសាទតាព្រហ្មដំណាក់កាលទី២

-មូលនិធិប្រាសាទពិភពលោករបស់សហរដ្ឋអាមេរិក WMF កំពុងថតរឿងកូរសមុទ្រទឹកដោះ ប្រាសាទអង្គរវត្ត ប្រាសាទព្រះខ័ន និងប្រាសាទភ្នំបាខែង

-ស្ថាប័ន CSA ប្រទេសចិនកំពុងបន្តជួសជុលប្រាសាទតាកែវ

-សាកលវិទ្យាល័យសូហ្វីយ៉ា ប្រទេសជប៉ុន សហការជាមួយអាជ្ញាធរជាតិអប្សរាកំពុងបន្តជួសជុលស្ពានហាលប្រាសាទអង្គរវត្ត ដំណាក់កាលទី២

-ក្រៅពីនោះស្ថាប័នអន្តរជាតិមួយចំនួនទៀត កំពុងធ្វើការអភិរក្ស និងជួសជុលបេតិកភណ្ឌក្នុងតំបន់រមណីយដ្ឋានអង្គរ និងក្រៅពីរមណីយដ្ឋានអង្គរ ដូចជាស្ថាប័ន KOCHEF ប្រទេសកូរ៉េ កំពុងសិក្សា និងជួសជុលប្រាសាទព្រះពិធូរ សាកលវិទ្យាល័យ NARA ប្រទេសជប៉ុន កំពុងនិងជួសជុលប្រាសាទតុបខាងលិច អង្គការ GACP អាល្លឺម៉ង់ ជួសជុលរូបចម្លាក់នៅប្រាសាទអង្គរវត្ត អង្គការ I-ges ប្រទេសអ៊ីតាលី កំពុងជួសជុលកាំជណ្ដើរប្រាំងកសិណអង្គរវត្ត មូលនិធិ ADF កំពុងស្រាវជ្រាវបុរាណវិទ្យា និងអភិរក្សក្រុមប្រាសាទនៅភ្នំគូលែន។

១.២ ការងារអភិរក្ស និងជួសជុលប្រាសាទដោយអាជ្ញាធរជាតិអប្សរា

១.២.១ ការងារអភិរក្ស និងជួសជុលប្រាសាទក្នុងឧទ្យានអង្គរ

| លរ | បរិយាយ | ចំនួន | កំពុងអនុវត្ត | បញ្ចប់ |
|---|---|---|---|---|
| ១ | ធ្វើកំណាយស្រាវជ្រាវ | ២០កន្លែង | - | ២០ |
| ២ | គម្រោងចងគ្រឹបរចនាសម្ព័ន្ធប្រាសាទ | ៣១កន្លែង | - | ៣១ |
| ៣ | គម្រោងទល់ទ្រកន្លែងគ្រោះថ្នាក់ | ៣៧កន្លែង | - | ៣៧ |

| | | | | |
|---|---|---|---|---|
| ៤ | សង់ជណ្តើរឈើថ្មីនិងស៊ុមការពារថ្មប្រាសាទ | ៣កន្លែង | - | ៣ |
| ៥ | ជួសជុលចម្រឹងបង្អួច | ៣៤ចម្រឹង | ៤ | ៣០ |
| ៦ | ធ្វើកំណល់ឈើតម្កល់ព្រះពុទ្ធរូប | ៦៩ កំណល់ | - | ៦៩ |
| ៧ | ជួសជុលបង្កាន់ដៃនាគ | ៣ទីតាំង | ១ | ២ |
| ៨ | ជួសជុលចម្លាក់តោ | ៤តោ | ១ | ៣ |
| ៩ | ជួសជុលចម្លាក់ផ្តែរ | ៥ផ្តែរ | ១ | ៤ |
| ១០ | ជួសជុលរចនាសម្ព័ន្ធប្រាសាទ (ប្រាំងកសិន្ទុ កម្រាល កំពែង ប៉មឥដ្ឋ) | ២២ទីតាំង | ១០ | ១២ |
| ១១ | ដាក់សំណាញ់ការពារប្រចៀវចូលនៅក្នុងដំបូលប្រាសាទ | ៤ទីតាំង | - | ៤ |
| ១២ | ជួសជុលដំបូលវិហារព្រះអង្គងោក | ១ទីតាំង | - | ១ |
| ១៣ | ចុះបញ្ជីសារពើភ័ណ្ឌលើចម្លាក់ទោលតាមប្រាសាទ | ៩១ប្រាសាទ | ៤០ | ៥០ |

១.២.២ ការងារអភិរក្សនិងជួសជុលប្រាសាទក្រៅឧទ្យានអង្គរ ៖

-បានធ្វើការទល់ទ្រក្រុមប្រាសាទកោះកេរ ចំនួន ០៨ទីតាំង និងសង់ជណ្តើរឡើងប្រាសាទធំ ០១ទីតាំង ប្រាសាទបេងមាលា បន្ទាយអំបិល ប្រាសាទផ្លាង និងប្រាសាទចៅស្រីវិបុល សរុបចំនួន ១៧ទីតាំង

-ជួសជុលស្ពានហាលប្រាសាទបេងមាលា បានប្រវែង ៤៥០ម៉ែត្រ ធ្វើផ្លូវទស្សនាជុំវិញប្រាសាទបានប្រវែង ៩៥០ម៉ែត្រ ទទឹង ២ម៉ែត្រ ធ្វើជណ្តើរ និងស្ពានហាល១កន្លែង

-បោះបង្គោលព្រំការពារឧទ្យានកោះកេរ បានចំនួន១៧បង្គោល និងបេងមាលាបានចំនួន ១៦បង្គោល

-ដាំបង្គោលការពារចម្លាក់លិង្គមួយពាន់ និងទឹជ្លាស្តេចគម្លង់ សរុបចំនួន២៦២ដើម ព្រមទាំងតំបន់ការពាររមណីយដ្ឋានមួយចំនួនទៀត ចំនួន ១៩២ដើម

-ធ្វើប៉ាណូព័ត៌មានបង្ហាញពីបុរាណដ្ឋានចំនួន៥ផ្ទាំង និងស្លាកសញ្ញាការពារព្រៃឧទ្យានចំនួន ៥០ស្លាក

-សង់រោងផ្ទាំ ចំនួន៣ខ្នង និងបង្គន់អនាម័យចំនួន១ខ្នង

-ដាំកូនឈើតាមតំបន់រមណីយដ្ឋានបានចំនួន២៤ ៥២៧ដើម។

២-ការងារអភិវឌ្ឍន៍ទេសចរណ៍-វប្បធម៌

២.១ ចំនួនភ្ញៀវប្រតិភូ អ្នកស្រាវជ្រាវ ចូលទស្សនារមណីយដ្ឋានអង្គរ

| ឆ្នាំ | គណៈប្រតិភូចូលអង្គរ | | អ្នកស្រាវជ្រាវចូលអង្គរ | |
|---|---|---|---|---|
| | ចំនួន(នាក់) | កូតា(នាក់/ថ្ងៃ) | ចំនួន (នាក់) | ចំនួនថ្ងៃ |
| ២០១២ | ៧ ៥១៧ | ១០ ០៤៩ | ៩២៣ | ៩៦ ១០៣ |

| | | | | |
|---|---|---|---|---|
| ២០១៣ | ៤ ៦៦០ | ៦ ៨១០ | ៧២០ | ៧០ ៥០០ |
| ២០១៤ | ៦ ៧០២ | ៩ ៤៤៩ | ៦៧២ | ៤៣ ១០៦ |
| ២០១៥ | ៥ ១៥០ | ៩ ១៩៤ | ១ ៣៩០ | ៧៥ ៤០៩ |
| ២០១៦ | ៦ ៧៦៧ | ១០ ១០៥ | ៦២៨ | ២៩ ២៨១ |
| សរុប | ៣០ ៧៩៦នាក់ | ៤៥ ៦០៧ថ្ងៃ | ៤ ៣៣៣ នាក់ | ៣១៤ ៣៩៩ ថ្ងៃ |

២.២-ទិន្នន័យភ្ញៀវទេសចរអន្តរជាតិគិតតាមសញ្ជាតិ ក្នុងឆ្នាំ២០១៥-២០១៦

ភ្ញៀវទេសចរបរទេសតាមសញ្ជាតិចំនួន១០ប្រទេស ដែលបានមកទស្សនារមណីយដ្ឋានអង្គរច្រើនជាងគេប្រចាំឆ្នាំ២០១៥ (គិតត្រឹមខែមេសា ដល់ខែធ្នូ) និងប្រចាំឆ្នាំ២០១៦មានចំនួនដូចខាងក្រោម ៖

| បរិយាយ | ២០១៥ | | ២០១៦ | |
|---|---|---|---|---|
| | ភ្ញៀវអន្តរជាតិ | ភាគរយ(%) | ភ្ញៀវអន្តរជាតិ | ភាគរយ(%) |
| ចិន | ៤០១ ៦៤២ | ២៨,៤៧% | ៦៦៧ ២៨៥ | ៣០,៣៧% |
| កូរ៉េ | ១៥៥ ០០៨ | ១០,៩៩% | ២៤៦ ៦១០ | ១១,២២% |
| ជប៉ុន | ៨៨ ០៥៣ | ៦,៣០% | ១២៥ ៤១០ | ៥,៧១% |
| អាមេរិក | ៨៨ ៨៦៤ | ៦,២៤% | ១៥៤ ៦៨៥ | ៧,០៤% |
| អង់គ្លេស | ៧៤ ៨៥០ | ៥,៣១% | ១២៥ ៩៩៩ | ៥,៧៣% |
| ថៃ | ៦៣ ១៨៨ | ៤,៤៨% | ៨៥ ៨០៩ | ៣,៩១% |
| អូស្ត្រាលី | ៦២ ២៣៣ | ៤,៤១% | ៩២ ៣៨១ | ៤,២០% |
| វៀតណាម | ៥៧ ៣២៥ | ៤,០៦% | ៦៨ ៤៩៦ | ៣,១២% |
| បារាំង | ៥៦ ០៩៦ | ៣,៩៨% | ៩៩ ១៨០ | ៤,៥១% |
| អាល្លឺម៉ង់ | ៤៦ ៥៥២ | ៣,៣០% | ៧៧ ៩០២ | ៣,៥៥% |
| សរុប ៩ខែ | ១ ៤១០ ៨៦១ | ១០០% | ២ ១៩៧ ២៥៤ | ១០០% |

សម្គាល់៖ ទិន្នន័យភ្ញៀវទេសចរបរទេសតាមសញ្ជាតិចូលទស្សនាអង្គរ គិតត្រឹម ៩ខែ គឺពីខែមេសា ដល់ធ្នូ តែប៉ុណ្ណោះ។

២.៣-អាជ្ញាធរជាតិអប្សរា បានដាក់ដំណើរការអនុវត្តន៍ ក្រមប្រតិបត្តិអង្គរ នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៥ ដើម្បីអប់រំ ផ្សព្វផ្សាយដល់ភ្ញៀវទេសចរជាតិ អន្តរជាតិ ដែលមកទស្សនារមណីយដ្ឋានអង្គរឲ្យគោរពនូវតម្លៃបេតិកភណ្ឌវប្បធម៌ខ្មែរដ៏ល្បីល្បាញ ជៀសវាងនូវការប្រព្រឹត្តនូវអំពើអសីលធម៌

និងអាកប្បកិរិយាមិនសមរម្យក្នុងពេលទស្សនាប្រាសាទ។ ទន្ទឹមនេះ គេហទំព័រទេសចរណ៍ថ្មី ឈ្មោះ www.angkor.com.kh ក៏បានដាក់ឲ្យដំណើរការពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៧ ដើម្បីផ្សព្វផ្សាយព័ត៌មានផ្សេងៗ ទាក់ទងនឹងរមណីយដ្ឋានអង្គរ ដល់គ្រប់ស្ថាប័នជាតិ អន្តរជាតិ ក៏ដូចជាសាធារណជនជាតិ អន្តរជាតិ បានស្វែងយល់ពីមរតកវប្បធម៌ខ្មែរដ៏ល្បីល្បាញ សំដៅឲ្យមានភាពទាក់ទាញ និងមកទស្សនារមណីយដ្ឋានអង្គរកាន់តែច្រើនឡើងថែមទៀត។

២.៤- ការគ្រប់គ្រងបរិស្ថាននៅតំបន់រមណីយដ្ឋានអង្គរ ៖

ការគ្រប់គ្រងបរិស្ថានក្នុងតំបន់រមណីយដ្ឋានអង្គរតាមប្រព័ន្ធគ្រប់គ្រងបរិស្ថានស្តង់ដារអន្តរជាតិ ដោយបានទទួលវិញ្ញាបនបត្រ ISO-14001 ជាបន្តបន្ទាប់ចាប់ពីឆ្នាំ២០១៣ រហូតមកដល់ឆ្នាំ២០១៦ ចំនួន ៤លើក ដែលធ្វើឲ្យរមណីយដ្ឋានអង្គរ កាន់តែមានការទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិ មួយកម្រិតថែមទៀត។

៣- ការងារអភិវឌ្ឍន៍សហគមន៍ក្នុងឧទ្យានអង្គរ

៣.១- ការស្ថាបនាស្ពានថ្មល់ និងប្រព័ន្ធស្រោចស្រព

| បរិយាយ | ឯកតា | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | សរុប |
|---|---|---|---|---|---|---|---|
| សំណង់ទ្វារទឹក | ទ្វារទឹក | ១៤ | ៦ | ១ | ២ | ៣ | ២៦ |
| សំណង់បង្ហៀរទឹក | បង្ហៀរ | - | ១ | ៤ | - | - | ៥ |
| លូមូល និងលូប្រអប់ | កន្លែង | ៥ | - | ៣ | ១៥ | ១៩ | ៤២ |
| ស្តារប្រឡាយ | គ.ម | ៩.៣ | - | ១២.៤ | ១៦.៣ | ៤.១២ | ៤២ |
| ស្តារស្រះបុរាណ | ម$^{៣}$ | - | - | - | - | ២៣ ៤០០ | ២៣ ៤០០ |
| ស្តារប្រព័ន្ធរំដោះទឹក | ម | - | - | - | - | ១៥០ | ១៥០ |
| ស្ពាន (ឈើ ដែក និងថ្ម) | ស្ពាន | ២ | ២ | ១ | - | ១ | ៥ |
| ជួសជុលផ្លូវ | កន្លែង | ២ | - | - | - | - | ២ |
| ផ្លូវក្រួសក្រហម | ខ្សែ | - | - | - | ៧ | - | ៤ |
| ផ្លូវដីស | គ.ម | - | - | - | ៧ | - | ៧ |

៣.២-ការងារបណ្តុះបណ្តាល

| បរិយាយ | ឯកតា | ២០១៥ | ២០១៦ | សរុប |
|---|---|---|---|---|
| វគ្គបណ្តុះបណ្តាលទេសចរណ៍ និងវប្បធម៌ | នាក់ | ៤៦ | | ៤៦ |
| វគ្គបណ្តុះបណ្តាលការអភិរក្ស និងជួសជុលក្បាច់ចម្លាក់៣ដំណាក់កាល | នាក់ | ១៩ | ១៦ | ៣៥ |
| វគ្គបណ្តុះបណ្តាលស្តីពីទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌពិភពលោក ៖ ការប្រឈម និងទស្សនវិស័យ | នាក់ | ៤៨ | | ៤៨ |
| វគ្គបណ្តុះបណ្តាលស្តីពីការសិក្សាកំណត់តម្លៃសំបុត្រក្នុងតំបន់បេតិកភណ្ឌពិភពលោក | នាក់ | ១១ | | ១១ |

| | | | | |
|---|---|---|---|---|
| វគ្គបណ្តុះបណ្តាលស្តីពីទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌពិភពលោក | នាក់ | ៥០ | | ៥០ |
| វគ្គបណ្តុះបណ្តាលស្តីពីការកសាងសមត្ថភាពភ្នាក់ងារសណ្តាប់ធ្នាប់ និងអភិរក្សព្រៃឈើ | នាក់ | ៣៤ | | ៣៤ |
| វគ្គបណ្តុះបណ្តាលភាសាបារាំង | នាក់ | ១៤ | | ១៤ |
| ថ្នាក់រៀនភាសាអង់គ្លេសចំនួន ៥ថ្នាក់ | នាក់ | | ៧៤ | ៧៤ |
| វគ្គបណ្តុះបណ្តាលជំនាញសង្គ្រោះបឋមលើកទី១ និងលើកទី២ | នាក់ | | ៧៤ | ៧៤ |
| កម្មវិធីយុវជនស្ម័គ្រចិត្តបេតិកភណ្ឌពិភពលោក តំបន់អង្គរ | នាក់ | | ២៣ | ២៣ |
| វគ្គបណ្តុះបណ្តាលស្តីពីការអភិរក្សតាមបែប វិទ្យាសាស្ត្រ | នាក់ | | ២៨ | ២៨ |
| សរុប | | ២២០ | ២១៥ | ៤៣៧ |

## ខ.៤-លទ្ធផលការងារសំខាន់ៗរបស់អាជ្ញាធរជាតិព្រះវិហារ

-អាជ្ញាធរជាតិព្រះវិហារមានតួនាទី និងភារកិច្ចគិតគូរដឹកនាំ រៀបចំអភិវឌ្ឍន៍វិស័យទេសចរណ៍ក្នុងតំបន់រមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ដែលមានផ្ទៃដីសរុប ចំនួន ៤៨ ០១៨ ហិកតា មានទីតាំងស្ថិតនៅក្នុងឃុំស្រអែម ស្រុកជាំក្សាន្ត នៃជួរភ្នំដងរែក ខេត្តព្រះវិហារ (ព្រះរាជ-ក្រឹត្យលេខនស/រកត/០៨១១/៧៥២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១)។

-ចំនួនភ្ញៀវទេសចរចូលមកទស្សនារមណីយដ្ឋានប្រាសាទព្រះវិហារ ចាប់ពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៦ មានចំនួន ៤៨៣ ៥៣០នាក់ ក្នុងនោះភ្ញៀវជាតិចំនួន ៤១០ ៦៤៧នាក់ ភ្ញៀវអន្តរជាតិចំនួន ៧២ ៨៨៣នាក់។

| ឆ្នាំ | ចំនួនភ្ញៀវទេសចរជាតិ (នាក់) | ចំនួនភ្ញៀវទេសចរអន្តរជាតិ(នាក់) |
|---|---|---|
| ២០១២ | ៩៥ ៤៧៧ | ៧ ៤៥៨ |
| ២០១៣ | ៥៨ ៦៩២ | ១០ ៥៨៧ |
| ២០១៤ | ៨៦ ១១៥ | ១៣ ៦៣៩ |
| ២០១៥ | ៨៧ ៣៤១ | ១៧ ៣៥៧ |
| ២០១៦ | ៨៣ ០២២ | ២៣ ៨៤៣ |
| សរុប | ៤១០ ៦៤៧ | ៧២ ៨៨៣ |

-ក្នុងឆ្នាំ២០១៦នេះ ចំនួនភ្ញៀវទេសចរអន្តរជាតិ ចូលមកទស្សនារមណីយដ្ឋានប្រាសាទកោះកេរ ១៨ ០០០នាក់។

## ខ.៥-រមណីយដ្ឋានទេសចរណ៍ វប្បធម៌ ធម្មជាតិ និងកែច្នៃ

រយៈពេល៥ឆ្នាំ (២០១២-២០១៦) រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងជំរុញការអភិរក្ស និងការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍នៅគ្រប់រាជធានីខេត្ត មកដល់បច្ចុប្បន្ន យើងមានរមណីយដ្ឋានទេសចរណ៍ដែលត្រូវបានចុះបញ្ជីផ្លូវការប្រមាណ ៣៣៥កន្លែង រួមមាន (រមណីយដ្ឋានប្រាសាទបុរាណ) ក្រៅពីតំបន់អង្គរ (មានចំនួន៥៤កន្លែង ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ

មានចំនួន ៧២កន្លែង ទេសចរណ៍ធម្មជាតិចំនួន ១៦៩កន្លែង រមណីយដ្ឋានទេសចរណ៍កែច្នៃ ចំនួន ៤០កន្លែង)។ ក្នុងចំណោមរមណីយដ្ឋានទាំង៣៣៩កន្លែង រមណីយដ្ឋានដែលមានអាជ្ញាបណ្ណទេសចរណ៍ មានចំនួន ១៥កន្លែង។ ព្រមជាមួយនេះ យើងក៏មានកន្លែងដែលមានសក្តានុពលទេសចរណ៍រាប់សិបកន្លែងផ្សេងទៀត ដែលបាននិងកំពុងរៀបចំអភិរក្ស និងអភិវឌ្ឍដើម្បីទទួលភ្ញៀវទេសចរដែលកំពុងកើនឡើងគួរឲ្យកត់សម្គាល់។ ចំពោះការរៀបចំព្រឹត្តិការណ៍ទេសចរណ៍ រាជរដ្ឋាភិបាលក៏បាននិងកំពុងខិតខំបង្កើតព្រឹត្តិការណ៍ទេសចរណ៍ថ្មីៗ មានជាអាទិ៍ បុណ្យសមុទ្រ បុណ្យទន្លេ បុណ្យស្រូវនិងរៀងរាល់ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ បានរៀបចំពិធីអង្គរសង្ក្រាន្ត នៅខេត្តសៀមរាបព្រមទាំងសង្ក្រាន្តនៅរាជធានី ខេត្តជាដើម។

### ខ.៦-ការដាក់បញ្ចូលសម្បត្តិវប្បធម៌រូបី និងអរូបីរបស់ព្រះរាជាណាចក្រកម្ពុជានៅក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

| បរិយាយ | កាលបរិច្ឆេទ |
|---|---|
| មុនឆ្នាំ២០១២ | |
| តំបន់អង្គរ | ១៤ ធ្នូ ១៩៩២ |
| របាំព្រះរាជទ្រព្យ | ៧ វិច្ឆិកា ២០០៣ |
| ល្ខោនស្រមោលស្បែកធំ | ២៥ វិច្ឆិកា ២០០៥ |
| ប្រាសាទព្រះវិហារ | ៧ កក្កដា ២០០៨ |
| បណ្ណាសារឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង | ៣១ កក្កដា ២០០៩ |
| ក្រោយឆ្នាំ២០១២ | |
| ល្បែងទាញព្រ័ត្រ | ០២ ធ្នូ ឆ្នាំ២០១៥ |
| ចាប៉ីដងវែង | ៣០ វិច្ឆិកា ២០១៦ |

### ខ.៧-ការអភិវឌ្ឍតំបន់សមុទ្រ

ក្នុងក្របខណ្ឌ នៃកិច្ចសហការជាមួយក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសាកលលោក បន្ទាប់ពីបានចូលជាសមាជិកក្លឹបកាលពីឆ្នាំ២០១១ កម្ពុជាត្រូវបានសមាជិកក្លឹបជ្រើសរើសជាអនុប្រធានក្លឹបទទួលបន្ទុកតំបន់អាស៊ីប៉ាស៊ីហ្វិកកាលពីឆ្នាំ២០១២ និងបានធ្វើម្ចាស់ផ្ទះរៀបចំមហាសន្និបាតក្លឹបលើកទី៩ កាលពីខែធ្នូ ឆ្នាំ២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា។ កម្ពុជាក៏បានជាប់ឆ្នោតជាអនុប្រធានក្លឹបសម្រាប់អាណត្តិទី២ នាឱកាសកិច្ចប្រជុំមហាសន្និបាតលើកទី១១របស់ក្លឹបកាលពីខែកុម្ភៈ ឆ្នាំ២០១៦ នៅប្រទេសហ្វីលីពីន និងបានចុះវាយតម្លៃឆ្នេរបេក្ខភាព Miyazu-Ine និង Suruga ប្រទេសជប៉ុន ដែលបានដាក់ពាក្យស្នើសុំជាសមាជិកក្លឹប កាលពីខែឧសភា ឆ្នាំ២០១៦កន្លងមក។

## ២.៨-ស្ថិតិឧស្សាហកម្មទេសចរណ៍

គិតត្រឹមឆ្នាំ២០១៦នេះ សណ្ឋាគារមាន ៧០៩ ស្មើនឹង ៤៤ ១៦១បន្ទប់ ផ្ទះសំណាក់មាន ១ ៧៥៥ ស្មើនឹង ២៨ ៣០៣បន្ទប់ ភោជនីយដ្ឋានមាន ១ ៦៣៨កន្លែង ទីភ្នាក់ងារទេសចរណ៍មាន ៧៣០កន្លែង សេវាកម្សាន្តទេសចរណ៍មាន ៨៨កន្លែង និងមគ្គុទ្ទេសក៍ទេសចរមាន ៥ ០៨១នាក់។

## ២.៩-មគ្គុទ្ទេសក៍ទេសចរណ៍គិតត្រឹមឆ្នាំ២០១៦ មានចំនួន ៥ ០៨១នាក់ និង មាន ១២ភាសា

| ល.រ | ភាសា | សៀមរាប-អង្គរ | ភ្នំពេញ | ព្រះវិហារ | តំបន់ផ្សេរ |
|---|---|---|---|---|---|
| ១ | ចិន | ៧៣៨ | ១៧៣ | ០ | ៥ |
| ២ | អង់គ្លេស | ១ ៣០៧ | ២៩៣ | ៦ | ៣៣ |
| ៣ | បារាំង | ២៥៧ | ១១៤ | ០ | ០ |
| ៤ | អាល្លឺម៉ង់ | ១១០ | ៥១ | ០ | ០ |
| ៥ | អ៊ីតាលី | ២៥ | ១៣ | ០ | ០ |
| ៦ | ជប៉ុន | ៧៩៧ | ៧៦ | ០ | ០ |
| ៧ | កូរ៉េ | ២២៨ | ១០ | ០ | ០ |
| ៨ | ម៉ាឡេស៊ី | ៤ | ១០ | ០ | ០ |
| ៩ | រុស្ស៊ី | ៨២ | ២៤ | ០ | ០ |
| ១០ | អេស្ប៉ាញ | ១១៣ | ២៦ | ០ | ០ |
| ១១ | ថៃ | ៣៨៣ | ១៤ | ១០ | ០ |
| ១២ | វៀតណាម | ១១៧ | ៦២ | ០ | ០ |
| សរុប | | ៤ ១៦១ | ៨៦៦ | ១៦ | ៣៨ |

## ២.១០-គិតត្រឹមដំណាច់ឆ្នាំ២០១៦ នៅព្រះរាជាណាចក្រកម្ពុជាមានសណ្ឋាគារ ដែលបានធ្វើការចាត់លំដាប់ថ្នាក់ពីផ្កាយ៥ ដល់ផ្កាយ១ រួមមាន៖

| រាជធានី-ខេត្ត | ផ្កាយ៥ | | ផ្កាយ៤ | | ផ្កាយ៣ | | ផ្កាយ២ | |
|---|---|---|---|---|---|---|---|---|
| | សណ្ឋាគារ | បន្ទប់ | សណ្ឋាគារ | បន្ទប់ | សណ្ឋាគារ | បន្ទប់ | សណ្ឋាគារ | បន្ទប់ |
| ភ្នំពេញ | ៣ | ១ ១៩៤ | ៣ | ៤៤៥ | ១០ | ៩៩៨ | ៣ | ១៧៨ |
| សៀមរាប | ១៧ | ៣ ៦៦៩ | ២៦ | ៣ ២៩៣ | ៦ | ៤៨៧ | ១ | ៤៩ |
| កំពង់ធំ | | | ១៨៩ | | | | | |
| ស្វាយរៀង | | | ១ | ១៦១ | | | | |
| បាត់ដំបង | | | ១ | ១២៨ | ៣ | ៣៣៤ | ៣ | ២០៦ |
| កំពត | | | ២ | ៥៨៨ | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ព្រះសីហនុ | ១ | ៤០៣ | ២ | ១២៨ | ១ | ១០៨ | | |
| មណ្ឌលគិរី | | | | | ២ | ៤១ | ២ | ៥២ |
| ពោធិ៍សាត់ | | | | | | | | |
| កោះកុង | | | | | | | | |
| កំពង់ឆ្នាំង | | | | | | | | |
| **សរុប** | **២១** | **៥ ២១៦** | **៣៦** | **៤ ៧៩២** | **២២** | **១ ៩៦៨** | **១០** | **៥៨៥** |

| **រាជធានី ខេត្ត** | **ផ្កាយ១** | | **សរុប ចំនួនបន្ទប់** | **សរុបចំនួនសណ្ឋាគារ មានចំណាត់ថ្នាក់** | **សរុបចំនួន សណ្ឋាគារ** |
|---|---|---|---|---|---|
| | សណ្ឋាគារ | បន្ទប់ | | | |
| ភ្នំពេញ | | | ២ ៧៦៥ | ១៩ | ២២៨ |
| សៀមរាប | | | ៧ ៤៥៨ | ៥០ | ១៤០ |
| កំពង់ធំ | | | ៨៩ | ១ | ៦ |
| ស្វាយរៀង | | | ១៦១ | ១ | ៣ |
| បាត់ដំបង | | | ៦៦៨ | ៧ | ១៩ |
| កំពត | | | ៥៨៨ | ២ | ៦ |
| ព្រះសីហនុ | | | ៦៣៩ | ៤ | ៣៩ |
| មណ្ឌលគិរី | ១ | ៤៧ | ១៤០ | ៥ | ៥ |
| ពោធិ៍សាត់ | ២ | ១០០ | ២០០ | ៣ | ៤ |
| កោះកុង | ២ | ៨៨ | ៨៨ | ៨៨ | ២ |
| កំពង់ឆ្នាំង | ២ | ៩០ | ៩០ | ៩០ | ២ |
| **សរុប** | **៧** | **៣២៥** | **១២ ៨៨៦** | **៩៦** | **៤៩១** |

+ប៉ូលអភិវឌ្ឍន៍វិស័យទេសចរណ៍សំខាន់ៗ មាន ៖ រាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ តំបន់ឆ្នេរសមុទ្រ និងភូមិភាគឦសាន នៃព្រះរាជាណាចក្រកម្ពុជា។

♦រាជរដ្ឋាភិបាលកម្ពុជា បានព្រមព្រៀង**លើកលែងទិដ្ឋាការ**ចំពោះភ្ញៀវទេសចរអន្តរជាតិនៃប្រទេសសឹង្ហបុរី ម៉ាឡេស៊ី ហ្វីលីពីន ឡាវ វៀតណាម ថៃ និងប្រទេសឥណ្ឌូនេស៊ី ។ ចំណែកប្រទេសប្រ៊ុយណេ និងប្រទេសមីយ៉ាន់ម៉ា នៅពុំទាន់បានលើកលែងទិដ្ឋាការនៅឡើយទេ។

## គ-កិច្ចការសាសនា

| **ក-ពុទ្ធសាសនា** | | | | | |
|---|---|---|---|---|---|
| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| ចំនួនវត្ត | ៤ ៥៥៣ | ៤ ៦៧៦ | ៤ ៧៥៥ | ៤ ៨១៩ | ៤ ៨៧២ |
| ចំនួនព្រះសង្ឃ(អង្គ) | ៥៣ ២៥៧ | ៥៧ ៤៥៤ | ៥៩ ៥១៦ | ៦០ ៣៧០ | ៦៩ ១៩៩ |

| ខ-ឥស្លាមសាសនា | | | | | |
|---|---|---|---|---|---|
| វិហារ (កន្លែង) | ៤៣៩ | ៤០៩ | ៤០៩ | ៤០៩ | ៤៨៧ |
| បរិស័ទ (នាក់) | ៣៤២ ៩៩០ | ៣៤០ ១៦៣ | ៣៤០ ១៦៣ | ៣៤០ ១៦៣ | ៣៧១ ១៣២ |
| គ-គ្រិស្តសាសនា | | | | | |
| កាតូលិក | | | | | |
| វិហារ (កន្លែង) | ៥៥ | ៥២ | ៥២ | ៥២ | ៦៥ |
| បរិស័ទ (នាក់) | ១២ ៩៧៣ | ១១ ៨៤៣ | ១១ ៨៤៣ | ១១ ៨៤៣ | ១៥ ៦៩៧ |
| ប្រូតេស្តង់ | | | | | |
| វិហារ (កន្លែង) | ៤៣០ | ៦៣៥ | ៦៣៥ | ៦៣៥ | ៦៣៥ |
| បរិស័ទ (នាក់) | ៨៣ ០៨៦ | ១០០ ៥៤៩ | ១០០ ៥៤៩ | ១០០ ៥៤៩ | ៩០ ៩០៣ |

ក្រៅពីនេះមាន សាសនាមហាយាន សាសនាបាហៃ និងសាសនាកៅដាយ។ល។

## ៤-ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ

### ៤.១-ការអភិវឌ្ឍវិស័យធនាគារ

ធនាគារជាតិនៃកម្ពុជា គឺជាអាជ្ញាធររូបិយវត្ថុ និងអាជ្ញាធរត្រួតពិនិត្យលើប្រតិបត្តិការធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា។ បេសកកម្មចម្បងរបស់ខ្លួនគឺកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុក្នុងគោលដៅរក្សាឲ្យបាននូវស្ថិរភាពថ្លៃ និងសំដៅបង្កលក្ខណៈងាយស្រួលដើម្បីឲ្យសេដ្ឋកិច្ចរីកចម្រើន។

នៅឆ្នាំ២០១១ ធនាគារពាណិជ្ជមានចំនួន៣១ ដែលក្នុងនោះ ធនាគារ៦ ជាសាខាធនាគារបរទេស។ គិតត្រឹមចុងឆ្នាំ២០១៥ ធនាគារពាណិជ្ជមានចំនួន៣៦ ក្នុងនោះ ធនាគារ១១ ជាសាខាធនាគារបរទេស។ ក្នុងអំឡុងពេលដូចគ្នានេះដែរ ចំនួនធនាគារឯកទេសក៏មានការកើនឡើងពី៧ ដល់ ១២។ ចំនួនម៉ាស៊ីនដក និងដាក់ប្រាក់ស្វ័យប្រវត្តិ (ATM) កើនឡើងពី ៥៨៨ ទៅ ១ ១១៨ ។

ទ្រព្យសកម្មនៅក្នុងប្រព័ន្ធធនាគារបានកើនឡើងពី ៧,៩ប៊ីលានដុល្លារអាមេរិក គិតត្រឹមដំណាច់ឆ្នាំ២០១១ (ស្មើនឹង ៦០% នៃផលិតផលក្នុងស្រុកសរុប ផ.ស.ស ) ដល់ ១៩,៩ប៊ីលានដុល្លារអាមេរិក គិតត្រឹមដំណាច់ឆ្នាំ២០១៥ (ប្រមាណ១១០% នៃផ.ស.ស)។ ទន្ទឹមនឹងនោះ ប្រាក់បញ្ញើអតិថិជនសរុបធៀប ផ.ស.ស ក៏មានកំណើនដូចគ្នាដែរ ពោលគឺកើនពី ៤១% នៅឆ្នាំ២០១១ ទៅដល់ ៦២% នៅដំណាច់ឆ្នាំ២០១៥។

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ធនាគារជាតិនៃកម្ពុជា | ១ | ១ | ១ | ១ | ១ |
| សាខាធនាគារជាតិនៃកម្ពុជា | ២១ | ២១ | ២១ | ២១ | ២១ |
| ធនាគារពាណិជ្ជ | ៣២ | ៣៥ | ៣៦ | ៣៦ | ៣៧ |
| សាខាធនាគារពាណិជ្ជបរទេស | ៩ | ១០ | ១១ | ១១ | ១១ |

| | | | | | |
|---|---|---|---|---|---|
| បុគ្គលសម្ព័ន្ធធនាគារបរទេស | ១០ | ១១ | ១២ | ១២ | ១៤ |
| ធនាគារពាណិជ្ជក្នុងស្រុក | ១៣ | ១៤ | ១៣ | ១៣ | ១២ |
| សាខាធនាគារពាណិជ្ជរាជធានី ខេត្ត | ៣៣៧ | ៤៩៦ | ៥៥៧ | ៦១៤ | ៨១២ |
| ការិយាល័យតំណាងធនាគារបរទេស | ៤ | ៦ | ៧ | ៨ | ៧ |
| ធនាគារឯកទេស | ៧ | ៩ | ១១ | ១១ | ១៥ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានអាជ្ញាបណ្ណ | ៣៥ | ៣៨ | ៤០ | ៥៩ | ៧១ |
| តូបដូរប្រាក់ | ១ ៦០៥ | ១ ៦៧៣ | ១ ៧៧៥ | ១ ៧៧៥ | ២ ២៨៥ |

**❖❖ស្ថាប័នធនាគារពាណិជ្ជ ធនាគារឯកទេស និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់នៅកម្ពុជាមិនមែនជារបស់រដ្ឋ សូមប្រជាពលរដ្ឋកុំយល់ច្រលំ។**

-ចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មិនទទួលប្រាក់បញ្ញើ បានកើនឡើងពី២៣ នៅក្នុងឆ្នាំ២០១១ ដល់៣២ ក្នុងឆ្នាំ២០១៤។ ចំនួនគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើកើនឡើងពី៧ ក្នុងឆ្នាំ២០១១ ដល់ ៨ ក្នុងឆ្នាំ២០១៥។

-ក្នុងអំឡុងពេលពីឆ្នាំ២០១១-២០១៥ ទ្រព្យសកម្មសរុបរបស់វិស័យនេះបានកើនឡើងពី ៣ ០២៥ប៊ីលានរៀល ស្មើនឹង ៧៥៣លានដុល្លារអាមេរិក ដល់ ១៤ ៦២៦ប៊ីលានរៀល ស្មើនឹង ៣,៦ប៊ីលានដុល្លារអាមេរិក ខណៈដែលអត្រាឥណទានមិនដំណើរការស្ថិតក្នុងកម្រិតទាប (ជាមធ្យម ០,៧៧% ក្នុងឆ្នាំ២០១៥)។ លទ្ធភាពរកចំណូលរបស់វិស័យនេះនៅតែរឹងមាំ ដែលប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម(ROA) និងប្រាក់ចំណេញធៀបនឹងទុន(ROE) ជាមធ្យមមានចំនួន ៣,៦៨% និង ១៨,៦២% រៀងគ្នាក្នុងឆ្នាំ២០១៥។ រីឯអត្រាឥណទានមិនដំណើរការសម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ មានអត្រាជាមធ្យមទាបជាង ១%។

-ចំនួនអតិថិជនដែលបានសន្សំប្រាក់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ បានកើនឡើងពី ២៤២ ១១៦នាក់ ក្នុងឆ្នាំ២០១១ ដល់ចំនួន ១,៣៣លាននាក់ក្នុងឆ្នាំ២០១៥។ សមតុល្យប្រាក់បញ្ញើសរុបបានកើនឡើងជាលំដាប់ពីចំនួន ៤៦០ប៊ីលានរៀល ស្មើនឹង ១១៥លានដុល្លារអាមេរិក ដល់ចំនួន ៥ ៤១០ប៊ីលានរៀល ប្រមាណ ១,៣៥ប៊ីលានដុល្លារអាមេរិក។ បច្ចុប្បន្នប្រាក់សន្សំជាង ៧០% ជាប្រាក់សន្សំមានកាលកំណត់។ ចំនួនបុគ្គលិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានកើនឡើងទ្វេដងពី ៩ ៧៤៤នាក់ ក្នុងឆ្នាំ២០១១ ដល់ចំនួន ២៦ ២៦៨នាក់ ក្នុងឆ្នាំ២០១៥។

## ៤.២- ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ

### ៤.២.១-ចំណូល ចំណាយថវិកាជាតិ

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ បណ្ដោះអាសន្ន |
|---|---|---|---|---|---|
| ចំណូល (ប៊ីលានរៀល) | ៨ ១៤៤ | ៨ ៧៧៤ | ១១ ៥៩៦ | ១២ ៣៦៧ | ១៤ ២០២ |
| ចំណាយ(ប៊ីលានរៀល) | ១១ ៩០៧ | ១២ ៨៩៧ | ១៣ ៩៧៤ | ១៤ ៣៣១ | ១៣ ៧៧៥ |

### ៤.២.២-ការកៀរគរចំណូល

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ចំណូលពន្ធដារ (ប៊ីលានរៀល) | ២ ៩៦៣,៧ | ៣ ៥៣៥ | ៤ ២៣០,៩ | ៥ ២០៦,៩ | ៥ ៩៨៨,៧ |
| ចំណូលពន្ធគយ (ប៊ីលានរៀល) | ៣ ៧១៣,៣ | ៤ ០៨៥,៥ | ៥ ៤៥៥,៣ | ៦ ៤០៤,៧ | ៧ ០៧៨,២ |

### ៤.២.៣-ការកៀរគរឥណទានពីដៃគូអភិវឌ្ឍន៍ និងប្រទេសជាមិត្ត

ក្នុងរយៈពេល៥ឆ្នាំ (២០១២-២០១៦) រាជរដ្ឋាភិបាលបានកៀរគរឥណទានសម្បទានសរុបមានចំនួនប្រមាណ ៤ពាន់លានដុល្លារអាមេរិក សម្រាប់ហិរញ្ញប្បទានលើគម្រោងវិនិយោគសាធារណៈក្នុងវិស័យអាទិភាព សំដៅរួមចំណែកទ្រទ្រង់ចីរភាពកំណើនរយៈពេលវែង និងបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម រួមមាន ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (ស្ពាន ថ្នល់) អគ្គិសនី ធារាសាស្ត្រ ស្ពានីយ៍ប្រោះទឹកកខ្វក់ ផ្គត់ផ្គង់ទឹកស្អាត កសិកម្ម ហិរញ្ញវត្ថុ អប់រំ សុខាភិបាល និងពហុវិស័យ។

| ឥណទានសម្បទានដែលបានចុះហត្ថលេខា តាមវិស័យ (គិតជាលានដុល្លារអាមេរិក) | | | | | | | |
|---|---|---|---|---|---|---|---|
| វិស័យ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១២-២០១៦ | % |
| ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | ៦៣៩,២២ | ១២៤,៤៣ | ៣៥៨,៧៣ | ៣១៥,១៩ | ៣៣៣,០៦ | ១ ៧៧០,៦២ | ៤២,៣០ |
| ធារាសាស្ត្រ | ២៣២,០៤ | ២៩៨,៤៥ | ៩០,២០ | ៦០,១០ | ១១៦,៣២ | ៧៩៧,១២ | ១៩,០៥ |
| អគ្គិសនី | ០ | ១៣៣,៨៣ | ១០១,៦១ | ២៨៥,៨៥ | ៨៤,៩៨ | ៦០៦,២៧ | ១៤,៤៩ |
| ពហុវិស័យ | ៧១,៦៨ | ១៣៩,១៤ | ១២០,៧៩ | ០ | ០ | ៣៣១,៦១ | ៧,៩២ |
| ផ្គត់ផ្គង់ទឹកស្អាត | ៨៣,២៨ | ០ | ៣៣,២៦ | ៤៥,៤៨ | ៤៦,៤៥ | ២០៨,៤៧ | ៤,៩៨ |
| កសិកម្ម | ២៨,៣៦ | ៦១,៥៩ | ០ | ២៤,៦៧ | ២៧,៣៤ | ១៤១,៩៦ | ៣,៣៩ |
| ហិរញ្ញវត្ថុ | ០ | ១៥,៣០ | ១៤,៣៨ | ០ | ១០១,០១ | ១៣០,៦៩ | ៣,១២ |
| អប់រំ | ០ | ៣០,៤៥ | ២៨,២៨ | ១៤,៥២ | ៤៣,៤៤ | ១១៦,៦៩ | ២,៧៩ |
| សុខាភិបាល | ០ | ០ | ០ | ០ | ៤៩,៤៤ | ៤៩,៤៤ | ១,១៨ |
| ស្ពានីយ៍ប្រោះទឹកកខ្វក់ | ០ | ០ | ០ | ៣២,៥៩ | ០ | ៣២,៥៩ | ០,៧៨ |
| សរុប | ១ ០៥៤,៥៧ | ៨០៣,១៩ | ៧៤៧,២៤ | ៧៧៨,៤០ | ៨០២,០៥ | ៤ ១៨៥,៤៥ | ១០០ |

## IV- ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស

### ១-ការពង្រឹង និងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស

ក្រសួងអប់រំ យុវជន និងកីឡា មានបុគ្គលិកអប់រំទូទាំងប្រទេសបានកើនឡើងដល់ ១១៦ ៣៩១នាក់ (ស្រី ៤៤ ,៥%) ក្នុងនោះបុគ្គលិកបង្រៀន ៩៩ ១៦៤នាក់ (ស្រី ៤៨%)។

បុគ្គលិកបម្រើការងារនៅថ្នាក់ជាតិ ៣ ០៨២នាក់ (ស្រី ២៧,១%) និងថ្នាក់ក្រោមជាតិ ១១៣ ៤២៦នាក់ (ស្រី ៤៥,២%)។

កុមារបានទទួលសេវាអប់រំកុមារតូចគ្រប់រូបភាពមាន ៣៨៨ ៧៩៤នាក់ (ស្រី ៥១%)។ កុមារអាយុ៥ឆ្នាំ បានទទួលសេវាអប់រំតាមគ្រប់រូបភាពមាន ១៨៧ ៤១២នាក់ (ស្រី ៥០,៨%)។ សិស្សបឋមសិក្សាសាធារណៈសរុប ២ ០១០ ៦៧៣នាក់ (ស្រី ៤៨,៣%) ។ សិស្សបឋមសិក្សាឯកជន ៩៥ ២៣០នាក់ (ស្រី ៤៩,២%)។ សិស្សមធ្យមសិក្សាបឋមភូមិសរុប ៥៥៨ ៦២១នាក់ (ស្រី ៥១,១%) និងសិស្សមធ្យមសិក្សាទុតិយភូមិសរុប ២៦៦ ៤៤៩នាក់ (ស្រី ៥០,១%)។ ក្នុងឆ្នាំសិក្សា ២០១៦-២០១៧ មានសិស្សបច្ចេកទេស ១ ១១៤នាក់ (ស្រី ៤៥៧នាក់)។

## ក-ការសិក្សាចំណេះដឹងទូទៅ

| មត្តេយ្យសិក្សា (រដ្ឋ) | | | | |
|---|---|---|---|---|
| ឆ្នាំសិក្សា | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ |
| សាលា | ២ ៨១៣ | ៣ ១៨៤ | ៣ ៤៤៣ | ៣ ៧០៦ |
| សិស្ស (នាក់) | ១២៨ ២៥៧ | ១៥៧ ២៨៨ | ១៦៣ ៤៦៨ | ១៧៣ ៨៩៣ |
| គ្រូបង្រៀន(នាក់) | ៤ ៣០៩ | ៤ ៧១៧ | ៥ ០២៧ | ៤ ៧២២ |
| មត្តេយ្យសិក្សា (ឯកជន) | | | | |
| សាលា | ១៦៤ | ២២១ | ២៣៥ | ៣២១ |
| សិស្ស (នាក់) | ១៧ ៤៤៨ | ២៣ ៣៨៤ | ២៤ ០៤១ | ២៩ ៨៩០ |
| បឋមសិក្សា(រដ្ឋ) | | | | |
| ឆ្នាំសិក្សា | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ |
| សាលា | ៦ ៩១០ | ៦ ៩៩៣ | ៧ ០៥១ | ៧ ០៨៥ |
| សិស្ស (នាក់) | ២ ១៧៣ ៣៨៤ | ២ ០៧៣ ៨១១ | ២ ០១២ ១៧៥ | ២ ០១០ ៦៧៣ |
| គ្រូបង្រៀន(នាក់) | ៥៦ ១០៨ | ៥៥ ៩៥៨ | ៥៥ ៧៨៨ | ៥៦ ៤២១ |
| បឋមសិក្សា(ឯកជន) | | | | |
| សាលា | ២២៣ | ២៤៣ | ២៩៧ | ៣៥៧ |
| សិស្ស (នាក់) | ៥២ ៦៣០ | ៥៤ ៨២២ | ៧៣ ៧៩៤ | ៩៥ ២៣០ |
| មធ្យមសិក្សាបឋមភូមិ(រដ្ឋ) | | | | |
| ឆ្នាំសិក្សា | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ |
| អនុវិទ្យាល័យ | ១ ២១៤ | ១ ២៤៤ | ១ ២៤៩ | ១ ២៥១ |
| សិស្ស (នាក់) | ៥៣៤ ៧១០ | ៥៣៨ ៦២៦ | ៥៤៦ ៨៦៤ | ៥៥៨ ៦២១ |

| | | | | |
|---|---|---|---|---|
| គ្រូបង្រៀន(នាក់) | ៣១ ៨១៥ | ៣២ ៦១៦ | ៣២ ៥២៥ | ៣៣ ១៦៤ |
| **មធ្យមសិក្សាបឋមភូមិ(ឯកជន)** | | | | |
| សាលា | ៣០ | ៣៥ | ៤៦ | ៤៣ |
| សិស្ស (នាក់) | ១ ៦០៦ | ១ ៨២៨ | ៣ ៦១៥ | ២៨ ២៣៥ |
| **លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ** | | | | |
| បេក្ខជនមកប្រឡង (នាក់) | ១១២ ៥៨១ | ១១៧ ១៤២ | ១២៣ ៩៤២ | ១២៥ ៩៤៥ |
| បេក្ខជនប្រឡងជាប់ (នាក់) | ១០៤ ៧០៨ | ១០៩ ៦៤៩ | ១១៦ ០០៤ | ១១៨ ០៣០ |
| **មធ្យមសិក្សាទុតិយភូមិ(រដ្ឋ)** | | | | |
| ឆ្នាំសិក្សា | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ |
| វិទ្យាល័យ | ៤៣៣ | ៤៤៤ | ៤៥៥ | ៤៦៣ |
| សិស្ស (នាក់) | ២៨៨ ៧៨៩ | ២៦៦ ២៩៣ | ២៦២ ០៧២ | ២៦៦ ៤៤៩ |
| គ្រូបង្រៀន(នាក់) | ១២ ៨៨០ | ១៣ ៣៣០ | ១៤ ០៥៥ | ១៤ ៤៣៤ |
| **មធ្យមសិក្សាទុតិយភូមិ(ឯកជន)** | | | | |
| សាលា | ៧៤ | ៨៧ | ៨៧ | ១០៨ |
| សិស្ស (នាក់) | ២៤ ០២៥ | ២៧ ៦៤៤ | ២៦ ៩៤០ | ៨ ៦៩១ |
| **លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ** | | | | |
| បេក្ខជនមកប្រឡង (នាក់) | ១០៥ ២៩៧ | ៨៣ ៥៩៩ | ៨៣ ៣២៥ | ៨៩ ៦៦១ |
| បេក្ខជនប្រឡងជាប់ (នាក់) | ៩១ ៣៧០ | ៣៣ ៩៩៧ | ៤៦ ៥៦០ | ៥៥ ៧៥៣ |
| **ឧត្តមសិក្សា(រដ្ឋ និងឯកជន)** | | | | |
| ឆ្នាំសិក្សា | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ |
| គ្រឹះស្ថានរដ្ឋ (១) | ៣៩ | ៤៣ | ៤៦ | ៤៨ |
| គ្រឹះស្ថានឯកជន(២) | ៦៦ | ៦៧ | ៧២ | ៧៣ |
| សរុប ១+២ | ១០៥ | ១១០ | ១១៨ | ១២១ |
| និស្សិតថ្នាក់បរិញ្ញា-បត្ររង(នាក់) | ២៣ ៦៧៨ | ១៥ ៦៣៥ | ២៤ ៩៧០ | ២៣ ៧៤៦ |
| និស្សិតថ្នាក់បរិញ្ញាបត្រ (នាក់) | ២១៦ ០៥៣ | ២១៤ ២៦៦ | ១៨២ ៩៨៧ | ១៧៤ ១៤២ |

| | | | | |
|---|---|---|---|---|
| និស្សិតថ្នាក់បរិញ្ញា-បត្រជាន់ខ្ពស់ (នាក់) | ១៦ ៦៥៦ | ១៨ ០១០ | ១៨ ២៥៣ | ១៨ ៧២៣ |
| បណ្ឌិត (នាក់) | ១ ០៨៣ | ១ ១៨១ | ១ ១៧៥ | ១ ២២៩ |
| ឧត្តមសិក្សា(ឯកជន) | | | | |
| សាលា | ៦៦ | ៦៧ | ៧២ | ៧៣ |
| សិស្ស (នាក់) | ១៥១ ៧៩៩ | ១៥៥ ៥៦១ | ១៤៦ ៥០១ | ១៤០ ៨៨១ |

## ខ-គ្រឹះស្ថានសិក្សាឯកជនភាសាខ្មែរ និងបរទេស

| គ្រឹះស្ថានសិក្សាឯកជនភាសាខ្មែរ និងបរទេស (ឆ្នាំសិក្សា ២០១៥-២០១៦) | | | | | | |
|---|---|---|---|---|---|---|
| ប្រភេទសាលា/ភាសា | ខ្មែរ | ចិន | ម៉ូស្លីម | អង់គ្លេស | ផ្សេងទៀត | សរុប |
| សាលាមត្តេយ្យ | ២០៤ | ២១ | ២ | ៩២ | ១ | ៣២០ |
| សាលាបឋមសិក្សា | ២៤៤ | ៣១ | ៩ | ៧២ | ០ | ៣៥៦ |
| អនុវិទ្យាល័យ | ២៧ | ៨ | ១ | ៦ | ១ | ៤៣ |
| វិទ្យាល័យ | ៨៧ | ២ | ៥ | ១៤ | ០ | ១០៨ |

និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្ររងសរុប ២៤ ៩៧០នាក់ ស្រី ៤៩% ក្នុងនោះ និស្សិតអាហារូបករណ៍ ២ ៤៩១នាក់ ស្រី៤៦,៣%។ និស្សិតកំពុងសិក្សាថ្នាក់បរិញ្ញាបត្រសរុប ១៨២ ៩៨៧នាក់ ស្រី ៤៥,៩%។ និស្សិតកំពុងសិក្សាលើមុខវិជ្ជាវិទ្យាសាស្ត្របច្ចេកវិទ្យាវិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា សរុប ៤៤ ៥៥៨នាក់ ស្រី២៥,៥% និស្សិតអាហារូបករណ៍ សរុប ២៤ ០០៩នាក់ ស្រី ៤៦,៨%។ និស្សិតកំពុងសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រសរុប ១៩ ៤២៨នាក់ ស្រី ២០,៦% ក្នុងនោះថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ១៨ ២៥៣នាក់ ស្រី២១,៦% និងថ្នាក់បណ្ឌិត ១១៧៥នាក់ ស្រី៥,១%។

គិតមកដល់ដំណាច់ខែមីនា ឆ្នាំ២០១៧នេះ សំណង់អគារសិក្សាដែលជាអំណោយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សរុបចំនួន ១ ១៤០ខ្នង ស្មើនឹង ២៤ ១០៥បន្ទប់ ក្នុងនោះ វិទ្យាល័យចំនួន ១ ២១១ ស្មើនឹង ៨ ០៣១បន្ទប់ អនុវិទ្យាល័យចំនួន៥០៨ខ្នង ស្មើនឹង ២ ៨៧៨បន្ទប់ និងបឋមសិក្សាចំនួន ២ ៤០៦ខ្នង ស្មើនឹង ១២ ៩៩៥បន្ទប់ ដោយរួមបញ្ចូលអគារសិក្សាចំនួន ៣ ៦១២ខ្នង ទីចាត់ការចំនួន ២៩០ខ្នង អគារស្នាក់នៅចំនួន ៧៨ខ្នង អគារកាត់ដេរចំនួន ១៣០ខ្នង សាលាមត្តេយ្យសិក្សាចំនួន ៥ខ្នង និងសាលសហសិក្សាចំនួន ១០ខ្នង។

## គ-ការបណ្តុះបណ្តាលជំនាញបច្ចេកទេស

### គ.១-ការបណ្តុះបណ្តាលនៅសាលាតូមិន្តរដ្ឋបាល

| ឆ្នាំសិក្សា | ផ្នែកបណ្តុះបណ្តាលដំបូង |
| --- | --- |
| ២០១០-២០១២ | សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៧ ចំនួន ៦០នាក់ (ស្រី ១៣នាក់) |
| ២០១២-២០១៣ | សិស្សមន្ត្រីក្រមការជំនាន់ទី៥ ចំនួន ៧១នាក់ (ស្រី ២៩នាក់) |
| ២០១២-២០១៤ | សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៨ ចំនួន ៦០នាក់ (ស្រី ២០នាក់) |
| ២០១៤-២០១៥ | សិស្សមន្ត្រីក្រមការជំនាន់ទី៦ ចំនួន ៦០នាក់ (ស្រី ១៩នាក់) |
| ២០១៦-២០១៧ | សិស្សមន្ត្រីជាន់ខ្ពស់ជំនាន់ទី៩ ចំនួន ៦០នាក់ (ស្រី ១១នាក់) |
| | **ផ្នែកបណ្តុះបណ្តាលបន្ត** |
| ២០១១-២០១២ | -កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ ៩៣នាក់ (ស្រី ៩នាក់)<br>-កម្មសិក្សាការីមធ្យម ៧៨នាក់ (ស្រី ១៨នាក់) |
| ២០១២-២០១៣ | -កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ ៩៩នាក់ (ស្រី ១៤នាក់)<br>-កម្មសិក្សាការីមធ្យម ៧០នាក់ (ស្រី ២០នាក់) |
| ២០១៣-២០១៤ | -កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ ៩០នាក់ (ស្រី ៩នាក់)<br>-កម្មសិក្សាការីមធ្យម ៨០នាក់ (ស្រី ១៧នាក់) |
| ២០១៤-២០១៥ | -កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ ១១៥នាក់ (ស្រី ១៩នាក់)<br>-កម្មសិក្សាការីមធ្យម ៨៣នាក់ (ស្រី ១៨នាក់) |
| ២០១៥-២០១៦ | -កម្មសិក្សាការីមន្ត្រីជាន់ខ្ពស់ ៣៧៨នាក់ (ស្រី ៣៩នាក់)<br>-កម្មសិក្សាការីមធ្យម ១២៤នាក់ (ស្រី ១១នាក់) |

### គ.២-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មាន ៖

### គ.២.១-សាកលវិទ្យាល័យភូមិន្ទកសិកម្ម

| ស្ថិតិនិស្សិត | | | | | | | | | | |
| --- | --- | --- | --- | --- | --- | --- | --- | --- | --- | --- |
| ឆ្នាំសិក្សា | ២០១២-២០១៣ | | ២០១៣-២០១៤ | | ២០១៤-២០១៥ | | ២០១៥-២០១៦ | | ២០១៦-២០១៧ | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| វិទ្យាសាស្ត្រកសិកម្ម | ១ ១៨៥ | ២៤៥ | ១ ៤៤៩ | ៣២៣ | ១ ២៩០ | ៣៣០ | ១ ១១៦ | ៣១៥ | ៩៦៧ | ៣០០ |
| វិទ្យាសាស្ត្រសត្វ | ២៤៤ | ៣៩ | ២៦៩ | ៤៦ | ២៥៣ | ៥៤ | ២២១ | ៤១ | ១៨២ | ៤៦ |
| វេជ្ជសាស្ត្រសត្វ | ១ ៣៥២ | ១៩៩ | ១ ៤១៣ | ២០៦ | ១ ២៤១ | ២២៣ | ១ ០២៥ | ២០០ | ៨៥៦ | ១៦៩ |
| វិទ្យាសាស្ត្រព្រៃឈើ | ១៤៩ | ៥៣ | ១៤២ | ៤៨ | ១០៩ | ៣៩ | ៧៧ | ៣០ | ៦៩ | ២៨ |
| វិទ្យាសាស្ត្រជលផល | ១៦៦ | ៤៤ | ១៣៧ | ៣៩ | ១១១ | ៣០ | ៨៣ | ៣២ | ៨៧ | ៣០ |
| វិស្វកម្មកសិកម្ម | ១៤៣ | ៣៦ | ១៧០ | ៣៨ | ១៤៧ | ៣៦ | ១១៩ | ២៤ | ១១៤ | ២១ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ | ១ ០៣០ | ៣២១ | ១ ០៤៤ | ៣៣៩ | ៧២៥ | ២៥៨ | ៥៣១ | ២០៣ | ៣៤០ | ១៣៦ |
| កសិឧស្សាហកម្ម | ៤០៥ | ១៦១ | ៤៨០ | ២១៥ | ៤៦៤ | ២២៤ | ៤៨៩ | ២៨៩ | ៤៩៤ | ២៩៩ |
| រៀបចំដែនដី និងរដ្ឋបាលដីធ្លី | ៣៤១ | ៦៥ | ២៨៨ | ៥៦ | ២៥៧ | ៥៧ | ១៦៩ | ៤៤ | ១៨១ | ៥៨ |
| វិទ្យាសាស្ត្រកៅស៊ូ | ២១៣ | ១៤ | ២៥៦ | ៣២ | ១៩៤ | ២៥ | ៩៤ | ១៧ | ៥៧ | ១៥ |
| **សរុបរួម** | **៥ ២២៨** | **១ ១៧៧** | **៥ ៦៤៨** | **១ ៣៤២** | **៤ ៧៩១** | **១ ២៧៦** | **៣ ៩២៤** | **១ ១៩៥** | **៣ ៣៤៧** | **១ ១០២** |
| **ស្ថិតិនិស្សិតបង់ថ្លៃសិក្សា** | | | | | | | | | | |
| វិទ្យាសាស្ត្រកសិកម្ម | ១ ០៦៤ | ២០៩ | ១ ២៧៥ | ២៦៥ | ១ ១១៤ | ២៦៦ | ៩៧០ | ២៦១ | ៨២៧ | ២៣៨ |
| វិទ្យាសាស្ត្រសត្វ | ១៦៣ | ១៨ | ១៨០ | ២៧ | ១៥០ | ២៨ | ១៣៩ | ១៣ | ៩៩ | ១៩ |
| វេជ្ជសាស្ត្រសត្វ | ១ ២៤៣ | ១៦២ | ១២៦១ | ១៦៤ | ១ ០៨១ | ១៦៩ | ៩១៤ | ១៥៧ | ៧៤៦ | ១២២ |
| វិទ្យាសាស្ត្រព្រៃឈើ | ៥៦ | ១៣ | ៤៥ | ៥ | ៣៦ | ៤ | ១៩ | ៤ | ១១ | ៤ |
| វិទ្យាសាស្ត្រជលផល | ៦៦ | ៥ | ៥៦ | ៩ | ៣៥ | ២ | ១៧ | ១ | ១៣ | ០ |
| វិស្វកម្មកសិកម្ម | ៥០ | ៧ | ៧២ | ១០ | ៥៣ | ៦ | ២៧ | ៣ | ២៤ | ២ |
| សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ | ៨៧៣ | ២៤៥ | ៨៥៤ | ២៥៣ | ៥៤៣ | ១៦៧ | ៤០៣ | ១៣៣ | ២៤៤ | ១៤៩ |
| កសិឧស្សាហកម្ម | ២៨៨ | ១០៩ | ៣៣៦ | ១៤៥ | ៣០៥ | ១៤១ | ៣៣៦ | ១៩៧ | ៣២៨ | ១៩៤ |
| រៀបចំដែនដី និងរដ្ឋបាលដីធ្លី | ២៥៨ | ៣៧ | ១៩២ | ២៨ | ១៥៩ | ២៨ | ៩៨ | ២២ | ១០១ | ២៧ |
| វិទ្យាសាស្ត្រកៅស៊ូ | ២០៣ | ១២ | ២០២ | ១០ | ១៤១ | ៦ | ៥១ | ១ | ១៨ | ០ |
| **សរុបរួម** | **៤ ២៦៤** | **៨១៧** | **៤ ៤៧៣** | **៩១៦** | **៣ ៦១៧** | **៨១៧** | **២៩៧៤** | **៧៩២** | **២ ៩១១** | **៧៥៥** |
| **ស្ថិតិនិស្សិតអាហារូបករណ៍** | | | | | | | | | | |
| វិទ្យាសាស្ត្រកសិកម្ម | ១២១ | ៣៦ | ១៧៤ | ៥៨ | ១៧៦ | ៦៤ | ១៤៦ | ៥៤ | ១៤០ | ៦២ |
| វិទ្យាសាស្ត្រសត្វ | ៨១ | ២១ | ៨៩ | ១៩ | ១០៣ | ២៦ | ៨២ | ២១ | ៨៣ | ២៧ |
| វេជ្ជសាស្ត្រសត្វ | ១០៩ | ៣៧ | ១៥២ | ៤២ | ១៦០ | ៥៤ | ១១១ | ៤៣ | ១១០ | ៤៧ |
| វិទ្យាសាស្ត្រព្រៃឈើ | ៩៣ | ៤០ | ៩៧ | ៤៣ | ៧៣ | ៣៥ | ៥៨ | ២៦ | ៥៨ | ២៤ |
| វិទ្យាសាស្ត្រជលផល | ១០០ | ៣៩ | ៨១ | ៣០ | ៧៦ | ២៨ | ៦៦ | ៣២ | ៧៤ | ៣០ |
| វិស្វកម្មកសិកម្ម | ៩៣ | ២៩ | ៩៨ | ២៨ | ៩៤ | ៣០ | ៩២ | ២១ | ៩០ | ២០ |
| សេដ្ឋកិច្ចកសិកម្ម និងអភិវឌ្ឍន៍ជនបទ | ១៥៧ | ៧៦ | ១៩០ | ៨៦ | ១៨២ | ៩១ | ១២៨ | ៧០ | ៩៦ | ៤៧ |
| កសិឧស្សាហកម្ម | ១១៧ | ៥២ | ១៤៤ | ៧០ | ១៥៩ | ៨៣ | ១៥៣ | ៩២ | ១៦៦ | ១០៥ |
| រៀបចំដែនដី និងរដ្ឋបាលដីធ្លី | ៨៣ | ២៨ | ៩៦ | ២៨ | ៩៨ | ២៩ | ៧១ | ២២ | ៨០ | ៣១ |
| វិទ្យាសាស្ត្រកៅស៊ូ | ១០ | ២ | ៥៤ | ២២ | ៥៣ | ១៩ | ៤៣ | ១៦ | ៣៩ | ១៧ |
| **សរុបរួម** | **៩៦៤** | **៣៦០** | **១ ១៧៥** | **៤២៦** | **១ ១៧៤** | **៤៥៩** | **៩៥០** | **៣៩៧** | **៩៣៦** | **៤១០** |

## គ.២.២-សាលាជាតិកសិកម្មព្រែកលៀប

-ស្ថិតិនិស្សិតថ្នាក់បរិញ្ញាបត្ររងបានបញ្ចប់ការសិក្សាឆ្នាំ**២០១១-២០១២** លើមុខជំនាញ ៩គឺមានជំនាញក្សេត្រសាស្ត្រ ផលិតកម្មនិងបសុព្យាបាល ជលផល រុក្ខកម្ម សាកវប្បកម្ម សេដ្ឋកិច្ច

កសិកម្ម កសិ-ឧស្សាហកម្ម សុរិយោដី និងផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ ដែលមាន**និស្សិតអាហារូបករណ៍ចំនួន ១៤៥នាក់ (ស្រី ៦១នាក់)** និង**និស្សិតបង់ថ្លៃចំនួន ១៧នាក់ (ស្រី ១នាក់)**។

-ស្ថិតិនិស្សិតថ្នាក់បរិញ្ញាបត្ររងបានបញ្ចប់ការសិក្សាឆ្នាំ**២០១២-២០១៣** លើមុខជំនាញ ៩ គឺមានជំនាញក្សេត្រសាស្ត្រ ផលិតកម្មនិងបសុព្យាបាល ជលផល រុក្ខកម្ម សាកវប្បកម្ម សេដ្ឋកិច្ចកសិកម្ម កសិ-ឧស្សាហកម្ម សុរិយោដី និងផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ ដែលមាន**និស្សិតអាហារូបករណ៍ចំនួន ១០១នាក់ (ស្រី ៣៧នាក់)** និង**និស្សិតបង់ថ្លៃចំនួន ២៣នាក់ (ស្រី ១នាក់)**។

-ស្ថិតិនិស្សិតថ្នាក់បរិញ្ញាបត្ររងបានបញ្ចប់ការសិក្សាឆ្នាំ**២០១៣-២០១៤** លើមុខជំនាញ១១ គឺមានជំនាញក្សេត្រសាស្ត្រ ផលិតកម្មនិងបសុព្យាបាល ជលផល រុក្ខកម្ម សាកវប្បកម្ម សេដ្ឋកិច្ចកសិកម្ម កសិ-ឧស្សាហកម្ម សុរិយោដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ ដំណាំកៅស៊ូ និងគ្រឿងយន្តកសិកម្ម ដែលមាន**និស្សិតអាហារូបករណ៍ចំនួន ១០៩នាក់ (ស្រី ៣៧នាក់)** និង**និស្សិតបង់ថ្លៃចំនួន ១៤នាក់ (ស្រី ២នាក់)**។

-ស្ថិតិនិស្សិតថ្នាក់បរិញ្ញាបត្ររងបានបញ្ចប់ការសិក្សាឆ្នាំ**២០១៤-២០១៥** លើមុខជំនាញ១០ គឺមានជំនាញក្សេត្រសាស្ត្រ ផលិតកម្មនិងបសុព្យាបាល ជលផល រុក្ខកម្ម សាកវប្បកម្ម សេដ្ឋកិច្ចកសិកម្ម កសិ-ឧស្សាហកម្ម សុរិយោដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ និងដំណាំកៅស៊ូ ដែលមាន**និស្សិតអាហារូបករណ៍ចំនួន ៣០នាក់ (ស្រី ១១នាក់)** និង**និស្សិតបង់ថ្លៃចំនួន ៧នាក់ (ស្រី ១នាក់)**។

-ស្ថិតិនិស្សិតថ្នាក់បរិញ្ញាបត្ររងបានបញ្ចប់ការសិក្សាឆ្នាំ**២០១៥-២០១៦** លើមុខជំនាញ៩ គឺមានជំនាញក្សេត្រសាស្ត្រ ផលិតកម្មនិងបសុព្យាបាល ជលផល រុក្ខកម្ម សាកវប្បកម្ម សេដ្ឋកិច្ចកសិកម្ម កសិ-ឧស្សាហកម្ម សុរិយោដី និងផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ ដែលមាន**និស្សិតអាហារូបករណ៍ចំនួន ៤៧នាក់ (ស្រី ១៣នាក់)** និង**និស្សិតបង់ថ្លៃចំនួន ៤១នាក់ (ស្រី ៩នាក់)**។

### គ.២.៣-សាលាជាតិកសិកម្មកំពង់ចាម

| ស្ថិតិនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ បានបញ្ចប់ការសិក្សា និងបណ្តុះបណ្តាលពីឆ្នាំ២០១២-២០១៦ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ឆ្នាំសិក្សា | ២០១២-២០១៣ | | ២០១៣-២០១៤ | | ២០១៤-២០១៥ | | ២០១៥-២០១៦ | |
| | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| វិទ្យាសាស្ត្រកសិកម្ម | ៧២ | ៣៥ | ៦៦ | ៣១ | ៦៧ | ៣៤ | ៥៦ | ២៥ |
| វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ | ៨២ | ៤០ | ៧៥ | ៣៨ | ៧៧ | ៣៥ | ៦៨ | ៣៤ |
| វិទ្យាសាស្ត្រជលផល | ៤២ | ២០ | ៣៨ | ២១ | ៣២ | ១៩ | ២១ | ១១ |
| វិទ្យាសាស្ត្រដំណាំកៅស៊ូ | ៤២ | ២០ | ៤៥ | ២១ | ៣៥ | ១៤ | ២៥ | ១២ |
| វិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម | ៤៥ | ២៥ | ៤២ | ២០ | ៣៣ | ២១ | ២៥ | ១៧ |
| **សរុបរួម** | **២៨៣** | **១៤០** | **២៦៦** | **១៣១** | **២៤៤** | **១២៣** | **១៩៥** | **៩៩** |
| ស្ថិតិនិស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្ររង បានបញ្ចប់ការសិក្សា និងបណ្តុះបណ្តាលពីឆ្នាំ២០១២-២០១៦ | | | | | | | | |
| វិទ្យាសាស្ត្រកសិកម្ម | ៥៨ | ២៣ | ៥២ | ២១ | ៥៥ | ២០ | ២២ | ១៣ |
| វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ | ៥៥ | ២១ | ៥៧ | ២២ | ៥២ | ១៩ | ៣១ | ១៧ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| វិទ្យាសាស្ត្រជលផល | ១៣ | ៥ | ១៤ | ៦ | ១១ | ៥ | ៨ | ៣ |
| វិទ្យាសាស្ត្រដំណាំកៅស៊ូ | ១៦ | ៧ | ១២ | ៥ | ៩ | ៣ | ០ | ០ |
| វិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម | ៣១ | ១៧ | ២៨ | ១៥ | ១៨ | ១២ | ២១ | ១៣ |
| **សរុបរួម** | **១៧៣** | **៧៣** | **១៦៣** | **៦៩** | **១៤៥** | **៥៩** | **៨២** | **៤៦** |
| **ស្ថិតិនិស្សិតបង់ថ្លៃថ្នាក់បរិញ្ញាបត្របានបញ្ចប់ការសិក្សា និងបណ្តុះបណ្តាលពីឆ្នាំ២០១២-២០១៦** | | | | | | | | |
| វិទ្យាសាស្ត្រកសិកម្ម | ៥៤ | ២៥ | ៤៧ | ១៨ | ៤២ | ២១ | ៣៨ | ១៦ |
| វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ | ៦៧ | ២៧ | ៦៨ | ២៤ | ៦៥ | ២៤ | ៥៧ | ២១ |
| វិទ្យាសាស្ត្រជលផល | ១៥ | ៥ | ១៦ | ៧ | ១៤ | ៦ | ១១ | ៦ |
| វិទ្យាសាស្ត្រដំណាំកៅស៊ូ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ |
| វិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម | ២២ | ៩ | ១៧ | ៨ | ១៥ | ៦ | ២៤ | ១១ |
| **សរុបរួម** | **១៥៨** | **៦៦** | **១៤៨** | **៥៧** | **១៣៦** | **៥៧** | **១៣០** | **៥៤** |

**គ.៣-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការបានចំនួន ១ ៣៣៨នាក់ (ស្រី ៤២៧នាក់) លើជំនាញកាត់ដេរសម្លៀកបំពាក់និង កាបូប អេឡិចត្រូនិច ជួសជុលម៉ាស៊ីន អ៊ុតសក់ ធ្វើមុខនិងសម្អាងការ កសិកម្ម ជួសជុលទូរស័ព្ទ និងជំនាញគ្រប់គ្រងអាជីវកម្មនិងអនាម័យ។ ទន្ទឹមនេះ បានដោះស្រាយការងារ និងមុខរបរជូនជនពិការផងដែរ។ ដោយឡែក កុមារ គ ថ្លង់ ខ្សោយសតិបញ្ញា និងពិការភ្នែករាប់រយនាក់ បានសិក្សាភាសាសញ្ញា និងអក្សរស្ទាប តាមរយៈកម្មវិធីសិក្សារបស់អង្គការដៃគូ។

**វិទ្យាស្ថានជាតិសង្គមកិច្ច** បានបណ្តុះបណ្តាលសិស្សនិស្សិតសរុបចំនួន ៤៤១នាក់ (ស្រី ១៦៧នាក់) ដូចជាជំនាញសង្គមកិច្ច ១២១នាក់ ជំនាញសង្គមវិទ្យា ៥៧នាក់ ជំនាញកិច្ចគាំពារសង្គមចំនួន ៧០នាក់ ជំនាញគ្រប់គ្រងសាធារណៈ ៥០នាក់ ជំនាញរដ្ឋបាលសាធារណៈ ៥៨នាក់ ជំនាញអក្សរសាស្ត្រអង់គ្លេស ២៨នាក់ ជំនាញគោលនយោបាយសង្គម ៣នាក់ ជំនាញគោលនយោបាយសាធារណៈ ៥នាក់ និងជំនាញបរិញ្ញាបត្រវិស្វកម្មឧបករណ៍សិប្បនិម្មិត និងរណប៤៩នាក់។ក្រៅពីនេះបានបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លីជាច្រើនវគ្គ។

## ឃ-ការងារយុវជន និងកីឡា

### ឃ.១-សមិទ្ធផលវិស័យយុវជន

ក្រសួងបានធ្វើចលនាប្រឡងប្រណាំងពាល្អនៅតាមក្រុមប្រឹក្សាយុវជន ក្រុមប្រឹក្សាកុមារ ដោយជ្រើសរើសយុវជនឆ្នើម ១០នាក់ ក្នុង១រាជធានី ខេត្ត ព្រមទាំងបានបណ្តុះបណ្តាលភាពជាអ្នកដឹកនាំដល់ក្រុមប្រឹក្សាយុវជន និងក្រុមប្រឹក្សាកុមារ តាមរយៈការបោះជំរំថ្នាក់ជាតិ និងបានជំរុញឲ្យមានក្លឹបសិក្សានៅតាមវិទ្យាល័យ។

ក្រសួងបានផ្តល់ការបណ្តុះបណ្តាលជំនាញខ្លី ក្នុងខេត្តចំនួន៦ គឺ ខេត្តសៀមរាប កំពង់ចាម កំពង់ឆ្នាំង កំពង់ធំ តាកែវ និងខេត្តកណ្តាល។ ការបណ្តុះបណ្តាលនេះផ្តោតសំខាន់លើជំនាញកុំព្យូទ័រ និងអគ្គិសនី។

ក្រសួងបានដំណើរការមជ្ឈមណ្ឌលព័ត៌មានទីផ្សារ នៅខេត្តកណ្ដាល កំពង់ចាម និងខេត្តកំពង់ធំ ដោយមានការគាំទ្រពីដៃគូ និងបានអនុវត្តកម្មវិធីអភិវឌ្ឍន៍សហគ្រាសសហគមន៍ និងកម្មវិធីសហគ្រិនភាព នៅតាមវិទ្យាល័យចំនួន៥ នៅខេត្តកណ្ដាល តាកែវ កំពង់ឆ្នាំង និងរាជធានីភ្នំពេញ តាមកម្មវិធីសិក្សា ១១០ម៉ោង លើមុខវិជ្ជាយល់ដឹងអំពីធុរកិច្ច។

ក្រសួង បានពង្រឹងការងារកាយរឹទ្ធិកម្ពុជាក្នុងគោលបំណងជំរុញចលនារបស់យុវជន ក្នុងការអភិវឌ្ឍខ្លួនឯង និងការអប់រំខ្លួនឯង រៀនបណ្ដើរ អនុវត្តបណ្ដើរ ´ជាពិសេសលើការអភិវឌ្ឍប្រាជ្ញាស្មារតី និងកាយសម្បទា និងផ្ដោតលើការអភិវឌ្ឍសហគមន៍ និងស្រឡាញ់ធម្មជាតិតាមរយៈការរៀបចំយន្តការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ សមាជិកកាយរឹទ្ធិត្រូវបានបង្កើននៅតាមអនុវិទ្យាល័យ វិទ្យាល័យ និងសាកលវិទ្យាល័យមានចំនួន ១៣០ ៩៨៨នាក់។ ជាមួយគ្នានេះ ក្រសួងក៏បានជំរុញសកម្មភាពរបស់យុវជនកាកបាទក្រហម ឲ្យស្របនឹងរចនាសម្ព័ន្ធយុវជនកាកបាទក្រហមអន្តរជាតិ ក្នុងគោលបំណងជួយដល់កិច្ចការសង្គម ជាពិសេស នៅពេលមានហានិភ័យ និងគ្រោះធម្មជាតិកើតឡើង។ យុវជនកាកបាទក្រហមមានចំនួន ៣៣ ៦៩៧នាក់។

### ឃ.២-សមិទ្ធផលវិស័យអប់រំកាយ និងកីឡា

ក្រសួងបានអនុម័តគោលនយោបាយជាតិ ស្ដីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា និងអនុម័តកម្មវិធីសិក្សាអប់រំកាយនៅមធ្យមសិក្សា ព្រមទាំងផ្សព្វផ្សាយការអនុវត្តសៀវភៅអប់រំកាយកម្រិតបឋមសិក្សា។ ក្រសួងបានបណ្ដុះបណ្ដាលថ្នាលកីឡាករ កីឡាការិនី ចំនួន៩ប្រភេទកីឡាសរុប ១៧២នាក់ មានកីឡាបាល់ទាត់ តេក្វាន់ដូ ប៉េតង់ ហែលទឹក បាល់បោះ ចំបាប់ អត្តពលកម្ម បាល់ទះ ប្រដាល់ និងបណ្ដុះបណ្ដាលក្រុមជម្រើសជាតិ ចំនួន២៦ប្រភេទកីឡា សរុបចំនួន ៤១៧នាក់។

ការប្រកួតកីឡាជាតិលើកទី១ ឆ្នាំ២០១៦ មានការចូលរួមពីរាជធានី ខេត្តទាំង២៥ ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ មានកីឡាករ កីឡាការិនី មន្ត្រីដឹកនាំ និងគ្រូបង្វឹក អ្នកចូលរួម ២៧០០នាក់ ប្រកួតលើប្រភេទកីឡាចំនួន១៥ ដែលក្នុងនោះមានប្រភេទកីឡា ៖ បាល់ទាត់ បាល់ទះ បាល់បោះ អត្តពលកម្ម ប្រដាល់ តេក្វាន់ដូ សូរិនហ្សិកាំប៉ូ ប៉េតង់ ចំបាប់ វាយកូនបាល់ វាយកូនឃ្លីលើតុ វាយសី ល្បុក្កតោ កាយសម្ព័ន្ធ និងហែលទឹក ធ្វើនៅមជ្ឈមណ្ឌលកីឡាហែលទឹកតេជោសែន ខេត្តកំពង់ចាម ហើយមានវិញ្ញាសាចំនួន១៨៩។ ព្រឹត្តិការណ៍នេះជាកំណែទម្រង់នៃការប្រកួត និងជាការសាកល្បងដើម្បីវាស់ស្ទង់គុណផល កីឡាជាតិ និងហ្វឹកហ្វឺន មន្ត្រីជំនាញកីឡា ឲ្យមានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រាន់ សម្រាប់ត្រៀមលក្ខណៈធ្វើជាម្ចាស់ផ្ទះក្នុងការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ ក្នុងឆ្នាំ២០២៣។

ការប្រកួតជើងឯកពិភពលោកអាស៊ី និងអាស៊ីអាគ្នេយ៍ កម្ពុជាទទួលបានមេដាយ៣០ ក្នុងនោះ មេដាយមាស ៧ ប្រាក់៦ និងសំរឹទ្ធ១៧។ ការប្រកួតកីឡាស៊ីហ្គេមលើកទី២៨ កម្ពុជាទទួលបានមេដាយ១៥ ក្នុងនោះមេដាយមាស១ ប្រាក់៥ និងសំរឹទ្ធ៩។ លទ្ធផលនេះ ធ្វើឲ្យកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់ទី៨ ក្នុងចំណោម១១ប្រទេស។ មេដាយសរុបដែលទទួលបានពីការប្រកួតកីឡាអន្តរជាតិនានា មាន៤៦គ្រឿង។

ការប្រកួតកីឡាជាលក្ខណៈអន្តរជាតិដទៃទៀតរួមមាន ការប្រកួតកីឡាការ៉ាតេដូជ្រើសរើសជើងឯកអាស៊ីអាគ្នេយ៍លើកទី៥ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ជាលទ្ធផលកម្ពុជាទទួលបានមេដាយប្រាក់១គ្រឿង។ ការប្រកួតកីឡាប៉េតង់ ជ្រើសរើសជើងឯកអាស៊ីអាគ្នេយ៍លើកទី៣ នៅប្រទេសឡាវ ជាលទ្ធផលកម្ពុជាទទួលបានមេដាយមាស៥គ្រឿង ប្រាក់៥គ្រឿង និងសំរឹទ្ធ៦គ្រឿង។ ការប្រកួតកីឡាចំបាប់ជ្រើសរើសជើងឯកអាស៊ីអាគ្នេយ៍ ឆ្នាំ២០១៦ នៅពហុកីឡដ្ឋានជាតិ ដែលមាន៦ប្រទេសចូលរួមកីឡាករសរុប ៧៨នាក់ (ស្រី១៩នាក់) ជាលទ្ធផលកម្ពុជាទទួលបានមេដាយមាស៣គ្រឿង ប្រាក់១០គ្រឿង និងសំរឹទ្ធ១៧គ្រឿង។ ការប្រកួតកីឡាតេក្វាន់ដូជ្រើសរើសជើងឯកអាស៊ីអាគ្នេយ៍លើកទី១ ឆ្នាំ២០១៦ នៅពហុកីឡដ្ឋានជាតិ ដែលមាន៧ប្រទេសចូលរួមកីឡាករសរុប ៩១នាក់ (ស្រី ២៣នាក់) ជាលទ្ធផលកម្ពុជាទទួលបានមេដាយមាស ៣១គ្រឿង ប្រាក់១០គ្រឿង សំរឹទ្ធ១១គ្រឿង។ ការប្រកួតកីឡាតេក្វាន់ដូ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ជាលទ្ធផលកម្ពុជាទទួលបានមេដាយមាស១គ្រឿង។ ការប្រកួតកីឡាប៉េតង់ជើងឯកពិភពលោកលើកទី៤៧ ឆ្នាំ២០១៦ នៅប្រទេសម៉ាដាហ្គាស្ការ ជាលទ្ធផលកម្ពុជាទទួលបានមេដាយមាស១គ្រឿង។

| ការប្រមូលផ្តុំកីឡាករ កីឡាការិនី | | | | | |
|---|---|---|---|---|---|
| ឆ្នាំ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| កីឡាករ | ១៨២ | ២០៧ | ២០៧ | ២៣៨ | ២៤៤ |
| កីឡាការិនី | ៥៦ | ៦៧ | ៦៤ | ៦៦ | ៧៨ |

**ឃ.៣-កីឡាជនពិការ** ៖ បានចូលរួមប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី៧ នៅប្រទេសភូមា ទទួលមេដាយសរុបចំនួន ៣២គ្រឿង ក្នុងនោះ មេដាយមាស ០៤គ្រឿង មេដាយប្រាក់ ១១គ្រឿង និងមេដាយសំរឹទ្ធ ១៧គ្រឿង និងបានទៅចូលរួមប្រកួតផ្នែកព័ត៌មានវិទ្យាថ្នាក់អន្តរជាតិ នៅទីក្រុងប៊ូសាន សាធារណរដ្ឋកូរ៉េ ដោយទទួលបានមេដាយមាស ប្រាក់ និងមេដាយសំរឹទ្ធសរុបចំនួន ១៥គ្រឿង។

## ២-ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ

### ក-មូលដ្ឋានសុខាភិបាលសាធារណៈ

-គិតត្រឹមដំណាច់ឆ្នាំ២០១៦នេះ មូលដ្ឋានសុខាភិបាលទូទាំងប្រទេស មានមណ្ឌលសុខភាពចំនួន ១ ១៦៥ (ក្នុងនោះមណ្ឌលសុខភាពមានគ្រែចំនួន៧៧) ប៉ុស្តិ៍សុខភាព៨៣ មន្ទីរពេទ្យបង្អែក ១១០ ក្នុងនោះ មន្ទីរពេទ្យជាតិ ៩ មន្ទីរពេទ្យបង្អែករាជធានី/ខេត្ត២៤ និងមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ ៧៧ នៅក្នុងស្រុកប្រតិបត្តិ ៩៨ ក្នុងរាជធានី ខេត្តទាំង២៥។

-នៅឆ្នាំ២០១៦ គ្រែសរុបនៃមន្ទីរពេទ្យទាំងអស់ក្នុងទូទាំងប្រទេសមានចំនួន ១០ ៨៧០គ្រែ (ដោយមិនរាប់បញ្ចូលគ្រែសម្រាប់អ្នកជំងឺរបេង) បើធៀបនឹងឆ្នាំ២០១២ មាន ១០ ៦៨៩គ្រែ កើនឡើង ១៨១គ្រែ។ រីឯគ្រែសម្រាប់អ្នកជំងឺរបេងនៅឆ្នាំ២០១៦ មានចំនួន ២ ៣៥៣គ្រែ បើធៀបនឹងឆ្នាំ២០១២ មាន ២ ២៤២គ្រែ កើនឡើង ១១១គ្រែ។

| ប្រភេទមូលដ្ឋានសុខាភិបាលតាមរាជធានី ខេត្ត ឆ្នាំ២០១២ ដល់ ២០១៦ | | | | | |
|---|---|---|---|---|---|
| មូលដ្ឋានសុខាភិបាល | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| ស្រុកប្រតិបត្តិ | ៧៩ | ៨១ | ៨៣ | ៩៤ | ៩៨ |
| មន្ទីរពេទ្យបង្អែក | ៩១ | ៩៤ | ៩៧ | ៩៩ | ១១០ |
| បុស្តិ៍សុខភាព | ១២១ | ៨៦ | ១០៦ | ៨១ | ៨៣ |
| មណ្ឌលសុខភាព | ១០២៤ | ១០៨៨ | ១១០៥ | ១១៤១ | ១១៦៥ |

### ខ-ចំនួនមន្ត្រីសុខាភិបាល

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| វេជ្ជបណ្ឌិត | ២ ១៧៨ | ២ ០២១ | ២ ៣៤៧ | ២ ៣៤៦ | ៣ ១២៩ |
| គ្រូពេទ្យមធ្យម | ១ ០១៨ | ៩៦២ | ៩០៦ | ៨៦៣ | ៨៦៦ |
| ទន្តបណ្ឌិត | ២១៤ | ២២៦ | ២៤៣ | ២៥០ | ៤៧៦ |
| បរិញ្ញាបត្រឆ្មប | | | | | ៨៩ |
| ឱសថការី | ៤៨៦ | ៥២៩ | ៥២៦ | ៥២៥ | ៧៥៩ |
| ឆ្មបមធ្យម | ២ ៤៣២ | ២ ៧៣៤ | ២ ៩៦៣ | ៣ ១៣០ | ៤ ០២២ |
| ឆ្មបបឋម | ២ ១៦៤ | ២ ៣៣២ | ២ ៣២៧ | ២ ២៨២ | ២ ៣៦៤ |
| បរិញ្ញាបត្រគិលានុបដ្ឋាក | | | | | ១១៦ |
| គិលានុបដ្ឋាក/គិលានុបដ្ឋាយិកាមធ្យម | ៥ ៦៦២ | ៥ ៥៣៤ | ៥ ៧០០ | ៥ ៧៤៥ | ៧ ៨៩៧ |
| គិលានុបដ្ឋាក/គិលានុបដ្ឋាយិកាបឋម | ៣ ៣៦៦ | ៣ ៣៨៧ | ៣ ២៩៩ | ៣ ១៧៣ | ៣ ១៩៨ |
| អ្នកបច្ចេកទេសមធ្យម | ៤៥៤ | ៤៦០ | ៤៨៤ | ៥០៦ | ៨៣៣ |
| បុគ្គលិកផ្សេងៗ | ១ ៧៤៧ | ២ ៤៨៣ | ២ ១៧៩ | ២ ១៣៤ | ១ ៦៣៣ |
| **សរុប** | ១៩ ៧២១ | **២០ ៦៦៨** | **២០ ៩៧៤** | **២០ ៩៥៤** | **២៥ ៣៨២** |

-វេជ្ជបណ្ឌិតរួមមាន៖ វេជ្ជបណ្ឌិត វេជ្ជបណ្ឌិតឯកទេស និងសាស្ត្រាចារ្យ។

-បុគ្គលិកផ្សេងៗរួមមាន៖ ឱសថការីបណ្ឌិត ឱសថការីមធ្យម ឱសថការីបឋម ទន្តពេទ្យ ទន្តគិលានុបដ្ឋាក ពេទ្យធ្មេញបឋម បរិញ្ញាបត្រគិលានុបដ្ឋាក បរិញ្ញាបត្រឆ្មប ព្យាបាលដោយចលនា មន្ទីរពិសោធន៍បឋម វិទ្យុសាស្ត្រ ជំនាញក្រៅសុខាភិបាល និងផ្សេងៗ។

### គ-ឱសថស្ថាន ឱសថស្ថានរង និងគ្រឹះស្ថានអាជីវកម្មឱសថឯកជន

-គិតត្រឹមដំណាច់ឆ្នាំ២០១៦ ឱសថស្ថាន ឱសថស្ថានរង និងគ្រឹះស្ថានអាជីវកម្មឱសថឯកជន ដែលបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាលនៅទូទាំងប្រទេស មានចំនួនសរុប ២ ២៣៤ កន្លែង បើប្រៀបធៀបនឹងឆ្នាំ២០១២ មាន ១ ៦៩៩កន្លែង កើនឡើង ៥៣៥កន្លែង។

| ស្ថិតិឱសថស្ថាន ឱសថស្ថានរង និងគ្រឹះស្ថានអាជីវកម្មឱសថ-គ្រឿងសំអាងឯកជន | | | | | |
|---|---|---|---|---|---|
| ប្រភេទ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| ឱសថស្ថានឱសថស្ថានរង | ១ ៦៩៩ | ១ ៧៩៥ | ១ ៩១៩ | ២ ១៥៦ | ២ ២៣៤ |

| | | | | | |
|---|---|---|---|---|---|
| គ្រឹះស្ថានផលិតឱសថ | ៩ | ៩ | ១៣ | ១៤ | ១៨ |
| គ្រឹះស្ថានអាហារ៉ណៃ នីហារ៉ណៃឱសថ | ២២៨ | ២៧៧ | ២៩៥ | ៣០៨ | ៣៣៧ |
| សាខាគ្រឹះស្ថានអាហារ៉ណៃ នីហារ៉ណៃ | ១៥ | ១៨ | ២០ | ២៦ | ៣០ |
| គ្រឹះស្ថានអាហារ៉ណៃនីហារ៉ណៃគ្រឿងសំអាង | ៧១ | ៩៨ | ១៤១ | ១៨៦ | ២៣២ |
| មជ្ឈមណ្ឌលថែរក្សាសម្ផស្ស | ១៥ | ១៧ | ២១ | ២៣ | ២៦ |
| សាខាមណ្ឌលថែរក្សាសម្ផស្ស | ៣ | ២ | ២ | ២ | ២ |

### ឃ-សេវាសុខាភិបាលឯកជន

-គិតត្រឹមដំណាច់ឆ្នាំ២០១៦ អ្នកផ្ដល់សេវា និងមូលដ្ឋានសុខាភិបាលឯកជនដែលបានទទួលការអនុញ្ញាតពីក្រសួងសុខាភិបាល មានចំនួន ៨ ៦២២កន្លែង គឺកើនឡើង ១៣៤កន្លែងលើសឆ្នាំ២០១៥ ។

| ស្ថិតិសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រឯកជន ដែលមានអាជ្ញាបណ្ណធ្វើអាជីវកម្ម | |
|---|---|
| **ប្រភេទសេវាខ្នាតតូច** | |
| **បរិយាយ** | **ចំនួន** |
| បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះឯកជន | ៨៨៤ |
| បន្ទប់ថែទាំជំងឺឯកជន | ៣ ២២៧ |
| បន្ទប់ព្យាបាលដោយចលនាឯកជន | ១៣ |
| បន្ទប់ពិគ្រោះព្យាបាលជំងឺឯកជន | ៣ ១៨៦ |
| បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់ ធ្មេញឯកជន | ៧៦៥ |
| បន្ទប់ពិគ្រោះព្យាបាលជំងឺភ្នែកឯកជន | ១៨ |
| បន្ទប់ពិគ្រោះព្យាបាលជំងឺត្រចៀក ច្រមុះ បំពង់កឯកជន | ២៣ |
| បន្ទប់ពិគ្រោះជំងឺសើស្បែកឯកជន | ១៥ |
| បន្ទប់ពិគ្រោះព្យាបាលជំងឺផ្លូវចិត្តឯកជន | ៩ |
| បន្ទប់ពិសោធន៍វេជ្ជសាស្ត្រឯកជន | ៣៨ |
| **សរុប** | **៨ ១៧៨** |
| **ប្រភេទសេវាខ្នាតធំ** | |
| មន្ទីរពេទ្យឯកជន | ១៥ |
| មន្ទីរពេទ្យពហុព្យាបាលឯកជន | ៥៤ |
| មន្ទីរសម្រាកព្យាបាលឯកជន | ២៥០ |
| មន្ទីរសម្ភពឯកជន | ១១ |
| មន្ទីរព្យាបាលជំងឺមាត់ ធ្មេញឯកជន | ៤១ |

| | |
|---|---|
| មន្ទីរពិសោធន៍វេជ្ជសាស្ត្រឯកជន | ៥៣ |
| មជ្ឈមណ្ឌលកែសម្ផស្សឯកជន | ១៣ |
| ការិយាល័យទំនាក់ទំនងសេវាសុខភាពឯកជន | ៧ |
| **សរុប** | **៤៤៤** |
| **សរុបរួម (ប្រភេទសេវាខ្នាតតូច និងធំ)** | **៨ ៦២២** |

-បច្ចុប្បន្នកម្មវិធីមូលនិធិសមធម៌ កំពុងត្រូវបានអនុវត្តទូទាំងប្រទេស ក្នុងរាជធានីខេត្ត ទាំង២៥ គ្របដណ្តប់មូលដ្ឋានសុខាភិបាលសរុប ១ ២៥៨ ក្នុងនោះមានមន្ទីរពេទ្យជាតិ១ មន្ទីរពេទ្យខេត្ត២១ មន្ទីរពេទ្យបង្អែកស្រុក ៩៨ មណ្ឌលសុខភាព ១ ០៦៩ និងប៉ុស្តិ៍សុខភាព៦៨។ នៅឆ្នាំ២០១៦ កម្មវិធីមូលនិធិសមធម៌គ្របដណ្តប់ប្រជាជនក្រីក្រប្រមាណ ២,៦លាននាក់ (តាមការកំណត់អត្តសញ្ញាណក្រីក្រទុកជាមុន និងការកំណត់អត្តសញ្ញាណក្រីក្រនៅពេលប្រើប្រាស់សេវា)។

| ការគ្របដណ្តប់នៃកម្មវិធីមូលនិធិសមធម៌និងគម្រោងឧបត្ថម្ភធន | | | | | |
|---|---|---|---|---|---|
| មូលដ្ឋានសុខាភិបាល | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| ១-មន្ទីរពេទ្យជាតិ | | | | | |
| • មូលនិធិសមធម៌ | ១ | ១ | ១ | ១ | ១ |
| • ឧបត្ថម្ភធន | ៦ | ៦ | ៦ | ៦ | ៦ |
| ២-មន្ទីរពេទ្យបង្អែក | | | | | |
| • មូលនិធិសមធម៌ | ៤៧ | ៥១ | ៦៣ | ៨១ | ១០០ |
| • ឧបត្ថម្ភធន | ១១ | ១១ | ១១ | ១១ | ២ |
| ៣-មណ្ឌលសុខភាព (គ្រែ) | | | | | |
| • មូលនិធិសមធម៌ | ៣១៣ | ៤៥៨ | ៦៥៩ | ១ ០៤៦ | ១ ១៤៩ |
| • ឧបត្ថម្ភធន | ៥៧ | ៥៧ | ៥៧ | ៥៧ | ០ |
| សរុបមន្ទីរពេទ្យជាតិនិងមន្ទីរពេទ្យបង្អែក | ៤៣៥ | ៦៣៤ | ៧៩៧ | ១ ២០២ | ១ ២៥៨ |

ក្រសួងសុខាភិបាល ក៏បានសម្រេចសមិទ្ធផលទៅតាមសូចនាករចម្បងៗមួយចំនួនទៀត ដូចខាងក្រោម ៖

១-ការកាត់បន្ថយអត្រាមរណភាពមាតាបានថយចុះយ៉ាងលឿនពី ៤៧២ក្នុងទារកកើតរស់ ១០០ ០០០នាក់ នៅឆ្នាំ២០០៥ មកត្រឹម១៧០ ក្នុង១០០ ០០០កំណើតរស់ នៅឆ្នាំ២០១៤។ ការសម្រាលដោយអ្នកផ្តល់សេវាមានជំនាញ/វេជ្ជបណ្ឌិត/ឆ្មប/គិលានុបដ្ឋាយិកា បានកើនឡើងយ៉ាងខ្លាំងពី ៤៤%នៅឆ្នាំ២០០៥ ដល់៨៥% នៅឆ្នាំ២០១៦។ រីឯការសម្រាលនៅមូលដ្ឋាន

សុខាភិបាលបានកើនពី ២២%នៅឆ្នាំ២០០៥ ដល់ ៨០,៥២%នៅឆ្នាំ២០១៦។ អត្រាផ្តល់កំណើតសរុបបានធ្លាក់ចុះពី៤នាក់ក្នុងឆ្នាំ២០០០ មក ២,៧នាក់ក្នុងឆ្នាំ២០១៤។

២-ស្ត្រីមានស្វាមីក្នុងវ័យបន្តពូជដែលបានរៀបអាពាហ៍ពិពាហ៍អាយុពី១៥-៤៩ឆ្នាំ ប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបណាមួយបានកើនឡើងពី១៩%ក្នុងឆ្នាំ២០០០ ដល់ ២៤,៨២% ក្នុងឆ្នាំ២០០៨ និង ៣២,៦៥%ក្នុងឆ្នាំ២០១៦។ ទោះបីការប្រើប្រាស់វិធីពន្យារកំណើតបានកើនឡើងសម្រាប់ស្ត្រីមានស្វាមី ប៉ុន្តែការមានផ្ទៃពោះក្នុងចំណោមស្ត្រីវ័យក្មេងអាយុពី ១៥-១៩ឆ្នាំ ចាប់ផ្តើមមានកូនមានចំនួន១២% ក្នុងនោះ៧% បានក្លាយទៅជាមាតា និង៥%ទៀតកំពុងមានគភ៌លើកទី១ (ឆ្នាំ២០១៤)។

៣-ស្ត្រីមានគភ៌បានមកពិនិត្យថៃទាំគភ៌មុនសម្រាលជាមួយបុគ្គលិកសុខាភិបាលលើកទី២ បានកើនឡើងពី ២៥,៤% ក្នុងឆ្នាំ២០០០ ដល់៩៦,៦% នៃស្ត្រីមានគភ៌រំពឹងទុកក្នុងឆ្នាំ២០១៦។ ចំណែកការពិនិត្យថៃទាំគភ៌មុនសម្រាលលើកទី៤ មានចំនួន ៧២,២៣%នៃស្ត្រីមានគភ៌រំពឹងទុកក្នុងឆ្នាំ២០១៦។ អត្រានៃការសម្រាលកូនដោយវិធីវះកាត់(គិតជាភាគរយនៃចំនួនសម្រាលសរុប) មានកំណើនប្រចាំឆ្នាំជាមធ្យមក្នុងរង្វង់១% រវាងឆ្នាំ២០០៨(១,០៤%) និងឆ្នាំ២០១៦(៥,៤០%) ដោយសារការពង្រីកសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងថៃទាំទារកកាន់តែច្រើន និងបង្កើនការស្រាវជ្រាវរកស្ត្រីមានគភ៌ប្រឈមនឹងហានិភ័យខ្ពស់។

៤-សូចនាករសំខាន់ៗរបស់សុខភាពទារក និងកុមារមានការជឿនលឿនគួរឲ្យកត់សំគាល់។ អត្រាមរណភាពកុមារអាយុក្រោម១ឆ្នាំ បានធ្លាក់ចុះពី៩៥នាក់ក្នុង១០០០កំណើតរស់ក្នុងឆ្នាំ២០០០ មក២៨នាក់ក្នុង១០០០កំណើតរស់ក្នុងឆ្នាំ២០១៤ និងអត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ ធ្លាក់ចុះពី១២៤នាក់ក្នុង១០០០កំណើតរស់ក្នុងឆ្នាំ២០០០ មក៣៥នាក់ក្នុង១០០០កំណើតរស់ក្នុងឆ្នាំ២០១៤ ។

៥-អត្រាគ្របដណ្តប់ នៃការផ្តល់វ៉ាក់សាំងបង្ការជំងឺខាន់ស្លាក់-ក្អកមាន់-តេតាណូស ៣លើក មានការកើនឡើងដោយក្នុងឆ្នាំ២០០៣ មានអត្រាត្រឹមតែ៧៣% និងបានឡើងដល់ ៩៨,៨៥% នាឆ្នាំ២០១៦។ វឌ្ឍនភាពគួរឲ្យកត់សម្គាល់គឺ "សូន្យករណី" នៃជំងឺកញ្ជ្រឹលដែលមានចាប់ពីឆ្នាំ២០១២មក។

៦-ប្រេវ៉ាឡង់នៃមេរោគអេដស៍ក្នុងប្រជាជនអាយុ ១៥-៤៩ឆ្នាំ បានធ្លាក់ចុះពី១,៦% ក្នុងឆ្នាំ២០០០មក០,៨%នៅឆ្នាំ២០១០ និងបន្តធ្លាក់មកត្រឹម ០,៦%នៅឆ្នាំ២០១៥ ដូចនេះសម្រេចបានចំណុចដៅ ផ.យ.អ.ជ ០,៥%ក្នុងឆ្នាំ២០១៥។ អត្រាប្រេវ៉ាឡង់ជំងឺរបេងធ្លាក់ចុះពី

១ ២៣០ករណីនៅឆ្នាំ២០០៥ មកត្រឹម ៦៦៨ករណីក្នុងប្រជាជន ១០០ ០០០នាក់ក្នុងឆ្នាំ២០១៤។ ការគ្របដណ្តប់នៃវិធីសាស្ត្រព្យាបាលដោយត្រួតពិនិត្យផ្ទាល់កម្រិតមូលដ្ឋាននៃជំងឺរបេង (ដូតស៍ DOTS) រក្សាបាន១០០%នៃមណ្ឌលសុខភាពទូទាំងប្រទេស។ អត្រាស្លាប់ដោយជំងឺគ្រុនចាញ់បានធ្លាក់ចុះពី៥,៣ក្នុងប្រជាជន ១០០ ០០០នាក់ ក្នុងឆ្នាំ២០០០ មក ០,០១% ក្នុងប្រជាជន ១០០ ០០០នាក់នៅឆ្នាំ២០១៦។

| សូចនាករស្នូល | លទ្ធផលសម្រេចបាន | | | | |
|---|---|---|---|---|---|
| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| ១.អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប | ៣០,៤៨ | ៣៤,២៥% | ៣៥% | ៤១% | ៣២,៦៥% |
| ២.%ស្ត្រីមានគភ៌ទទួលការពិនិត្យផ្ទៃពោះយ៉ាងតិច ២លើក ដោយបុគ្គលិកសុខាភិបាល | ៨៧,០១ | ៨១,៥ | ៩០,៥ | ៩៣,១៩ | ៩៦,៦ |
| ៣.%ស្ត្រីមានគភ៌ទទួលការពិនិត្យផ្ទៃពោះលើកទី៤ ដោយបុគ្គលិកសុខាភិបាល | ៥៥,០២ | ៥៦,៤៥ | ៦៦,៤ | ៧១,៥៣ | ៧២,២៣ |
| ៤.%ស្ត្រីមានគភ៌បានទទួលជីវជាតិដែក ហ្វូលីក អាស៊ីត ៩០គ្រាប់ | ៨៨,២៤ | ៨៤,០ | ៨៦,១ | ៧៣ | ៨៦,៥ |
| ៥.%នៃការសម្រាលកូននៅមូល-ដ្ឋានសុខាភិបាលសាធារណៈ | ៦៦,៣៣ | ៨០ | ៨០ | ៨០,៣៥ | ៨០,៥២ |
| ៦.%នៃកុមារក្រោម១ឆ្នាំបានទទួលវ៉ាក់សាំងការពារជំងឺកញ្ជ្រឹល | ៩៣ | ៩៣ | ៩៤ | ៩១,៩៣ | ១០០ |
| ៧.អត្រាជាសះស្បើយនៃការព្យាបាលជំងឺរបេង | ៩១ | ៩១% | ៩០% | ៩០% | ៩០% |
| ៨.អត្រាស្លាប់នៃជំងឺគ្រុនចាញ់រាយការណ៍ដោយមូលដ្ឋានសុខា-ភិបាលសាធារណៈលើប្រជាជន ១០០ ០០០នាក់ | ០,២៩ | ០,០៨ | ០,០៧ | ០,០៦ | ០,០១ |
| ៩.ករណីថ្មីគ្រុនចាញ់ព្យាបាលនៅមូលដ្ឋាន សុខាភិបាល | ៣,០ | ១,៥ | ២,២៦ | ២,០ | ១,៥ |

| | | | | | |
|---|---|---|---|---|---|
| សាធារណៈក្នុងប្រជាជន ១ ០០០នាក់ (អាំងស៊ីដង់) | | | | | |
| ១០.ការពិគ្រោះជំងឺ (ករណីថ្មី) លើប្រជាជនម្នាក់ក្នុងមួយឆ្នាំ | ០,៦៣ | ០,៦១ | ០,៥៩ | ០,៦១ | ០,៦៣ |
| ១១.អត្រាមធ្យមនៃការប្រើប្រាស់គ្រែនៅមន្ទីរពេទ្យសាធារណៈ | ៨១,១៦% | ៧៨,៧២% | ៩៥,២០% | ៨៧,៥២% | ៩៣% |

**ខ-លទ្ធផលការងារគ្រប់គ្រងគ្រោះមហន្តរាយ(២០១៤-២០១៦)**

ដាក់ស្តែងការងារសំខាន់ៗដែលសម្រេចបាន ៖

១-ច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានអនុម័ត និងប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកត/០៧/១៥/០០៧ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៥។

២-ធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយដល់ក្រសួងស្ថាប័នគណៈ-កម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ក្នុង២៥រាជធានី ខេត្ត។

៣-បញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងការរៀបចំផែនការតាមវិស័យអប់រំ សុខាភិបាល កសិកម្ម...។ល។

៤-ដាក់បញ្ចូលការប្រែប្រួលអាកាសធាតុនៅក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ។

៥-បង្កើតប្រព័ន្ធព័ត៌មាននៃការបាត់បង់ និងការខូចខាតដោយគ្រោះមហន្តរាយនៅកម្ពុជា (CamDi)។

៦-បកប្រែជាភាសាខ្មែរ និងផ្សព្វផ្សាយក្របខណ្ឌការងារសេនដាយសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ២០១៥-២០៣០ ដែលសន្និសីទពិភពលោកលើកទី៣ នៃអង្គការសហ-ប្រជាជាតិបានអនុម័ត។

៧-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា ដើម្បីឆ្លើយតបសង្គ្រោះបន្ទាន់ ពេលមានគ្រោះមហន្តរាយ និងវិបត្តិផ្សេងៗកើតឡើង។

## ៣-ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម

### ៣.១-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

✡ អភិវឌ្ឍន៍របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល

-បានផ្តល់នូវការលើកទឹកចិត្តតាមរយៈការផ្តល់នូវកិត្តិយស សេចក្តីថ្លៃថ្នូរ និងការផ្តល់នូវរបបសន្តិសុខសង្គម ដោយមានការកែសម្រួលជាបន្តបន្ទាប់ស្របតាមលទ្ធភាពនៃសេដ្ឋកិច្ចជាតិ។ បានរៀបចំ និងដាក់ឲ្យដំណើរការជាបន្តបន្ទាប់នូវរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលមានតាវកាលិកចំនួន ៦ រួមមាន ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់

ការងារ មរណភាព និងអ្នកនៅក្នុងបន្ទុក។ របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ត្រូវបាន ដំឡើងជារៀងរាល់ឆ្នាំស្របតាមការដំឡើងបៀវត្សរ៍មន្ត្រីរាជការស៊ីវិល។ ក្នុងរយៈពេល ៥ឆ្នាំនេះ រាជរដ្ឋាភិបាលបានដំឡើងប្រាក់សោធនជូននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈជាបន្តបន្ទាប់ គិតជាមធ្យមប្រមាណ ២០២ ២៨៨រៀលក្នុងម្នាក់។

-បានធ្វើបច្ចុប្បន្នភាព និងអនុវត្តការបើកផ្តល់ប្រាក់សោធនប្រចាំខែតាមប្រព័ន្ធធនាគារទូទាំង ២៥រាជធានី ខេត្ត បច្ចុប្បន្ន មាននិវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈចំនួន ៥២ ០១២នាក់ និងអ្នកនៅក្នុងបន្ទុកចំនួន ៤០ ៤២៣នាក់ កំពុងទទួលរបបសន្តិសុខសង្គមប្រមាណ ៥០ ៦០៨ ៧០៨ ដុល្លារអាមេរិកក្នុងមួយឆ្នាំៗ។ រាជរដ្ឋាភិបាលបានកំណត់ផ្តល់ប្រាក់ភាគទាន ៦% ជំនួសមន្ត្រីរាជការស៊ីវិលរហូតដល់ឆ្នាំ២០១៨។

✡ ការកសាងតំបន់អភិវឌ្ឍន៍យោធិនពិការ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិតបានកសាងតំបន់អភិវឌ្ឍន៍យោធិនពិការតាកែនកោះស្លា ស្រុកឈូក ខេត្តកំពត មណ្ឌលអភិវឌ្ឍន៍យោធិនពិការ ៣១៧ ស្រុកគូលែន ខេត្តសៀមរាប និងមណ្ឌលអភិវឌ្ឍន៍យោធិនពិការភ្នំឆ័ត្រ ខេត្តបន្ទាយមានជ័យ និងឈានទៅកសាងនៅតំបន់ដទៃមួយចំនួនទៀត។

✡ កិច្ចសហប្រតិបត្តិការជាមួយដៃគូ

-បានយកចិត្តទុកដាក់លើភាពជាដៃគូ ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិទ្វេភាគី ពហុភាគី ក្នុងក្របខ័ណ្ឌតំបន់ និងសកលលោក។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុវត្តគោលនយោបាយលើកទឹកចិត្តដោយបង្កលក្ខណៈងាយស្រួលដល់អង្គការពាក់ព័ន្ធនានាក្នុងសកម្មភាពរបស់ខ្លួន។ គិតមកដល់ចុងឆ្នាំ២០១៦នេះក្រសួងបានចុះកិច្ចព្រមព្រៀងជាមួយអង្គការដៃគូចំនួន ២៣៨ ដែលមានថវិកាគម្រោងសរុបចំនួន ៦៤០ ៩៣៥ ២០៩,៩០ដុល្លារអាមេរិកដែលរួមចំណែកសម្រាលបន្ទុកថវិកាជាតិ និងប្រមូលបាននូវធនធានមនុស្ស បច្ចេកទេស និងបទពិសោធន៍ល្អៗ ជាច្រើនសម្រាប់វិស័យសង្គមកិច្ច។

✡ ការគ្រប់គ្រងកុមារកំព្រា

បានកំណត់ទីតាំងកន្លែងថែទាំកុមារ នៅទូទាំង ២៥រាជធានី ខេត្ត មានកន្លែងថែទាំកុមារ ៦៣៩កន្លែង មានកុមារ និងយុវជនចំនួន ២៦ ១៨៧នាក់ (ស្រី ១២ ៥២៦នាក់) ក្នុងនោះ មណ្ឌលថែទាំកុមារចំនួន ៤០៦កន្លែង មានកុមារសរុបចំនួន ១៦ ៥៧៩នាក់ (មណ្ឌលរដ្ឋ ២២ មានកុមារ និងយុវជន ១ ៣៩៣នាក់) ផ្ទះស្នាក់នៅបណ្តោះអាសន្ន ២៥កន្លែងមានកុមារ ៦២៨នាក់ ផ្ទះស្នាក់នៅជាក្រុម ៧១កន្លែងមានកុមារ ១ ៥៩២នាក់ ក្រៅពីនោះ កុមារមួយចំនួនបានកំពុងស្នាក់នៅអន្តេវាសិកដ្ឋាន ទីវត្តអារាម និងទីកន្លែងសាសនា ១៣៧កន្លែងមានកុមារ ៧ ៣៨៨នាក់។ កុមារកំព្រា

សុទ្ធតែទទួលនូវសេវាស្នាក់នៅអប់រំចិញ្ចឹមបីបាច់ថែរក្សា បង្កលក្ខណៈឲ្យរៀនសូត្រចំណេះដឹងទូទៅបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងធ្វើសមាហរណកម្មទៅរស់នៅសហគមន៍វិញ។ ក្រៅពីការថែទាំក្នុងមណ្ឌលកុមារកំព្រា កុមារងាយរងគ្រោះជាច្រើនទៀត បានទទួលចិញ្ចឹមថែទាំ និងផ្តល់សេវាឧបត្ថម្ភផ្សេងៗទៀត នៅក្នុងសហគមន៍ដោយសាច់ញាតិ គ្រួសារធម៌ គ្រួសារចិញ្ចឹម។

**៣.២-វិស័យសោធន (ប្រព័ន្ធគាំពារសង្គម)**

-រាជរដ្ឋាភិបាលបានបង្កើតបេឡាជាតិចំនួន៣ សម្រាប់គ្រប់គ្រងរបបសោធននៅកម្ពុជា ដែលមាន ១-បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល(ប.ជ.ស) ២-បេឡាជាតិ អតីតយុទ្ធជន (ប.ជ.អ) និង៣-បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស)។

-បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ(ប.ជ.ស) និងបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ) ត្រូវបានបង្កើតឡើងដោយស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា។ ប.ជ.ស មានតួនាទីតាវកាលិកចំនួន៦ ដល់មន្ត្រីរាជការស៊ីវិល ១-សោធននិវត្តជន ២-សោធនពិការភាព ៣-មាតុភាព ៤-មរណភាព ៥-អ្នកនៅក្នុងបន្ទុក និង ៦-គ្រោះថ្នាក់ការងារ។ ចំណែក ប.ជ.អ វិញ មានតួនាទីជាអ្នកចាត់ចែងតាវកាលិកសម្រាប់អតីតយុទ្ធជនមួយចំនួនដូចជា ការចូលនិវត្តន៍ ការបាត់បង់សមត្ថភាពការងារ ការលំហែមាតុភាព អាពាហ៍ពិពាហ៍ដំបូង ពលី មរណភាព និងអ្នកនៅក្នុងបន្ទុក។

-បេឡាជាតិសន្តិសុខសង្គម(ប.ស.ស) ដែលត្រូវបានបង្កើតឡើង និងស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាស្ថាប័នដែលមានតួនាទីគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិត ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ។

-បេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការ(ប.ជ.ស) បាននិងកំពុងដំណើរការរបបសន្តិសុខសង្គមសម្រាប់និវត្តជនដែលជាមន្ត្រីរាជការចំនួន ៥០ ៤១៦នាក់។ ចំណែកឯបេឡាជាតិអតីតយុទ្ធជន (ប.ជ.អ) ដែលមានតួនាទីចាត់ចែងរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជនបាននិងកំពុងដំណើរការរបបរបស់ខ្លួនសម្រាប់អតីតយុទ្ធជនចំនួន ២៥ ៤២៥នាក់។

-បេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) បាននិងកំពុងដំណើរការរបបសន្តិសុខសង្គមផ្នែកធានារ៉ាប់រងហានិភ័យការងារដែលផ្តល់ការគាំពារដល់កម្មករ និយោជិតប្រមាណ ១,២លាននាក់។ ប.ស.ស គ្រោងនឹងដាក់ឲ្យដំណើរការរបបថែទាំសុខភាពសម្រាប់កម្មករ និយោជិតនៅក្នុងឆ្នាំ២០១៦នេះ។

**៣.៣-ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម**

រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ដោយកំណត់ជាអាទិភាពដ៏សំខាន់មួយនៅក្នុងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលចាប់ពីដំណាក់កាលទី១ និងទី២មកម្ល៉េះ។ ការណ៍នេះ បាន

បង្ហាញឲ្យឃើញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ជីវភាព និងសុខុមាលភាពរបស់ប្រជាជនគ្រប់រូប ជាពិសេសប្រជាជនក្រីក្រ និងងាយរងគ្រោះ។ តាមរយៈការអនុវត្តយុទ្ធសាស្ត្រទាំងពីរដំណាក់កាលកន្លងមក រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលធំៗជាច្រើន រួមមាន ៖

ក-ការដាក់ឲ្យដំណើរការមូលនិធិសមធម៌ ដែលបានផ្ដល់ជូនប្រជាជនក្រីក្រគ្រប់រូប (ប្រមាណជាង ២លាននាក់) នូវសេវាកម្មសុខាភិបាលឥតបង់ថ្លៃ។

ខ-ការដាក់ឲ្យអនុវត្តដំណើរការកម្មវិធីអាហារូបករណ៍សម្រាប់ថ្នាក់បឋមសិក្សា និងមធ្យមសិក្សា ដែលផ្ដល់លទ្ធភាពឲ្យកុមារមកពីគ្រួសារក្រីក្រទទួលបានការអប់រំទាន់ពេលវេលាដូចកុមារដទៃ។

គ-ការដាក់ឲ្យអនុវត្តដំណើរការកម្មវិធីផ្ដល់អាហារតាមសាលារៀន ដែលជួយលើកកម្ពស់អាហារូបត្ថម្ភ ជូនកុមារនៅថ្នាក់បឋមសិក្សា ក្នុងគោលដៅបង្កើនបញ្ញា និងស្មារតីរបស់កុមារ។

ឃ-ការដាក់ឲ្យអនុវត្តដំណើរការមូលនិធិជនពិការ ដែលផ្ដល់សេវាស្ដារលទ្ធភាពពលកម្មជូនជនពិការគ្រប់រូប តាមរយៈការផ្ដល់សេវាព្យាបាលរហូតជាសះស្បើយ ការផ្ដល់អវៈយវៈចាំបាច់ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

ង-ការដាក់ឲ្យអនុវត្តដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនជនពិការ ដែលចូលរួមលើកកម្ពស់ជីវភាពជនពិការក្រីក្រ។

ច-ការដាក់ឲ្យអនុវត្តដំណើរការកម្មវិធីសន្តិសុខស្បៀង ដើម្បីការពារបញ្ហាកង្វះខាតស្បៀង និងដើម្បីទប់ស្កាត់ការឡើងថ្លៃស្បៀងនៅពេលមានគ្រោះធម្មជាតិនានា។

ឆ-ការដាក់ឲ្យអនុវត្តដំណើរការកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈផ្សេងៗ ដែលផ្ដល់ឱកាសឲ្យយុវជនដែលបានបោះបង់ការសិក្សា មានលទ្ធភាពទទួលយកចំណេះវិជ្ជាជីវៈដែលអាចឈានចូលទីផ្សារការងារដែលមានប្រាក់បៀវត្សសមរម្យ។ល។

## ៤-ការអនុវត្តគោលនយោបាយជាតិប្រជាជន និងសមភាពយេនឌ័រ

### ៤.១-ការអនុវត្តគោលនយោបាយជាតិប្រជាជន

គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ ត្រូវបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៦។ គោលនយោបាយនេះ រួមចំណែកក្នុងការបន្តលើកកម្ពស់គុណភាពជីវិតនិងសុខុមាលភាពរបស់ប្រជាជនកម្ពុជា និងការកាត់បន្ថយភាពក្រីក្រ និងផលប៉ះពាល់នៃបម្រែបម្រួលប្រជាសាស្ត្រទៅលើការអភិវឌ្ឍ តាមរយៈការជំរុញឲ្យមានការបញ្ចូលបញ្ហាប្រជាជន និងកត្តាឌីណាមិកប្រជាសាស្ត្រ ទៅក្នុងផែនការអភិវឌ្ឍគ្រប់វិស័យគ្រប់កម្រិត និងនៅក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍជាតិ និងសាកលដោយរក្សានូវតម្លៃវប្បធម៌និងប្រពៃណីខ្មែរ និងការធានាការគោរពសិទ្ធិមនុស្សមូលដ្ឋាន។ គោលនយោបាយជាតិប្រជាជននេះ បន្តឈរលើគោលការណ៍ដែលមានចែងក្នុងគោលនយោបាយឆ្នាំ២០០៣ ដោយទទួលស្គាល់និងគាំទ្រចំពោះសិទ្ធិរបស់គូស្វាមីភរិយា និងបុគ្គលទាំងអស់ឲ្យមានសិទ្ធិជាមូលដ្ឋានក្នុងការសម្រេចចិត្តដោយសេរី និង

ដោយទទួលខុសត្រូវលើចំនួនកូន និងការពន្យារកំណើត ហើយមានលទ្ធភាពទទួលបាននូវព័ត៌មាន ការអប់រំ សេវា និងមធ្យោបាយ ដើម្បីធ្វើការសម្រេចចិត្តនេះ។

ផែនការសកម្មភាព២០១៦-២០១៨ ដែលទទួលបានការឯកភាពពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៧ គឺជាផែនការសកម្មភាពលើកទីមួយ ដើម្បីអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០។ ផែនការសកម្មភាពនេះ ត្រូវបានរៀបចំឡើងដើម្បីចងក្រងកម្មវិធី អនុកម្មវិធីគម្រោង និងសកម្មភាពនានា ដែលកំពុងត្រូវបានអនុវត្ត ឬនិងត្រូវអនុវត្តដោយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់។ ក្រសួងស្ថាប័នពាក់ព័ន្ធចំនួន២៣ បានដាក់បញ្ចូលកម្មវិធី អនុកម្មវិធីគម្រោង និងសកម្មភាពរបស់ខ្លួនទៅក្នុងផែនការសកម្មភាព២០១៦-២០១៨នេះ សរុបចំនួន ១៥២។

## ៤.២-សមភាពយេនឌ័រ

ក្រសួងកិច្ចការនារីបាន ៖

-ចងក្រងជាក្រុមផលិត និងក្រុមសន្សំប្រាក់ចំនួន ២១១ក្រុម លើជំនាញសិប្បកម្ម កសិកម្ម កែច្នៃអាហារ ជំនាញគ្រប់គ្រងអាជីវកម្ម និងការអប់រំបំណិនជីវិតក្នុងខេត្តចំនួន៥។

-គាំទ្រក្នុងការបង្កើត និងដំណើរការសមាគមសហគ្រិនស្ត្រីកម្ពុជា (CWEA) និងសហព័ន្ធស្ត្រី (CWBF) អ្នកជំនួញកម្ពុជា មានសមាជិកសរុបចំនួន ៥០០នាក់។

-បង្កើតថ្នាក់អក្ខរកម្មសម្រាប់កម្មករ កម្មការិនីរោងចក្រ ចំនួន ១ ៩២៦នាក់ (ស្រី ១ ៥៥៩នាក់)។

-អប់រំផ្សព្វផ្សាយឲ្យមានការផ្លាស់ប្តូរឥរិយាបថសង្គម ពិសេសទាក់ទងនឹងទិវានៃក្តីស្រឡាញ់ ១៤កុម្ភៈ។

-ចូលរួមជំរុញ និងគាំទ្រដល់ដំណើរការថ្នាក់មត្តេយ្យសិក្សាសហគមន៍នៅភូមិចំនួន ១៣៧ ក្នុងខេត្ត ក្រុងចំនួន ១២។

✡ ការងារយេនឌ័រ

-បានបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់ដីធ្លី។

-បានបង្កើត និងអភិវឌ្ឍន៍សមត្ថភាពក្រុមការងារបញ្ជ្រាបយេនឌ័រ តាមក្រសួងស្ថាប័នទាំង២៨

-ក្រសួងចំនួន២៤ មានផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ និងទទួលបានថវិកាជាតិ និងថវិកាដៃគូសម្រាប់អនុវត្តការងារយេនឌ័រតាមវិស័យ។

✡ ស្ត្រី និងសុខភាព

-បានរៀបចំកែសម្រួលគោលនយោបាយស្តីពីស្ត្រី ក្មេងស្រី មេរោគអេដស៍ ជំងឺអេដស៍ ជំងឺកាមរោគ និងបង្កើនការយល់ដឹងដល់ប្រជាជន។

-បង្កើនចំណេះដឹងមូលដ្ឋាន អំពើហិង្សាទាក់ទងនឹងយេនឌ័រ ការកសាងទំនាក់ទំនងរវាងមាតា និងយុវតីស្តីពីសុខភាពផ្លូវភេទ សុខភាពបន្តពូជ មូលដ្ឋានគ្រឹះអំពីបទដ្ឋានអប្បបរមា សម្រាប់ផ្តល់ប្រឹក្សាដល់ជនរងគ្រោះជាស្ត្រី និងកុមារ។

-បានកសាងសមត្ថភាពដល់មន្ត្រីកិច្ចការនារីថ្នាក់ជាតិ និងក្រោមជាតិ ព្រមទាំងភ្នាក់ងារអប់រំសុខភាពភូមិ ស្តីពីជំងឺគ្រុនចាញ់ និងសុខភាពភ្នែក។

✡ស្ត្រី និងការអប់រំ ៖ បានរៀបចំវេទិកាពិគ្រោះយោបល់ដើម្បីផ្លាស់ប្តូរឥរិយាបថ និងរួមចំណែកលើកកម្ពស់សីលធម៌សង្គម និងបានអភិវឌ្ឍសមត្ថភាពគ្រូបង្គោលមន្ទីរកិច្ចការនារី ដើម្បីផ្សព្វផ្សាយបន្តអំពីសិទ្ធិស្ត្រីក្នុងការគ្រប់គ្រងលើអចលនទ្រព្យ ការចុះបញ្ជីអត្រានុកូលដ្ឋាន និងសិល្បៈក្នុងការរស់នៅ។

✡ យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ ៖ គម្រោងចំនួន៥ ត្រូវបានអនុវត្តក្នុងខេត្តគោលដៅចំនួន៩ ដោយបានអភិវឌ្ឍសមត្ថភាពជនបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបានសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកពន្លឺព្រះអាទិត្យ ឬប្រព័ន្ធសូឡា អណ្តូងទឹកស្នប់ ធ្វើបង្គន់អនាម័យសម្រាប់សិស្សស្រី និងបានតបណ្តាញចែកចាយទឹកបន្ថែមដល់កសិករនៅក្នុងខេត្តគោលដៅ។

✡ការអភិរក្សស្ថាប័ន ៖ បានអភិវឌ្ឍសមត្ថភាពដល់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងមជ្ឈមណ្ឌលអភិវឌ្ឍន៍ស្ត្រីលើជំនាញចំណេះដឹងតាមវិស័យនៃផែនការយុទ្ធសាស្ត្រនារីរតនៈ ដោយប្រើប្រាស់ថវិកាជាតិតាមកម្មវិធី ស្តីពី ៖

-ការវិភាគយេនឌ័រនិងជំនាញសម្របសម្រួលភាពជាអ្នកដឹកនាំ និងគ្រប់គ្រងយេនឌ័រ និងការធ្វើអាជីវកម្ម កាត់ដេរ តម្បាញ សំអាងការ និងអ៊ុតសក់។

- ការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រីនិងកុមារ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ទប់ស្កាត់ការជួញដូរមនុស្ស ការកេងប្រវ័ញ្ច និងចំណាកស្រុក ការសរសេរបណ្តឹង និងកំណត់ហេតុស្របតាមនីតិវិធីតុលាការ។

-លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រីនិងគ្រួសារខ្មែរ និងសុខុមាលភាពសង្គម និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រីពិការ។

-សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ការតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងសរសេររបាយការណ៍ណែនាំពីនីតិវិធីសវនកម្ម និងនីតិវិធីចំណាយតាមកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ រៀបចំផែនការ ស្ថិតិ ត្រួតពិនិត្យ និងវាយតម្លៃឆ្លើយតបយេនឌ័រ ។

-កិច្ចការស្ត្រី និងអាស៊ាននិងការចុះអនុស្សរណៈយោគយល់គ្នារវាងក្រសួង និងដៃគូអភិវឌ្ឍន៍។

✡ សមាមាត្រស្ត្រីក្នុងថ្នាក់ធ្វើសេចក្តីសម្រេច ៖

| បរិយាយ | ២០១២ | ២០១៦ |
|---|---|---|
| ស្ត្រីជាសមាជិកព្រឹទ្ធសភា | ៩នាក់ (១៤,៧៥%) | ១០នាក់ (១៦,៣៩%) |
| ស្ត្រីជាសមាជិករដ្ឋសភា | ២៦នាក់ (២១,១៣%) | ២៥នាក់(២០,៣២%) |
| ស្ត្រីជារដ្ឋមន្ត្រី | ២នាក់ | ៣នាក់ |
| ស្ត្រីជារដ្ឋលេខាធិការ | ១៦នាក់ | ៣៧នាក់ |
| ស្ត្រីជាអនុរដ្ឋលេខាធិការ | ៣៣នាក់ | ៥៤នាក់ |
| ស្ត្រីជាអភិបាលរងខេត្ត រាជធានី | ២៤នាក់ | ២៧នាក់ |
| ស្ត្រីជាអភិបាលស្រុក ក្រុង | ២នាក់ | ៦នាក់ |
| ស្ត្រីជាអភិបាលរងស្រុក ក្រុង | ១៩៤នាក់ | ១៩១នាក់ |
| ស្ត្រីជាសមាជិកក្រុមប្រឹក្សាខេត្ត | ៣៧នាក់ | ៥៥នាក់ |
| ស្ត្រីជាប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | | ៦នាក់ |
| ស្ត្រីជាសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ | ៤០៦នាក់ | ៣៩៤នាក់ |
| ស្ត្រីជាមេឃុំ ចៅសង្កាត់ | ៩៦នាក់ | ១១២នាក់ |
| ស្ត្រីជាជំទប់ទី១ | ១៨៩នាក់ | ២១៤នាក់ |
| ស្ត្រីជាជំទប់ទី២ | ១៥១នាក់ | ១៥៥នាក់ |
| ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ | ២ ០៣៨នាក់ | ១ ៨៣៧នាក់ |
| ស្ត្រីជាចៅក្រម | ៣៤នាក់ | ៤០នាក់ |
| ស្ត្រីជាព្រះរាជអាជ្ញា | ១៥នាក់ | ២៣នាក់ |
| ស្ត្រីជាក្រឡាបញ្ជី | ១២៥នាក់ | ១៥៩នាក់ |
| ស្ត្រីជាមន្ត្រីរាជការ | ៣៥% | ៤០% |
| ស្ត្រីជាមន្ត្រីរាជការ ដែលមានមុខតំណែង ចាប់ពីថ្នាក់ការិយាល័យតាមស្រុក ដល់ ថ្នាក់អគ្គនាយក | ១៩% | ២២% |

ស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ជាតិ និងក្រោមជាតិមានសមត្ថភាពក្នុងការបំពេញការងារ និងដោះស្រាយបញ្ហាដែលពាក់ព័ន្ធស្ត្រី និងកុមារ។

✡ ស្ត្រី និងកិច្ចការពារផ្លូវច្បាប់

-បានអនុម័ត និងអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ ២០១២-២០១៨ និងក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋានមានផែនការប្រតិបត្តិការប្រចាំឆ្នាំ។

-បានធ្វើការវិភាគស៊ីជម្រៅលើទិន្នន័យ ស្តីពីបទពិសោធន៍របស់ស្ត្រីដែលរងអំពើហិង្សាក្នុងគ្រួសារ និងទម្រង់អំពើហិង្សានៃការអង្កេតប្រជាសាស្ត្រ និងសុខភាព (CDHS) ២០១៤ ភាគរយអំពីហិង្សាពីដៃគូស្និទ្ធស្នាលដែលកើតឡើងអំឡុងពេល១២ខែកន្លងមក ធៀបនឹងអំពើហិង្សាក្នុងមួយជីវិតមានការថយចុះ។

-ក្រសួងកិច្ចការនារី បានសម្របសម្រួលជាមួយក្រសួងស្ថាប័នចំនួន១៣ ក្នុងការបន្តរៀបចំផែនការសកម្មភាពជាតិ ឆ្លើយតបចំពោះហិង្សាលើកុមារ។

-បានពង្រឹង និងពង្រីកការផ្តល់សេវាចម្រុះជួយជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ (One Stop Services Center) ដែលស្ថិតក្រោមគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារថ្នាក់ខេត្ត និងស្រុកនៅក្នុងខេត្តចំនួន ៧ និងបណ្តុះបណ្តាលអ្នកផ្តល់សេវាចំនួន ២៥០នាក់។

-មន្ត្រីក្រសួងកិច្ចការនារីចំនួន ៩៤រូប (ស្ត្រី ៨៥រូប) ត្រូវបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌។

-បានដឹកនាំក្រុមការងារអន្តរក្រសួងដើម្បីរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងការពពោះជំនួស។

-ក្រុមការងារកម្ពុជាប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ(COMMIT) ដឹកនាំសម្របសម្រួលដោយក្រសួងកិច្ចការនារី បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នាក្នុងការប្រឆាំងអំពើជួញដូរមនុស្ស (កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម) និងបានរៀបចំកិច្ចប្រជុំថ្នាក់តំបន់ចំនួន ០១លើក ថ្នាក់មន្ត្រីជាន់ខ្ពស់ខមមីតលើកទី១០ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីលើកទី៤ ដើម្បីពិនិត្យការងារដែលបានអនុវត្តកន្លងមក និងអនុម័តនូវផែនការសកម្មភាព (ឆ្នាំ២០១៥-២០១៨) ព្រមទាំងបានចុះហត្ថលេខាលើសេចក្តីថ្លែងការណ៍រួមទី៣ ស្តីពីការប្តេជ្ញាចិត្តក្នុងការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស។

-បានរៀបចំកិច្ចប្រជុំទ្វេភាគីកម្ពុជា-វៀតណាម ចំនួន ០២លើក ដើម្បីកែសម្រួលកិច្ចព្រមព្រៀងស្តីពីសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តក្នុងឆ្នាំ២០១២។

## ❖❖❖ សមិទ្ធផលសំខាន់ៗដែលសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងការសម្ពោធដាក់ឲ្យប្រើប្រាស់ (២០១២-២០១៦) មានជាអាទិ៍ ៖

### ❖❖ ឆ្នាំ២០១២

១-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការស្ពានអាកាសពមករា (ស្តុបពេទ្យលោកសង្ឃ) មានបណ្តោយ ៣៩៥ម ទទឹង១៥,២០ម ចំណាយថវិកាប្រមាណ៨លានដុល្លារអាមេរិក នៅខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៦ ខែមករា ឆ្នាំ២០១២។

២-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការកំណាត់ផ្លូវជាតិលេខ៧៦ ប្រវែង១២៦គ.ម ពីស្នួល ខេត្តក្រចេះ ដល់ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ចំណាយថវិកាប្រមាណ ៥១លានដុល្លារអាមេរិក និងពិធីបើកការដ្ឋានសាងសង់បន្តកំណាត់ផ្លូវជាតិលេខ៧៦ ប្រវែង ១៧២គ.ម ពីក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ដល់តាអង ស្រុកកូនមុំ ខេត្តរតនគិរី ចំណាយថវិកាប្រមាណ ៩១លានដុល្លារអាមេរិក ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នៅក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី កាលពីព្រឹកថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២។

៣-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៦៨ ប្រវែង ១១៧គ.ម ពីក្រឡាញ់ ខេត្តសៀមរាប ដល់អូរស្មាច់ ខេត្តឧត្តរមានជ័យ និងផ្លូវយុទ្ធសាស្ត្រព្រំដែន ឬបណ្ដោយផ្លូវគមនាគមន៍ទិសឧត្តរនៃមាតុភូមិកម្ពុជា ប្រវែង ១ ២៨៧គ.ម ចំណាយថវិកាប្រមាណ ១៤៩,២៨ពាន់លានរៀល ដែលជាថវិការបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នៅឃុំកំពង់ថ្កូវ ស្រុកក្រឡាញ់ ខេត្តសៀមរាប កាលពីព្រឹកថ្ងៃទី៩ ខែមេសា ឆ្នាំ២០១២។

៤-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការសណ្ឋាគារ និងផ្លូវអ៊ុតកៅស៊ូបេទីម ៣ខ្សែ (ខ្សែទី១-មហារុក្ខវិថីគិរីតេជោ ខ្សែទី២-វិថីគិរីតេជោគង្គា និងខ្សែទី៣-វិថីគិរីតេជោសែនជ័យ) ប្រវែង ៤៩គ.ម របស់ក្រុមហ៊ុនសុខាអូតែល នៅរមណីយដ្ឋានឋានសួគ៌បូកគោ ខេត្តកំពត កាលពីព្រឹកថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១២។

៥-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការរោងចក្រស្រាបៀរកម្ពុជា របស់ក្រុមហ៊ុនខ្មែរប្រ៊ូវើរី លីមីធីត នៅសង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១២។

៦-ពិធីសម្ពោធជាផ្លូវការបង្គោលព្រំដែនលេខ៣១៤ កំពត-គៀនយ៉ាង ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ង្វៀន តាន់យុង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅឃុំឫស្សីខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត កាលពីព្រឹកថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១២។

៧-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការកំណាត់ផ្លូវជាតិលេខ៦២ ផ្នែកខាងត្បូងពីខេត្តកំពង់ធំទៅក្រុងព្រះវិហារ ខេត្តព្រះវិហារ ប្រវែង ១២៨គ.ម ចំណាយថវិកាប្រមាណ ៥២លានដុល្លារអាមេរិក ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នៅឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ កាលពីព្រឹកថ្ងៃទី៨ ខែសីហា ឆ្នាំ២០១២។

៨-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៨ ពីស្ពានព្រែកតាមាក់ ខេត្តកណ្ដាល ដល់អន្លង់ជ្រៃ ខេត្តកំពង់ចាម ព្រំប្រទល់កម្ពុជា-វៀតណាម ផ្លូវជាតិលេខ៨.១ ពីក្របៅដល់មឺនជ័យ ខេត្តព្រៃវែង ព្រំប្រទល់កម្ពុជា-វៀតណាម ផ្លូវជាតិលេខ៨.២ ពីអន្លង់ជ្រៃ ដល់ពញាក្រែក ខេត្តកំពង់ចាម ប្រវែងសរុប ១០៩គ.ម ចំណាយថវិកាប្រមាណ ៨៦,៣១ លានដុល្លារអាមេរិក ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នៅឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១២។

៩-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៧៨ ប្រវែង ១២១,១០គ.ម ពីអូរពងមាន់ ខេត្តស្ទឹងត្រែង ដល់ក្រុងបានលុង ខេត្តរតនគិរី ចំណាយថវិកាប្រមាណ ៧៣,៣លានដុល្លារអាមេរិក ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តរតនគិរី កាលពីព្រឹកថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១២។

១០-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគាររដ្ឋបាល នៃទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារផែនការសកម្មភាព ៤ឆ្នាំ (២០០៩-២០១២) និងទិសដៅការងារឆ្នាំ២០១៣ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាល-វិជ្ជាជីវៈ កាលពីព្រឹកថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១២។

១១-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការតំបន់ឧស្សាហកម្មសេដ្ឋកិច្ចពិសេសកោះកុង និងពិធីសម្ពោធរោងចក្រគ្រឿងផ្គុំ ប្រព័ន្ធខ្សែភ្លើងរថយន្តរបស់ក្រុមហ៊ុនយ៉ាហ្សាគី (Yazaki) ជប៉ុន នៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីព្រឹកថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២។

១២-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការរោងចក្រផលិតជីកសិកម្ម ចំណាយថវិកាប្រមាណជាង ៨០លានដុល្លារអាមេរិក របស់ក្រុមហ៊ុនជីអន្តរជាតិផ្កាយ៥កម្ពុជា នៅស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១២។

១៣-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការរោងចក្រផលិតស្ករស ចំណាយថវិកាប្រមាណជាង ២៥០លានដុល្លារអាមេរិក របស់ក្រុមហ៊ុន ស៊ូហ្គើរ នៅឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១២។

## ✡✡ ឆ្នាំ២០១៣

១៤-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់សមិទ្ធផលនានា នៅក្រុងប៉ៃលិន ខេត្តប៉ៃលិន កាលពីព្រឹកថ្ងៃទី៣ ខែមករា ឆ្នាំ២០១៣។

១៥-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការចំណតផែកុងតឺន័រថ្មីរបស់កំពង់ផែស្វយ័តភ្នំពេញ ចំណាយថវិកាប្រមាណ ២៨,២២លានដុល្លារអាមេរិក ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នៅឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីព្រឹក ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣។

១៦-ពិធីសម្ពោធអគារពុទ្ធិកថ្មី នៃសាកលវិទ្យាល័យព្រះសីហមុនីរាជា នៅវត្តស្វាយពពែ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣។

១៧-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការស្ថានីយវារីអគ្គិសនីគិរីរម្យទី៣ មានអានុភាព ១៨ មេហ្គាវ៉ាត់ នៅឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង កាលពីព្រឹកថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៣។

១៨-ពិធីសម្ពោធបើកជាផ្លូវការក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍បៃតង និងផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍបៃតង ឆ្នាំ២០១៣-២០៣០ នៅអគារសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៣។

**១៩**-ពិធីសម្ពោធឧបដ្ឋានសាលា និងសម្ពោធសមិទ្ធផលនានា នៅវត្តកំពង់ពពិល ឃុំកំពង់ពពិល ស្រុកពារាំង ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣។

**២០**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់សាលាខេត្តថ្មី និងសមិទ្ធផលនានានៃខេត្តកំពត នៅសង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត កាលពីព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៣។

**២១**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការរោងចក្រកែច្នៃជ័រកៅស៊ូស្ងួត និងពិធីបើកចៀរជ័រកៅស៊ូរបស់ក្រុមហ៊ុនសុភក្តិនីកា នៅឃុំកំភុន ស្រុកសេសាន ខេត្តស្ទឹងត្រែង កាលពីព្រឹកថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៣។

**២២**-ពិធីសម្ពោធពុទ្ធិកអនុវិទ្យាល័យ **ហ៊ុន សែន** សិរីសារពេជ្រ និងសម្ពោធសមិទ្ធផលនានា នៅវត្តសិរីសារពេជ្រ ឃុំល្វា ស្រុកព្រះស្ដេច ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣។

**២៣**-ពិធីសម្ពោធសមិទ្ធផលនានា នៅខេត្តកែប កាលពីព្រឹកថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣។

**២៤**-ពិធីសម្ពោធអគារសិក្សា១ខ្នង ៣ជាន់ ៣០បន្ទប់ នៅវិទ្យាល័យ **សម្ដេច ហ៊ុន សែន ស្ទឹងត្រង់** និងពុទ្ធាភិសេកព្រះពុទ្ធរូបទ្រង់ផ្ចាញ់មារធ្វើពីថ្មភក់ នៅវត្តព្រះមហោសថសុវណ្ណគិរីបឹងដែង ឃុំព្រែក-កក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៣។

**២៥**-ពិធីសម្ពោធឆ្លងកុដិសម្ដេចព្រះមហាអរិយវង្ស **សៅរ៍ ចន្ទថុល្ល** ព្រះចៅអធិការវត្តលង្កា ព្រះកុសុមារាម និងពុទ្ធាភិសេកព្រះពុទ្ធរូប ១២ ៦៤៩អង្គ នៅវត្តលង្កា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣។

**២៦**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការរោងចក្រផលិតទឹកស្អាតនិរោធជំហានទី១ ចំណាយថវិកាប្រមាណ ៩០,៤លានដុល្លារអាមេរិក ជាហិរញ្ញប្បទានពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ហិរញ្ញប្បទានពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និងថវិកាបដិភាគរបស់រដ្ឋាករទឹកស្វយ័តរាជធានីភ្នំពេញ នៅសង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៣។

**២៧**-ពិធីសម្ពោធសាកលវិទ្យាល័យ **ជា ស៊ីម កំចាយមារ** និងវិទ្យាល័យ **ហ៊ុន សែន កំចាយមារ** នៅក្រុងព្រៃវែង ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣។

**២៨**-ពិធីសម្ពោធអគារសិក្សាវិទ្យាល័យសម្ដេចតេជោ **ហ៊ុន សែន ព្រែកអំបិល** និងសម្ពោធផ្លូវលំ ០៩ខ្សែ ប្រវែង ៩ ០០០ម នៅឃុំត្រើយស្លា ដែលប្រព្រឹត្តទៅនៅឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល កាលពីព្រឹកថ្ងៃ ទី០៨ ខែមិថុនា ឆ្នាំ២០១៣។

**២៩**-ពិធីសម្ពោធសាលាធម្មសភា និងសមិទ្ធផលនានា ក្នុងវត្តសុវណ្ណសនារាម នៅឃុំអភិវឌ្ឍន៍ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង កាលពីព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៣។

**៣០**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការស្ពាន ០៣កន្លែង នៅសង្កាត់លលកស ខេត្តពោធិ៍សាត់ កាលពីព្រឹកថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣។

**៣១**-ពិធីសម្ពោធស្នាក់ការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា នៅសង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣។

៣២-ពិធីសម្ពោធបណ្ណាល័យ**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** និងសមិទ្ធផលនានាក្នុងវត្តនាគវ័ន្ត នៅឃុំបុសខ្នុរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម កាលពីព្រឹកថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣។

៣៣-ពិធីសម្ពោធមជ្ឈមណ្ឌល និងសាលាកីឡាបាល់ទាត់ជាតិ នៅឃុំក្រាំងធ្នង់ ស្រុកបាទី ខេត្តតាកែវ កាលពីព្រឹកថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៣។

៣៤-ពិធីសម្ពោធអគារសិក្សា ០១ខ្នង ២ជាន់ ទីចាត់ការ ០១ខ្នង នៅវិទ្យាល័យ **ហ៊ុន សែន អន្លពពាយ** ឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល និងសម្ពោធអគារសិក្សា ០១ខ្នង ២ជាន់ នៅវិទ្យាល័យ **ហ៊ុន សែន ថ្នល់ទទឹង** ឃុំលំហាច ស្រុកអង្គស្នួល ដែលប្រព្រឹត្តទៅនៅវិទ្យាល័យ **ហ៊ុន សែន អន្លពពាយ** ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣។

៣៥-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៥៩ ប្រវែង ១៤៤,២៧គ.ម ពីបំបែកផ្លូវជាតិលេខ៥ ត្រង់គីឡូម៉ែត្រលេខ៣៩៣ ភូមិកូនដំរី ខេត្តបន្ទាយមានជ័យ ដល់គីឡូម៉ែត្រលេខ៩០ ផ្លូវជាតិលេខ៥៧ នៅភូមិស្ទឹងកាច់ ខេត្តប៉ៃលិន ចំណាយថវិកាប្រមាណ ៧២,៨៨លានដុល្លារអាមេរិក ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នៅសង្កាត់ស្ទឹងកាច់ ខេត្តប៉ៃលិន កាលពីព្រឹកថ្ងៃទី២១ ខែ មិថុនា ឆ្នាំ២០១៣។

**✡✡ ឆ្នាំ២០១៤**

៣៦-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការមន្ទីរពេទ្យជោរៃភ្នំពេញ ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ង្វៀន តាន់យុង** (Nguyen Tan Dung) នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយចំណាយទុនវិនិយោគអស់ប្រមាណ ៣៨ ៨៧៩ ០០០ដុល្លារអាមេរិក នៅសង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៤។

៣៧-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់សាលាភូមិកុមារSOSក្រចេះ នៅសង្កាត់អូរឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ កាលពីព្រឹកថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៤។

៣៨-ពិធីសម្ពោធជាផ្លូវការ នៃយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ឆ្នាំ២០១៤-២០១៨ នៅអគារសន្តិភាព នៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤។

៣៩-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការរោងចក្រអគ្គិសនីដុតធ្យូងថ្ម មានអានុភាព ១០០ មេហ្គាវ៉ាត់ និងខ្សែបណ្តាញបញ្ជូនអគ្គិសនីកម្លាំង ២៣០គីឡូវ៉ុល រាជធានីភ្នំពេញ កំពង់ចាម ចំណាយទុនវិនិយោគអស់ប្រមាណជាង ១៩៥លានដុល្លារអាមេរិក នៅឃុំកំពេញ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤។

៤០-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៥៧B ប្រវែង ១៧៦,៣៥គ.ម. ទទឹង ១១ម ផ្លូវជាតិលេខ៥ កំណាត់ថ្មគោល បវេល សំពៅលូន កំណាត់បវេល ភូមិសាមសិប ភ្នំព្រឹក្ស និងកំណាត់ភូមិសាមសិប កំរៀង អូរដា ប្រសព្វផ្លូវជាតិលេខ៥៩ ខេត្តបាត់ដំបង ចំណាយថវិកាប្រមាណ ៨៩,៩៨លានដុល្លារអាមេរិក ដែលជាកម្ចីសម្បទានពីសាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាល័យ **ហ៊ុន សែន បវេល** ស្រុកបវេល ខេត្តបាត់ដំបង កាលពីព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៤។

៤១-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការវារីអគ្គិសនីស្ទឹងអាតៃ មានអានុភាព ១២០ មេហ្គាវ៉ាត់ និងខ្សែបណ្តាញបញ្ជូនអគ្គិសនីកម្លាំង ២៣០គីឡូវ៉ុល រាជធានីភ្នំពេញ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ប្រវែង ៣០២ គ.ម. ដោយចំណាយទុនវិនិយោគប្រមាណ ២៥៥,៣០លានដុល្លារអាមេរិក នៅក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤។

៤២-ពិធីសម្ពោធផ្សារទំនើប **អ៊ីអនម៉ល ភ្នំពេញ** របស់ក្រុមហ៊ុនជប៉ុន អ៊ីអនម៉ល ខេមបូឌា ដោយចំណាយទុនវិនិយោគអស់ប្រមាណ ២៥០លានដុល្លារអាមេរិក នៅសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤។

៤៣-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការស្ពានអាកាសស្ទឹងមានជ័យ ចំណាយថវិកាជាតិប្រមាណ ១៩លានដុល្លារអាមេរិក ដែលស្ថិតក្នុងមុំបីនៃភូមិសាស្ត្រខណ្ឌចំការមន ខណ្ឌទួលគោក និងខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៤។

៤៤-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលមានទឹកប្រាក់វិនិយោគសរុបចំនួន ៥០លានដុល្លារអាមេរិក កាលពីព្រឹកថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤។

**☆☆ ឆ្នាំ២០១៥**

៤៥-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការវារីអគ្គិសនីស្ទឹងឫស្សីជ្រំក្រោម មានអានុភាព ៣៣៨ មេហ្គាវ៉ាត់ ដោយចំណាយទុនវិនិយោគប្រមាណ ៤៩៥លានដុល្លារអាមេរិក នៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីព្រឹកថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥។

៤៦-ពិធីសម្ពោធសមិទ្ធផលនានា រួបសំណាកព្រះនាងប្រាជ្ញាបារមី ច្រាំងទន្លេសួនច្បារ ជ្រោយចង្វា ត្រើយខាងកើត និងសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការសណ្ឋាគាររ៉េស៊ីដង់ សុខាភ្នំពេញ នៅសង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥។

៤៧-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការវិហារឥស្លាម "អាល់សារកាល់" នៅសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥។

៤៨-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការស្ពានមិត្តភាពកម្ពុជា-ចិន ប្រវែង ១ ៧៣១ម ទទឹង ១៣,៥០ម ឆ្លងកាត់ទន្លេមេគង្គលើ និងសម្ពោធផ្លូវជាតិលេខ៩ ប្រវែង ១៤៣,៣៣គ.ម. ពីក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ដល់ក្រុងព្រះវិហារ ខេត្តព្រះវិហារ ចំណាយ ថវិកា ១១៦,៥លានដុល្លារអាមេរិក ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីព្រឹកថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥។

៤៩-ពិធីសម្ពោធអគារផ្កាម្លិះ គាំទ្រចិត្តសាស្ត្រសង្គម និងសួរសុខទុក្ខកុមារកំព្រា កុមារពិការភ្នែក កុមារគ ថ្លង់ នៃសាលាគ្រួសារថ្មី និងមណ្ឌលភ្នំពេញ នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពី ព្រឹកថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៥។

៥០-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការស្ពានមិត្តភាព**កម្ពុជា-ជប៉ុន "ត្សឹបាសា" ឬស្ពានអ្នកលឿង** មានបណ្តោយ ២ ២២០ម ទទឹង ១៤ម ឆ្លងកាត់ទន្លេមេគង្គក្រោម ចំណាយថវិកា ១២៧លាន

ដុល្លារអាមេរិក ដែលជាជំនួយឥតសំណងរបស់ប្រជាជន និងរដ្ឋាភិបាលជប៉ុន នៅត្រើយខាងលិចអ្នកលឿង ក្នុងឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៥។

**៥១**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការរោងចក្រចម្រាញ់ដូងប្រេងទី២ របស់ក្រុមហ៊ុនម៉ុងឫទ្ធីគ្រុប នៅឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥។

**៥២**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារមជ្ឈមណ្ឌលចក្ខុរោគ មិត្តភាពកម្ពុជា-កូរ៉េ ដែលជាជំនួយឥតសំណងរបស់សាធារណរដ្ឋកូរ៉េ នៅក្នុងបរិវេណមន្ទីរពេទ្យព្រះអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៥។

**៥៣**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៤១ ប្រវែង ៩៥,២៨គ.ម. បំបែកពីផ្លូវជាតិ លេខ៤ ថ្នល់ទទឹង ខេត្តកំពង់ស្ពឺ ឆ្លងកាត់ខេត្តកណ្តាល និងខេត្តតាកែវ ទៅដល់ផ្លូវជាតិលេខ៣ នៅដងទង់ ខេត្តកំពត ចំណាយថវិកា ៤៦,២៥លានដុល្លារអាមេរិក ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៥។

**៥៤**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការស្ពានមិត្តភាព **កម្ពុជា-ចិន**( **ស្ពានតាខ្មៅ** ឆ្លងកាត់ទន្លេបាសាក់) មានបណ្តោយ ៨៥៥ម ទទឹង ១៣,៥០ម និងផ្លូវតភ្ជាប់ពីផ្លូវលេខ២ ទៅផ្លូវលេខ២១ ស្ថិតនៅខេត្តកណ្តាល និងរាជធានីភ្នំពេញ ចំណាយថវិកា ៣២,៨៩លានដុល្លារអាមេរិក ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៥។

**៥៥**-ពិធីសម្ពោធអគារសិក្សាថ្មីរបស់សាលាអន្តរជាតិភ្នំពេញ នៅសង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥។

**៥៦**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការស្ពានមិត្តភាព **កម្ពុជា-ចិន** ( **ស្ពានជ្រោយចង្វាទី២** ឆ្លងកាត់ទន្លេសាប) បណ្តោយ ៧២៥ម ទទឹង ១៣,៥០ម ចំណាយថវិកា ២៧,៥លានដុល្លារអាមេរិក ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅសង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥។

**៥៧**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការមណ្ឌលកីឡាហែលទឹក **តេជោសែន** ខ្នាតអន្តរជាតិ នៅក្រុងកំពង់ចាម ខេត្តកំពង់ចាម កាលពីរសៀលថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥។

**៥៨**-ពិធីប្រកាសផ្សព្វផ្សាយរបាយការណ៍ជាតិ ស្តីពីលទ្ធផលចុងក្រោយជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៣ នៅអគារសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី កាលពីព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៥។

**៥៩**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការទំនប់វារីអគ្គិសនីស្ទឹងតាតៃ មានអានុភាព ២៤៦មេហ្គាវ៉ាត់ នៅឃុំតាតៃ ស្រុកកោះកុង ខេត្តកោះកុង កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥។

៦០-ពិធីសម្ពោធបង្គោលព្រំដែនលេខ៣០ និងកំណាត់ផ្លូវប្រវែង ៥៣៩ម តភ្ជាប់ច្រកទ្វារព្រំដែនអន្តរជាតិអូរយ៉ាដាវ ខេត្តរតនគិរី នៃព្រះរាជាណាចក្រកម្ពុជា និងស្រុកឡេថាញ់ ខេត្តយ៉ាឡាយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ង្វៀន តាន់យុង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅច្រកទ្វារព្រំដែនអន្តរជាតិអូរយ៉ាដាវ ខេត្តរតនគិរី កាលពីព្រឹកថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៥។

៦១-ពិធីសម្ពោធបង្គោលព្រំដែនលេខ ២៧៥ នៅច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន ខេត្តតាកែវ និងខេត្តអាងយ៉ាង ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ង្វៀន តាន់យុង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅច្រកទ្វារព្រំដែនអន្តរជាតិភ្នំដិន ស្រុកគិរីវង់ ខេត្តតាកែវ កាលពីរសៀលថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៥។

**✡✡ ឆ្នាំ២០១៦**

៦២-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការស្ពានអាកាសតិចណូ "ស្ពានអាកាស ៥មករា" (ស្ទឹងមានជ័យ/ស្តុបទួលគោក) ចំណាយថវិកាជាតិប្រមាណ ១៤លានដុល្លារអាមេរិក ដែលស្ថិតនៅក្នុងភូមិសាស្ត្រនៃសង្កាត់ចំនួន២ មានសង្កាត់ទឹកល្អក់១ និងសង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែមករា ឆ្នាំ២០១៦។

៦៣-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការសាកលវិទ្យាល័យ **ហេង សំរិន ត្បូងឃ្មុំ** និងពិធីប្រកាសសាងសង់អគារអន្តេវាសិកដ្ឋាន សម្រាប់និស្សិត សាស្ត្រាចារ្យ អគារពិសោធន៍ និងសាលប្រជុំ នៅឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦។

៦៤-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារ "**មរតកតេជោ**" ក្រសួងបរិស្ថានថ្មី និងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៥ និងទិសដៅការងារឆ្នាំ២០១៦ របស់ក្រសួងបរិស្ថាន នៅទីស្តីការក្រសួងបរិស្ថាន ក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦។

៦៥-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារថ្មីមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ ចំណាយថវិកា ១៥,៤៥លានដុល្លារអាមេរិក ដែលជាជំនួយឥតសំណងរបស់ប្រទេសជប៉ុន កាលពីព្រឹកថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦។

៦៦-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការភូមិកុមារ SOS ខេត្តកំពត នៅឃុំបឹងទូក ស្រុកទឹកឈូ ខេត្តកំពត កាលពីព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៦។

៦៧-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការស្ថានីយអ្នកដំណើរថ្មី នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៦។

៦៨-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាវិទ្យាល័យ **ប៊ុន រ៉ានី ហ៊ុន សែន អម្ពរវ័ន ជំនីក** និងស្ពានបេតុងព្រែកតាកុច ប្រវែង ១៨០ម នៅឃុំជំនីក និងឃុំកោះខ្នុរ ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កាលពីព្រឹកថ្ងៃ ទី៣០ ខែមីនា ឆ្នាំ២០១៦។

**៦៩**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារថ្មីរបស់រដ្ឋបាលសាលារាជធានីភ្នំពេញ នៅ សាលារាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៦។

**៧០**-ពិធីសម្ពោធមហាកុដិ "**តេជោវាសីវតេនៈ**" នៅវត្តប្រជុំនទីក្រពើហា សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីព្រឹកថ្ងៃទី៧ ខែមេសា ឆ្នាំ២០១៦។

**៧១**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការរោងចក្រផលិតស្ករស ដែលមានទុនវិនិយោគ ៣៦០លានដុល្លារអាមេរិក របស់ក្រុមហ៊ុនចិនរួយហ្វេង ខេមបូឌា អ៊ិនធើណេស្សណល់ ខេមភីនី លីមីតធីត នៅឃុំម្លូព្រៃមួយ ស្រុកឆែប ខេត្តព្រះវិហារ កាលពីព្រឹកថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៦។

**៧២**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការកំណាត់ផ្លូវជាតិលេខ៥៦និងផ្លូវចូលប្រាសាទ បន្ទាយឆ្មារ ប្រវែង ១២៤គ.ម.ពីសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដល់ក្រុងសំរោង ខេត្តឧត្តរ-មានជ័យ ចំណាយថវិកា ៤៩លានដុល្លារអាមេរិក ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋកូរ៉េ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាល័យថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦។

**៧៣**-ពិធីសម្ពោធរោងចក្រ សហគ្រាសទី១០០ នៃតំបន់សេដ្ឋកិច្ចពិសេសនៅឃុំបិតត្រាង និងឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីព្រឹកថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៦។

**៧៤**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាថ្មី និងពិធីអបអរសាទរខួប ៧០ឆ្នាំ (ឆ្នាំ ១៩៤៦-ឆ្នាំ២០១៦) នៃការបង្កើតសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល នៅសាកលវិទ្យាល័យ សុខាភិបាល រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦។

**៧៥**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារសេនាធិការដ្ឋាន និងសមិទ្ធផលនានា របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស នៅបញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស កាលពីព្រឹក ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦។

**៧៦**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការគម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ខេត្តបាត់ដំបង និងខេត្តកំពង់ចាម ចំណាយថវិកា ៣៣,៥៥លានដុល្លារអាមេរិក ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុន នៅសង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង កាលពីព្រឹក ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦។

**៧៧**-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៤៤ ប្រវែង ១៣៩,៦១គ.ម. ពីផ្លូវជាតិលេខ៤ ឆ្លងកាត់ក្រុងច្បារមន និងស្រុក៤ របស់ខេត្តកំពង់ស្ពឺ មានស្រុកសំរោងទង ស្រុកឱរ៉ាល់ ស្រុកថ្ពង និងស្រុកឧត្តុង្គ តភ្ជាប់ទៅផ្លូវជាតិលេខ៥ ត្រង់គីឡូម៉ែត្រលេខ៣៩ ចំណាយថវិកា ៨០,៣០ លានដុល្លារអាមេរិក ដែលជាកម្ចីឥណទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី២ ខែសីហា ឆ្នាំ២០១៦។

៧៨-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការមន្ទីរពេទ្យជប៉ុនសាន់រាយស៍(ឯកជន)ចំណាយថវិកា ៣៥លានដុល្លារអាមេរិក នៅសង្កាត់ជ្រោយចង្វា ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១៦។

៧៩-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការកំណាត់ផ្លូវជាតិលេខ៧៦បន្ត ប្រវែង ១៧២គ.ម. ពីក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ដល់តាអង ខេត្តរតនគិរី ចំណាយថវិកា **៩១,៦៨លានដុល្លារអាមេរិក** ដែលជាកម្ចីសម្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅឃុំជ័យឧត្តម ស្រុកលំផាត់ ខេត្តរតនគិរី កាលពីព្រឹកថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦។

៨០-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការរោងចក្រផលិតភេសជ្ជៈកូកាកូឡា របស់ក្រុមហ៊ុនភេសជ្ជៈកម្ពុជា ចំណាយទុនវិនិយោគប្រមាណជាង ១០០លានដុល្លារអាមេរិក នៅតំបន់សេដ្ឋកិច្ចពិសេស រាជធានីភ្នំពេញ ក្នុងសង្កាត់ភ្លើងឆេះរទេះ សង្កាត់កន្ទោក និងសង្កាត់បឹងធំ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៦។

៨១-ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការអគារថ្មី នៃទីស្តីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នៅសង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦។

### ❖❖ ស្ពានបេតុងធំៗឆ្លងកាត់ទន្លេ និងដៃសមុទ្រ ដែលបានសាងសង់រួច និងដាក់ឲ្យប្រើប្រាស់ពីឆ្នាំ២០១០-២០១៥

| លរ | ឈ្មោះស្ពាន និងទីតាំង | បណ្តោយ | ទទឹង | កាលបរិច្ឆេទ |
|---|---|---|---|---|
| ១ | ស្ពានព្រែកក្ដាម ឆ្លងកាត់ទន្លេសាប ខេត្តកណ្ដាល | ៩៧៥ម៉ែត្រ | ១៣,៥០ម៉ែត្រ | ២០១០ |
| ២ | ស្ពានព្រែកព្នៅ ឆ្លងកាត់ទន្លេសាប រាជធានីភ្នំពេញ | ៩៦៦,២០ម៉ែត្រ | ១៤ម៉ែត្រ | ២០១០ |
| ៣ | ស្ពានមិត្តភាពកម្ពុជា-ចិន ព្រែកតាមាក់ ឆ្លងកាត់ទន្លេមេគង្គ ខេត្តកណ្ដាល | ១ ០៦០ម៉ែត្រ | ១៣,៥០ម៉ែត្រ | ២០១១ |
| ៤ | ស្ពានតេជោមរកត ស្ពានកោះពស់ខេត្តព្រះសីហនុ | ៩០០ម៉ែត្រ | ១២ម៉ែត្រ | ២០១១ |
| ៥ | ស្ពានមិត្តភាពកម្ពុជា-ចិន ឆ្លងកាត់ទន្លេមេគង្គលើ ខេត្តស្ទឹងត្រែង | ១ ៧៣១ម៉ែត្រ | ១៣,៥០ម៉ែត្រ | ២០១៥ |
| ៦ | ស្ពានមិត្តភាពកម្ពុជា-ជប៉ុន ឆ្លងកាត់ទន្លេមេគង្គក្រោមអ្នកលឿងត្រើយខាងកើត ខេត្តព្រៃវែង ភ្ជាប់ត្រើយខាងលិចខេត្តកណ្ដាល | ២ ២២០ម៉ែត្រ | ១៤ម៉ែត្រ | ២០១៥ |
| ៧ | ស្ពានមិត្តភាពកម្ពុជា-ចិន (ស្ពានតាខ្មៅ) ឆ្លងកាត់ទន្លេបាសាក់ | ៨៥៥ម៉ែត្រ | ១៣,៥០ម៉ែត្រ | ២០១៥ |
| ៨ | ស្ពានមិត្តភាពកម្ពុជា-ចិន (ស្ពានជ្រោយចង្វារទី២) ឆ្លងកាត់ទន្លេសាប | ៧២៥ម៉ែត្រ | ១៣,៥០ម៉ែត្រ | ២០១៥ |

❖❖❖❖❖❖❖

រៀបចំចងក្រង និងបោះពុម្ពផ្សាយ
ដោយនាយកដ្ឋានសរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

ទូរស័ព្ទលេខ : ០១២ ៧៩១ ៨៨៨ / ០១២ ៨៩១ ៨៥៥
០១២ ៩០៨ ៥៥២ / ០១៧ ៧៣៧ ២៤៧

ទូរសារ : ០២៣ ២១២ ៤២៣

Email: lysivanna@gmail.com / monisovan@yahoo.com